

រាជបណ្ឌិត្យសភាកម្ពុជា

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# ទស្សនាវដ្តី
# មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម












ឆ្នាំទី១
លេខ១

ចេញផ្សាយប្រចាំឆមាស

ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែមករា-មិថុនា
ឆ្នាំ២០២២

**និពន្ធនាយកៈ**

*ឯកឧត្តមបណ្ឌិត* **ផុន កសិកា**

**ក្រុមត្រួតពិនិត្យៈ**

*១-លោក* : **យិន ពោ**

*២-លោក* : **យិន យ៉េង**

*៣-លោក* : **លី តុង**

*៤-លោកបណ្ឌិត* : **តូច សុធារី**

*៥-លោកបណ្ឌិត* : **ទុយ យូយីម**

*៦-លោកស្រី* : **យាង ធានី**

រចនាគម្របៈ **ឡេង សត្យា** និង **នេត ចំរើន**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខរាជធានីភ្នំពេញ (ស្ថិតក្នុងបរិវេណសកលវិទ្យាល័យភ្នំពេញ២)

គេហទំព័រ (Website) : https://ihss.rac.gov.kh

ហ្វេសប៊ុក (Facebook) : https://web.facebook.com/វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# កថាមុខ

រាជបណ្ឌិត្យសភាកម្ពុជាជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។ រាជបណ្ឌិត្យសភាកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ ដើម្បីផ្តល់ជាធាតុចូលជូនរាជរដ្ឋាភិបាលដើម្បីបម្រើដល់កិច្ចការស្តារ និង អភិវឌ្ឍសេដ្ឋកិច្ចសង្គម។

វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនដូចជា ស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម រួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួន ក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្របានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។

"**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**" ប្រមូលផ្តុំដោយអត្ថបទទាក់ទងនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជាអ្នកអានទូទៅផងដែរ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រ នៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់និស្សិត ក៏ដូចជាអ្នកស្រាវជ្រាវទូទៅ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២

**ប្រធានវិទ្យាស្ថាន**

# មាតិកា


ទំព័រ

១-ប្រវត្តិបុរាណវត្ថុវិទ្យានៅតំបន់អាស៊ីខាងត្បូង និង អាស៊ីអាគ្នេយ៍..........................................១

២-ពាណិជ្ជកម្មចល័តរបស់មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា.............១៧

៣-បទពិសោធន៍គួរឱ្យចងចាំនៃជីវិតដឹកនាំនិងគ្រប់គ្រងអង្គភាពក្នុងបណ្ដាឆ្នាំកន្លងទៅ.........២២

៤-គំនិតបង្រួបបង្រួមខ្មែរ......................................................................................................៤២

៥-សីលធម៌ក្នុងដំណាក់កាលរាតត្បាតជំងឺកូវីដ១៩ (Covid-19)...........................................៥៨

៦-ស្ថាប័ននីតិប្បញ្ញត្តិ(១៩៩៣-២០១៨)......................................................................................៧៤

៧-ផលិតកម្មបន្លែចង្ក្រងដោយសហគមន៍អភិវឌ្ឍន៍កសិកម្មបន្លែចម្រុះដាយក្រុងកំពង់ស្ពឺ....៨៣

៨-ប្រវត្តិកីឡាអាស៊ីអាគ្នេយ៍.................................................................................................៨៧

៩-ឧស្សាហកម្មសណ្ឋាគារនិងភោជនីយដ្ឋានកម្ពុជាក្នុងដំណាក់កាលកូវីដ-១៩.....................៩៥

១០-សេដ្ឋកិច្ចនិងទេសចរណ៍កម្ពុជាក្នុងដំណាក់កាលជំងឺកូវីដ១៩.....................................១០៨

# ប្រវត្តិបុរាណវត្ថុវិទ្យានៅតំបន់អាស៊ី ខាងត្បូង និង អាស៊ីអាគ្នេយ៍

## South and Southeast Asia: Historical Archaeology

រៀបរៀងដោយៈ Prof. **Miriam Stark**
Professor of Anthropology, Department of Anthropology,
University of Hawai-Manoa, Honollu,HI,USA.
បកប្រែដោយៈ បណ្ឌិត **ផុន កសិកា** ប្រធានវិទ្យាស្ថាន
មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា
Email: kaseka1975@yahoo.com

## សេចក្តីផ្តើម

*អត្ថបទនេះពិនិត្យនឹងឡើងវិញអំពីប្រវត្តិបុរាណវត្ថុវិទ្យានៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ពីទិដ្ឋភាពខាងក្នុងដោយមើលពីក្នុង និងមើលពីក្រៅមកវិញដែរ។ ការស្រាវជ្រាវប្រវត្តិបុរាណវត្ថុវិទ្យាភាគច្រើនបានប្រព្រឹត្តទៅនៅពិភពលោកសម័យថ្មីដែលជាការបែងចែកដ៏សំខាន់មួយរវាងសម័យមុនកូឡុំប៊ី និងសម័យក្រោយកូឡុំប៊ី។ ការអភិវឌ្ឍប៉ាន-អ៊ឺរ៉ាស៊ាន* (Pan-Eurasian) *បានវាយលុកចូលក្នុងទូទាំងអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍អស់រយៈពេលមួយសហស្សវត្សរ៍ មុនពេលលោក កូឡុំបូស*(Columbus)*ចេញដំណើរឆ្ពោះទៅឥណ្ឌាខាងកើត។ ដូច្នេះគ្មានការបែងចែកច្បាស់លាស់ទេរវាងសម័យដំបូងនៃការបណ្តាក់វប្បធម៌និងទម្រង់ និងសម័យកាលក្រោយនៃការធ្វើទំនាក់ទំនងជំងឺនិងអាណានិគម។ ដើម្បីផ្សះផ្សាភាពមិនស៊ីចង្វាក់គ្នារវាងប្រវត្តិបុរាណវត្ថុវិទ្យាដែលបានកំណត់ និង ព្រឹត្តិការណ៍បន្តគ្នានៅទ្វីបអាស៊ី* (Asian sequences) *អត្ថបទនេះនឹងផ្តោតលើសម័យកាលចំនួនពីរនៃអន្តរកម្មសេដ្ឋកិច្ចអន្តរតំបន់នៅអា ស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ដែលមានទាំង ភស្តុតាងបុរាណវត្ថុវិទ្យា និង កំណត់ត្រាឯកសារនានា។ សម័យកាលដំបូងចាប់ផ្តើមនៅចុងបញ្ចប់នៃសម័យ "បុរេប្រវត្តិសាស្ត្រ" និង រួមបញ្ចូលការលេចរូបរាងឡើងនូវប្រព័ន្ធអក្សររបស់ជនជាតិដើមក្នុងប្រទេសនីមួយៗ(ប្រហែល៥០០មុនគ.ស៥០០*

នៃគ.ស)។ សម័យកាលទីពីរ និងសម័យកាលដែលកំណត់ដោយអ្នកខាងក្រៅត្រូវបានផ្សារភ្ជាប់ជាមួយនឹងការជ្រៀតចូលរបស់ពួកអឺរ៉ុបដំបូងៗបំផុតនៅក្នុងតំបន់ និងចាប់ផ្តើមនៅចុងសតវត្សទី១៥នៃគ.ស. ដែលនៅកន្លែងផ្សេងៗទៀតត្រូវបានគេហៅថា «សម័យមុនទំនើប»។

ការប្រើប្រាស់សម័យកាលដែលបានកំណត់ទាំងស្ថានភាពខាងក្នុងនិងឥទ្ធិពលពីខាងក្រៅ នៅក្នុងក្របខ័ណ្ឌជនជាតិដើមនៃប្រវត្តិបុរាណវត្ថុវិទ្យាផ្តល់នូវទិន្នន័យបុរាណវត្ថុវិទ្យាបែបប្រៀបធៀប ស្តីអំពីទំនាក់ទំនងអឺរ៉ុបនិងអាណានិគម ហើយមើលរំលងការអភិវឌ្ឍសំខាន់ៗ នៅក្នុងតំបន់នីមួយៗដែលទាក់ទងនឹងសម័យក្រោយហ្គុបតា(Gupta)និងដើមមជ្ឈឹមសម័យនៅអាស៊ីខាងត្បូង (Hawkes 2014a)និងអាស៊ីអាគ្នេយ៍"បុរាណ"(ឧទាហរណ៍ Istiwan 2012:43)។ ដោយពេលវេលានោះ បណ្តារដ្ឋនៅអឺរ៉ុបបានចាប់ផ្តើមគម្រោងពង្រីកខ្លួន អាណាចក្រមជ្ឈិមសម័យអាស៊ីខាងត្បូងជាច្រើនបានរីកចម្រើនកើនឡើង ហើយក៏ដួលរលំទៅវិញ ចំណែកតំបន់ភាគខាងជើងក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មូស្លីម។ ដោយពេលវេលានោះ ជនជាតិអ៊ឺរ៉ុបបានទៅដល់អាស៊ីអាគ្នេយ៍ អាណាចក្រកសិកម្មបុរាណស្ទើរតែទាំងអស់(ឧ អាណាចក្រអង្គរ បាកាន ដាយវៀត ម៉ាចាប៉ាហិត និងសុខោទ័យ) ប្រគល់អំណាចនិងឥទ្ធិពលដល់រដ្ឋស្នងបន្ត ដែលមានមូលដ្ឋានឬពឹងផ្អែកលើសមុទ្រ ទៅភាគខាងត្បូង។

"សម័យប្រវត្តិសាស្ត្រ" ដំបូងនៃបុរាណវត្ថុវិទ្យានៅអាស៊ីខាងត្បូង, "ដើមសម័យប្រវត្តិសាស្ត្រ"មានរយៈពេលចាប់ពីសតវត្សទី៣ មុនគ.សដល់សតវត្សទី៤នៃគ.ស។ រយៈពេលនេះរួមបញ្ចូលផ្នែកខ្លះនៃចក្រភពម៉ូរីយ៉ាន (Maury-anEmpire)និងបញ្ចប់វិញដោយការដួលរលំនៃហ្គុបតា (Gupta) ដែលអ្នកជំនាញបុរាណវត្ថុវិទ្យាធ្វើការនៅភាគខាងត្បូងប្រទេសឥណ្ឌាហៅថា សម័យសង់ហ្គាម(Sangam)។ អ្នកជំនា-ញបុរាណវត្ថុវិទ្យាធ្វើការនៅទីក្រុងឆ្នេរសមុទ្រធំៗ (ឧទាហរណ៍ ស៊ីស៊ុប៉ាល់ហ្គា Sisupalgarh, អារីកាមេឌូ Arikamedu,ផាទីនណាំ Pattinam, កោណ្ឌិន្យបុរៈ Kau-ndinyapura) និងនៅស្ថានី-យព្រះពុទ្ធសាសនាធំៗផ្សេងៗទៀត (ឧទាហរ-ណ៍ អម៉ារាវតិ Amara-vati, សាន់ជី Sanchi និងសាណាត Sarnath) ពីសម័យនេះ រកឃើញកស្តុតាងជាច្រើននៃអន្តរពាណិជ្ជកម្ម,សាសនារដ្ឋ និងតំបន់មាននគរូបនីយកម្មរីកចម្រើននៅរលកទីពីរជាមួយនឹងការប្រែប្រួលតាមមូលដ្ឋាន(ឧទាហរណ៍(e.g.,Casile 2014 ;Haw-kes 2014b; Shaw 2013; see reviews in Fogelin

2006; Smith 2006, 2016b)។ គម្ពីព្រហ្មញ្ញសាសនា និង គម្ពីព្រះពុទ្ធសាសនា ត្រូវបានចារជាអត្ថបទ និង សម្តី ជាអក្សរសរសេរ និងវត្ថុផ្សេងៗទៀត បានធ្វើដំណើរឆ្ពោះទៅទិសខាងកើតពីអាស៊ីខាងត្បូងទៅអ្វីដែលឥឡូវនេះ គឺជា អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍។ មានការស្រាវជ្រាវពហុជំនាញជាច្រើនត្រូវបានបោះពុម្ពផ្សាយអំពីដើមសម័យប្រវត្តិសាស្ត្រ ដោយអ្នកបុរាណវត្ថុវិទ្យា ប្រវត្តិវិទូ និងអ្នកប្រវត្តិសិល្បៈ។ តាមរយៈការណ៍ទាំងអស់នេះបានលេចចេញនូវការយល់ដឹងក្នុងតំបន់នៃដើមសម័យប្រវត្តិសាស្ត្រដូចជា ទេសភាពក្រុង ដែល ទីក្រុងក្នុងតំបន់មានលក្ខណៈមជ្ឈ មណ្ឌលនយោបាយនិងមជ្ឈមណ្ឌលសេដ្ឋកិច្ច និងនៅក្នុងរដ្ឋអាណាចក្រ និងស្ថាប័នសាសនា បានលេចជារូបរាងឡើងមុនគេ នៅភាគខាងជើង (សូមមើល Morrison 1997)។

ចុងមជ្ឈឹមសម័យក្នុងបុរាណវត្ថុវិទ្យាអាស៊ីខាងត្បូង ត្រូវភ្ជាប់ជាមួយនឹងសម័យកាលរីណេសង់(Renaissance)អឺរ៉ុបនិងសម័យកាលនៃការរុករក។ មានករណីលើកលែងមួយចំនួនតូច ដូចជាកម្មវិធីស្រាវជ្រាវបុរាណវត្ថុវិទ្យាគួរឱ្យចាប់អារម្មណ៍នៅស្ថានីយតណ្តាកណ្តាលនៅវិជ័យយ៉ាណាហ្គារ៉ា (Vijay anagara) (ធ្វើការដោយ Sinopoli,Morrison និងអ្នកផ្សេងទៀត) ដែលការងារភាគច្រើនត្រូវបានអនុវត្តតាមរយៈគម្រោងបុរាណវត្ថុវិទ្យារបស់រដ្ឋ ហើយត្រូវបានបោះពុម្ពខ្មៅស។ ទ្រឹស្តីតិចតួច ឬ ការស្រាវជ្រាវខាងបុរាណវត្ថុវិទ្យាបែបទ្រឹស្តីត្រូវបានបោះពុម្ពផ្សាយអំពីចុងមជ្ឈឹមសម័យនៅអាស៊ីខាងត្បូង(ប៉ុន្តែសូមមើល Chakrabarti 20-03)។ រហូតមកដល់ពេលថ្មីៗនេះ អ្នកប្រវត្តិសាស្ត្រ(មិនមែនអ្នកបុរាណវត្ថុវិទ្យា)បានគ្របដណ្តប់លើការសរសេរអំពីសម័យកាលនៅមានភាពចម្រូងចម្រាស់នៃតំបន់អាស៊ីខាងត្បូង។

អ្នកបុរាណវត្ថុវិទ្យាអាស៊ីអាគ្នេយ៍ជាច្រើនពិពណ៌នាសម័យកាលពីសតវត្សទី៣ មុន គ.ស. ទៅដល់សតវត្សទី៤ ឬ ទី៥ នៃគ.ស ជាសម័យបុរេប្រវត្តិ ("យុគដែក") ទោះបីជាមានកស្តុតាងឯកសារចិនជាច្រើនកត់ត្រាអំពីតំបន់នៅជិតខាងនិងឯកសារដើមផ្សេងៗទៀតរបស់ជនជាតិអាស៊ីគ្នេយ៍ក៏ដោយ។ អត្ថបទនេះប្រើ "សម័យប្រវត្តិសាស្ត្រដំបូង" សម្រាប់កំណត់តំបន់ទាំងពីរគឺអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍សម្រាប់"សម័យកាលប្រវត្តិសាស្ត្រដំបូង" ដែលរហូតដល់២០ឆ្នាំចុងក្រោយ ទើបកស្តុតាងបុរាណវត្ថុវិទ្យានៃតំបន់អាស៊ីអាគ្នេយ៍បានកត់ត្រាពីសម័យកាលនេះ។ ដូចអាស៊ីខាងត្បូងដែរ អាស៊ីអាគ្នេយ៍មិនដែលឯកោពីទំនាក់

ទំនាក់ទំនងជាមួយជនបរទេស ដែលមកពីគ្រប់ទិសតំបន់។ ប៉ុន្តែ ការអភិវឌ្ឍឆ្នាំ១៤៥០នៃគ.ស រហូតមក ដែលអ្នកស្រាវជ្រាវហៅថា«យុគសម័យពាណិជ្ជកម្មអាស៊ីអាគ្នេយ៍»ឬ«ដើមសម័យទំនើប» បានជំរុញឱ្យមានការផ្លាស់ប្តូរសង្គមនិងសេដ្ឋកិច្ចនៅទូទាំងតំបន់ដែលទាក់ទាញ។ សម័យកាលនេះស្ថិតនៅក្នុងពេលស្តង់ដារកំណត់សម្រាប់អ្នកបុរាណវត្ថុវិទ្យាប្រវត្តិសាស្ត្រធ្វើការនៅលោកខាងលិច និងផ្តល់ការយល់ដឹងបែបប្រៀបធៀបអំពីដំណើរការនៃការធ្វើអាណានិគម, ការលេចឡើងនៃការធ្វើចំណាត់ថ្នាក់សង្គម/ថ្នាក់ និងការផ្លាស់ប្តូរវប្បធម៌។

ឧបសគ្គនៃលំហក៏កំណត់ដែនភូមិសាស្ត្ររួមទាំងពាក្យ"ត្បូង"និង"អាស៊ីអាគ្នេយ៍"។ អ្នកជំនាញបុរាណវត្ថុវិទ្យាអាស៊ីខាងត្បូងភាគច្រើនយកឧទាហរណ៍មកពីឥណ្ឌាឬបង់ក្លាដែ-ស ពីតំបន់ហួសពីអាស៊ីខាងត្បូង គន្លងនយោបាយនិងសេដ្ឋកិច្ចស្មុគស្មាញដែលមានប្រភពពីការស្វែងរកលម្អិតខ្លះទៀត "ការអានបន្ថែម Further Readings"។ ឧទាហរណ៍បុរាណវត្ថុវិទ្យានៅតំបន់អាស៊ីអាគ្នេយ៍ភាគច្រើនយកពីប្រជុំកោះឥណ្ឌូនេស៊ី ឬពីអាងទន្លេមេគង្គ(ឧ. ថៃ ឡាវ កម្ពុជា) ពីតំបន់ផ្សេងៗដែលមានលក្ខណៈពិសេសដែលបណ្តារដ្ឋនៅអឺរ៉ុបចូលរួមក្នុងពាណិជ្ជកម្ម និងក្រោយមកគ្រប់គ្រងនយោបាយ។ ដូចអាស៊ីខាងត្បូងខុសគ្នាគួរឱ្យកត់សម្គាល់ពីតំបន់មួយទៅតំបន់មួយ ដូច្នេះភាគអាគ្នេយ៍ដីគោកនិងតំបន់កោះមានបទពិសោធន៍គន្លងប្រវត្តិសាស្ត្រផ្សេងៗគ្នាផ្អែកលើផ្នែកមួយនៃការភ្ជាប់ទំនាក់ទំនងខាងក្រៅនៅអាស៊ីខាងត្បូងឬអាស៊ីបូព៌ា។ រដ្ឋកសិកម្មបានលេចឡើងនៅទូទាំងជ្រលងទន្លេនិង ដីសណ្តរនៅអាស៊ីអាគ្នេយ៍ដីគោកចាប់ពីដើមដល់ពាក់កណ្តាលសហវត្សទី១នៃគ.ស។ រដ្ឋដំបូងៗចំនួ-នតូចដែលកើតឡើងនៅទូទាំងអាស៊ីអាគ្នេយ៍ដីកោះ បានចំណាយពេលជាច្រើនសតវត្សទៀតដើម្បីលេចចេញជារូបរាង។ ដោយមានករណីលើកលែងតិចតួច អាស៊ីអាគ្នេយ៍ដីកោះក្នុងពេលភ្ជាប់ទំនាក់ទំនងជាមួយអឺរ៉ុប មានទេសភាពទំនាក់ទំនងសង្គម នៃរដ្ឋដែនសមុទ្រតូចៗ (Bacus 1999)ពឹងផ្អែកលើសម្ព័ន្ធភាពដែលមិនរឹងមាំនិងមិនស្ថិតស្ថេរ ហើយដែលប្រកួតប្រជែងគ្នាដើម្បីការភ្ជាប់ជំនួញពាណិជ្ជកម្ម (e.g., Junker 2004) ។

## បញ្ហាវិធីសាស្ត្រនិងប្រធានបទសំខាន់ៗ

បញ្ហាវិធីសាស្ត្រនិងខ្លឹមសារស្រដៀងគ្នាត្រូវបានយកមកអនុវត្តចំពោះសម័យដើមប្រវត្តិសាស្ត្រ នៅអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេ-

យ៍។ ការផ្ទុះឡើងនូវឯកសារបុរាណវត្ថុវិទ្យានៅអាស៊ីអាគ្នេយ៍ ផ្តល់តម្រុយដល់អត្ថបទនេះឆ្ពោះទៅយល់ពីសក្តានុពល ក្នុងកំឡុងសម័យកាលទាំងពីរ។ បញ្ហាវិធីសាស្ត្រប៉ះពាល់ដល់ការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យា ទាំងក្នុងសម័យដើមប្រវត្តិសាស្ត្រ និង ការស្រាវជ្រាវសតវត្សទី១៩នៃអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍និងស្របគ្នានឹងការរកឃើញ "ប្រវត្តិបុរាណវត្ថុវិទ្យា"ដ៏ទូលំទូលាយ។ សំខាន់បំផុតក្នុងចំណោមរឿងទាំងនោះ គឺការប្រើប្រាស់ឯកសារមិនច្បាស់លាស់សម្រាប់កំណត់ព្រំដែនទិន្នន័យ ដើម្បីកំណត់ការស្រាវជ្រាវបុរាណវត្ថុវិទ្យានៅក្នុងតំបន់ទាំងពីរ។ តំបន់អាស៊ីខាងត្បូង ប្រកពឯកសារសំខាន់ៗមួយចំនួន (ឧទាហរណ៍មហាភរត Maha-bharata, រាមកេរ្តិ៍ Ramayana និងបុរន្ស Puranas) ត្រូវបានបង្កើតឡើង ក្នុងអំឡុងពេលនេះ និង មានឥទ្ធិពលដល់ការបកស្រាយនានា។ ដូច្នេះ ដូចគ្នានឹងឥណ្ឌាវិទ្យា(Indology) ដែលផុសចេញប្រពៃណីអ្នកចេះដឹងអាណានិគម ដែលជាចំណុចបន្ទាប់បន្សំ ពីលំនាំបុរាណវត្ថុវិទ្យា និងឯកសារ (Trautmann and Sinopoli 2002: 496)។ បញ្ហាប្រឈមចំពោះផ្នែកបុរាណវត្ថុវិទ្យាបន្ថែមទៀតទាក់ទងនឹងកាលប្បវត្តិ និងនិយមន័យ (e.g., Smith 2016a: 688–689) (Ali 2014)។ ដើមសម័យប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍ក៏ត្រូវបានបកស្រាយតាមរយៈកំណត់ត្រាចិនសម័យប្រវត្តិរាជវង្ស និង ភាពស្រដៀងគ្នាជាមួយអាស៊ីខាងត្បូង។ មូលហេតុមួយគឺការស្រាវជ្រាវភាគច្រើននៅដើមសម័យប្រវត្តិសាស្ត្រត្រូវបានអនុវត្តដោយអ្នកជំនាញសិលាចារឹក និងអ្នកប្រវត្តិសាស្ត្រ ដែលអាជីពដំបូងបំផុតបានចាប់ផ្តើមជាអ្នកជំនាញឥណ្ឌាវិទ្យា និងអ្នកជំនាញចិនវិទ្យា (Indologist and Sinologist)។ បញ្ហាមួយទៀត អ្នកជំនាញបុរាណវត្ថុវិទ្យានៅអាស៊ីអាគ្នេយ៍ភាគច្រើន បានផ្តោតការខិតខំរបស់ពួកគេលើការសិក្សាបុរេប្រវត្តិសាស្ត្រ (ពិសេសយុគថ្មរំលីង, យុគសំរឹទ្ធ និង យុគដែក) និង ការសិក្សាអភិរក្សប្រាសាទសាងក្នុងសតវត្សទី៩-១៨ ដែលមានហេតុផលបង្ហាញពីជាតិនិយម និងមានភាពទាក់ទាញដល់វិស័យទេសចរណ៍។ កិច្ចការបុរាណវត្ថុវិទ្យាថ្មីៗ បានផលិតទិន្នន័យបុរាណវិទ្យាដែលបប្រឈមគ្នានឹងឯកសារកំណត់ហេតុនៅមាននៅឡើយ ហើយដែលអ្នកប្រវត្តិវិទូធ្លាប់ប្រើប្រាស់និងពឹងផ្អែកជាយូរមកហើយ។

អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍នៅតែរក្សាភាសាសាស្ត្រ វប្បធម៌ និង ភូមិសាស្ត្រដែលដាច់ចេញពីចុងសហវត្សទី១ មុនគ្រីស្តសករាជ រហូតដល់ពាក់កណ្តាលសហវត្សទី២ នៃគ្រឹស្តសករាជ។ ប៉ុន្តែចាប់ផ្តើមដើមសម័យប្រវត្តិសាស្ត្រ មនុស្ស ទំនិញ និង គំនិតបានផ្លាស់

ទីតាមផ្លូវគោកនិងផ្លូវទឹក។ ថាតើប្រជាជននៃតំបន់ទាំងពីរបានធ្វើអន្តោប្រវេសន៍ទៅតំបន់ផ្សេងទៀត នៅតែជាប្រធានបទនៃការជជែកវែកញែកខ្លះ ហើយក៏ដូចនឹងពេលវេលាច្បាស់លាស់ នៃការអភិវឌ្ឍតំបន់ទាំងនេះដែរ។ ប្រធានបទសំខាន់ៗជាច្រើនបង្ហាញពីលក្ខណៈស្រាវជ្រាវបុរាណវត្ថុវិទ្យា អំពីដើមសម័យប្រវត្តិសាស្ត្រទាំងអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍៖

•ការសិក្សាអំពីនគរូបនីយកម្ម("រលកទី២"សម្រាប់អាស៊ីខាងត្បូងបន្ទាប់ពីអារ្យធម៌ជ្រលងភ្នំឥណ្ឌូស និងរលកទី១សម្រាប់អាស៊ីអាគ្នេយ៍)ការបន្តពីវប្បធម៌សហវត្សទី១នៃគ.ស៖ ការផ្លាស់ប្តូរវប្បធម៌ក្នុងសាសនានិងជំនឿជាមួយនឹងការលេចចេញនូវប្រពៃណីសិប្បកម្ម (ការសិក្សាអំពីសំណង់ស្ថាបត្យកម្មសាសនាដំបូងៗ និង បដិមាសាស្ត្រ ព្រមទាំងតួនាទីពាណិជ្ជកម្មក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា)

•ការកើតឡើងនៅខាងអាស៊ីត្បូងនិងអាស៊ីអាគ្នេយ៍ទាំងមូលនូវបណ្តាញអន្តរកម្មដែលពឹងផ្អែកលើចរាចរផ្លូវសមុទ្ររបស់មនុស្ស និង ទំនិញឆ្លងកាត់ឈូងសមុទ្របង់ហ្កាល់ដែលជាទូទៅ គេពិពណ៌នាថាជាផ្លូវសូត្រសមុទ្រ

•បុរាណវិទ្យាទេសភាព៖ (ទេសភាពពិធីសាសនា/ភូមិសាស្ត្រពិសិដ្ឋនិងធម្មយាត្រា ទេសភាពកសិកម្ម និងការគ្រប់គ្រងទឹក)

ប្រធានបទសំខាន់ៗនៅក្នុងប្រវត្តិបុរាណវត្ថុវិទ្យានៃយុគសម័យមជ្ឈិមសម័យ(សម័យកណ្តាល)នៅអាស៊ីខាងត្បូង(សតវត្សទី៩ដល់សតវត្សទី១៦) និងប្រវត្តិសាស្ត្រនិងសម័យបុរាណនៃអាស៊ីអាគ្នេយ៍ រួមមាន៖

•ធម្មជាតិនៃចក្រពត្តិនិយម (មនោគមវិជ្ជា យោធានិយម, ផលិតកម្ម និងការចែកចាយ)

•ធម្មជាតិនៃនគរូបនីយកម្ម (សេដ្ឋកិច្ចនយោបាយនៃផលិតកម្មសិប្បកម្ម និងការបង្កើតទីក្រុង)

•មូលដ្ឋានកសិកម្មរបស់រដ្ឋ អ្នកអានត្រូវបានយោងទៅលើអត្ថបទរបស់ Mionica Smith (២០១៦) និយាយអំពីបុរាណវត្ថុវិទ្យាក្នុងសម័យប្រវត្តិសាស្ត្រ និង សម័យមជ្ឈិមសម័យ (សម័យកណ្តាល)។

ប្រធានបទសំខាន់ៗនៅក្នុងបុរាណវត្ថុវិទ្យាអាស៊ីអាគ្នេយ៍ ចាប់ពីសតវត្សទី១៥ ទៅសតវត្សទី១៨ ពាក់ព័ន្ធនឹងផលប៉ះពាល់នៃទំនាក់ទំនងអឺរ៉ុប ស្តីពីការតាំងទីលំនៅ, ការរៀបចំនយោបាយនិងរចនាសម្ព័ន្ធសង្គម។ រដ្ឋសាសន៍អឺរ៉ុបដោយឡែកៗស្វែងរកការគ្រប់គ្រងអាស៊ីអាគ្នេយ៍ទាំងការគ្រប់គ្រងធនធានធម្មជាតិផ្ទាល់របស់តំបន់(ជាពិសេសលោហធាតុមានតម្លៃ និងគ្រឿងទេសពីកោះគ្រឿងទេស (Spice Isla-

nds)) និងសម្រាប់ការភ្ជាប់ទៅនឹងប្រទេសចិនតាមសមុទ្រចិនខាងត្បូង។ ទំនាក់ទំនងដំបូងបំផុតទាក់ទងនឹងការបង្កើតបណ្តាញពាណិជ្ជកម្មនៅសតវត្សទី១៥/១៦ ក្នុងនាមជាជនជាតិអឺរ៉ុប បានប្រកួតប្រជែងគ្នាដើម្បីទទួលបានដូចចំណុចរៀបរាប់ខាងលើ។ អំឡុងពេលពីរទៅបីសតវត្សបន្ទាប់ អាស៊ីអាគ្នេយ៍ភាគច្រើនត្រូវបានគ្រប់គ្រងដោយពួកអឺរ៉ុបដូចជា ព័រទុយហ្គាល់, អេស្ប៉ាញ និង ហូឡង់ និងនៅក្នុងសតវត្ស ទី១៩ ដោយបារាំង, អង់គ្លេស និង អាមេរិក។ ទំនាក់ទំនងពាណិជ្ជកម្មអាស៊ីអាគ្នេយ៍ទៅលោកខាងកើតនិងខាងលិចបានចាប់ផ្តើមជាច្រើនសតវត្សមុន និង កាន់តែខ្លាំងឡើងនៅសតវត្សទី១៤/១៥ នៅពេលសាសនាអ៊ីស្លាមមកដល់កោះក្នុងអាស៊ីអាគ្នេយ៍។ ការផ្ទុះឡើងនៃការសិក្សាស្រាវជ្រាវរុករកតាមរយៈការធ្វើកំណាយបុរាណវត្ថុវិទ្យានៅក្នុងរយៈពេលពី២៥០០មុនគ.ស ដល់១០០០មុនបច្ចុប្បន្ន ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ បានបង្កើតការយល់ដឹងច្រើនសន្ធឹកសន្ធាប់អំពីសេដ្ឋកិច្ច ការតាំងទីលំនៅនិង មនោគមវិជ្ជាក្នុងកំឡុងពេលសម័យអន្តរកាលទៅកាន់សម័យប្រវត្តិសាស្ត្រ (ពីឆ្នាំ៥០០មុនគ.ស ដល់៥០០គ.ស) និងរយៈពេលបន្តរបន្ទាប់មកទៀតអាស៊ីអាគ្នេយ៍បានបញ្ចូលប្រព័ន្ធសរសេរ(អក្សរ)ប្រព័ន្ធនគរូបនីយកម្ម, និងសិប្បកម្មរដ្ឋ (e.g., Agustijanto 2012; Bulbeck et al. 2016; Kim et al. 2010; Miksic 2000; Stark 2006)។ ការងារបែបនេះផ្តល់ភស្តុតាងសម្ភារៈសម្រាប់សម័យអន្តរកាលវប្បធម៌នៅក្នុងតំបន់ដែលបានប្តូរទីតាំងនៅតាមផ្លូវពាណិជ្ជកម្មជាប្រវត្តិសាស្ត្រដែលមានដើមកំណើតនៅសហស្សវត្សទី២ មុនគ.ស (Bellina 2014; Favereau and Bellina 2016; Hung et al. 2013)។

បុរាណវត្ថុវិទ្យាបានរកឃើញអង្គាំពីស្ថានីយនានា នៅទូទាំងតំបន់សមុទ្របានផ្តល់ភស្តុតាងដ៏រឹងមាំបំផុតសម្រាប់កំណត់ពេលវេលានិងទំហំនៃបណ្តាញនេះ (Calo et al. 2015; Carter 2015) ចំណែកការសិក្សាអំពីរុក្ខបុរាណវត្ថុវិទ្យាក៏ផ្តល់លទ្ធផល និងលំនាំគួរឱ្យចាប់អារម្មណ៍ (Castillo et al. 2016)។ កំណើនពាណិជ្ជកម្មរវាងតំបន់នេះជាមួយនិងលោកខាងលិចអមដោយការផ្លាស់ប្តូរការគោរពសាសនា, ឯកសារការងារបុរាណវត្ថុវិទ្យាបានកត់ត្រាអំពីសេដ្ឋកិច្ច និង ការផ្លាស់ប្តូរការតាំងទីលំនៅមានមុនពួកអឺរ៉ុបបានចូលមកពាក់ព័ន្ធ (Christie 1996; Lape 2000)។ រូបភាពទី១ បង្ហាញពីភាពខុសប្លែកគ្នានៃទីក្រុងនៅភាគអាគ្នេយ៍ដែលបង្កើតឬពង្រីកនៅទូទាំងតំបន់ (ខ្លះរួមជាមួយការកើនឡើងនៃឥស្សរជនមូស្លីម) ពីបាតាវៀម៉ានីល និង សិង្ហបុរីរហូតដល់រដ្ឋធានីដីគោក ដែលមានមុខងារជាកំពង់ផែក្នុងស្រុកដូចជាទីក្រុងបាងកក និងភ្នំ-

ពេញ(Miksic 2006)។ មានតែពីរបីប៉ុណ្ណោះ មជ្ឈមណ្ឌលបែបនេះបានទទួលការយកចិត្តទុកដាក់ខាងបុរាណវត្ថុវិទ្យា ដូចជាសិង្គបុរីនិងប៉ាតានី នៅភាគខាងត្បូងប្រទេសថៃ។




*រូបភាពទី១៖ ផែនទីបង្ហាញទីតាំងក្រុងនៅអាស៊ីអាគ្នេយ៍ដែលមានទំនាក់ទំនងជាមួយពាណិជ្ជកម្មពិភពលោក នៅសតវត្សទី១៦-១៧ (ផែនទីគូដោយ* Alex Morrison)

ការស្រាវជ្រាវបុរាណវត្ថុវិទ្យាតិចតួចបានផ្តោតលើការតស៊ូក្នុងតំបន់ចំពោះភាពជឿនលឿនរបស់ចក្រពត្តិនិយម ប៉ុន្តែការស្រាវជ្រាវដែនសមុទ្រអំពីការអញ្ជើញពួកម៉ុងហ្គោលនៅភាគខាងជើងប្រទេសវៀតណាម (Kimura et al. 2014) ផ្តល់ជូនករណីសិក្សាល្អមួយៗ

សតវត្សទី១៨/១៩បានប្តូរគោលនយោបាយសេដ្ឋកិច្ចរបស់ចក្រពត្តិមិង ហើយក៏មានឥទ្ធិពលលើការផ្លាស់ប្តូរនៅក្នុងអាស៊ីអាគ្នេយ៍ដែរ។ ការស្រាវជ្រាវបុរាណវត្ថុវិទ្យានៅ

ក្នុងប្រទេសហ្វីលីពីនបង្ហាញថា ការបង្កើនវិស័យកសិកម្មនិងនយោបាយ បានកើតឡើងក្នុងអំឡុងពេលនេះដែរ។ ការវាយធ្នក់សមុទ្រជាញឹកញយនិងសង្គ្រាមនៅតាមជ្រលងភ្នំនៅតាមបណ្តាកោះដែលផ្តោតលើការនាំចេញ ក៏កើតមានឡើងនៅសម័យនោះដែរ។ ឧស្សាហកម្ម ផលិតផ្សេងៗ ដូចជា ការផលិតកុលាលភាជន៍រឹងបានលេចឡើងក្នុងអំឡុងពេលនេះដើម្បីបំពេញតម្រូវការតំបន់ (Grave et al. 2000, 2017; Gutman 2002) និង សាយភាយហួសដែនដីអាស៊ីអាគ្នេយ៍ទៀត។ ភស្តុតាងនៃការផលិតកម្រិតឧស្សាហកម្មក្នុងតំបន់ទំនិញពាណិជ្ជកម្ម ដូចជា សេរ៉ាមិចដុតក្នុងសីតុណ្ហភាពខ្ពស់ ត្រូវបានដកស្រង់ពីការស្រាវជ្រាវបុរាណវត្ថុវិទ្យាពីនាវាលិចនៅក្នុងតំបន់(រូបលេខ២)។ ការស្រាវជ្រាវពីសម្ភារៈ ផ្តល់នូវការយល់ដឹងដ៏មានតម្លៃ ប៉ុន្តែវត្ថុពាណិជ្ជកម្មដែលអាចរលួយដូចជាជ័រទឹក (Lambert et al. 2017) និងការស្រាវជ្រាវភូមិសាស្ត្របុរាណវត្ថុវិទ្យាអាចជួយដល់ការសិក្សាអំពីស្ថានីយដែនសមុទ្រដែលឥឡូវនេះគ្របដណ្តប់ដោយល្បាប់ (Guy 2017; Kimura et al. 2014)។

អ្នកជំនាញបុរាណវត្ថុវិទ្យាអាស៊ីអាគ្នេយ៍មិនត្រឹមតែកត់ត្រាការផ្លាស់ប្តូរ ដែលបានកើតឡើងមុនឬស្របគ្នាជាមួយទំនាក់ទំនងអ៊ឺរ៉ុប ប៉ុណ្ណឹងទេ (e.g.,Kim 2013; Stark 2006)។ ឥឡូវនេះការងារត្រូវបានធ្វើទៅលើផលប៉ះពាល់នៃអាណានិគមអឺរ៉ុបៈ ក្នុងការតាំងទីលំនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការបង្កើតសង្គមនយោបាយ។ អាណានិគមអឺរ៉ុបទាមទារឱ្យមានការរៀបចំលំនៅដ្ឋានសំខាន់ៗ ដើម្បីបំពេញតម្រូវការពួកអឺរ៉ុបសម្រាប់ផលិតផលក្នុងស្រុកនិងទំនិញចិន ហើយបានផ្លាស់ប្តូរតាមរយៈពេលវេលា ឆ្លើយតបទៅនឹងគោលនយោបាលអាណានិគមអឺរ៉ុប។ការតស៊ូដំបូងៗចំពោះទំនាក់ទំនងអឺរ៉ុបមានភាពខ្លាំងក្លានៅទូទាំងតំបន់




*រូបលេខ២៖ ផែនទីបង្ហាញទីតាំងកប៉ាល់លិចនៅតំបន់អាស៊ីអាគ្នេយ៍រកឃើញនៅសតវត្សទី១៤-១៦*

(From Flecker 2007, with permission from John Wiley and Sons)

នៅខាងក្រៅប្រទេសវៀតណាមខាងជើង និងប៉ះពាល់ដល់ការប្រែប្រួលលំនៅដ្ឋាន។ នៅភាគខាងកើតកោះគ្រឿងទេស (Spice Island) របស់ឥណ្ឌូនេស៊ីដែលជនជាតិហូឡង់បានវាយប្រហារដោយសម្លាប់ប្រជាជនក្នុងតំបន់ដើម្បីគ្រប់គ្រងកោះដែលដាំគ្រឿងទេសដូចជា

បានដា (Banda) (Lape 2000)។ ប្រជាជនហ្វីលីពីនមួយចំនួនបានភៀសខ្លួនចូលទៅក្នុងតំបន់ខ្ពង់រាបលូហ្សុន (Luzon) ដើម្បីគេចពីគោលនយោបាយផ្លាស់ប្តូរទីលំនៅរបស់ពួកអេស្ប៉ាញ (Acabado 2016)។ អត្តសញ្ញាណអ្នកស្រុកដែលបានកត់ត្រាក្នុងផ្នូរបញ្ចុះសពហ្វីលីពីន ក៏បញ្ចូលទាំងមេដឹកនាំនយោបាយនិងស្មារតី (Barreto-Tesoro 2008)។ការងារនៅភាគខាងជើងប្រទេសថៃបង្ហាញពីការធ្វើចំណាកស្រុកទៅតំបន់ខ្ពង់រាប ឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មរបស់រដ្ឋអយុធ្យានៅតំបន់ទំនាប ដើម្បីកម្លាំងពលកម្មទាំងនោះជួយគាំទ្រដល់ប្រព័ន្ធផលិតកម្មដែលផ្តោតលើការនាំចេញថ្មី (Grave 1995: 258)។

អាណានិគមអឺរ៉ុបក៏បាននាំមកនូវការបង្កើតផងដែរនូវបណ្តាញម៉ានីលហ្គាលឡេន (Manila Galleon) ថ្មីដែលបានចលនាទំនិញរវាងអាស៊ីនិងពិភពលោកថ្មី។ បណ្តាញនេះបានភ្ជាប់ហ្វីលីពីនអេស្ប៉ាញ ទៅម៉ិកស៊ិកអេស្ប៉ាញ តាមរយៈការធ្វើដំណើរប្រចាំឆ្នាំ ឬ ២ ដងក្នុង១ឆ្នាំពីសតវត្សទី១៦ដល់១៩។ ជនជាតិចិន និងទំនិញអាស៊ីអាគ្នេយ៍បានធ្វើដំណើរ (តាមផ្លូវសមុទ្រ)ឆ្ពោះទៅទិសភាគខាងកើតឆ្លងកាត់មហាសមុទ្រប៉ាស៊ីហ្វិក ដើម្បីទៅដល់អាកាភុលកូ (Acapulco) នៅខាងលិចឆ្នេរម៉ិកស៊ិក។ ទំនិញទាំងនេះត្រូវបានដោះដូរជាមាសប្រាក់ និងកាក់ប្រាក់ដែលបានត្រឡប់ទៅហ្វីលីពីនវិញ។ បេសកជនម៉ានីលហ្គាលឡេនជាង ១០០ នាក់ធ្វើដំណើរតាមសមុទ្រក្នុងកំឡុងពេលនេះ។ អាណានិគមអឺរ៉ុបនៅសតវត្សទី១៧ដល់ ១៩ មិនត្រឹមតែទាក់ទាញភាគអាគ្នេយ៍ទេ ទៅក្នុងលោកខាងលិចទេ;វាក៏រឹតចំណងពាណិជ្ជកម្មចិនកាន់តែជិតស្និទ្ធជាមួយភាគខាងលិច។ សហគមន៍ជាតិពន្ធ និងជាតិពន្ធនៅទីក្រុងកើតចេញពីសហជីពរវាងអាណានិគមចិននិងអឺរ៉ុបនៅបរទេស និងស្ត្រីក្នុងស្រុក គឺជាផលិតផលមួយនៃពាណិជ្ជកម្មបែបនេះ ដែលអ្នកបុរាណវត្ថុវិទ្យាមិនទាន់បានសិក្សានៅឡើយទេ។ ម៉ាឡាកា (ម៉ាឡេស៊ី)និងហូឡង់បា តាវៀ(ឥណ្ឌូណេស៊ី)ឧទាហរណ៍ មានជម្រកនៅ Peranakan(ចិន/ម៉ាឡេស៊ី)Mardijker(ដោះលែងទាសករម៉ាឡេស៊ី និងដើមកំណើតឥណ្ឌា)និងសហគមន៍"តូប៉ាស"ឬ"ព័រទុយហ្គាល់ខ្មៅ"(កូនចៅព័រទុយហ្គាល់និងរស់ Flores ឬ មនុស្សសុលុរ Solor) ។

ការស្រាវជ្រាវខាងបុរាណវត្ថុវិទ្យាបានចាប់ផ្តើមបង្ហាញផលប៉ះពាល់ផ្សេងៗគ្នានៃទំនាក់ទំនងអឺរ៉ុប និង ការធ្វើអាណានិគមនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍។ ឆ្នេរសមុទ្រនិងតំបន់ទំនាបច្រើនទទួលបានការទាក់ទងដំបូង

ហើយផ្ទាយនឹងមានអាណានិគមជាបន្តបន្ទាប់។ អាណានិគមអឺរ៉ុបក៏បានប៉ះពាល់ដល់ការរៀបចំសង្គមនយោបាយផងដែរនៅក្នុងតំបន់ខ្លះហាក់ដូចជាស្តែងពីការស្រាវជ្រាវកុលាលភាជន៍សម្រាប់បញ្ចុះសពនៅសតវត្សទី១៦ នៅស្ថានីយ Calatagan ប្រទេសហ្វីលីពីន (Barretto-Tesoro 2013)។

ចំណុចខ្សោយទាក់ទងនឹងការផ្សារបុរាណវត្ថុវិទ្យានៅសតវត្សទី១៤ ដល់សតវត្សទី១៨ អាស៊ីអាគ្នេយ៍ស្ទើរគ្មានចំណុចពិភាក្សាជាគន្លឹះ។ ប្រហែលថា កន្លែងតែមួយគត់ដែលសំខាន់និងជាប់គ្រមសីលធម៌នៃ "ប្រវត្តិបុរាណវត្ថុវិទ្យា" គឺប្រមូលយកមកវិញនូវវត្ថុកប៉ាល់លិចនៅសមុទ្រសម្រាប់ធ្វើពាណិជ្ជកម្ម។ វត្ថុទាំងនេះផ្តល់កាលប្បវត្តិជាមូលដ្ឋាន។ ដោយមានទិន្នន័យអាយុកាលនៅសម័យនេះមិនមានភាពជឿជាក់និងកង្វះខាតបច្ចេកទេសធ្វើវិភាគអាយុកាលតាមវិធីផ្សេងៗទៀត អ្នកជំនាញបុរាណវត្ថុវិទ្យាភាគច្រើនឲ្យអាយុកាល (កាលបរិច្ឆេទ) ស្ថានីយដែលគេស្រាវជ្រាវតាមរយៈទំនាក់ទំនង កុលាលភាជន៍រឹងផលិតក្នុងស្រុកនិង គ្រឿងឧបករណ៍ពាណិជ្ជកម្មចិន។ ការវិភាគគីមីភូមិសាស្ត្រ (Geochemical analysis) ទៅលើសេរ៉ាមិកពាណិជ្ជកម្មផ្លូវសមុទ្រក៏អាចជួយអ្នកជំនាញបុរាណវត្ថុវិទ្យាកសាងឡើងវិញនូវបម្រែបម្រួលបណ្តាញពាណិជ្ជកម្មក្នុងតំបន់និងអន្តរជាតិក្នុងរយៈពេលនោះ។ បុរាណវត្ថុវិទ្យាអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍បន្តដើរតួយ៉ាងសំខាន់ក្នុងការសិក្សាសតវត្សទី១៥ រហូតសតវត្សទី១៦ ដែលការស្រាវ ជ្រាវបុរាណវត្ថុវិទ្យាបន្ថែមទៀតអាចរួមចំណែកដើម្បីពង្រីកនិងកែលម្អប្រវត្តិសាស្ត្រខ្នាតធំនិងខ្នាតតូច។ អ្នកប្រវត្តិជាតិពន្ធុវិទ្យា ប្រើឯកសារយោងអឺរ៉ុបនិងអាស៊ីអាគ្នេយ៍ជាច្រើន បានចាប់អារម្មណ៍យ៉ាងខ្លាំងតែចំពោះសេដ្ឋកិច្ចនិងប្រវត្តិសាស្ត្រនយោបាយ ដែលការស្រាវជ្រាវបុរាណវត្ថុវិទ្យាលើប្រធានបទទាំងពីរ តែងតែផ្តល់ការយល់ដឹងប្លែកៗ។

តាមទស្សនៈពិភពលោក អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍បានដើរតួយ៉ាងសំខាន់ក្នុងការកើតឡើង និង ដំណើរការនៃប្រវត្តិសាស្ត្រអាស៊ីដែលស្របគ្នាជាមួយការពង្រីកប្រព័ន្ធពិភពលោក ដែលភ្ជាប់ទំនាក់ទំនងថ្មីជា មួយពិភពចាស់តាមបណ្តោយទាំងដីនិងផ្លូវមហាសមុទ្រ។ បុរាណវត្ថុវិទ្យាដែលមានបង្កើតការស្រាវជ្រាវយ៉ាងល្អនៅអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ផ្តល់ពត៌មានអំពីរបៀបដែលការផ្លាស់ប្តូរនៅក្នុងតំបន់ប្រកពសំខាន់ៗនិងបរិមាត្របានធ្លុះបញ្ចាំងនិងប៉ះពាល់ដល់ផ្នែកផ្សេងទៀតនៃប្រព័ន្ធ។ តំបន់ទាំងនេះ មានទិន្នន័យ

បុរាណវត្ថុវិទ្យាសម្បូរបែបសម្រាប់សិក្សាប្រធានបទផ្សេងទៀតដែលស្ថិតនៅក្រោមទស្សនៈវិស័យបុរាណវត្ថុវិទ្យា ដូចជា នគរូបនីយកម្មនិងតំណពូជ។ ស្ទើរតែគ្មាននរណាសិក្សាស្រាវជ្រាវអំពីបេសកកម្មកាតូលិកនៅអាស៊ីអាគ្នេយ៍ដែលបានធ្វើឡើងនៅសតវត្សទី១៧ នៅប្រទេសហ្វីលីពីន, ទីម័រខាងកើត, វៀតណាម និង ប្រទេសកម្ពុជា។ ការស្រាវជ្រាវបែបនេះនឹងផ្តល់នូវទិន្នន័យប្រៀបធៀបជាមួយនឹងការសិក្សាដែលបានធ្វើរួចនៅក្នុងសកលលោកថ្មី New World (និងជាពិសេសនៅអាមេរិកខាងជើង) បេសកកម្មអេស្ប៉ាញ និង បារាំង។

## ទិសដៅនាពេលអនាគត

តំបន់ភាគច្រើននៃអាស៊ីអាគ្នេយ៍នៅតែទទួលរងពីភាពខ្វះខាតនៃការយកចិត្តទុកដាក់ខាងបុរាណវត្ថុវិទ្យាចំពោះសម័យប្រវត្តិសាស្ត្រដំបូងបំផុត (៥០០ មុនគ.ស -៥០០នៃគ.ស) និង សម័យមុនដែលបានចាប់ផ្តើមនៅចុងសតវត្សទី១៩ នៃគ.ស។ ទោះយ៉ាងណា អ្នកជំនាញបុរាណវត្ថុវិទ្យាអំពីចក្រពត្តិអឺរ៉ុបនឹងរកឃើញទិន្នន័យច្រើនទាំងអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍៖ជនជាតិអឺរ៉ុបធ្វើអាណានិគមប្រទេសអាស៊ីអាគ្នេយ៍ លើកលែងតែថៃ ប្រទេសអង់គ្លេស បារាំង ព័រទុយហ្គាល់ និង ដាណឺម៉ាកបានបង្កើតវត្តមានអាណានិគមនៅក្នុងអាស៊ីខាងត្បូង។ ដូច្នេះអ្នកជំនាញបុរាណវត្ថុនឹងសិក្សាអ្វីដែលកំពុងលេចធ្លោនៃបុរេប្រវត្តិឧស្សាហកម្មនិងសម័យទំនើបដំបូង "មូលធននិយម"។ មិនមានការយកចិត្តទុកដាក់គ្រប់គ្រាន់លើវិស័យបុរាណវត្ថុវិទ្យា ចំពោះសេដ្ឋកិច្ចនយោបាយរបស់អាណានិគម និងជាពិសេសចំពោះការកើនឡើងនៃឧស្សាហកម្មអាណានិគមនៅសតវត្សទី១៩៖ កៅស៊ូនៅឥណ្ឌូចិន ម៉ាឡេស៊ី និង ស្រីលង្កា ស្ករនៅក្នុងហ្វីលីពីន ឥណ្ឌូនេស៊ីនិងឥណ្ឌា តែនៅឥណ្ឌាស្រីលង្កានិងម៉ាឡេស៊ី គ្រឿងទេសនៅឥណ្ឌូនេស៊ី; indigo និងកប្បាសនៅឥណ្ឌា; និងកាហ្វេនៅឥណ្ឌូនេ ស៊ីវៀតណាម និង ស្រីលង្កា។

ការប្តេជ្ញាចិត្តខ្ពស់ដើម្បីស្រាវជ្រាវរយៈពេលវែង អំពីកស្តុតាងបុរាណវត្ថុវិទ្យានៅអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍នៅសតវត្សទី១៥-១៩ នឹងជួយដោះស្រាយអតុល្យភាពបច្ចុប្បន្នដែលអ្នកប្រវត្តិសាស្ត្របានធ្លាប់បានបកស្រាយ កន្លងមក។ ការសិក្សាក្នុងស្រុកដោយយកចិត្តទុកដាក់ លើសម័យកាលនេះនឹងបំពេញបន្ថែមចំណេះដឹងរបស់យើង ផ្អែកលើទិន្នន័យឯកសារ និង ការយល់ដឹងអំពីប្រធានបទដែលចាប់អារម្មណ៍ដល់អ្នកជំនាញប្រវត្តិបុរាណវត្ថុវិទ្យានៅទូទាំងពិភពលោក និង

ប្រមូលបានការឆ្លើយតបក្នុងរយៈពេលវែង ចំពោះការប្រែប្រួលសង្គម និងទប់ទល់នឹងសង្គមៗ តម្រូវការគឺកាន់តែបន្ទាន់ ដោយសារផ្នែកជាច្រើននៃអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ធ្វើអន្តរកាលចេញពីស្ថានភាពដើមរបស់ពួកគេទៅជាប្រទេសកំពុងអភិវឌ្ឍន៍ និងលុបចោល (បំផ្លាញ) កស្តុតាងប្រវត្តិបុរាណវត្ថុវិទ្យាជាច្រើនៗ

## ឯកសារយោង


1. Acabado, S.A. 2016. The archaeology of pericolonialism: Responses of the “unconquered” to Spanish conquest and colonialism in Ifugao, Philippines. International Journal of Historical Archaeology 21 (1): 1–26.
2. Agustijanto, I. 2012. The pre-Srivijaya period on the easterncoast of Sumatra: Preliminary research at the Air Sugihan site. In Connecting empires and states; selected papers from the 13th international conference of the European Association of Southeast Asian Archaeologists, ed. –
3. M.L. Tjoa-Bonatz, A. Reinecke, and D. Bonatz, 32–41. Singapore: NUS Press.
4. Ali, D. 2014. The idea of the medieval in the writing of south Asian history: Contexts, methods and politics. Social History 39 (3): 382–407.
5. Bacus, E. 1999. Prestige and potency: Political economies of protohistoric Visayan polities. In Complex polities in the ancient tropical world, Archeological Papers of the American Anthropological Association 91, ed. E.A. Bacus and L.J. Lucero, 67–87. Washington, DC: American Anthropological Association.
6. Barreto-Tesoro, G. 2008. Identity and reciprocity in 15th century Philippines, BAR International Series, 1813. Oxford: John & Erica Hedges Ltd.
7. Bellina, B. 2014. Maritime silk road’s ornament industries: Socio-political practices and cultural transfers in the South China Sea. Cambridge Archaeological Journal 24 (3): 345–377.
8. Bulbeck, D., F.A. Aziz, S. O’Connor, A. Calo, J.N. Fenner, B. Marwick, J. Feathers, R. Wood,
    a. and D. Prastiningtyas. 2016. Mortuary caves and the dammar trade in the Towuti-Routa region, Sulawesi, in an island Southeast Asian context. Asian Perspectives 55 (2): 148–183.
9. Calo, A., B. Prasetyo, P. Bellwood, J.W. Lankton, B. Gratuze, T.O. Pryce, A. Reinecke, V.
    a. Leusch, H. Schenk, R. Wood, R.A. Bawono, I.D.K. Gede, N.L.K.C. Yuliatia, J. Fenner, C. Reepmeyer,
10. C. Castillo, and A.K. Carter. 2015. Sembiran and Pacung on the north coast of Bali: A strategic crossroads for early trans-Asiatic exchange. Antiquity 89: 378–396.
11. Carter, A.K. 2015. Beads, exchange networks and emerging complexity: A case study from Cambodia and Thailand (500 BCE – CE 500). Cambridge Archaeological Journal 25 (4): 733–757.
12. Casile, A. 2014. Changing religious landscapes in Gupta times: Archaeological evidence from the area of Baḍoh Paṭhāri in Central India. South Asian Studies 30 (2): 245–268.
13. Castillo, C.C., B. Bellina, and D.Q. Fuller. 2016. Rice, beans and trade crops on the early maritime silk route in Southeast Asia. Antiquity 90 (353): 1255–1269.

14. Chakrabarti, D.P., ed. 2003. The archaeology of European expansion in India: Gujarat, c. sixteenth to eighteenth centuries. New Delhi: Aryan Books International.

15. Christie, J. 1996. Money and its uses in the Javanese states of the ninth to fifteenth centuries A. D. Journal of the Economic and Social History of the Orient 39: 243–286.
16. Favereau, A., and B. Bellina. 2016. Thai-Malay Peninsula and South China Sea networks (500 BC–AD 200), based on a reappraisal of “Sa Huynh-Kalanay”-related ceramics. Quaternary International 416: 219–227.
17. Fogelin, L. 2006. Archaeology of early Buddhism. Lanham: Altamira Press.
18. Grave, P. 1995. Beyond the mandala: Buddhist landscapes and upland-lowland interaction in North-West Thailand AD 1200–1650. World Archaeology 272: 243–265.
19. -Grave, P., M. Barbetti, M. Hotchkis, and R. Bird. 2000. The stoneware kilns of Sisat chanalai and Early Modern Thailand. Journal of Field Archaeology 27 (2):169–182.
20. Grave, P., M. Stark, D. Ea, L. Kealhofer, B.S. Tan, and T. Tin. 2017. Differentiating Khmer stoneware production: An NAA pilot study from Siem Reap Province, Cambodia. Archaeometry 59 (1): 13–24.
21. Gutman, P. 2002. The Martaban trade: An examination of the literature from the seventh century until the eighteenth century. Asian Perspectives 40: 108–118.
22. Guy, J. 2017. The Phanom Surin shipwreck, a Pahlavi inscription, and their significance of the history of early Lower Central Thailand. Journal of the Siam Society 105: 179–196.
23. Hawkes, J.D. 2014a. Chronological sequences and the problem of early medieval settlement in India. Puratattva 44: 208–228.
24. Hawkes, J.D. 2014b. One size does not fit all: Landscapes of religious change in Vindhya Pradesh. South Asian Studies 30 (1): 1–15.
25. Hung, H.-S., K.D. Nguyen, P. Bellwood, and M. Carson. 2013. Coastal connectivity: Long-term trading networks across the South China Sea. The Journal of Island and Coastal Archaeology 8 (3): 384–404.
26. Junker, L. 2004. Political economy in the historic period chiefdoms and states of Southeast Asia. In Archaeological perspectives on political economies, ed. G.M. Feinman and L.M. Nicholas, 223–251. Salt Lake City: University of Utah Press.
27. Kim, N.C. 2013. Lasting monuments and durable institutions: Labor, urbanism, and statehood in northern Vietnam and beyond. Journal of Archaeological Research 21: 217–267.
28. Kimura, J., M. Staniforth, L.T. Lien, and R. Sasaki. 2014. Naval battlefield archaeology of the lost Kublai Khan fleets. The International Journal of Nautical Archaeology 43 (1): 76–86.
29. Lambert, J. B., A. J. Levy, L. C. Niziolek, G. M. Feinman, P. J. Gayford, J. A. Santiago-Blay and Y. Wu. 2017. The resinous cargo of the Java Sea Wreck. Archaeometry published online February 2017. https://doi.org/10.1111/arcm.12279.
30. Lape, P. 2000. Contact and colonialism in the Banda Islands, Maluku, Indonesia. Bulletin of the Indo-Pacific Prehistory Association 20: 48–55.
31. Miksic, J. 2000. Heterogenetic cities in premodern Southeast Asia. World Archaeology 32: 106–120.
32. Morrison, K.D. 1997. Commerce and culture in South Asia: Perspectives from archaeology and history. Annual Review of Anthropology 26: 87–108.
33. Shaw, J. 2013. Archaeologies of Buddhist propagation in ancient India: ‘Ritual’ and ‘practical’ models of religious change. World Archaeology 45 (1): 83–108.

34. Smith, M.L. 2006. The archaeology of South Asian cities. Journal of Archaeological Research 14: 97–142.
35. Smith, M.L. 2016a. Archaeology at Sisupalgarh: The chronology of an early historic urban centre in eastern India. In South Asian archaeology and art 2012, ed.V. Lefèvre, A. Didier, and B. Mutin, vol. 2, 683–695. Turnhout: BREPOLS.
36. Smith, M.L. 2016b. Historical and medieval period archaeology. In A companion to South Asia in the past, ed. G.-R. Schug and S.R. Walimbe, 332–343. Hoboken: Wiley.
37. Stark, M.T. 2006. Early mainland Southeast Asian landscapes in the first millennium AD. Annual Review of Anthropology 35: 407–432.
38. Trautmann, T., and C. Sinopoli. 2002. In the beginning was the word: Excavating the relations between archaeology and history in South Asia. Journal of the Economic and Social History of the Orient 45: 492–523.

# ពាណិជ្ជកម្មចល័តរបស់មីក្រូសហគ្រាស សហគ្រាសធុនតូច និង មធ្យមនៅកម្ពុជា

ដោយៈ បណ្ឌិត **ព្រុំ ទេវី**
អនុប្រធានវិទ្យាស្ថានសង្គមសាស្ត្រ និង វិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា
Email: promtevy@gmail.com

*ពាណិជ្ជកម្មចល័ត* (Mobile Commerce: M-Commerce) *ជាផ្នែកមួយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ទើបតែបង្កើតឡើងនៅឆ្នាំ១៩៩៧ ដោយលោក* Kevin Duffey *ក្នុងឱកាសបើកវេទិកាពាណិជ្ជកម្មតាមទូរសព្ទចល័តសកល នៅទីក្រុងឡុងដ៍ប្រទេសអង់គ្លេស។ ពាណិជ្ជកម្មចល័ត គឺ ជាការបញ្ជូនសមត្ថភាពពាណិជ្ជកម្មអេឡិចត្រូនិចដោយផ្ទាល់ទៅក្នុងដៃអ្នកប្រើប្រាស់នៅគ្រប់ទីកន្លែងតាមរយៈបច្ចេកវិទ្យាឥតខ្សែ។ វិធីសាស្ត្រនេះមានអត្ថប្រយោជន៍ច្រើនណាស់សម្រាប់មីក្រូសហគ្រាសសហគ្រាសធុនតូច និងធុនមធ្យម*(Micro,Small and Medium Enterprises: MSMEs) *និងអ្នកប្រើប្រាស់ចុងក្រោយ។ តាមរយៈការប្រើប្រាស់អ៊ីនធឺណិតជាមួយនឹងឧបករណ៍ចល័ត ដូចជាទូរសព្ទ* (mobile phone) *ថាបឡេត* (tablets) *អាយផេត* (i-pad) *បានធ្វើឱ្យមនុស្សជាច្រើនជ្រើសរើសគិតថា ពាណិជ្ជកម្មចល័តជា ហាងលក់ផលិតផលមួយនៅក្នុងហោប៉ៅរបស់គេ។ នៅប្រទេសកម្ពុជា នាឆ្នាំ២០១៩កន្លងទៅ យោងតាមទិន្នន័យរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ចំនួនអ្នកប្រើទូរសព្ទចល័តនិងអ្នកប្រើអ៊ីនធឺណិតលើសពីចំនួនប្រជាជនសរុបទៀតផង ដូចនេះអ្នកចូលរួមក្នុងពាណិជ្ជកម្មចល័តក៏មានច្រើនដែរ។*

*ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក* (E-Commerce) *ទើបនឹងចាប់ផ្តើមនាចុងទសវត្សទី៩០នេះទេហើយដូចបានបញ្ជាក់ខាងលើរួចមកថា ពាណិជ្ជកម្មចល័តគ្រាន់ជាផ្នែកមួយនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប៉ុណ្ណោះ តែមានការលូតលាស់ខ្លាំងជាងដោយសារមានអ្នកប្រើឧបករណ៍ចល័តច្រើនជាង។ ទន្ទឹមគ្នានឹងនេះដែរ បណ្តាញសង្គមដូចជា* Facebook ,Twitter, Pinterest, *និង* Instagram *ក៏បានបង្កើតកម្មវិធី*(App) *របស់គេរៀងៗ*

ខ្លួនដើម្បីឱ្យអ្នកប្រើប្រាស់មានភាពងាយស្រួលក្នុងការទិញទំនិញឬប្រើប្រាស់សេវាដោយផ្ទាល់ពីបណ្ដាញសង្គមតែម្ដង។ អ្នកជំនាញមួយចំនួន ក៏បានគិតរួចស្រេចហើយថា ពាណិជ្ជកម្មចល័តជាដំណាក់កាលថ្មីមួយទៀតនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដោយសារអ្នកប្រើប្រាស់អាចទិញទំនិញឬសេវាអនឡាញពីគ្រប់ទីកន្លែង និងគ្រប់ពេល វេលាតាមរយៈការប្រើប្រាស់ឧបករណ៍ចល័តរបស់គេ។ ការទាញយកកម្មវិធី និងការប្រើប្រាស់ទិន្នន័យផ្សេងទៀតជាការចំណាយមួយសម្រាប់អតិថិជនពាណិជ្ជកម្មចល័ត លើសពីអតិថិជនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ទោះជាយ៉ាងណាក៏ដោយ ពាណិជ្ជកម្មចល័តមានភាពប្លែកខុសគ្នាច្រើនពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រង់៖

- ***ភាពចល័ត***៖ ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកធ្វើឡើងតាមអ៊ីនធឺណិត ហើយជាទូទៅត្រូវមានកុំព្យូទ័រឬឡេបថបជាជំនួយ រីឯអ្នកប្រើប្រាស់ត្រូវមានកន្លែងត្រឹមត្រូវដើម្បីធ្វើប្រតិបត្តិការ។ ពាណិជ្ជកម្មចល័តវិញត្រូវការតែឧបករណ៍ចល័ត គេអាចធ្វើប្រតិបត្តិការនៅទីកន្លែងណាក៏បានឱ្យតែឧបករណ៍ចល័តនោះអាចភ្ជាប់បានជាមួយនឹងសេវាអ៊ីនធឺណិត។

-***ភាពអាចទៅដល់***៖ ដោយសារឧបករណ៍ចល័តគេងាយយកតាមខ្លួន ពាណិជ្ជកម្មចល័តងាយទៅ ដល់អតិថិជនបានច្រើនជាងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ MSMEs អាចទៅដល់អតិថិជនគ្រប់ទីកន្លែង នេះជាឱកាស ដែលគេអាចធ្វើពាណិជ្ជកម្មចល័តបានច្រើន ដោយសារមានអតិថិជនទូលំទូលាយ។

-***ភាពងាយស្រួលនៃប្រតិបត្តការ***៖ គ្រប់គ្នាអាចធ្វើប្រតិបត្តិការអាជីវកម្មនៅកន្លែងណាក៏បានឱ្យតែមានសេវាអ៊ីនធឺណិតតាមរយៈទូរសព្ទវៃឆ្លាតឬឧបករណ៍ចល័តផ្សេងទៀតដែលគេមានក្នុងដៃដោយគ្រាន់តែចុច ២-៣ប៊ូតុងទៅលើកញ្ចក់ឧបករណ៍ចល័តរបស់គេ។ ខុសពីពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិចត្រូនិក គេត្រូវធ្វើប្រតិបត្តការជាមួយនឹងកុំព្យូទ័រ។ អ្នកប្រើប្រាស់ត្រូវមានកន្លែងដើម្បីធ្វើប្រតិបត្តិការឬត្រូវប្រើឡេបថបបើសិនជាគេកំពុងធ្វើដំណើរ។

-***កំណត់ទីតាំង***៖ សមត្ថភាពនៃការកំណត់ទីតាំងរបស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានដែនកំណត់ដោយសារឧបករ-ណ៍ពិបាកយកតាមខ្លួន។ កម្មវិធីរបស់ពាណិជ្ជកម្មចល័ត អាចផ្ដល់ទីតាំងជាក់លាក់របស់អ្នកប្រើប្រាស់ ដោយមានជំនួយពីបច្ចេកវិទ្យាប្រព័ន្ធកំណត់ទីតាំងសកល (Global Positioning System: GPS) wifi ជាដើម។ ជាលទ្ធផលកម្ម

វិធីរបស់ពាណិជ្ជកម្មចល័តអាចផ្ដល់ទីតាំង ជាក់លាក់និងអត្តសញ្ញាណរបស់អតិថិជន។ ឧទាហរណ៍ដូចជាកម្មវិធី PassApp Taxi អ្នកបើកបរ អាចទៅរកអតិថិជនបានយ៉ាងស្រួល។

បាគង Bakong រថយន្តក្រុង

- **សុវត្ថិភាព៖** ក្នុងករណីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការទូទាត់ភាគច្រើនប្រើបណ្ណឥណទាន។ អតិថិជនតែងមានការព្រួយបារម្ភព្រោះត្រូវផ្ញើលេខបណ្ណឥណទានតាមអ៊ីនធឺណិត។ សុវត្ថិភាពសម្រាប់ករណីពាណិជ្ជកម្មចល័តអាចប្រសើរជាងតាមរយៈការស្កេនមុខ ក្រយៅដៃជាដើម។

កម្មវិធីរបស់ពាណិជ្ជកម្មចល័តមានច្រើនទៅវិស័យដែលគេយកទៅអនុវត្ត។ ទោះជាយ៉ាងណា ក៏ដោយគេអាចបែងចែកពាណិជ្ជកម្មចល័តជា៣ប្រភេទផ្សេងគ្នា៖

**-ទិញឥវ៉ាន់តាមឧបករណ៍ចល័ត** (Mobile shopping)៖ ជាប្រភេទមួយនៃពាណិជ្ជកម្មចល័ត ដែលប្រហាក់ប្រហែលទៅនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ខុសគ្នាត្រង់ថា គេប្រើឧបករណ៍ចល័ត។ លក្ខណៈល្អប្រសើររបស់កម្មវិធីឬបណ្ដាញសង្គម ដូចជា Facebook ,Twitter, Pinterest, Instagram ជាដើម អនុញ្ញាតឱ្យអតិថិជនទិញទំនិញតាមកម្មវិធីដែលភ្ជាប់ទៅនឹងហាងអនឡាញ។

- **ប្រតិបត្តិការធនាគារចល័ត** (Mobile banking)៖ជាប្រភេទមួយនៃពាណិជ្ជកម្មចល័ត ដែលប្រហាក់ប្រហែលទៅនឹងប្រតិបត្តិការធនាគារអនឡាញ ខុសគ្នាត្រង់ថាគេប្រើឧបករណ៍ចល័ត។ ក្នុងប្រតិបត្តិការធនាគារចល័តតែងតែមានកម្មវិធីដែលគ្រឹះស្ថានហិរញ្ញវត្ថុរៀបចំទុករួចជាស្រេច ដោយ មានភ្ជាប់ជាមួយកម្មវិធីជជែក ឬកម្មវិធីផ្ញើសារដើម្បីផ្ដល់សេវាទៅអតិថិជន ឧ. ACLEDA Unity Toan Chet របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។

- **ទូទាត់ចល័ត** (Mobile payments)៖ ជាប្រភេទមួយនៃពាណិជ្ជកម្មចល័ត ដែលផ្ដោតលើ ការបង្កើតថ្មីៗ នៃជម្រើសក្នុងការទូទាត់។ បច្ចុប្បន្ននេះ អ្នកប្រើប្រាស់អាចទាញយកអត្ត

ប្រយោជន៍ពីជម្រើសនៃការទូទាត់តាមទូរស័ព្ទចល័តជាច្រើនដែលហួសពីកាបូបចល័ត។

ពាណិជ្ជកម្មចល័តដែលបានបង្ហាញមកនេះ ជាក់ស្តែងមិនមែនសម្រាប់ប្រើប្រាស់តែការទិញ ទំនិញនិងទូទាត់ប៉ុណ្ណោះទេ គឺទាំងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ទាំងរដ្ឋបាលទូទៅ។ ការដាក់បញ្ចូលគ្នារវាងពាណិជ្ជកម្មចល័តនិងគំរូអាជីវកម្ម ឬការធ្វើឱ្យប្រសើរឡើងនៃសេវាពាណិជ្ជកម្មចល័តដែលមានរួច មកហើយ ជាជំហានយ៉ាងសំខាន់សម្រាប់មុខរបរជាច្រើន។







វចនានុក្រមសេដ្ឋកិច្ចកម្មវិធីបង់ប្រាក់ពន្ធ

និយាយរួម ពាណិជ្ជកម្មចល័តជាបច្ចេកទេសទំនើបដែលផ្តល់នូវភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម។ តាមរយៈការប្រើប្រាស់ឧបករណ៍ចល័ត ការបង្ហាញផលិតផលរបស់ MSMEs អាចទៅដល់ហោប៉ៅរបស់អតិថិជន។ ពាណិជ្ជកម្មចល័តអាចជួយ MSMEs ឱ្យកំណត់បានអតិថិជន គោលដៅតាមទីតាំង អ្នកផ្តល់សេវា ប្រភេទឧបករណ៍ចល័តដែលគេប្រើ និងលក្ខខណ្ឌផ្សេងៗទៀត ហើយនេះជាឧបករណ៍កិច្ចទីផ្សារយ៉ាងល្អ។ មិនតែប៉ុណ្ណោះ MSMEs អាចកាត់បន្ថយថ្លៃដើមបានច្រើនតាមរយៈការបន្ថយថ្លៃដើមប្រតិបត្តការ ថ្លៃដើមដឹកជញ្ជូន ក៏ដូចជាថ្លៃដើមបញ្ជាទិញផងដែរ។ ទន្ទឹមគ្នានឹងភាពងាយស្រួលសម្រាប់ការប្រើប្រាស់ពាណិជ្ជកម្មចល័តក៏មានគុណវិបត្តិមួយចំនួនដែរ ដូចជា ឧបករណ៍ចល័តនិងការបង្កើតកម្មវិធីសម្រាប់យកមកប្រើប្រាស់អាចមានតម្លៃខ្ពស់ចំពោះម្ចាស់មីក្រូសហគ្រាសមួយចំនួន ជាពិសេសនៅតាមទីជនបទ។ ម្យ៉ាងទៀតដើម្បីដាក់បង្ហាញផលិតផលថ្មីៗក្នុងកម្មវិធីម្ចាស់សហគ្រាសត្រូវបង់ថ្លៃដំណើរការកម្មវិធីជាប្រចាំទៀតផង។ ក្រៅពីនោះអាចមានបញ្ហា ដូចជា សេវាអ៊ីនធឺណិតខ្សោយ សុវត្ថិភាពនៃភាពជាឯកជនរបស់អតិថិជនជាដើម។

# គន្ថនិទ្ទេស


១-https://en.wikipedia.org/wiki/Mobile_com -merce#History

២- https://www.trc.gov.kh/km/internet-subc-ribers/

៣-https://www.forbes.com/sites/quora-/2018/05/25/what-is-the-difference-between-e commerce-and-mobile- commerce/#2cf94e574c6d

៤- https://www.thedroidsonroids.com/blog/-what-is-mobile-commerce-definition-andtypes-of - mobile-commerce។

៥- https://www.investopedia.com/terms/m/-mobile-wallet.asp

# បទពិសោធន៍គួរឱ្យចងចាំនៃជីវិតដឹកនាំ និងគ្រប់គ្រងអង្គភាពក្នុងបណ្តាឆ្នាំកន្លងទៅ

*ដោយៈ បណ្ឌិត អ៊ុំ ម៉ុម ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ជាធម្មតា ក្នុងជីវិតសកម្មភាពការងារ របស់មនុស្សយើងម្នាក់ៗ ទោះបីអ្នកនោះជាជនសាមញ្ញក្តី ឬក៏ជាអ្នកទទួលខុសត្រូវស្ថាប័នណាមួយក្តីច្រើនឬតិច តែងតែទទួលបាននូវលទ្ធផលជាផ្លែផ្កាពីជីវិតបំពេញការងារ ដែលរូបគេម្នាក់ៗបានឆ្លងកាត់។ លទ្ធផលទាំងនោះមានល្អផង និងអាក្រក់ផង ហើយត្រូវបានសាម៉ីខ្លួនជាអ្នក អនុវត្តផ្ទាល់ចាត់ទុកថា ជាមេរៀនពិសោធន៍ដ៏មានតម្លៃប្រចាំជីវិតដែលគួរគប្បីចៀសវាង ឬក៏ទទួលយកមកប្រើ ប្រាស់បន្តទៅទៀតដោយធ្វើការកែលម្អនិងបំពេញបន្ថែមនូវចំណុចខ្វះ ដើម្បីអនុវត្តការងារតទៅមុខទៀតឱ្យមានប្រសិទ្ធភាព ក៏ដូចជាចែករំលែកនូវចំណេះដឹងចំពោះអ្នកដទៃបានជ្រួតជ្រាបជាសាធារណៈ។ អ្វីៗដែលអ្នកអានបានឃើញជាបន្តបន្ទាប់ទៅទៀតនេះ គឺជាបទពិសោធន៍ការងារដែលខ្ញុំធ្លាប់បានជួបប្រទះក្នុងឆាកជីវិតជាអ្នកដឹកនាំ និងគ្រប់គ្រងអស់រយៈពេល៣៥ឆ្នាំកន្លងផុតទៅមុនពេលដែលរូបខ្ញុំក្លាយខ្លួនជានិវត្តជនដូចសព្វថ្ងៃ។*

*ខ្ញុំជឿជាក់ថា អ្វីៗដែលខ្ញុំនឹងធ្វើការរៀបរាប់តទៅនេះ ពិតជាមានចំណុចខ្វះត្រូវ* ***"អារម្មណ៍"*** *ឬក៏* ***"ទាស់ អារម្មណ៍"*** *អ្នកអានខ្លះជាក់ជាមិនខាន ប៉ុន្តែទោះជាមានចំណុចបែបនេះកើតឡើងយ៉ាងណាក្តី ក៏ខ្ញុំនៅ តែសញ្ជឹងគិតក្នុងចិត្តថា អ្វីៗទាំងអស់នោះជាចំណងកាតព្វកិច្ចខានមិនបាន ដែលខ្ញុំត្រូវបំពេញក្នុងនាមជាអ្នកធ្លាប់បានចូលប្រឡូកដោយផ្ទាល់ក្នុងកិច្ចការបម្រើសេវាសាធារណៈកន្លងមកមុនពេលសន្និប្រកាសនៃជីវិតចុងក្រោយរបស់ខ្ញុំធ្វើដំណើរចូលមកដល់។*

*ខាងក្រោមនេះ គឺជាប្រការជាក់ស្តែងទាំងឡាយនៃមេគំនិតដែលខ្ញុំបានខិតខំសម្រិតសម្រាំងរៀបចំចង ក្រងឱ្យទៅជាលក្ខណៈប្រព័ន្ធលាយឡំដោយអន្ទើៗ ជាការចាប់ចុងជូនផ្តួនរណ្តំនៃប្រការខ្វះៗ ទាក់ទងទៅនឹង បទពិសោធន៍ការងារដែលខ្ញុំធ្លាប់បានជួបប្រទះ។*

ខ្ញុំសូមលើកឡើងនូវប្រការទាំងនោះមួយម្តងៗ មកបង្ហាញជូន ដើម្បីទុកគ្រាន់ជាការត្រិះរិះពិចារណាទាំងអស់គ្នា សម្រាប់ជីវិតបំពេញការងាររបស់យើងម្នាក់ៗតទៅមុខៗ

## ១-កសាងអង្គភាពថ្មី គប្បីគិតពីប្រភពមនុស្ស

ការរៀបចំកសាងអង្គភាពថ្មី ពុំមែនជារឿងធម្មតាពេកទេ ឬជារឿងកើតឡើងដោយចៃដន្យនោះដែរ ប៉ុន្តែជារឿងចាំបាច់ ខានមិនបានសម្រាប់ប្រទេសជាតិនីមួយៗក្នុងកាលៈទេសៈណាមួយតម្រូវឱ្យ។ ការរៀបចំអង្គភាពថ្មីរមែងតែងតែត្រូវការមនុស្សជាចាំបាច់ពីព្រោះយើងធ្វើការជាមួយមនុស្ស និងសម្រេចបានជោគជ័យ ដោយសារមនុស្ស។ តាមទស្សនាទានអនុវត្ត មនុស្សជាកត្តាកំណត់សម្រាប់បរិស្ថានខាងក្នុងរបស់អង្គភាពនីមួយៗ។ តម្រូវការមនុស្ស ត្រូវបានគេយកចិត្តទុកដាក់បន្ទាប់ពីការគិតពិចារណា គូសវាសជារចនាសម្ព័ន្ធអង្គភាពបានចប់សព្វគ្រប់។ ជារួមការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពនីមួយៗ ត្រូវឆ្លើយតបទៅនឹងរបបនយោបាយដែលសាមីប្រទេសប្រកាន់យក ស្របទៅតាមគោលដៅ ក៏ដូចជាសំណូមពរដែលអង្គភាពនោះ ត្រូវការដោយរៀបចំយ៉ាងណាកុំឱ្យរចនាសម្ព័ន្ធមានវិសាលភាពធំពេកឬក៏តូចពេក ហើយត្រូវតែសមស្របទៅនឹងអ្វីដែលបានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសប្រយោជន៍ដើម្បីឱ្យអង្គភាពនោះមានលទ្ធភាពរក្សាបាននូវដំណើរប្រព្រឹត្តទៅក៏ដូចជាប្រសិទ្ធភាពអនុវត្តការងាររបស់ខ្លួន។ តាមបទពិសោធន៍ដែលខ្ញុំធ្លាប់បានឆ្លងកាត់កន្លងមក ទាក់ទងទៅនឹងប្រភពមនុស្សឃើញថា ក្រៅពីលក្ខខណ្ឌទាំងឡាយដែលធ្លាប់បានជ្រួតជ្រាបរួចមក ហើយតាមរយៈទ្រឹស្តីពីពេលមុនក៏ដូចជាទ្រឹស្តីបច្ចុប្បន្ន ប្រការសំខាន់គឺត្រូវស្គាល់ឱ្យបានច្បាស់លាស់ពីប្រភពមនុស្សដែលយើងត្រូវជ្រើសរើសយកមកប្រើប្រាស់។ ជាបឋមអ្នកទទួលខុសត្រូវគប្បីចោទសួរខ្លួនឯងថា តើអ្នកទាំងអស់នោះជានរណា? មកពីប្រភពណា? ជាមនុស្សបែបណា? សំខាន់អ្នកដែលខ្ញុំបានជ្រើសរើសយកមកបម្រើការក្នុងពេលនោះ ភាគច្រើនសុទ្ធតែជាអតីតសាស្ត្រាចារ្យឬគ្រូបង្រៀន ប្រកបដោយសមត្ថភាពនិងសីលធម៌វិជ្ជាជីវៈខ្ពស់ដែលខ្ញុំធ្លាប់បានស្គាល់យ៉ាងច្បាស់ កាលពីពេលមុនសង្គ្រាមឆ្នាំ១៩៧០ ហើយពួកគាត់នៅរស់រានមានជីវិតក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អ្នកទាំងអស់នោះ ត្រូវបានជ្រើសរើសឱ្យចូលមកបម្រើការងារក្នុងអង្គភាពបន្ទាប់ពីបានរៀនចប់វគ្គបណ្តុះបណ្តាលផ្នែកទ្រឹស្តី និងសមត្ថភាពជំនាញនៅក្នុងសាលានិងចុះទៅធ្វើការ

នៅឯមូលដ្ឋានមួយរយៈ។ ដោយសារតែលក្ខណសម្បត្តិដែលពួកគាត់ធ្លាប់មានកន្លងមករួមជាមួយនឹងការបណ្តុះបណ្តាលបំពាក់បំប៉នពីសមត្ថភាពជំនាញថ្មី ពួកគាត់បានជួយខ្ញុំយ៉ាងច្រើនក្នុងបុព្វហេតុ កសាងអង្គភាពឱ្យមានដំណើរការឆ្ពោះទៅមុខដោយគ្មានឧបសគ្គរហូតទាល់តែដល់ពេលមួយដែលប្រទេសរបស់យើងផ្លាស់ប្តូររបបនយោបាយក្នុងឆ្នាំ១៩៩១។ ដោយឡែក ជាមួយនឹងការខិតខំប្រឹងប្រែងរបស់ពួកគាត់ ខ្ញុំក៏មិនអាចបំភ្លេចពីគុណបំណាច់ដែលពួកគាត់ធ្លាប់មានកន្លងមកនោះឡើយ។ ជាក់ស្តែង ខ្ញុំបានស្នើសុំទៅថ្នាក់លើនូវតួនាទីមួយដ៏សក្តិសម ស្របទៅតាមសមត្ថភាពជំនាញ ក៏ដូចជាភាពស្មោះត្រង់ដែលពួកគាត់ធ្លាប់មាន ចំពោះអង្គភាពកន្លងមក។ ជាមួយនឹងស្ថានភាពវិវត្តប្រែប្រួលឆ្ពោះទៅរកវឌ្ឍនភាពដ៏គាប់ប្រសើរបែបនេះ ខ្ញុំអាចចាត់ទុកថា អ្វីៗទាំងអស់នោះពិតជាអនុស្សាវរីយ៍នៃជោគជ័យ ជំហានដំបូងដែលខ្ញុំមិនអាចបំភ្លេចបានសម្រាប់ជីវិតដឹកនាំនិងគ្រប់គ្រងក្នុងវ័យនៃអាយុកាល២៨ឆ្នាំរបស់ខ្ញុំ។

## ២-ជោគជ័យច្រើនឬតិច អាស្រ័យលើប្រភេទមនុស្សក្នុងមជ្ឈដ្ឋានដែលយើងកំពុង បំពេញការងារ

ផ្សារភ្ជាប់ទៅនឹងបញ្ហាមនុស្សដដែល គេអាចវាយតម្លៃបានថា ការដឹកនាំនិងគ្រប់គ្រងអង្គភាពមួយ អាចទទួលបានជោគជ័យច្រើនឬតិច អាស្រ័យទៅលើប្រភេទមនុស្សកំពុងបំពេញការងារ ក្នុងអង្គភាពដែលយើងទទួលខុសត្រូវ។ ជាក់ស្តែងបើមជ្ឈដ្ឋាននោះពោរពេញទៅដោយមនុស្សស្មោះត្រង់ មានសមត្ថភាពគ្រប់គ្រាន់ ប្រកបដោយបុគ្គលិកលក្ខណៈខ្ពស់ (មនុស្សមាន Super Ego) ដែលជាលទ្ធផលបានមកពីការអប់រំដ៏ល្អប្រពៃរបស់គ្រួសារ សាលារៀន ក៏ដូចជាស្ថាប័នសាសនា ជោគជ័យដែលយើងទទួលបានក៏មានលក្ខណៈធំធេង ទៅ តាមនោះដែរ ពីព្រោះអ្នកទាំងអស់នោះមានសីលធម៌ល្អ ចេះគោរពច្បាប់ទម្លាប់ជាមន្ត្រី ចេះគោរពគ្នានិងឱ្យតម្លៃគ្នាទៅវិញទៅមក ចេះដឹងពីឋានានុក្រមខ្ពស់ទាប និងចេះគោរពបទដ្ឋានរបស់អង្គភាព។ ផ្ទុយទៅវិញ បើមជ្ឈដ្ឋានដែលយើងកំពុងទទួលខុសត្រូវសម្បូណ៌ទៅដោយប្រភេទមនុស្សប្រកបដោយសមត្ថភាពដែរ ប៉ុន្តែមិនប្រកបដោយបុគ្គលិកលក្ខណៈខ្ពស់ មិនប្រកបដោយសីលធម៌ខ្ពស់ មានអាកប្បកិរិយាមើលស្រាលលើបទដ្ឋាន របស់អង្គភាព មានមនសិការ វិជ្ជាជីវៈ

ទន់ខ្សោយ ស្មារតីមិនបរិបូណ៌ដោយការភ្ញាក់រលឹក និងការទទួលខុសត្រូវ ខ្ពស់ក្នុងការងាររវល់តែច្រណែនឈ្នានីសគ្នា គិតតែបុគ្គលខ្លួនឯង បែងចែកជាបក្សពួកក្នុងចំណោមបញ្ញវន្តដូចគ្នា មិនទទួលស្គាល់សមត្ថភាពគ្នាមិនចេះសម្របសម្រួលគ្នា ដើម្បីឱ្យការងាររីកចម្រើនទៅមុខ តាមគោលដៅ ដែលបានកំណត់នោះ ជោគជ័យនៃការដឹកនាំ និងគ្រប់គ្រងរបស់យើង ក៏មានកម្រិតទៅតាមនោះដែរ ពោលគឺអ្នកគ្រប់គ្រង រវល់តែជាប់ដៃចំណាយពេលវេលាច្រើនសន្ធឹកសន្ធាប់សម្រាប់កិច្ចការផ្ទៃក្នុង ដោយខិតខំលើក កំពស់មនសិការវិជ្ជាជីវៈផង បង្រួបបង្រួមអ្នកទាំងនោះឱ្យចូលធុងគ្នាផង និងសម្របសម្រួលឱ្យត្រូវរ៉ូវគ្នាផង ព្រមទាំងអាចធ្វើការជាមួយគ្នាបាន សាមគ្គីឯកភាពគ្នា ដើម្បីឈានទៅសម្រេចគោលដៅរួម ដែលជាបំណង ប្រាថ្នាតែមួយគត់របស់អង្គភាព។

ទាំងអស់នេះ គឺជាអ្វីដែលខ្ញុំបានជួបប្រទះភាគច្រើន ក្នុងដំណាក់កាលបន្តបន្ទាប់មកទៀត ហើយដែលខ្ញុំគិតថា មានសភាពផ្ទុយគ្នាស្រឡះពីមជ្ឈដ្ឋាននៃការដឹកនាំ និងគ្រប់គ្រងរបស់ខ្ញុំ ក្នុងដំណាក់កាលដំបូង ជាហេតុធ្វើឱ្យខ្ញុំពុំទទួលបានជោគជ័យដ៏គាប់ប្រសើរ តាមឆន្ទៈដែលខ្ញុំប្រាថ្នាចង់បាន។

## ៣-ចេះធ្វើតុល្យការដោយមិនប្រសប់ខាង"វិធីរដ្ឋបាល" និង"វិធីសេដ្ឋកិច្ច"

***"វិធីរដ្ឋបាល"*** *និង* ***"វិធីសេដ្ឋកិច្ច"*** *ជាវិធីពីរយ៉ាងដែលអ្នកគ្រប់គ្រងតែងតែជួបប្រទះ និងយកមកប្រើ ប្រាស់ទៅតាមកាលៈទេសៈទីមួយៗ ដើម្បីជំរុញការបំពេញការងារឱ្យបានលឿនទៅមុខៗ ប៉ុន្តែក្នុងការអនុវត្ត ជាក់ស្តែងនូវវិធីទាំងពីរនេះ គេគប្បីមានការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ ជាពិសេសកុំឱ្យធ្ងន់ខ្លាំងទៅលើតែវិធីសេដ្ឋកិច្ចក្នុងពេលដែលអង្គភាពស្ថិតក្នុងសភាពធម្មតា មិនមែនស្ថិតក្នុងស្ថានភាពវាយសម្រុកដ៏មមាញឹកក្នុងការងារ។ អនុស្សាវរីយ៍មួយ ទាក់ទងទៅនឹងបញ្ហានេះ រូបខ្ញុំផ្ទាល់នៅចាំបានថា នៅពេលមួយនោះ កាលខ្ញុំនៅកាន់ការជានាយករងអចិន្ត្រៃយ៍ មានសហការីរបស់ខ្ញុំម្នាក់ជានាយករង បានជក់ចិត្តជិតអារម្មណ៍និងការប្រើប្រាស់* ***"វិធីសេដ្ឋកិច្ច"*** *នេះណាស់។ ដោយមើលឃើញវែងឆ្ងាយពីផលវិបាកដែលនឹងធ្លាក់មកដល់អង្គភាពនាពេលខាងមុខ ខ្ញុំតែងតែរំលឹក ដាស់តឿនរូបគាត់ជាញឹកញយ ដើម្បីឱ្យគាត់ថ្លឹងថ្លែងឡើងវិញនូវវិធីសាស្ត្រគ្រប់គ្រងរបស់គាត់។ ប៉ុន្តែផ្ទុយទៅវិញ រូបគាត់នៅតែជក់ចិត្តនឹងវិធីនេះដដែល ដោយម្យ៉ាងគាត់ប្រហែលជាមើលឃើញថា វិធីនេះ មានប្រសិទ្ធភាព អាចសម្រេចកិច្ចការបានភ្លាមៗ តាមឆន្ទៈដែលគាត់ចង់បាន ហើយម្យ៉ាងទៀត*

*ក៏អាចធ្វើឱ្យរូបគាត់មានឥទ្ធិពលមួយផ្នែកធំទៅលើបុគ្គលិកនៅក្រោមបង្គាប់ផ្ទាល់របស់គាត់ដោយសារតែវិធីនេះថែមទៀតផង។ សភាពបែបនេះ ចេះតែអូសបន្ទាយយូរទៅៗ រហូតដល់ពេលមួយ បានចេញជាលទ្ធផលជាក់ស្តែង ដោយសារតែទង្វើនោះបានជះឥទ្ធិពលទៅជាទម្លាប់មិនល្អសម្រាប់ការប្រើប្រាស់បុគ្គលិកឱ្យបំពេញការងារ សំខាន់គឺក្នុងពេលម៉ោងធ្វើការធម្មតារបស់អង្គភាព។ ឧទាហរណ៍ថា បើប្រើអ្នកទាំងនោះដោយមានលុយកាក់ភ្ជាប់ទៅជាមួយការងារ ហាក់ដូចជាស្ទុះស្ទាគ្រាន់បើ ផ្ទុយទៅវិញបើគ្មានលុយកាក់ខ្វះភ្ជាប់ទៅជាមួយទេ ពួកគេធ្វើការហាក់ដូចជា"**ប៉ក់ល្វើយ**"ចុងដៃចុងជើង មិនសូវស្វាហាប់រហូតដល់ពេលខ្វះ ហ៊ានបំភ្លេចការកិច្ចចោល ចេះកិកកុករកលេសយ៉ាងនេះឬយ៉ាងនោះ ធ្វើឱ្យយឺតយ៉ាវមិនបានសម្រេចការងារទៅតាមផែនការកំណត់ដែលថ្នាក់លើប្រគល់ឱ្យហើយ ទន្ទឹមនឹងនេះ ក៏ជះឥទ្ធិពលទៅជាការមើលស្រាលចំពោះវិន័យម៉ឺងម៉ាត់របស់អង្គភាពថែមទៀតផង។ ដូច្នេះ ដើម្បីចៀសវាងពីគុណវិបត្តិដូចដែលបានបង្ហាញជូនជាឧទាហរណ៍រួចមកហើយនេះ តាមទស្សនៈផ្ទាល់របស់ខ្ញុំ អ្នកគ្រប់គ្រងគួរតែចេះថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ ចេះគួបផ្សំប្រើប្រាស់ឱ្យបានល្អនូវវិធីទាំងពីរនេះយ៉ាងប៉ិនប្រសប់ដោយកុំឱ្យធ្ងន់ខ្លាំងតែទៅលើ "**វិធីសេដ្ឋកិច្ច**"ក្តេច"**វិធីរដ្ឋបាល**"ជាហេតុ ធ្វើឱ្យវិធីមួយនេះមានឥទ្ធិពលគ្របដណ្តប់ ហើយក្លាយទៅជាទម្លាប់មិនល្អក្នុងចំណាត់ការការងាររបស់ខ្លួន។*

## ៤-ធ្វើការក្រៅម៉ោងគោចចេះសងកម្រៃ

*បើគេគិតពិចារណាទៅលើទស្សនៈរបស់ខុងជឺ ទស្សនវិទូរូបនេះបានលើកឡើងពី "**ភាពត្រឹមត្រូវ**"របស់ បុគ្គលិក ក្រោមបង្គាប់នោះគឺ "**កម្រៃ**" នេះឯង។ កម្រៃគឺជារូបភាពមួយបែបនៃ "**វិធីសេដ្ឋកិច្ច**" ដែលអ្នកគ្រប់គ្រងតែងយកមកប្រើប្រាស់។ ប៉ុន្តែក្នុងកាលៈទេសៈខុសគ្នា ដូចដែលមានចែងរួចមកហើយក្នុងប្រការទី៣ ពោលគឺ វិធីលើកនេះប្រើប្រាស់តែនៅក្រៅម៉ោងធ្វើការ ឬថ្ងៃឈប់សម្រាកពីការងារដើម្បីសម្រុកធ្វើការឱ្យបានទាន់ តាមពេលវេលាកំណត់តែប៉ុណ្ណោះ។ ជាទូទៅគេច្រើនអនុវត្តវិធីនេះក្នុងអង្គភាពផលិតកម្ម ដោយគោរពតាមស្តង់ដារ តម្លៃមួយច្បាស់ លាស់ និងមានតម្លាភាព ហើយត្រូវបានធានាដោយច្បាប់ពលកម្មរបស់រដ្ឋថែមទៀតផង។ និយាយយ៉ាងនេះ មិនមែនមានន័យថាអង្គភាពសាធារណៈរបស់រដ្ឋ ដែលឋិតក្រៅអង្គភាពផលិតកម្ម មិនបានអនុវត្តនូវវិធីនេះសោះតែម្តងនោះទេ។*

ផ្ទុយទៅវិញ គេក៏អាចយកវិធីនេះមកអនុវត្តបានដែរ ដោយពឹងផ្អែកទៅលើកម្រៃដែលអង្គភាពនោះ ខិតខំស្វះស្វែងរកបាន។ ផ្សារភ្ជាប់ទៅនឹងបញ្ហានេះដដែល បើគេគិតពិចារណាឱ្យបានវែងឆ្ងាយតទៅទៀតនោះ ការសងកម្រៃអាចជាទឹកប្រាក់ដែលប្រគល់ជូនភ្លាមៗក្រោយពេលបញ្ចប់ការងារ ឬក៏អាចជាអ្វីៗផ្សេងទៀត មានតម្លៃខ្ពស់ជាងនេះដែលតបស្នងដោយមិនចំពោះក្នុងពេលភ្លាមៗទេ ប៉ុន្តែក្នុងពេលណាមួយក្រោយមកទៀត ដូចជាការលើកទឹកចិត្ត ឬការប្រគល់ជូនជាសក្តិ តំណែងណាមួយ បើសិនជាបុគ្គល នោះមានអំណត់ព្យាយាមតស៊ូរែកពុនការលំបាក(Hard Work) របស់អង្គភាពជាមួយយើង ដោយមិនគិតពីរឿងហត់នឿយជួយធ្វើការយើងទាំងយប់ ទាំងថ្ងៃមិនថាក្រៅម៉ោងធ្វើការ ឬថ្ងៃឈប់សម្រាក ដើម្បីរួមចំណែកធ្វើឱ្យអង្គភាពមានដំណើររីកចម្រើនទៅមុខ និងសម្រេចបានផ្លែផ្កាតាមគោលដៅកំណត់។

សរុបមកវិញ ការតបស្នងជាកម្រៃចំពោះបុគ្គលិកដែលបំពេញការងារក្រៅម៉ោងធ្វើការ រួមទាំងថ្ងៃឈប់ សម្រាកផងនោះ ជាទម្លាប់ដ៏គាប់ប្រសើររបស់ប្រធានអង្គភាពក្នុងការគោរពចំពោះតម្លៃមនុស្សដែលខុសប្លែកពីទំនិញធម្មតា ជាពិសេសតម្លៃពលកម្មដែលបុគ្គលិកទាំងនោះបានបំពេញជូនអង្គភាទាំងកម្លាំងកាយ និងកម្លាំងប្រាជ្ញា ហើយក៏អាចជាចំណងទាក់ទងសម្រាប់ផ្សារភ្ជាប់បុគ្គលិកឱ្យស្ថិតក្នុងបរិយាកាសសប្បាយរីក រាយផងដែរជាមួយអង្គភាពនោះជារៀងរហូតតទៅដោយគ្មានចេតនាណាមួយចង់ផ្លាស់ប្តូរទីកន្លែងធ្វើការទៅកាន់ទីដទៃទៀត។ ហេតុនេះហើយបានជាគេតែងតែឮក្នុងអង្គភាពខ្លះដែលទម្លាប់ធ្វើផ្ទុយពីនេះនូវពាក្យសំដីរអ៊ូរទាំដោយអសុរសរបស់បុគ្គលិកយ៉ាងដូច្នេះថា **"បានតែប្រើគោ ប៉ុន្តែមិនចេះឱ្យស្មៅគោស៊ីសោះ»**។

## ៥-ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់អង្គភាពឱ្យអស់លទ្ធភាពពេលបុគ្គលិកធ្លាក់ ក្នុងសភាពក្រខ្សត់

ភាពក្រខ្សត់ គឺជាសត្រូវដ៏ធំធេងបំផុតចំពោះអង្គភាព អាចធ្វើឱ្យអង្គភាពនោះរលំរលាយឬចុះទន់ខ្សោយ ខ្លះលំនឹងឬក៏ធ្វើឱ្យអង្គភាពនោះមិនអាចសម្រេចនូវគោលដៅទៅតាមបំណងប្រាថ្នាបាន។ ភាពក្រខ្សត់ ក៏អាចជះឥទ្ធិពលដល់ការគោរពវិន័យនិងប្រសិទ្ធភាពបំពេញការងាររបស់បុគ្គលិក។ បន្ថែមទៅលើនេះ បើយើង ជាអ្នកគ្រប់គ្រងខ្វះចន្ទោះនូវចិត្តសាស្ត្រគ្រប់គ្រង ពុំបានសិក្សាឱ្យស៊ីជម្រៅពីមូលហេតុហើយត្រឡប់ទៅរកតែវិធីរដ្ឋបាលយកទៅរឹតបន្តឹងការអនុវត្តបន្ថែមទៀតនោះ មិនខុសអ្វីពី

យកថ្មមកសង្កត់លើដើមទ្រូងឯង ឱ្យថប់ដង្ហើមស្លាប់ឬក៏វិស័យដូចជារុញទូកខ្លួនឯងដែលគ្រាំគ្រាស្រាប់ឱ្យទៅប៉ះទង្គិចនឹងផ្ទាំងថ្មមួយដ៏ធំបែកធ្លាយលិចទូក ខ្លួនឯងនោះទេ។ ប្រឈមមុខទៅនឹងហេតុការណ៍ដ៏លំបាកបែបនេះ ខ្ញុំក៏បែកគំនិតថ្មីមួយដើម្បីដោះស្រាយភាពក្រខ្សត់ ដោយស្នើសុំការអនុញ្ញាតពីលោកសាកលវិទ្យាធិការបានជួលសាលប្រជុំ ជួលបន្ទប់ធ្វើការខ្លះ ជាជាងទុកចោលទំនេរ ដើម្បីឱ្យអតិថិជនតំណាងឱ្យអង្គភាពនានាធ្វើសិក្ខាសាលា ជួលបរិវេណសាលា ពេលថ្ងៃឈប់សម្រាកឱ្យក្រុមហ៊ុនឯកជនមកថតជាវីដេអូឬថតខ្សែភាពយន្តផ្សេងៗ ជួលដំបូលអគារឱ្យក្រុមហ៊ុនទូរស័ព្ទចល័តដាក់អង់តែន ដើម្បីបង្កើនរលកសំឡេងឱ្យបានឮច្បាស់ ឬក៏បើកជាសាលាបង្រៀនភាសាអង់គ្លេសក្រៅ ម៉ោងធ្វើការ។ល។ ហេតុអ្វីក៏ខ្ញុំបែកគំនិតធ្វើយ៉ាងនេះដើម្បីដោះស្រាយភាពក្រខ្សត់? ពីព្រោះទីតាំង "**មណ្ឌល២**" ពេលនោះ កំពុងតែទទួលការចាប់អារម្មណ៍ពីអតិថិជនយ៉ាងខ្លាំង ហើយយើងក៏ឆ្លៀតឱកាសអំណោយផលបែបនេះ ធ្វើទំនាក់ទំនងជាមួយអតិថិជនយ៉ាងជិតស្និទ្ធតែម្តង ដើម្បីទាក់ទាញឱ្យគេមកជួលទីតាំងរបស់យើងគ្រាន់នឹងបានកម្រៃខ្លះៗ យកមកដោះស្រាយកង្វះខាតជីវភាពបុគ្គលិក ហើយម្យ៉ាងទៀតយើងក៏គ្មានជម្រើសប្រើប្រាស់មធ្យោបាយណាដែលល្អជាងនេះដែរ។ បើងាកមករកការបង្កបង្កើនផលដើម្បីផ្គត់ផ្គង់ជីវភាពខ្លួនឯង ដូចនៅអង្គភាពចាស់ពីមុនក៏មិនអាចទៅរួចព្រោះទីតាំងខុសគ្នា ហើយកាលៈទេសៈក៏មិនអំណោយផលឱ្យយើងធ្វើបែបនេះបានតទៅទៀតដែរ។ ចំពោះសំណើនេះ ថ្នាក់លើមិនដែលចង្អៀតចង្អល់អ្វីឡើយ ប៉ុន្តែគ្រាន់តែសំណូមពរឱ្យពួកខ្ញុំជាគណៈគ្រប់គ្រងផ្ទាល់ ធានាខុសត្រូវកុំឱ្យមានហេតុការណ៍ចៃដន្យអាក្រក់ណាមួយកើតឡើងដូចជា ហេតុផលខាងសន្តិសុខឬហេតុផលខាងនយោបាយណាមួយ បង្កឡើងដោយជនឱកាសនិយម ឆ្លៀតប្រើប្រាស់កន្លែងនេះធ្វើជាឈ្នាន់សម្រាប់វាយប្រហារទៅលើគណបក្សកាន់អំណាចតាមរយៈអង្គប្រជុំឬសិក្ខាសាលាផ្សេងៗដែលតាមភាសាសាមញ្ញ គេនិយមហៅថា "**ធ្វើនយោបាយតាមរយៈអង្គប្រជុំ**"។ ដូច្នេះដើម្បីធានាឱ្យថ្នាក់លើនឹងទុកចិត្ត រូបខ្ញុំផ្ទាល់ព្រមទាំងសហការី ចាំបាច់ត្រូវតែលើកជាវិធានការការពារជាមុន ដោយសហការជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ក៏ដូចជាពង្រឹងក្រុមសន្តិសុខផ្ទៃក្នុងរបស់ខ្លួន ព្រមទាំងចុះកិច្ចសន្យាច្បាស់លាស់ជាមួយអតិថិជន។ ប៉ុន្តែទោះបីជាមានវិធានការម៉ឺងម៉ាត់ល្អិតល្អន់បែបនេះក្តីក៏គណៈគ្រប់គ្រងសាលានៅតែមានការព្រួយបារម្ភ

ចំពោះបញ្ហានេះ ដោយខ្លាចក្រែងមានការថ្លោះធ្លោយ ដោយឆកល្វែងណាមួយកើតឡើង។ ប៉ុន្តែអាស្រ័យដោយភាពក្រខ្សត់ញាំញីជីវភាពបុគ្គលិកខ្លាំងពេក ទើបជំរុញឱ្យខ្ញុំនាំគ្នាជំនះពុះពារប្រថុយប្រថានបែបនេះក្នុងកាលៈទេសៈដែលប្រទេសជាតិបិតក្នុងអន្តរកាលនៃការប្រែប្រួលស្ថានការណ៍។ ជាភ័ព្វសំណាងល្អ ដំណើរការទាំងនោះចេះតែប្រព្រឹត្តទៅដោយសុវត្ថិភាព រហូតមកធ្វើឱ្យគណៈគ្រប់គ្រងសាលា បានរួចផុតពីការព្រួយបារម្ភ ព្រមទាំងសម្រេចបាននូវបំណងប្រាថ្នា ក្នុងការរកប្រាក់ចំណូលដោយខ្លួនឯងខ្លះដើម្បីទប់ទល់និងជួយសម្រាល បន្ទុករបស់រដ្ឋទៅលើការដោះស្រាយជីវភាពបុគ្គលិក។

## ៦-គ្រប់គ្រងនិងបែងចែកប្រាក់ចំណូលដោយតម្លាភាព

បើគ្រាន់តែស្តាប់ដោយមិនបានគិតគូរវែងឆ្ងាយ ការងារប៉ុណ្ណេះ ហាក់ដូចជាសាមញ្ញធម្មតា គ្មានអ្វីពិបាក ធ្វើសោះឡើយ អ្នកណាក៏ធ្វើបាន ហេតុអ្វីក៏មានបញ្ហា? គប្បីចងចាំថា ក្នុងការគ្រប់គ្រង **"អ្វីមិនទាន់កើត ក៏កើតជាបញ្ហា ពេលមានហើយ បើមិនប្រុងប្រយ័ត្ន ក៏កើតជាបញ្ហាថ្មីមួយទៀត"**។ នេះជារឿងដែលអ្នកគ្រប់គ្រង តែងតែជួបប្រទះ។ ដូច្នេះដើម្បីទប់ស្កាត់កុំឱ្យកើតមានជាបញ្ហា ពេលដែលអ្វីមួយត្រូវបានបង្កើតឡើង ហើយកំពុងទទួលបាននូវផ្លែផ្កា ចាំបាច់ត្រូវតែគ្រប់គ្រងឱ្យបានម៉ត់ចត់ តួយ៉ាងដូចជាប្រាក់ចំណូលដែលរកបានជាការល្អ ត្រូវរៀបចំជាគណៈកម្មការឬជាអង្គការ (អង្គការសហជីព) ទទួលខុសត្រូវច្បាស់លាស់ មានអ្នកទុកដាក់លុយកាក់ មានអ្នកកាន់បញ្ជីទូទាត់ចំណាយដោយមិនឱ្យច្របូកច្របល់គ្នា។ គណៈកម្មការត្រូវដឹងពីស្ថានភាពលុយកាក់ទាំងអស់គ្នា ហើយក្នុងនោះប្រធានគណៈកម្មការជាអ្នកទទួលខុសត្រូវរួម។ ពេលបែងចែកលុយកាក់ត្រូវមានគោលការណ៍បែងចែកឱ្យបានច្បាស់លាស់ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យត្រឹមត្រូវប្រកបដោយតម្លាភាព។ បន្ទាប់មកត្រូវផ្សព្វផ្សាយឱ្យបានដឹងឮទាំងអស់គ្នា។ អ្នកណាមិនច្បាស់លាស់ពីបញ្ហាអ្វីឬមិនទាន់យល់បញ្ហាអ្វីមួយ ត្រូវលើកជាសំណួរសួរនាំគ្នា ដើម្បីបានស្តាប់ឮទាំងអស់គ្នា។ រួចហើយទើបអនុវត្តការបែងចែក។ បែងចែកឱ្យអ្នកណាប៉ុន្មានត្រូវមានហត្ថលេខាទទួលត្រឹមត្រូវមិនឱ្យបើកជំនួសគ្នា បើមានករណីបើកជំនួស ត្រូវមានលិខិតផ្ទេរសិទ្ធិ ។ល។ ម្យ៉ាងទៀតទាក់ទងទៅនឹងការបែងចែកនេះដែរ ធម្មតាអ្នកគ្រប់គ្រងតែងមានមនោសញ្ចេតនាជាមួយកូនចៅក្រោមបង្គាប់។ ខុសត្រូវលើសខ្វះគ្នាជាបរិមាណលុយកាក់បន្តិចបន្តួច ត្រូវហ៊ានលះបង់ឱ្យគ្នាពីព្រោះគេជាអ្នកក្រខ្សត់ជាងយើង ជាអ្នក

ធ្វើផ្ទាល់ជាមួយអង្គភាព មិនមែនយើងជាអ្នកគ្រប់គ្រងអាចទៅធ្វើកិច្ចការនោះទាំងយប់ទាំងថ្ងៃ តស៊ូក្រាញននៀលដូចគេបានទេ។ ដូច្នេះហើយបានជាគេតែងពោលពាក្យយ៉ាងដូច្នេះថា **"អ្នកគ្រប់គ្រង គឺជាអ្នកសម្រេចកិច្ចការដោយសារអ្នកដទៃ"**។ យើងត្រូវតែហ៊ានលះបង់ឱ្យកូនចៅ យើងនៅពេលដែលគេកំពុងលំបាកវេទនាក្រខ្សត់។បើលះបង់បានដូចករណីខាងលើ អ្នកក្រោមបង្គាប់គេនឹង អាណិតស្រឡាញ់យើង គោរពយើងហើយភាពសុខដុមប្រាកដជានឹងកើតមានឡើងដោយ សារតែកាយវិការលះបង់ប្រកប ដោយសមានចិត្តរបស់យើងចំពោះគេ។ ប៉ុន្តែក្នុងភាពជាក់ស្តែង គេតែងសង្កេតឃើញមានបញ្ហា កើតឡើងនៅតាមអង្គភាពមួយចំនួន ហើយបង្កទៅជាទំនាស់ពិបាកដោះស្រាយ ដោយសារតែខ្វះតម្លាភាពក្នុងការបែងចែកលុយកាក់បន្តិចបន្តួចដែលអង្គភាពខិតខំរកបាន។ត្រង់ប្រការនេះហើយដែលខ្ញុំលើកឡើងថា **"ពេលមិនទាន់មានក៏កើតជាបញ្ហាដល់ពេលមានហើយ ក៏កើតជាបញ្ហាមួយថ្មីទៀត បើយើងធ្វេសប្រហែស មិនមានគោលការណ៍អនុវត្តឱ្យបានច្បាស់លាស់"**។ ប៉ុន្តែជាតិជាអ្នកគ្រប់គ្រងមិនត្រូវខ្លាចរអារចំពោះបញ្ហារហូតដល់មិនហ៊ានពុះពារបង្កើតឡើងនូវអ្វីដែលថ្មីសម្រាប់សេចក្តីសុខរបស់អ្នកនៅក្រោមបង្គាប់ ក៏ដូចជាភាពរីកចម្រើនទៅមុខរបស់អង្គភាពនោះឡើយ ផ្ទុយទៅវិញត្រូវតែមានសេចក្តីក្លា ហានប្រឈមមុខនឹងបញ្ហា ប៉ុន្តែត្រូវត្រៀមបង្ការទុកជាមុន ដើម្បីកុំឱ្យកើតមានបញ្ហាគួរសោកស្តាយណាមួយកើតឡើង។

## ៧-ធ្វើជាអនុប្រធានក៏ដូចជាធ្វើប្រធានទទួលបន្ទុកធ្ងន់ធ្ងរដូចគ្នា

ហេតុអ្វីបានជាមានពុំនោលបែបនេះទៅវិញ? ជាធម្មតា គេតែងតែពោលពាក្យយ៉ាងនេះថា **"សូវធ្វើប្រធានជាជាងធ្វើអនុប្រធាន"**។ ពីព្រោះបានធ្វើប្រធាន គឺមានអំណាចអាចសម្រេចលើគ្រប់កិច្ចការបាន។ជាចិត្តសាស្ត្រទូទៅរបស់មនុស្សម្នាក់ៗ គេតែងចង់ធ្វើប្រធាន ជាជាងធ្វើអនុប្រធាន។ គេកម្រឮបុគ្គលណាចង់ធ្វើអនុប្រធាន ជាជាងធ្វើប្រធាននេះណាស់។ ប៉ុន្តែក្នុងកាលៈទេសៈមិនទាន់តម្រូវឱ្យ តើគេសុខចិត្តរង់ចាំចាប់ស្រមោល ដែលជារបស់មិនពិតប្រាកដ ឬមួយក៏ស្រវាចាប់អ្វីដែលមានពិតប្រាកដ? ដោយឡែក បើគេនិយាយពីតួនាទីអនុប្រធានវិញ ក៏មិនមែនជាតួនាទីសាមញ្ញពេកនោះដែរ ប៉ុន្តែជាតួនាទីដែលរ៉ាប់រងកិច្ចការផ្ទាល់ធ្ងន់ធ្ងរបំផុតទៅតាមឯកទេសនីមួយៗ ដែលខ្លួនមាននៅចំពោះមុខប្រធាន ក៏ដូចជាអង្គភាពទាំងមូល វិស័យដូចសសរទ្រទម្ងន់ដូច្នោះដែរ បើសសរនោះរឹងមាំ ប្រធាននៅខាងលើក៏រឹងមាំ

ទៅតាមនោះដែរ។ ម្យ៉ាងទៀត បើគេគិតទៅលើតួនាទីវិញ ប្រធានជាអ្នកទទួលបន្ទុករួមគិតគូរខ្លាំងបំផុតទៅលើយុទ្ធសាស្ត្ររបស់អង្គភាពតែប៉ុណ្ណោះ ព្រមទាំងមានសិទ្ធិសម្រេចលើគ្រប់កិច្ចការទាំងអស់ ដែលជាអាយុជីវិតរបស់អង្គភាព ប្រកបដោយការទទួលខុសត្រូវខ្ពស់។នោះហើយដែលគេហៅថា"**សិទ្ធិអំណាចប្រធាន**"។ ទន្ទឹមនឹងនេះ ក្នុងចំណោមអនុប្រធានទទួលបន្ទុកក្នុងការងារនីមួយៗរមែងមានអនុប្រធានមួយប្រភេទទៀតដែលគេចាត់ទុកថាមានភាពចាស់ទុំខាងនយោបាយ មានទស្សនៈគោលជំហររឹងមាំច្បាស់លាស់ មានសមត្ថភាពនិងបទពិសោធន៍ជ្រៅជ្រះជាងអ្នកដទៃ។ អនុប្រធានរូបនោះ អាចត្រូវបានថ្នាក់លើផ្តល់ទំនុកចិត្តតែងតាំងឱ្យធ្វើជាអនុប្រធានអចិន្ត្រៃយ៍(ប្រចាំការ)ក្នុងចំណោមអនុប្រធានទាំងអស់។ អនុប្រធាន អចិន្ត្រៃយ៍អាចមានសិទ្ធិសម្រេច និងដោះស្រាយការងារប្រចាំថ្ងៃរបស់អង្គភាពជំនួសមុខប្រធានដោយមិនចាំបាច់សុំយោបល់ផ្ទាល់ ប៉ុន្តែគ្រាន់តែធ្វើរបាយការណ៍ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ជាលាយលក្ខណ៍អក្សរជូនប្រធានតែប៉ុណ្ណោះ អាស្រ័យទៅលើទំនុកចិត្តនិងការប្រគល់ភារកិច្ចរបស់ប្រធាន។ ពេលប្រធានអវត្តមានចេញទៅបំពេញបេសកកម្មនៅខាងក្រៅ អនុប្រធាននោះ នឹងអាចត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើជាប្រធានស្តីទីក្នុងដែនសមត្ថកិច្ចដ៏សមស្របណាមួយជំនួសប្រធានក៏សឹងមាន។ ដូច្នេះបើធ្វើអនុប្រធាន ទទួលបន្ទុកការងារធ្ងន់ធ្ងរបែបនេះទៅហើយ ក៏អាចប្រហាក់ប្រហែលគ្នាទៅនឹងប្រធានដែរ ពីព្រោះអនុប្រធានបែបនេះ ធ្លាប់បានហ្វឹកហាត់ដ៏ច្រើនបំផុតក្នុងការប្រតិបត្តិ ព្រមទាំងអាចសន្សំបរិមាណជាបណ្តើរៗ ឆ្ពោះទៅរកតំណែងបន្តវេនពីប្រធានដ៏សក្តិសមបំផុតក្នុងថ្ងៃអនាគត។ បើក្នុងអង្គភាពផលិតកម្មវិញ គេតែងសង្កេតឃើញ ហេតុការណ៍ខុសប្លែកពីនេះបន្តិច។ ជាក់ស្តែង បើប្រធានយកមកពីក្រៅស្រុក អនុប្រធានត្រូវដាក់អ្នកក្នុងស្រុក ឱ្យនៅធ្វើការអមជាមួយ។ យូរៗទៅអាស្រ័យដោយការប្រតិបត្តិជាក់ស្តែងក្នុងការងារ អនុប្រធានក្នុងស្រុកអាច ជំនួសប្រធានមកពីក្រៅស្រុកបាន។ ខ្ញុំសូមត្រឡប់មករកករណីខាងដើមវិញបន្តិច ដោយសូមរំលឹកដាស់តឿនសាជាថ្មីថា បើបានធ្វើជាប្រធានស្តីទីកុំភ្លេចអនុវត្តឱ្យបានត្រឹមត្រូវទៅតាមដែនសមត្ថកិច្ចដែលប្រធានប្រគល់ឱ្យពេលប្រធានអវត្តមាន។ បើពុំនោះសោតទេ នឹងកើតមានជាបញ្ហាក្រោយពេលដែលប្រធានត្រឡប់មកវិញ ដោយសារតែប្រធានស្តីទីធ្វើអ្វីៗហួសពីព្រំដែនកំណត់។ ហេតុនេះបានជាក្នុងសភាពជាក់ស្តែងមានអនុ

ប្រធានខ្លះអាច ជំនួសប្រធានបានអនុប្រធានខ្លះទៀត ជំនួសប្រធានមិនបានដោយសារខ្លះទំនុកចិត្តពីប្រធាន ទៅលើការបំពេញការងារជាប្រធានស្តីទីហួសដែនសមត្ថកិច្ចដែលប្រគល់ឱ្យពេលប្រធានអវត្តមាន។

## ៨-បើឱ្យត្រៀមដប់គប្បីត្រៀមម្ភៃ បើបញ្ជា ត្រឹមដប់កុំធ្វើដល់ម្ភៃ

អ្នកគ្រប់គ្រងដែលល្អ ត្រូវតែចេះត្រៀមបម្រុង និងជាអ្នកចេះគោរពបទបញ្ជាដែលហៅតាមភាសាមួយ បែបទៀតថា ចេះគោរពថ្នាក់លើរបស់ខ្លួន។ ត្រៀមបម្រុងនៅទីនេះ ចង់សំដៅទៅលើការត្រៀមបម្រុងទាំងកម្លាំងមនុស្ស ទាំងសម្ភារៈ ទាំងប្រាក់កាស។ល។ ជាទូទៅ ផ្សារភ្ជាប់នឹងបញ្ហាត្រៀមបម្រុង **"ចំនួន"** មានសារៈសំខាន់ ណាស់។ ប៉ុន្តែគប្បីកុំចាត់ទុកថា**"ចំនួន"**ដែលគេប្រាប់មកយើងសុទ្ធតែពិតប្រាកដ១០០%ឱ្យសោះ។ អាចមានពេលខ្វះលើសពេលខ្វះខ្វះ។ប្រសិនបើខ្វះវាជាអំណោយផលសម្រាប់ការត្រៀមបម្រុងរបស់យើង។ តែបើចំនួន នោះលើសច្រើនវិញ យើងមានការលំបាកបន្តិចក្នុងការប៉ាន់ប្រមាណដើម្បីត្រៀមបម្រុង។ ដោយឡែកចំពោះអ្នកកាន់ការងារផ្នែករដ្ឋបាលគ្រប់គ្រងវិញការត្រៀមបម្រុង គឺជាទម្លាប់ល្អមួយ ជារឿងចាំបាច់ខានមិនបាន។ បើបាត់ម្ចាស់ការ មិនបានត្រៀមបម្រុងទុកនោះ វាជារឿងដ៏គួរឱ្យខ្មាសអៀនមួយសម្រាប់អ្នកកាន់កិច្ចការនេះ ហើយលទ្ធផលទទួលបានគឺច្រើនតែ"**ខូចការ**"ឬទទួលការស្តីបន្ទោសពីប្រធាន។ ដូច្នេះដើម្បីកុំឱ្យកើតមានករណីបែបនេះ គប្បីសុខចិត្តត្រៀមបម្រុងឱ្យលើសប្រសើរជាងត្រៀមខ្វះ។ ប៉ុន្តែដើម្បីត្រៀម ឱ្យបានត្រឹមត្រូវពីបរិមាណ ទាល់តែយើងមានវិធីដើម្បីត្រៀម។ ឧទាហរណ៍ថា ក្នុងករណីជាក់ស្តែងខ្លះ យើងគប្បីដឹងត្រួសៗជាមុនពីកម្មវិធីជាក់ស្តែង។ ត្រូវដឹងថា តើប្រធានចុះទៅធ្វើការនៅកន្លែងណាខ្លះ? ជួបអ្នកណាខ្លះៗជួបប៉ុន្មានដង? ជួបម្តងៗប្រហែលប៉ុន្មាននាក់? ទើបយើងប៉ាន់ស្មានដឹងពីចំនួនដែលត្រូវត្រៀមបានត្រឹមត្រូវ ហើយប្រមើលមើលបានពីភាពចៃដន្យណាមួយដែលអាចនឹងកើតមានឡើងដោយឥតព្រាងទុក។ បើយើងត្រៀមលក្ខណៈបានល្អ ប្រធានក៏មិនខ្មាស់គេ ប្រធានតែងមានភាពកក់ក្តៅមានទំនុកចិត្តមកលើយើង ហើយតែងហៅរកយើងឱ្យទៅជាមួយគាត់ជានិច្ច។ ម្យ៉ាងទៀត ការត្រៀមបម្រុងឱ្យ លើស មិនមែនជាការធ្លាក់ក្នុងទង្វើខ្ជះខ្ជាយ សប្បាយចាយនោះទេ ហើយក៏រឹតតែមិនមែនជារឿងសាមញ្ញធម្មតាពេកដែរ សម្រាប់ជីវិតអ្នកកាន់ការងារគ្រប់គ្រង។

ចំណែកបទបញ្ញាវិញ ថ្នាក់ក្រោមត្រូវតែគោរពតាមឱ្យបានម៉ឺងម៉ាត់។ មិនអាចមានករណីមិនគោរពបទបញ្ញាឬ"**បញ្ញាដប់**"ធ្វើលើសដល់ម្ដែនោះបានដែរ។ ព្រោះទង្វើបែបនេះអាចធ្លាក់ទៅក្នុងករណីមិនគោរពបទបញ្ញាផង និងនាំទៅដល់ការបាត់បង់ទំនុកចិត្តពីប្រធាន ចំពោះសាមីខ្លួនដែលជាអ្នកកាន់កិច្ចការនោះ ដោយផ្ទាល់ ហើយក៏អាចជារឿងដែលថ្នាក់ក្រោមមិនសប្បាយចិត្តជាមួយប្រធានផង ព្រោះតែការចង់បានគាប់គួររបស់អ្នកអនុវត្តផ្ទាល់ ហើយ ទៅដាក់គំនាបថ្នាក់ក្រោមឱ្យបំពេញដោយយកឈ្មោះប្រធានទៅប្រើប្រាស់។ បើមានករណីដូចខាងក្រោយនេះកើតឡើង គឺជាគ្រោះថ្នាក់ដោយមិនដឹងខ្លួនសម្រាប់ប្រធានដោយសារតែ ការចង់បានគាប់គួរធ្វើលើសបទបញ្ញា។ ដូច្នេះប្រធានត្រូវតែម៉ឺងម៉ាត់ចំពោះទង្វើធ្វើលើសបទបញ្ញារបស់អ្នកនៅក្រោមបង្គាប់របៀបនេះ ដើម្បី កុំឱ្យបាត់បង់ជំនឿទុកចិត្តនិងប្រជាប្រិយភាពរបស់ខ្លួនជាប្រធានចំពោះអ្នកក្រោមបង្គាប់។

## ៩-បង្កើតបទដ្ឋាន គោរពបទដ្ឋាន ដោះស្រាយការងារតាមបទដ្ឋាន

បទដ្ឋាន ជាកត្តាសំខាន់ចាំបាច់សម្រាប់អង្គភាពនីមួយៗធ្វើសកម្មភាពត្រឹមត្រូវមានសណ្ដាប់ធ្នាប់ របៀបរៀបរយ និងឈានទៅសម្រេចបានគោលដៅ។ បទដ្ឋានអាចជារូបភាពនៃច្បាប់ដែលមនុស្សទាំងឡាយ ក្នុងអង្គភាពស្រុះស្រួលគ្នាបង្កើតឡើង និងនាំគ្នាគោរពតាមបទដ្ឋាននោះ។ ប៉ុន្តែបើបង្កើតបានជាបទដ្ឋានហើយ ត្រូវមានវិធីដើម្បីឱ្យបទដ្ឋាននោះធានានូវប្រសិទ្ធភាព។ ដាក់ស្ដែងមុននឹងដាក់ឱ្យបទដ្ឋាននោះដំណើរការប្រការសំខាន់គត្រូវយកបទដ្ឋាននោះ ទៅដាក់ឆ្លងអង្គប្រជុំគ្រប់សមាសភាព ដើម្បីរួមមតិកែលម្អ។ បន្ទាប់មកទើបដាក់ឱ្យអនុវត្តជាផ្លូវការ។ មកដល់ដំណាក់កាលនេះ ការអនុវត្តត្រូវតែប្រព្រឹត្តឡើងជាទូទៅមិនថាឡើយអ្នកនោះ ជាបុគ្គលិកសាមញ្ញ ឬថ្នាក់ដឹកនាំអង្គភាពកម្រិតណានោះទេ សុទ្ធតែមានកាតព្វកិច្ចគោរពទាំងអស់គ្នា ព្រោះបទដ្ឋាននោះជាតំណាងឱ្យឆន្ទៈរបស់ខ្លួន។ បើមិនគោរពបទដ្ឋានបានន័យថា មិនគោរពនូវឆន្ទៈខ្លួនឯង។ ដោយឡែកបទដ្ឋាននីមួយៗមិនដូចគ្នាទេ មិននៅហ្នឹងថ្កល់មួយកន្លែងទេ ប៉ុន្តែអាចមានការប្រែប្រួលទៅតាមចរិតការងារនិងការរីកចម្រើនរបស់អង្គភាពថែមទៀតផង។ ឧបមាថា បើអង្គភាពនោះទទួលគ្រប់គ្រងតែបុគ្គលិកសុទ្ធ សាធ បទដ្ឋាននោះតម្រង់ឆ្ពោះតែទៅលើបុគ្គលិកប៉ុណ្ណោះ។ ផ្ទុយទៅវិញ បើសិនជាអង្គភាពនោះជាសាលាបណ្ដុះបណ្ដាលផង គេត្រូវធ្វើបទដ្ឋានពីរៈ មួយសម្រាប់បុគ្គលិក

មួយទៀតសម្រាប់និស្សិតឬសិក្ខាកាម ហើយការអនុវត្តត្រូវមានទំនាក់ទំនងគ្នានិងបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំងមានការកែលម្អទៅតាមកាលៈទេសៈប្រែប្រួល។ ដោយឡែកដើម្បីឱ្យបទដ្ឋានមួយមានប្រសិទ្ធភាពក្រៅពីការធ្វើគំរូល្អក្នុងការគោរពបទដ្ឋានរបស់ថ្នាក់ដឹកនាំអង្គភាព ក៏នៅមានការត្រួតពិនិត្យជាប់ជាប្រចាំ និងការដាក់ពិន័យម៉ឺងម៉ាត់ចំពោះជំពូកជនដែលប្រព្រឹត្តល្មើសនឹងបទដ្ឋាន។ ម្យ៉ាងទៀត ទន្ទឹមនឹងការគោរពអ្នកដឹកនាំគ្រប់គ្រង អាចយកបទដ្ឋាននេះមកធ្វើជាមូលដ្ឋានបង្អែកសម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងដោយមិនលម្អៀងទៅរកអគតិទាំងបួន(ស្រឡាញ់ ស្អប់ ខ្លាច និងមិនដឹងច្បាស់)។ ធ្វើបានដូច្នេះ ទើបមានឈ្មោះជាអ្នកគ្រប់គ្រងដែលអាចចៀសវាងបាន ពីទំនាស់កើតមានឡើងក្នុងអង្គភាព បណ្តាលមកពីអំពើលម្អៀងដោយឆន្ទាគតិមិនគោរពបទដ្ឋាន ហើយអាចនាំទៅដល់ ការរក្សានូវសណ្តាប់ធ្នាប់របៀបរៀបរយ និងភាពសុខស្ងប់ក្នុងស្ថាប័នបានល្អប្រសើរ។នេះជាបទពិសោធន៍ដ៏មានជោគជ័យមួយទៀត ដែលខ្ញុំតែងតែរក្សាយ៉ាងខ្ជាប់ខ្ជួនក្នុងការដឹកនាំនិងគ្រប់គ្រងអង្គភាពកន្លងមក។

## ១០-ឡើងថ្នាក់តាមលំដាប់ ទទួលបានបទពិសោធន៍កាន់តែច្រើន

ខ្ញុំបានជួបនឹងហេតុការណ៍បែបនេះចំនួនពីរលើក គឺលើកទីមួយពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩១ ដែលជាដំណាក់កាលចាប់ផ្តើមការងារគ្រប់គ្រងដំបូង និងលើកទីបីពីឆ្នាំ២០០២ដល់ឆ្នាំ២០១៤(លើកទីពីរពីឆ្នាំ១៩៩១-២០០០) ដែលជាឆ្នាំចុងក្រោយនៃការបញ្ចប់ជីវិតការងារជាមន្ត្រីក្របខណ្ឌទៅកាន់ជីវិតជាមន្ត្រីចូលនិវត្តរហូតមកដល់សព្វថ្ងៃ។

- **ដំណាក់កាលទីមួយ(១៩៧៩-១៩៩១)**

បន្ទាប់ពីត្រូវបានគណៈឃោសនាអប់រំមជ្ឈិមចាត់បញ្ជូនឱ្យទៅរៀនវគ្គទ្រឹស្តីនយោបាយនិងជំនាញគ្រប់គ្រងថ្នាក់ស្រុកលើកដំបូងរយៈពេលបីខែ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោយពេលរៀនចប់វគ្គទី១នៅភ្នំពេញដែលជាវគ្គប្រមូលផ្តុំបញ្ញវន្តនៅសេសសល់ពីការកាប់សម្លាប់រៀនសូត្រពីគោលនយោបាយរបស់ប្រទេសមុននឹងចេញទៅបំពេញការងារនៅតាមក្រសួងនានា ខ្ញុំនឹងមិត្តភក្តិរួមជំនាន់មួយចំនួនត្រូវបានក្រសួងចាត់បញ្ជូនឱ្យទៅធ្វើការជាគ្រូជំនួយ (Assistant) នៅសាលានយោបាយមជ្ឈិមរណសិរ្ស(ពេលនោះមិនទាន់ប្តូរឈ្មោះមកជាសាលានយោបាយមជ្ឈិមនៅឡើយទេ)។ បន្ទាប់ពីធ្វើការជាមួយសិក្ខាកាមបានពីរវគ្គ ខ្ញុំត្រូវបានទទួលការកិច្ចមួយថ្មីជា

ប្រធានការិយាល័យសិក្សាទទួលបន្ទុកគ្រប់គ្រង និងបណ្តុះបណ្តាលសិក្ខាកាមដែលជាអនាគតមន្ត្រីរាជការ ឬជាកម្មាភិបាលបង្គោលនៅតាមក្រសួង មន្ទីរនានាជុំវិញមជ្ឈិមនិងតាមបណ្តាខេត្តនានានៃទូទាំងប្រទេស។ បន្ទាប់មកខ្ញុំត្រូវបញ្ជូនឱ្យទៅសិក្សានៅក្រៅប្រទេសម្តងទៀតក្នុងវគ្គទ្រឹស្តីនយោបាយ៦ខែនិងវគ្គជំនាញឃោសនាអប់រំចំនួនពីរខែបន្ថែមទៀត។ ត្រឡប់មកវិញ ធ្វើការមួយរយៈបានទទួលការតែងតាំងជានាយករងអចិន្ត្រៃយ៍ផង និងទទួលបន្ទុកបណ្តុះបណ្តាលផង។ ធ្វើការបានមួយឆ្នាំខ្ញុំត្រូវទៅសិក្សាម្តងទៀត ក្នុងវគ្គទ្រឹស្តីនយោបាយរយៈពេល២ឆ្នាំ(១៩៨៤-១៩៨៥)។ ពេលចប់ត្រឡប់មកវិញ បានទទួលភារកិច្ចជានាយករងអចិន្ត្រៃយ៍និងទទួលបន្ទុក ផ្ទាល់លើផ្នែកខ្លឹមសារនិងបណ្តុះបណ្តាល។ សូមកត់សម្គាល់ថា ជារៀងរាល់លើក ដែលខ្ញុំត្រូវបញ្ជូនទៅរៀន ខ្ញុំមិនអាចចៀសផុតពីការទទួលភារកិច្ចជាគណៈគ្រប់គ្រងវគ្គសិក្សាទាំងនោះបានទេ។ ដោយសារតែការចៀសមិនផុតបែបនេះ ធ្វើឱ្យខ្ញុំកាន់តែទទួលបាននូវបទពិសោធន៍ថ្មីៗបន្ថែមទៀតទៅលើការគ្រប់គ្រងវគ្គសិក្សាសម្រាប់កម្មាភិបាលក្រសួងមន្ទីរ និងកម្មាភិបាលនានានៅតាមខេត្តនៃទូទាំងប្រទេស។ ខ្ញុំសូមបញ្ជាក់ជូនតទៅទៀតថា ពេលរៀនចប់វគ្គ២ឆ្នាំចុងក្រោយ ក៏ជាពេលដែលសាលានយោបាយត្រូវរៀបចំខ្លួនទទួលភារកិច្ចថ្មី ដើម្បីទទួលខុសត្រូវបណ្តុះបណ្តាលវគ្គទ្រឹស្តីនយោបាយនិងគ្រប់គ្រង សម្រាប់រយៈពេល៦ខែ ដោយខ្លួនឯងឈប់បញ្ជូនសិក្ខាកាម ឱ្យទៅរៀននៅវៀតណាមដូចមុនទៀតហើយ។ ទន្ទឹមនឹងនេះដែរក៏មានសិក្ខាកាមមួយចំនួនទៀត ត្រូវបានចាត់បញ្ជូនឱ្យទៅរៀនវគ្គទ្រឹស្តីនយោបាយនៅសហភាពសូវៀតរយៈពេលយូរ ដើម្បីត្រឡប់មកវិញរួមគ្នាទទួលខុសត្រូវវគ្គទ្រឹស្តីនយោបាយនៅសាលានយោបាយជាន់ខ្ពស់របស់បក្ស។

- **ដំណាក់កាលទីបី(២០០២-២០១៤)**

ក្នុងដំណាក់កាលនេះ ក៏មានភាពមិនខុសប្លែកគ្នាប៉ុន្មានពីដំណាក់កាលទីមួយដែរ។ ពេលនោះជាពេល ខ្ញុំបានចាកចេញពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ ដែលជាស្ថាប័នដ៏កំសត់កម្រមួយទទួលភារកិច្ចបណ្តុះបណ្តាលនិស្សិតរយៈពេលបួនឆ្នាំលើមុខវិជ្ជាមនុស្សសាស្ត្រនិងសង្គមសាស្ត្រទៅបន្តការរៀនសូត្រថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់(ថ្នាក់ម៉ាស្ទ័រ) ផ្នែកវិទ្យាសាស្ត្រនយោបាយពីឆ្នាំ២០០០-២០០២ សិក្សានៅរាជបណ្ឌិត្យសភាកម្ពុជាដែលចាប់កំណើតតាំងពីឆ្នាំ១៩៩៩ដើម្បីលើកកំពស់សមត្ថភាពផ្ទាល់ខ្លួនឱ្យស្របទនឹងអ្វីដែលជាគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការកសាង

ធនធានមនុស្ស។ ជាមួយនឹងសញ្ញាប័ត្រដែលទទួលបាន ខ្ញុំក៏ត្រូវបានរាជបណ្ឌិត្យសភាកម្ពុជារក្សាទុកឱ្យនៅបំពេញ កិច្ចការក្នុងផ្នែកបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បី ជួយកិច្ចការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឱ្យមានសកម្ម ភាពជាបន្តទៅទៀត។ បំពេញការងារក្នុងឋានៈជាមន្ត្រីសាមញ្ញនៅផ្នែកនេះបានពីរឆ្នាំ(រាជបណ្ឌិត្យសភាកម្ពុជាបានកំណត់ដំណាក់កាលនេះ ថាជាដំណាក់កាលសាកល្បងមន្ត្រី) ខ្ញុំក៏ត្រូវបានដំឡើងឋានៈជាប្រធានផ្នែកទស្សនវិជ្ជានិងសង្គមវិជ្ជា(ឋានៈស្មើនឹងប្រធាននាយកដ្ឋាន) ក្នុងវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម(២០០៤-២០០៧)។ ទន្ទឹមនឹងភារកិច្ច ស្នូលក្នុងផ្នែកនេះ ខ្ញុំបានឆ្លៀតពេលសរសេរសៀវភៅមួយចំនួនដូចជាទស្សនវិជ្ជាខ្មែរតាមរយៈពាក្យស្លោកប្រវត្តិគំនិតនយោបាយបស្ចិមប្រទេស សន្តិវង្សនិងគំនិតដឹកនាំសម័យហ្វូណន ចេនឡា ចតុមុខ លង្វែក ចំណេះដឹងជាមូលដ្ឋានស្តីពីសង្គមវិជ្ជា សង្គមវិជ្ជាអប់រំវិតវិយាបថប្រទេសតូចនៅ ចន្លោះប្រទេសធំហើយខ្លាំង ផ្លូវបត់ជា ប្រវត្តិសាស្ត្រនៃនយោបាយកម្ពុជា...(សៀវភៅទាំងអស់នេះខ្លះក៏បានបោះពុម្ពផ្សាយខ្លះក៏មិនទាន់បោះពុម្ពហើយត្រូវពន្យារពេលដល់ក្រោយៗមកទៀត)។ ចាប់ពីឆ្នាំ២០០៧-២០០៩ ខ្ញុំត្រូវបានតែងតាំងជាអគ្គលេខាធិការរងនៃរាជបណ្ឌិត្យសភាកម្ពុជាដើម្បីទទួលបន្ទុករ៉ាប់រងកិច្ចការក្នុងអគ្គលេខាធិការដ្ឋានក៏ដូចជា កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់ស្ថាប័ន។ ដោយសារកិច្ចខិតខំប្រឹងប្រែងក្នុងការងារដ៏លំបាកលំបិនបំផុតនេះខ្ញុំត្រូវបានលើកទឹកចិត្ត ដោយទទួលការតែងតាំងជាអគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជាចាប់ពីឆ្នាំ២០០៩-២០១៤។ ជាការគួរឱ្យកត់សម្គាល់ក្នុងចន្លោះឆ្នាំនេះ ខ្ញុំបានរួមចំណែកជួយស្ថាប័នលើផ្នែកបណ្តុះបណ្តាលថ្នាក់បណ្ឌិតជំនាន់ទី១ ទី២ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែល កំពុងតែមានការខ្វះខាត មិនអាចឆ្លើយតបបានទៅនឹងសំណូមពរការងារដែលកាន់តែរីកចម្រើន។ ខ្ញុំសូមបញ្ជាក់បន្ថែមតទៅទៀតថា ចាប់ពីឆ្នាំ២០០៨ រហូតដល់ថ្ងៃ៣០ ខែមីនា ឆ្នាំ២០១២ ក្នុងស្ថានភាព"ធ្វើការផង រៀនផង" ខ្ញុំបានទទួលអាហារូបករណ៍ចូលរៀនថ្នាក់បណ្ឌិតជំនាន់ទី២និងបាន ការពារនិក្ខេប បទថ្នាក់នេះជាប់ជាស្ថាពរ ព្រមទាំងទទួលបានជាផ្លូវការនូវសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងសា-ធារណៈ។ ជាមួយនឹងមោទកភាពដ៏ខ្ពង់ខ្ពស់ពុំធ្លាប់មានក្នុងជីវិត ខ្ញុំបានបាត់បង់ទៅវិញនូវឱកាសដ៏កម្រមួយក្នុងការទទួលតំណែងខ្ពស់ជាងនេះបន្តិច ក្នុងរាជបណ្ឌិត្យសភាកម្ពុជា

ដោយសារតែភាពយឺតយ៉ាវរបស់ខ្ញុំ ក្នុងការសរសេរនិក្ខេបបទរយៈពេលបីខែ។

សរុបមក បើពិនិត្យទៅលើដំណាក់កាលទាំងពីរ ឃើញថា ដំណើរជីវិតនៃការដឹកនាំនិងគ្រប់គ្រងរបស់ខ្ញុំ បានចាប់ផ្ដើមពីមន្ត្រីគ្រប់គ្រងដ៏សាមញ្ញមួយរូបឈានទៅដល់តំណែងជានាយករងអចិន្ត្រៃយ៍ ក៏ដូចជាអគ្គលេខាធិការ។ ដូច្នេះ បើគិតពីពេលវេលាឃើញថា ខ្ញុំខាតបង់ច្រើនដោយសារតែការផ្ទេរដំណាក់កាលពីរលើក។ ប៉ុន្តែ បើគិតពីបទពិសោធន៍វិញឃើញថា ខ្ញុំសន្សំបរិមាណបានច្រើនគួរសមពីការងារ ព្រោះតែខ្ញុំបានហ្វឹកហាត់ដោយអំណត់ព្យាយាមបំផុតក្នុងការដឹកនាំគ្រប់គ្រងក៏ដូចជាការបណ្ដុះបណ្ដាល ហើយបានចូលប្រឡូកជាមួយនឹងជីវិតពិតនៃវិស័យនេះ នៅក្នុងស្រទាប់មនុស្សស្ទើរតែគ្រប់មជ្ឈដ្ឋានរបស់ប្រទេស។ ដោយសារតែហេតុផលបែបនេះហើយបានជាខ្ញុំអាចដកស្រង់បាននូវគតិដូចដែលបានបរិយាយមកពីខាងលើយ៉ាងដូច្នេះថា"**ឡើងថ្នាក់តាមលំដាប់ទទួលបានបទពិសោធន៍កាន់តែច្រើន**"។

## ១១-ពេលស្រុកទេសប្រែប្រួល កុំអាចសញ្ញាឃើញ ហើយគ្មានសញ្ញាប័ត្រ

នេះជាបទពិសោធន៍មួយទៀតនៃជីវិតដឹកនាំនិងគ្រប់គ្រងដែលខ្ញុំទទួលបាន ក្នុងដំណាក់កាលទីពីរ (១៩៩១-២០០០) ហើយក៏ជាដំណាក់កាលនៃជីវិតពោរពេញទៅដោយភាពផ្អែមល្ហែមផង និងភាពកំសត់ អំណត់ព្យាយាមផង។ ខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកអានជាបន្តទៅទៀតថា នៅពេលនោះ ដោយស្ថានភាព ស្រុកទេសយើងផ្លាស់ប្ដូររបបនយោបាយ កម្លាំងទាំងអម្បាលមាណនៅក្នុងសាលាត្រូវបានបំបែកចេញ និងធ្វើសមាហរណកម្មទៅក្នុងស្ថាប័នមួយទៀតដែលជាស្ថាប័នអប់រំរបស់រដ្ឋ មានចរិតប្រហាក់ប្រហែលគ្នាទៅនឹងសាលានយោបាយ ដែលខ្ញុំធ្លាប់បានដឹកនាំដែរ។ រូបខ្ញុំផ្ទាល់ នាយករងពីររូប និងសហការីជាច្រើនរូបទៀតដែល កាន់កិច្ចការតាមការិយាល័យ សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិក កម្មករត្រូវបានប្រគល់ភារកិច្ចឱ្យមកធ្វើការនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមណ្ឌល២ ដែលជាអតីតសាលានយោបាយជាន់ខ្ពស់របស់បក្សទើបតែសាងសង់ រួចតែមិនទាន់បានដំណើរការ រួមជាមួយនឹងប្រធាន អនុប្រធានដេប៉ាតឺម៉ង់បួនរូបទៀត មកពីសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ។ ខ្ញុំសូមបញ្ជាក់ជូនបន្ថែមថា អង្គភាពថ្មីនេះ ជាអង្គភាពបណ្ដុះបណ្ដាលនិស្សិតកម្រិតបរិញ្ញាបត្ររយៈពេលបួនឆ្នាំផ្នែកមនុស្សសាស្ត្រនិងសង្គមសាស្ត្រ។ នៅក្នុងអង្គភាពថ្មីនេះខ្ញុំគ្រប់គ្រងបណ្ដើរ ខិតខំរៀនសូត្របណ្ដើរ

ដើម្បីបញ្ចូលខ្លួនឱ្យស្របទៅនឹងការអប់រំ"**ម៉ូដែលថ្មី**" គួបផ្សំជាមួយនឹងចំណេះដឹងបន្តិចបន្តួចដែល ខ្ញុំធ្លាប់ទទួលបានកាលខ្ញុំកំពុងរៀនជានិស្សិតនៅឡើយ។ ខ្ញុំខិតខំរៀនសូត្ររហូតទទួលបានសញ្ញាប័ត្រឧត្តម ផ្នែកទស្សនវិជ្ជា និងសញ្ញាបត្រគ្រូមធ្យមសិក្សាកម្រិត២ ដើម្បីបំពេញបន្ថែមតាមតម្រូវការនៃស្ថានការថ្មី។ គឺនៅក្នុងពេលនោះហើយ ទើបខ្ញុំដឹងច្បាស់ថាសញ្ញាបត្រផ្នែកទ្រឹស្តីនយោបាយពីពេលមុនដែលខ្ញុំខិតខំចំណាយពេលរៀនសូត្ររាប់ឆ្នាំមកហើយ ត្រូវទុកចោលមួយអន្លើលែងយកមកប្រើប្រាស់បានទៀតហើយ ក្នុងពេលនេះព្រមទាំងក្លាយទៅជាអ្វីដែលគេហៅថា"**សញ្ញាឃើញ**"ទៅវិញ។ អាចនៅសេសសល់ខ្លះដែរ បើតាមខ្ញុំ គិតដូចជាបទពិសោធន៍នៃការបណ្តុះបណ្តាលនិងគ្រប់គ្រងចិត្តសាស្ត្រគ្រប់គ្រង ការត្រិះរិះពិចារណានិងវាយតម្លៃសភាពការណ៍តាមបែបវិចារវិទ្យា (Dialectique) ដែលតាមសម្តីអ្នកចំអកឡកឡឺយឱ្យខ្ញុំថាសុទ្ធតែជា "**សញ្ញាឃើញ**"ក្នុងរបបនយោបាយសង្គមនិយមរបស់ស្រុកទេសយើងកាលពីសម័យមុន។ បើពិតដូច្នេះមែន តាមទស្សនាទាននិយមថ្មីនេះ តើខ្ញុំនៅសល់អ្វីខ្លះជាប់នៅនឹងខ្លួនក្នុងកាលៈទេសៈប្រែប្រួលដ៏លំបាកនេះ? បើតាមទស្សនាទាន និយមថ្មីនេះ ខ្ញុំនៅសេសសល់ជាប់នឹងខ្លួនតែភាសាបារាំងមួយមុខគត់ដែលអាចទប់ទល់ជាមួយគេបាន ហើយ ដែលរូបខ្ញុំផ្ទាល់ ត្រូវបង្ខំចិត្តយកមកប្រើប្រាស់ឡើងវិញ ដើម្បីធ្វើជាមុខរបរចិញ្ចឹមជីវិតគ្រួសារនិងកូនស្រីពីរនាក់ទៀតដែលនៅតូចៗមិនទាន់ដឹងក្តីប៉ុណ្ណោះ។ ជាចៃដន្យល្អ គាប់ចួនពេលនោះប្រទេសបារាំងគេ មានគោលបំណងបណ្តុះបណ្តាលភាសារបស់គេឱ្យកូនខ្មែររៀនដូចកាលពីជំនាន់ ***សង្គមរាស្ត្រនិយម*** ហើយក៏ស្របទៅនឹង ការអំពាវនាវរបស់លោកសាកលវិទ្យាធិការ រកគ្រូដែលចេះភាសាបារាំងមកបង្រៀននិស្សិតផងនោះ ខ្ញុំក៏បាន ដាក់ពាក្យសុំអនុញ្ញាតពីគាត់ដើម្បីបានចូលបង្រៀនភាសាបារាំង ចំពោះនិស្សិតថ្នាក់ត្រៀម តាមកម្មវិធីសៀវភៅ G.MAUGER ចាប់ពីម៉ោង១២ថ្ងៃត្រង់រហូតដល់ម៉ោង៣រសៀល ដោយទទួលបានកម្រៃពីបារាំង៣០ដុល្លារ សហរដ្ឋអាម៉េរិកក្នុងមួយខែ បន្ថែមទៅលើប្រាក់បៀវត្សរ៍ជាមន្ត្រីរាជការតែប៉ុណ្ណោះ។ បង្រៀនចប់ត្រូវចុះទៅធ្វើការនៅមណ្ឌល២ជាបន្តទៅទៀត រហូតដល់ម៉ោងប្រាំកន្លះល្ងាច។ ចាប់ពីម៉ោងប្រាំកន្លះល្ងាច រហូតដល់ម៉ោង ប្រាំបីកន្លះយប់ ខ្ញុំត្រូវឆ្លៀតពេលទៅរៀនភាសាបារាំងបន្ថែមទៀតនៅសាលា ***អាលីយ៉ង់ ហ្វ្រង់សែស*** (Alliance Française)។ ដោយសុំលោកនាយកសាលា

បារាំង រៀនឥតបង់ថ្លៃ ដើម្បីទទួលបានការបណ្តុះបណ្តាលបន្ត (Formation continue)។ បើមិនដូច្នេះទេ បារាំងគេមិនឱ្យសិទ្ធិខ្ញុំទៅបង្រៀននិស្សិតថ្នាក់ត្រៀម នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញទេ។ ពេលថ្ងៃ សៅរ៍-អាទិត្យ ដើម្បីលំហែខួរក្បាលខ្លះពីការហត់នឿយពេញមួយសប្តាហ៍ ខ្ញុំបានឆ្លៀតប្រើប្រាស់កម្លាំងកាយ ដើម្បីបំភ្លេចការនឿយហត់ផ្នែកខួរក្បាល ដោយប្រកបរបរបោះពុម្ពអិដ្ឋខ្យល់ យកទៅបោះដុំឱ្យដេប៉ូសំណង់ ដើម្បីបានកម្រៃបន្ថែមយកទៅទប់ទល់នឹងការចំណាយដ៏ច្រើនពុំធ្លាប់មានក្នុងជីវភាពប្រចាំថ្ងៃនិងការរៀនសូត្រ។ ខ្ញុំខិតខំរៀនសូត្រនិងធ្វើការរបៀបនេះ រហូតទាល់តែប្រឡងជាប់ដោយទទួលបានសញ្ញាប័ត្រឌីប្លូមជាន់ខ្ពស់ផ្នែក ភាសាបារាំង (Diplôme supérieur de la langue française) ចេញឱ្យដោយសាលាអាលីយ៉ង់បារាំងនៅភ្នំពេញ ដើម្បីបញ្ជាក់ជាផ្លូវការនូវចំណេះដឹងផ្នែកភាសាបារាំងកាលពីពេលកន្លងមក។ គឺចាប់តាំងពីពេលនោះមកហើយ ដែលបារាំងចាប់ផ្តើមទទួលស្គាល់ខ្ញុំ ហើយចាត់ឱ្យខ្ញុំទៅបង្រៀនភាសាបារាំងចំពោះនិស្សិតឆ្នាំទី៣ តាមមុខវិជ្ជាមួយចំនួនផ្នែកលើកម្មវិធី **នូវ៉ូសង់ហ្វ្រុងទីយែរ** (Nouveau Sans Frontière) ដោយបានទទួលប្រាក់កម្រៃ៣ដុល្លារក្នុងមួយពេល (១ពេលស្មើនឹង៩០នាទី) សម្រាប់និស្សិតរៀន ភាសាបារាំងក្រៅដេប៉ាតឺម៉ង់។ ប៉ុន្តែអាចបង្រៀន តាមកម្មវិធីនេះជាបន្តទៅទៀតបាន ខ្ញុំត្រូវឆ្លងកាត់ការប្រឡងជារៀងរាល់ឆ្នាំនិងត្រួតពិនិត្យបច្ចេកទេសបង្រៀនភាសាបារាំងដោយម៉ត់ចត់បំផុតពីសាស្ត្រាចារ្យជំនាញរបស់ បារាំង ថែមទៀត។ ជាភ័ព្វសំណាងល្អ រួមផ្សំជាមួយនឹងការខិតខំដោយខ្លួនឯងផងនោះ ខ្ញុំបានប្រឡងជាប់ជារៀងរាល់ឆ្នាំ។ មានឆ្នាំមួយនោះ ខ្ញុំនៅចាំបានថា ខ្ញុំត្រូវទទួលបានចំណាត់ថ្នាក់លេខ៣ ជាហេតុធ្វើឱ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងក្នុងចំណោមសាស្ត្រាចារ្យបង្ហាត់ភាសាបារាំងដូចគ្នា។ ដោយសារជោគលាភដូច្នេះ បានជាខ្ញុំទទួលការអនុញ្ញាតជាចំហពីអ្នកទទួលខុសត្រូវបារាំងឱ្យខ្ញុំទៅបង្រៀននិ-ស្សិតនៅម៉ោងណាក៏បានបើទំនេរពីការងារ។ ប៉ុន្តែជាចៃដន្យមិនអំណោយផល ខ្ញុំត្រូវបង្ខំចិត្តផ្អាកសកម្មភាពបង្រៀនភាសាបារាំងត្រឹមឆ្នាំ១៩៩៨ ដោយសារតែខ្ញុំទទួលបានអាហារូបករណ៍ឱ្យទៅសិក្សាអំពីការរៀបចំកម្មវិធីផ្នែកអេកូទេសចរណ៍ពីសាកលវិទ្យាល័យស៊្រីណាខារីវីរតន៍ប្រទេសថៃ។ គឺនៅពេលនោះហើយ ដែលខ្ញុំត្រូវចាប់ផ្តើមប្រើប្រាស់ភាសាមួយថ្មីទៀតគឺ ភាសាអង់គ្លេសឡើងវិញជាលើកដំបូងបន្ទាប់ពីខំបំភ្លេចភាសានេះចោលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ព្រោះតែខ្លាចបាត់បង់ជីវិតដោយសារការចេះភាសាដើម្បីប្រាស្រ័យទាក់ទងជាមួយសាស្ត្រាចារ្យក្នុងការរៀនមុខវិជ្ជា សរសេរកម្មវិធីសិក្សា និងជជែកពិភាក្សា ការពារគម្រោងកម្មវិធីដោយផ្ទាល់ជា មួយសាស្ត្រាចារ្យជាគណៈមេប្រយោគ។ ពេលចាប់ផ្តើមដំបូង ខ្ញុំមានការលំបាកខ្លាំងដោយអានឬនិយាយទៅចេញតែសូរស័ព្ទ បារាំង ប៉ុន្តែដល់យូរបន្តិចទៅខ្ញុំហាក់ដូចជាស៊ាំឡើងវិញជាមួយនឹងភាសាថ្មីនេះ។ ខ្ញុំសូមត្រឡប់បកក្រោយបន្តិចដោយខ្ញុំភ្លេចជម្រាបជូនពីឆ្នាំគួរឱ្យចាប់អារម្មណ៍មួយទៀតដែលខ្ញុំបានឆ្លងកាត់។ នៅឆ្នាំ១៩៩៥ (រយៈពេលពេញមួយឆ្នាំ)ដោយ"**ធ្វើការផងរៀនផង**" ខ្ញុំត្រូវទទួលបាននូវការបណ្តុះបណ្តាលជាមួយនឹងសាស្ត្រាចារ្យដទៃទៀត លើមុខវិជ្ជាសង្គមវិជ្ជា នរវិទ្យាឧបត្ថម្ភដោយអង្គការ "**មនុស្សលោកថ្មី**"(New Hum-anity) មកពីប្រទេសអ៊ីតាលី។ មុខវិជ្ជានេះ ជាមុខវិជ្ជាថ្មីមួយនៅកម្ពុជាបន្ទាប់ពីស្រុកយើងផ្លាស់ប្តូររបបនយោបាយ។ ក្រោយពីបានបញ្ចប់ការរៀនសូត្របានមួយរយៈនៅឆ្នាំ១៩-៩៦ ខ្ញុំទទួលបានអាហារូបករណ៍ឱ្យទៅបំពេញបេសកកម្មសិក្សានៅខេត្តឈៀងម៉ៃ ប្រទេសថៃចំនួនមួយខែលើប្រធានបទស្តីពីសង្គមវិជ្ជា នរវិទ្យា ដោយហ្វឹកហាត់នៅលើទីលានផ្ទាល់ឧបត្ថម្ភដោយវិទ្យាស្ថានសង្គមវិជ្ជាក្រុងឈៀងម៉ៃ។ គឺចាប់ពីពេលនោះមកហើយដែលខ្ញុំត្រូវបានចាត់ឱ្យទៅបង្រៀននិស្សិតសង្គមវិជ្ជា នរវិទ្យាឆ្នាំទី២ ជារៀងរាល់ឆ្នាំក្នុងមួយសប្តាហ៍បីម៉ោងរហូតដល់ឆ្នាំ២០០០។ ខ្ញុំមានការសប្បាយចិត្តចំពោះចំណាត់តាំងថ្មីនេះ ពីព្រោះខ្ញុំបានចុះស្វែងយល់ដោយផ្ទាល់ក្នុងនាមខ្ញុំជាគណៈគ្រប់គ្រងមណ្ឌល២ទៅលើស្ថានភាពជាក់ស្តែងរបស់និស្សិតទាំងវិស័យចំណេះដឹងក៏ដូចជាទស្សនៈនយោបាយពីព្រោះស្រុកទេសយើងពេលនោះ កំពុងជួបការលំបាកខ្លាំងលើផ្នែកទាំងនេះហើយបើនិយាយពីនយោបាយវិញ នៅទីនេះទៀតសោតក៏ជាមុខសញ្ញានៃការប៉ុនប៉ងធ្វើឱ្យរំដើបរំជួលជ្រួលច្របល់ម្តងម្កាលពីរឿងបាតុកម្មបង្កឡើងដោយជនឱកាសនិយមឆ្លៀតញុះញង់និស្សិត។

ដោយសារតែស្ថានភាពប្រែប្រួលរបស់ស្រុកទេស ដើម្បីទុកជាមេរៀនសម្រាប់ជីវិតឥតមានលទ្ធភាព ត្រៀមបម្រុងទុកទើបខ្ញុំនៅតែចងចាំជាប់ជានិច្ចនូវពាក្យចំអកឡកឡឺយឱ្យខ្ញុំពីសំណាក់បញ្ញវន្តដូចគ្នានោះថា "**កុំអាងសញ្ញាឃើញតែគ្មានសញ្ញាប័ត្រ**"។ តាមពិតទៅពាក្យនេះមិនជាត្រឹមត្រូវទៅតាមការពិតដែលខ្ញុំធ្លាប់បាន ពុះពារឆ្លងកាត់នោះប៉ុន្មានទេ ប៉ុន្តែវាហាក់ដូចជាបានដាស់តឿនខ្ញុំឱ្យខិតខំប្រឹងប្រែងម្តងទៀតដើម្បីសម្រេចបាននូវសញ្ញា

បត្របន្ថែមក្នុងកាលៈទេសៈថ្មីនេះ ហើយជម្រះបាននូវពាក្យចំអកឡកឡឺយនោះឱ្យចប់ត្រឹមប៉ុណ្ណេះ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយស្រុកទេសយើងសព្វថ្ងៃបានផ្តល់នូវតម្លៃយ៉ាងត្រឹមត្រូវបំផុតចំពោះបុគ្គលម្នាក់ៗដោយចេះ គួបផ្សំទាំងសញ្ញាប័ត្រទាំងបទពិសោធន៍ដើម្បីរួមសាមគ្គីគ្នាទាំងវ័យចាស់ទាំងវ័យក្មេងឈានទៅកសាងសង្គមជាតិប្រកបដោយសុខសន្តិភាពនិងវឌ្ឍនភាព។ (នៅមានត)

# គំនិតបង្រួបបង្រួមខ្មែរ

## KHMER UNIFICATION IDEAS

*ដោយៈ បណ្ឌិត* **ក្ដាន់ ធុល**
មន្ត្រីស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា
Email: kdann_thoul@yahoo.com

## ១- សេចក្ដីផ្ដើម

*មិនថាមនុស្ស សត្វ វត្ថុ រុក្ខជាតិ ប្រទេស ... ទោះមានជីវិតក្ដី មិនមានជីវិតក្ដី សុទ្ធតែមានអត្ថិភាពដោយការឯកភាពគ្នានៅក្នុងនោះ។ បើមនុស្ស សត្វ វត្ថុ រុក្ខជាតិមានអត្ថិភាពដោយការឯកភាពរវាងលោកធាតុ៤ឬក្ខន្ធ៥ នេះបើតាមទស្សនៈរបស់ព្រះពុទ្ធ។ បើគ្រួសារ សង្គម ស្ថាប័នមានអត្ថិភាពដោយការឯកភាពរវាងអ្នកដឹកនាំគ្រួសារ និងសមាជិកគ្រួសារ រវាងអ្នកដឹកនាំសង្គមនិងសមាជិកសង្គម និងរវាងប្រធានស្ថាប័ននិងសមាជិក។*

*នៅក្នុងការបង្កើតរាជវង្សខ្មែរដំបូងផ្ដើមឡើងដោយការពើបប្រទះគ្នាជាចម្បាំងរវាងហ៊ុន ទៀន ដែល មកពីប្រទេសឥណ្ឌា និងនាងលីវយី ដែលជារាជិនីនៃរដ្ឋហ្វូណន។ ក្រោយពីច្បាំងគ្នាអស់ពេលដ៏យូរមក នាង លីវយី ត្រូវចាញ់ដៃការប្រយុទ្ធជាមួយហ៊ុនទៀន ដោយហ៊ុនទៀន បាញ់ទម្លាយសំពៅនាងពីម្ខាងទៅម្ខាងនាងមានការភិតភ័យជាខ្លាំងក៏សុំចុះចាញ់ហ៊ុនទៀន ក៏យកនាងធ្វើជាមហេសី រួចមកក៏នៅគ្រប់គ្រងរដ្ឋហ្វូណនជាតំណតទៅកូនចៅរៀងមក។ ប៉ុន្តែក្រោយមកអាណាចក្រហ្វូណននេះត្រូវបានបញ្ចប់ ដោយការវាយយករបស់អាណាចក្រចេនឡា។ អាណាចក្រចេនឡាត្រូវចុះខ្សោយអំណាចកណ្ដាលដោយសារតែអ្នកដឹកនាំជាស្ត្រី ដែលជាបុព្វហេតុនៃការបែងចែកចេនឡាធំទៅជាពីរចំណែក គឺចេនឡាលិចទឹកនិងចេនឡាដីគោក។ ក្រោយមកអាណាចក្រចេនឡាទាំងពីរនេះត្រូវបានបង្រួបបង្រួមឱ្យមានការឯកភាពគ្នាមកវិញ ក្រោមព្រះរាជតម្រិះរបស់ព្រះបាទជយវរ្ម័នទី២ គឺ*

ព្រះរាជតម្រិះរបស់ព្រះអង្គនេះហើយ ដែលនាំឱ្យសម័យមហានគរចាប់ផ្តើមឡើង។ តាមដំណើររឿងប្រវត្តិសាស្ត្រនេះ ប្រទេសខ្មែរត្រូវប្រព្រឹត្តទៅតាមដំណើរ ជម្លោះ-បង្រួបបង្រួម-ឯកភាព បំបែក បង្រួបបង្រួម ឯកភាព។ នៅក្នុងដំណើរនេះយើងសង្កេតឃើញមានបញ្ញត្តិសំខាន់ពីរ គឺជម្លោះ (confliction) និងបង្រួបបង្រួម (unification) ដែលចោទជាបញ្ហានៅក្នុងប្រធានបទនេះ ហើយដែលយើងត្រូវធ្វើការឈ្វេងយល់។ តើបញ្ញត្តិជម្លោះ និង ការបង្រួបបង្រួមគឺជាអ្វី? តើកត្តាអ្វីខ្លះដែលនាំឱ្យមានជម្លោះ និងការបង្រួបបង្រួម? តើជម្លោះនិងការបង្រួបបង្រួម មានសារៈប្រយោជន៍អ្វី?

## ២- កំណត់ន័យបញ្ញត្តិ "ជម្លោះ" និង "ការបង្រួបបង្រួម"

ជម្លោះនិងការបង្រួបបង្រួមគឺជាបញ្ញត្តិពីរដែលជាគូបដិបក្ខនឹងគ្នានិងមានទំនាក់ទំនងជាមួយគ្នា។ ជម្លោះមានសទិសន័យជាមួយនឹងបញ្ញត្តិមួយចំនួនដូចជា សង្គ្រាម ការតស៊ូ ទំនាស់ ការប្រយុទ្ធ ការប្រឆាំងកំហឹង បំបែក រំលាយ...។ ជម្លោះ គឺជាទំនាស់ ឬការតស៊ូរវាងអង្គបក្ខ ដិបក្ខពីរឬច្រើន។ ជម្លោះ មានពីរប្រភេទគឺ ជម្លោះរវាងវត្ថុមួយឬច្រើនជាមួយគ្នា គេហៅថា ជម្លោះក្រៅ និង ជម្លោះរវាងអង្គបដិបក្ខពីរឬច្រើននៅក្នុងអង្គវត្ថុតែមួយគេឱ្យឈ្មោះថា ជម្លោះក្នុង។ ជម្លោះ បើកាលណាមានទំហំធំឬមានកម្លាំងខ្លាំងជាងការ ឯកភាពនោះអង្គវត្ថុនឹងត្រូវបំបែកចេញពីគ្នាឬផ្លាស់ប្តូរយ៉ាងចាំបាច់ទៅជាអង្គវត្ថុថ្មីមួយ។ អង្គវត្ថុថ្មីមានន័យពីរយ៉ាង គឺអង្គវត្ថុថ្មីក្នុងន័យវិជ្ជមាន(ចម្រើនលូតលាស់)ករណីដូចជា អារីស្តូត (Aristotle) មិនឯកភាពនឹងគំនិតមនោនិយមរបស់ប្លាតុង (Plato) នាំឱ្យ គំនិតរូបធាតុនិយម របស់លោកចាប់បដិសន្ធិឡើង និង អង្គវត្ថុថ្មីក្នុងន័យអវិជ្ជមាន(វិនាស)ករណីដូចជា ជម្លោះរវាងស្តេចកនជាមួយនឹង ស្រីសុគន្ធបទ។ ចំពោះបញ្ញត្តិដែលជាគូបដិបក្ខគឺបញ្ញត្តិ "ការបង្រួបបង្រួម (unification)"។ បញ្ញត្តិនេះ មានសទិសន័យជាមួយនឹងបញ្ញត្តិដទៃជាច្រើនទៀត ដូចជា ការឯកភាពគ្នា (consensus) ការសំយោគ (synthesis) ការរួបរួមគ្នា (unity) ការសាមគ្គីគ្នា (solidarity) ការសហការគ្នា (collabo-ration) ការព្រមព្រៀងគ្នា (agreement) ការស្រុះស្រួលគ្នា (reconciliation) ស្នេហា (love)...។ ការឯកភាពគ្នា (consensus) (ន័យទី១) គឺជាមតិយោបល់

ឬការសម្រេចចិត្តដែលគេទទួលយកជាទូទៅ
នៅក្នុងចំណោមក្រុមមនុស្ស

[១]ឬក៏យើងអាចនិយាយបានម្យ៉ាងទៀត ថាជាកិច្ចព្រមព្រៀងទូទៅអំពីបញ្ហាអ្វីមួយនៅក្នុងក្រុមមួយ ឬនៅក្នុងមតិសាធារណៈ។ បើប្រៀបធៀប ស័ព្ទនេះផ្ទុយទៅនឹងស័ព្ទ ការខ្វែងគំនិតគ្នា (dissent-tsus)។ ការឯកភាពគ្នា (ន័យទី២) គឺជាគំនិត បទដ្ឋាននិងតម្លៃចែករំលែកនៅក្នុងសង្គម (ចំពោះអ្នកមុខងារនិយម (functionalists) ពិសេសចំពោះបព្វជិតឬអ្នកបួស(Parsons) វាជាមូលដ្ឋាននៃសណ្ដាប់ធ្នាប់សង្គម និងសមាហរណកម្មសង្គម)។ តម្លៃទាំងនេះត្រូវបានគេបន្តជានិរន្តតាមរយៈសង្គមនិយកម្ម(socializa-tion)។ ការឯកភាពគ្នា (ន័យទី៣) តាមទ្រឹស្ដី របស់ម៉ាក្ស គឺជាបញ្ញត្តិមនោគមវិជ្ជាមួយ ដែលគេប្រើដើម្បីធ្វើឱ្យស្ថានភាពនៃកិច្ចការអត្ថិភាព ជាពិសេសចំពោះបញ្ហាសង្គមឬ នយោបាយ (the status quo) ដោយការ លាក់បាំង វិសាលភាពនៃជម្លោះសង្គម[២]។

ចំពោះស័ព្ទ ការសំយោគគ្នា (synthesis) គឺជាលទ្ធភាពក្នុងការដាក់វត្ថុបញ្ចូលគ្នាដើម្បីបង្កើតជារបស់ថ្មីមួយ ដូចជា អភិវឌ្ឍន៍គំនិតថ្មីៗចេញពីគំនិតអត្ថិ ភាព (existing ideas) ឬជាការផ្សំធាតុផ្សេងៗចូលគ្នា ដើម្បីបង្កើតជាផលិតផលស្មុគស្មាញថ្មីមួយ[៣]។ ចំពោះស័ព្ទការរួបរួមគ្នា (unity) គឺជាសភាពនៃការភ្ជាប់គ្នាឬជាកិច្ចព្រមព្រៀងគ្នា[៤]។ ចំណែកស័ព្ទ ការសាមគ្គីគ្នា (solidarity) គឺជាកិច្ចព្រមព្រៀងរវាងគ្នា និង ជាការគាំទ្រសម្រាប់សមា ជិកក្រុម ជាពិសេសក្រុមនយោបាយ[៥]។ ឯស័ព្ទការ សហការគ្នា (collaboration) គឺជាសកម្ម ភាពរបស់មនុស្សពីរ ឬច្រើននាក់ធ្វើការរួមគ្នាដើម្បីបង្កើត

---

[១] Cambridge Advanced Learner's Dictionary, 3rd Ed. Cambridge University Press, 2008

[២] Daniel Chandler and Rod Munday, Oxford Dictionary of Media and Communication (3 ed.), 2020, p. consensus

[៣] Simon Blackburn, The Oxford Dictionary of Philosophy, (2 rev. Ed.), Oxford University Press 2008, p. synthesis

[៤] Cambridge Advanced Learner's Dictionary, op.cit, p. unity

[៥] Ibit, p. solidarity

ឬសម្រេច ទៅលើកិច្ចការតែមួយ[៦]។ ចំពោះស័ព្ទ កិច្ចព្រមព្រៀងគ្នា (agr-eement) គឺជាការមានគំនិតដូចគ្នា ឬជាការយល់ព្រមឬការទទួលយកអ្វីមួយរួមគ្នា[៧]។ ចំពោះស័ព្ទការស្រុះស្រួលគ្នា (recon-ciliation) គឺជាការត្រូវរ៉ូវ គ្នារវាងមនុស្សពីរនាក់ ឬក្រុមមនុស្សបន្ទាប់ពីពួកគេឈ្លោះគ្នាឬអាចនិយាយ ម្យ៉ាងទៀតថា ជាដំណើរនៃការធ្វើឱ្យជំនឿគំនិត ឬស្ថានភាពផ្ទុយគ្នាឱ្យចុះសម្រុងគ្នាវិ[៨]។ បញ្ញត្តិទាំងឡាយដូចបានរៀបរាប់ខាងលើនេះ មានន័យរួមគឺការឯកភាពរវាងអង្គវត្ថុឬការឯកភាព នៃអង្គវត្ថុដើម្បីឱ្យពួកវាអាចមានអត្ថិភាពនៅក្នុងលំហ (space) និង កាល(time)បាន។ ពួកវាទាំងនេះមានអត្ថន័យសំខាន់សម្រាប់អត្ថិភាពរបស់វត្ថុ សត្វ រុក្ខជាតិ គ្រួសារ សង្គម...។ ការបង្រួបបង្រួមគឺជាការធ្វើឱ្យអង្គឯកភាពមួយឬច្រើនមានការឯកភាពគ្នាដើម្បីមានអត្ថិភាព និងបន្តអត្ថិភាពរបស់វានៅក្នុងលំហ (space) និងកាល (time) បានតទៅទៀត។

## ៣- ទ្រឹស្តីជម្លោះនិងបង្រួបបង្រួម

### ៣-១-១- ទ្រឹស្តីចក្រវាឡរបស់អំពេដូក (Empedocles)

អំពេដូក គជា ទស្សនវិទូក្រិកមុនសូក្រាត (Greek pre-Socratic philosopher) និងជា ពលរដ្ឋដើមកំណើត អាក្រាហ្គេស (Akragas) ជាទីក្រុងក្រិកមួយនៅ ស៊ីស៊ីលី (Sicily)។ នៅក្នុងវិស័យទស្សនវិជ្ជា លោកយល់ថា លួងរូបធាតុ មាន៤យ៉ាងគឺ ទឹក ដី ភ្លើង និង ខ្យល់។ លោកយល់ថា ប្រភពរូបធាតុទាំង៤មាន អត្ថិភាពអមតៈ វាឥតត្រូវគេបង្កើតឡើង ឥតគេកំទេចចោល។ បើសិនជាវាវិនាសទៅ ចក្រវាឡក៏មិនអាចមានដែរ។ បើសិនជាវាស្លាប់ទៅ គឺពិតជាគ្មានលំហទេ។ ចំពោះ ការកើត និង ការស្លាប់នៃរាល់ទម្រង់រូបធាតុជាក់ស្តែង លោកដោះស្រាយដូចខាងក្រោមៈ

ដំណើរកើតនិងស្លាប់មាន២យ៉ាងគឺ ការច្របល់និងការបំបែកនៃម៉ូលេគុល។ ក្នុងពិភពធម្មជាតិ គ្មានអ្វីដែលកើតនិងគ្មានអ្វីដែលបាត់ទៅវិញទេ។ ពាក្យថា កកើត ឬ ស្លាប់ គឺ គ្រាន់តែ ជាការច្របល់ឬការបំបែកតាមកម្រិតផ្សេងៗនៃម៉ូលេគុលដែលរួមផ្សំ

[៦] Ibit, p. collaboration

[៧] Ibit, p. agreement

[៨] Ibit, p. reconciliation

ទម្រង់រូបធាតុដី ទឹក ភ្លើង ខ្យល់ តែប៉ុណ្ណោះ ។ វត្ថុបានចាប់ កំណើតពីបន្សំរូបធាតុដើម និង ស្លាប់ទៅវិញតាមការរំលាយធាតុដើម។ លោក យល់ថា ចលនា ស្តែងឡើងក្នុងដំណើរច្របល់ និង បំបែកនៃល្អងរូបធាតុ៤យ៉ាង។ ចលនា ចាប់ប្រភពពីកម្លាំងជះឥទ្ធិពលខាងក្រៅ។ ចលនា ស្តែងឡើងក្រោមការជះឥទ្ធិពលនៃ កម្លាំងបដិបក្ខពីរគឺ ស្នេហា និងកំហឹង។ កម្លាំង ទាំង២នេះធ្វើអន្តរកម្មតាមដំណើរផ្ទុយគ្នា ស្នេហាធ្វើឱ្យធាតុដើមរួមចូលគ្នា កំហឹងធ្វើឱ្យ ធាតុដើមរលាយចេញពីគ្នា។ ស្នេហាជាបន្សំ កត្តាផ្សេងៗ ក្លាយទៅជាការច្របល់មួយដើម្បី ឱ្យកត្តាជា ច្រើនរួមផ្សំគ្នាជាវត្ថុ។ កំហឹងជាការ រំលាយកត្តាផ្សេងៗធ្វើឱ្យកត្តាទាំងនោះដាច់ ចេញពីគ្នា ដើម្បីធ្វើឱ្យវត្ថុមួយ ក្លាយទៅជា កត្តាជាច្រើន។ ការយល់ថា ចលនាកើតឡើង ដោយសារការជះឥទ្ធិពលពីខាងក្រៅរបស់ លោក លោកបានពន្យល់ ពីកាចាប់ប្រភព របស់ចក្រវាឡតាមបែបបញ្ចោតដូចខាង ក្រោម៖

ចក្រវាឡ បានចាប់កំណើតដោយឆ្លង ៤ដំណាក់កាល៖

- រយៈពេលទីមួយ គឺជារយៈពេលស្នេហា។ រយៈពេលនេះកត្តាដើមបានរួមផ្សំយ៉ាងល្អ បំផុត។ ស្នេហា មាននាទីគ្រប់គ្រងចក្រវាឡ ទាំងស្រុង។ ចក្រវាឡត្រូវបានកើតឡើង។ វាជា វង់មូលអចល័ត។ គ្មានការបែង ចែកវង់មូល នេះបានឡើយ។ ក្នុងពេលនេះ កំហឹង ស្ថិត នៅឆ្ងាយពីចក្រវាឡដោយហុំព័ទ្ធចក្រវាឡ នោះ។
- រយៈពេលទី២ គឺជារយៈពេល កំហឹង។ កំហឹងជ្រៀតចូលក្នុង ស្នេហា។ ស្នេហា មិន អាចគ្រប់គ្រង បាន[៩]ទៀតឡើយ។ កត្តនានា បានដាច់ចេញពីគ្នា។ វត្ថុផ្សេងៗក៏បានកើត ឡើងដែរ។
- រយៈពេលទី៣ គឺជារយៈពេលដែលកត្តា ទាំងឡាយផ្តាច់ចេញផុតពីគ្នា។រយៈពេលនេះ កំហឹង មាននាទីគ្រប់គ្រងចក្រវាឡទាំងស្រុង

---

[៩] ធយ យីហ៊ាង "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស ប្រវត្តិ ទស្សនវិជ្ជាបូរាណសម័យក្រិក"សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ១៩៩៤ ទំព័រ៣០។

ស្នេហា ត្រូវឃ្លាតឆ្ងាយពីមជ្ឈមណ្ឌល ហើយស្ថិត នៅក្រៅចក្រវាឡ។

- រយៈពេលទី៤ គឺជារយៈពេលដែល ស្នេហាវិលត្រឡប់មកគ្រប់គ្រងវិញ។ រីឯកំហឹងបែរជាថយក្រោយចេញពីចក្រវាឡម្តងទៀត[១០]។

ហេតុនេះ បើតាម អំពេដូក ចក្រវាឡចាប់កំណើតឡើងដោយឆ្លងកាត់ដំណើរផ្លាស់ប្តូរ ជំនួស រវាង ស្នេហានិងកំហឹង។ នោះជាដំណើរច្របល់ បំបែក បំបែកច្របល់ ដោយកម្រិតផ្សេងៗនៃធាតុ ទឹក ដី ភ្លើង ខ្យល់។ ដំណើរនេះស្តែងឡើងជានិច្ចនិរន្តតាមខួបដូចបានរៀប រាប់ខាងលើ។

## ៣-១-២- ទ្រឹស្តីបដិសំយោគរបស់ម៉ាក្សនិងហេហ្គែល

ទ្រស្តីបដិសំយោគ (dialectic) ត្រូវបានគេស្គាល់ជាទូទៅថា ជាដំណើរឈានទៅដល់ពុទ្ធិ តាមរយៈ បច្ចេកទេសសំណួរ-ចម្លើយ (question-and-answer technique)។ ហេហ្គែល (Hegel) បានពិពណ៌នា វិធីនេះថាជទម្រង់ការមួយដែលគំនិត (thought) ឬ វត្ថុអត្ថិមួយ (existing thing) ដែលគេហៅថា ទស្សនកថា (thesis) ដឹកនាំនិងផ្លាស់ប្តូរយ៉ាងចាំបាច់ទៅរកគំនិតផ្ទុយ (contradictory idea) ដែលគេហៅថា ប្រតិទស្សនកថា (antithesis) ដោយហេតុនេះហើយទើប គំនិត ឬ វត្ថុថ្មី (new thought or thing) ដែលគេហៅថា សំយោគទស្សនកថា (synthesis) បានកើតឡើង។ ដំណើរនេះចាប់ផ្តើមឡើងតាមអំណះអំណាង មួយអំពីអ្វីមួយ (ទស្សនកថា) ដែលមានលក្ខណៈ មិនពេញលេញ (incomplete)។ អ្វីមួយដែលទាក់ទងទៅនឹងអំណះអំណាងនោះ ត្រូវបានគេលុបចោល (ប្រតិទស្សនកថា)។ អង្គបដិបក្ខ (conflict) ដែលគេ ហៅថាជា បដិសំយោគ (dialectic) រវាងអ្វីដែលគេបានអះអាង ហើយនិងអ្វីដែលគេបានលុបចោលនោះ មានអត្ថិភាព។ ដោយសារ អង្គបដិបក្ខ នេះហើយទើបលេចឡើងនូវ សំណើទី៣ថែមមួយទៀត នោះគឺ សំយោគទស្សនកថា (synthesis) ដែលលប់ព្រំដែនទស្សនកថា(the limitation of the thesis)

---

[១០] -ដ- ៣១

និង ប្រតិទស្សនកថា (the antithesis) ហោល ប៉ុន្តែវានៅតែថែរក្សាតម្លៃឱ្យគ្នាដដែល[១១]។

ម៉ាក្ស (Marx) និង ហេហ្គែល បានប្រើទ្រឹស្តីបដិសំយោគ (Dialectic) នេះដើម្បីវិភាគទៅលើ អភិវឌ្ឍន៍សង្គមកុំម្មុយនីស្តរបស់ពួកលោក។ លោកទាំងពីរបានបង្កើតទ្រឹស្តីថា អង្គបដិបក្ខ (conflict) កើតមានឡើងដោយសារមានវណ្ណៈសង្គមពីរ (two social classes) គឺ ពួកមូលធន (ទស្សនកថា) និង កម្មករ ស៊ីប្រាក់ឈ្នួល (ប្រតិទស្សនកថា)។ ការតស៊ូវណ្ណៈស្ថិតរមួត (បដិសំយោគ) មានអត្ថិភាពរវាងវណ្ណៈទាំងពីរ។ ចំណុចមួយដែលពួកគេនឹងឈានទៅដល់នោះ គឺចំនួនពួកកម្មករដែលមានកម្លាំងគ្រប់គ្រាន់អាចគ្របសង្កត់ទៅលើពួកមូលធននិយមបាន។ ការតស៊ូ នេះនឹងដឹកនាំឆ្ពោះទៅរកការបង្កើតសង្គមមួយថ្មី គឺ សង្គមកុម្មុយនីស្ត (communistic) ឬសង្គម គ្មានវណ្ណៈ (classless society) [សំយោគទស្សនកថា (syn-thesis)] [១២]។

## ៤- គំនិតបង្រួបបង្រួមរបស់បុព្វបុរសខ្មែរ

ភាពកំសោយអំណាចកណ្តាលដែលស្ថិតនៅក្នុងកណ្តាប់ដៃមេដឹកនាំដែលជាស្ត្រីបានធ្វើឱ្យចេនឡា ធំត្រូវបានពុះចែកជាពីរ។ នេះគឺបណ្តាលមកពីនយោបាយខ្មែរនៅពេលនោះគ្មានស្ថេរភាព ព្រោះតែមានការបែកបាក់ផ្ទៃក្នុងយ៉ាងធំណំ ដែលជាហេតុនាំឱ្យប្រទេសទាំងមូលត្រូវធ្លាក់ចូលទៅក្រោមអំណាចត្រួតត្រារបស់ជ្វា។ តែក្រោយមក ប្រទេសជាតិត្រូវបានបង្រួបបង្រួមឱ្យមាន ការឯកភាពគ្នាមកវិញ ហើយបានកសាងសម័យអង្គរ ឱ្យសម្បូររុងរឿងក្លាយជា មហានគរ បាន គេសង្កេតឃើញបុព្វបុរសយើង ករណីដូចជា ព្រះបាទជយវរ្ម័នទី២ ជាដើម ឈរលើមូលដ្ឋាន គំនិតសំខាន់ៗដូចខាងក្រោមៈ

### ៤-១- ការកសាងជំនឿដើម្បីបង្កើតទំនុកចិត្ត

មុននឹងឡើងសោយរាជ្យនៅព.ស១៣៤៥ (គ.ស៨០២) ព្រះបាទ ជយវរ្ម័នទី២ ត្រូវធ្វើការ

---

[១១] Venancio B. Ardales, "An Introductory Text to Philosophy", Philipine, 1987, p. 30

[១២] Venancio B. Ardales, p 31

បង្រួប បង្រួមទឹកដីឱ្យបានមួយភាគសិន ដោយហេតុនេះហើយបានជាព្រះអង្គត្រូវផ្លាស់ប្តូររាជធានីញឹកញាប់ តែជាចុងក្រោយព្រះអង្គបានយាងទៅគង់នៅលើ ភ្នំគូលែន (មហេន្ទ្រប័ត) ដើម្បីរៀបចំប្រារព្ធធ្វើពិធីទេវរាជ។ តើការរៀបចំប្រារព្ធធ្វើ ពិធីទេវរាជរបស់ព្រះបាទជ័យវរ្ម័នទី២ក្នុងគោលបំណងអ្វី? លទ្ធិទេវរាជ "Devarāja/devaraja" ជាភាសាសំស្ក្រឹត ឬ "God King (ទេវរាជ/ស្តេចជាអាទិទេព)" ជាអង់គ្លេស គឺសំដៅលើកតម្កើង ឬអភិសេក ព្រះរាជា (ជយវរ្ម័នទី២) ឱ្យមានឋានៈជា ទេវរាជ (ស្តេចជាអាទិទេព) ដែលពាក្យខ្មែរបុរាណហៅថា កម្រង់តេង៍ជគតរាជ្យ (ស្តេចជាម្ចាស់នៃចក្រវាឡ)[១៣] ហើយដែលបញ្ញត្តិឥណ្ឌាហៅថា "ចក្រវ៉ាទីន (Chakrava-rtin (ស្តេចចក្រវាឡ)"។ នៅក្នុងទេវឋានហិណ្ឌូព្រះនាមស្តេច នៃពពួកទេវ្តាតែងតែត្រូវបានកំណត់យកចំពោះ ព្រះសិវៈ (Shiva) ឬ ព្រះវិស្ណុ (Vishnu)។ ហេតុនេះ អាណាចក្រមនុស្សនៅលើផែនដីនេះ ធ្វុះបញ្ចាំងពីអាណាចក្រសួគ៌នៃពពួកទេវ្តា ជាបញ្ញត្តិសំដៅទៅលើស្តេច ដែលជា អាទិទេពមានជីវិត នៅលើផែនដី។ នៅក្នុងវិស័យ នយោបាយ លទ្ធិទេវរាជ ត្រូវបានគេមើលឃើញ ថាជា យុត្តិកម្មអាទិទេព (the divine justification) អំពីការគ្រប់គ្រងរបស់ព្រះរាជា។ លទ្ធិទេវរាជត្រូវបានព្រះបាទជ័យវរ្ម័នទី២ ប្រារព្ធធ្វើនៅលើភ្នំគូលែនក្នុងគោលបំណងដូច ខាងក្រោមៈ

បំណងទី១ ៖ ដើម្បីអភិសេកព្រះរាជាឱ្យមានឋានៈជាអាទិទេព។ តាមយោបល់លោក ហ្ស. សឺដែស (G. Coedés) ទាក់ទងទៅនឹងរឿងពិធីទេវរាជនេះ លោកបានរំលឹកទៅដល់រឿងដែលឈ្មួញអារ៉ាប់ឈ្មោះ សូឡៃម៉ាន់ បាននិទានដោយមានបញ្ជាក់ពីការដែល ជ្វា មកលុកលុយប្រទេស ចេនឡា ដោយចាប់បានព្រះ រាជាខ្មែរ ហើយកាត់ ព្រះសិរ ផងនោះ ហើយដើម្បីឱ្យប្រទេសនេះរួចផុតពី អំណាចជ្វា វិញ។ គេអាចសន្និដ្ឋាន ថា ក្នុងពិធីលើភ្នំគូលែននោះ ប្រហែលជាមានធ្វើឧបកិច្ចផ្តាច់ព្រះសិរបដិមា ជាតំណាង ស្តេចជ្វាវង្សសៃលេន្ទ្រ ស្របតាមគម្ពីរ សិរច្ឆេទ (កាត់ ក្បាល)

---

[១៣] ត្រឹង ង៉ា«ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)» ភ្នំពេញ គ.ស.១៩៧៣/ព.ស.២៥១៧ ទំព័រ ៧៨។

ជាមិនខាន។ ក្នុងពេលជាមួយគ្នានេះ គេ អភិសេក សិវលិង្គ ដែលគេសន្មត់ថាបានមកពី ព្រះឥសូរ តាមរយៈ ព្រាហ្មណ៍។ ធ្វើដូច្នេះ គេ អាចចាត់ទុកថា អាត្ម័នពិសិដ្ឋ របស់ព្រះរាជា បានទៅសណ្ឋិតនៅក្នុង សិវលិង្គ នោះ ដែល បានក្លាយជាតំណាង ឬ និមិត្តរូបនៃទេវរាជ។ បើ និយាយ ឱ្យងាយយល់គឺថា ក្រោយពីធ្វើ ពិធីអភិសេក នេះហើយ ព្រះរាជា ក៏ក្លាយទៅ ជា ព្រះឥសូរបែង ភាគ (មិនមែនគ្រាន់តែជា តំណាងទេ) ដែលមាន អំណាច គ្រប់គ្រងទៅ លើ សព្វសត្វ។ ចាប់ពីពេលនោះទៅ បញ្ហា របស់ ព្រះរាជា ក៏ជាបញ្ហារបស់ អាទិទេព នេះ ឯង[១៩]។ បំណងទី២ ៖ ការប្រារព្ធលទ្ធិទេវរាជ ដើម្បីបង្រួបបង្រួមឱ្យមានការឯកភាពជាតិ ដែលបានបែកបាក់ នៅសម័យចេនឡាក្រោម ការដឹកនាំរបស់ព្រះរាជា ដែលជាអាទិទេព។

បំណងទី៣ ៖ ការប្រារព្ធលទ្ធិទេវរាជដើម្បី រំដោះប្រទេសជាតិឱ្យមានឥស្សរភាព ពោលគឺ ប្រកាសឯក រាជ្យជាតិពីជ្វា។

បំណងទី៤ ៖ ការប្រារព្ធលទ្ធិទេវរាជដើម្បី បង្កើតជំនឿទុកចិត្តចំពោះប្រជារាស្ត្រ ដែលនាំ ឱ្យព្រះរាជា មានអំណាចទូលំទូលាយ

**៤-២- ការបង្រួបបង្រួមជំនឿ**

ជំនឿ បើមើលមួយភ្លែត ហាក់ដូចជា សាមញ្ញមិនគួរឱ្យចាប់អារម្មណ៍និងធ្វើការយក ចិត្តទុកដាក់ទេ តែ ព្រះព្រះរាជាដែលដឹកនាំ នៅសម័យអង្គរបានមើលឃើញពីជំនឿនិង ឥទ្ធិពលនិងសារៈ សំខាន់របស់វាមានកម្លាំង ខ្លាំងមហិមានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ជា ពិសេសនៅក្នុងនយោបាយដឹកនាំប្រទេស។ ដោយហេតុនេះហើយ បានជាគេឃើញការ បង្រួបបង្រួមជាតិ, ការឯកភាពជាតិ និង អភិវឌ្ឍន៍ជាតិ ក្រោមការដឹកនាំរបស់ព្រះរាជា ដែលជាអាទិទេព (ទេវរាជ) និងព្រះរាជាជា ព្រះពុទ្ធ (ពុទ្ធរាជ) ទទួលបានជោគជ័យនៅ ក្នុង កម្មវិធីដឹកនាំប្រទេស ដែលធ្វើឱ្យស្ថេរភាព និងការរីកចម្រើនមាននិរន្តរភាពជិត៥០០ឆ្នាំ (៨០២-១២៩៥) នៅសម័យអង្គរ។ ខាងក្រោម នេះជាកស្តុតាងបង្ហាញឱ្យឃើញនិងដឹងពី គំនិតបង្រួបបង្រួមទាំងនេះ៖

[១៩] ត្រឹង ងា, ដ.ឯ.ម.,ទំព័រ ៧៨-៧៩

ព្រះហរិហរៈ ៖ នៅក្នុងជំនឿរបស់ព្រហ្មញ្ញសាសនា អ្នកជឿជឿទៅលើអាទិទេពសំខាន់ៗបីដែលគេ ឱ្យឈ្មោះថា ត្រីមូ៌ត្តិ (trinity) គឺ គណៈព្រះព្រហ្ម គណៈព្រះសិវៈ និង គណៈព្រះវិស្ណុ។ ក្នុងចំណោមគណៈ ទាំងបីនេះ គណៈព្រះសិវៈ មានប្រជាប្រិយភាពជាងគណៈព្រះព្រហ្ម ជាពិសេស គណៈព្រះវិស្ណុ។ គណៈព្រះព្រហ្ម មិនសូវជាមានគេគោរពច្រើនទេនៅស្រុកខ្មែរ ដោយហេតុនេះហើយបានគេមិនដែលឃើញគណៈនេះមាន ការប៉ះទង្គិចគ្នាដូច គណៈព្រះសិវៈ និង គណៈព្រះវិស្ណុទេ។ ហេតុនេះ ព្រះហរិហរៈ គឺជាឈ្មោះថ្មីមួយដែលកើតឡើងមកពីការសម្របសម្រួលគ្នារវាងអាទិទេពពីរឱ្យមានការឯកភាពគ្នា គឺ ព្រះវិស្ណុ និង ព្រះសិវៈ (ព្រះ ហរិ = ព្រះវិស្ណុ; ព្រះ ហរៈ=ព្រះសិវៈ)សម្រាប់ការគោរពរួមគ្នាកុំឱ្យមានជម្លោះ។ ក្នុងការកសាង បដិមាព្រះហរិហរៈ គេត្រូវចែកជាពីរផ្នែក ៖ ពាក់កណ្ដាលខាងស្ដាំគឺជា ព្រះសិវៈ និង ពាក់កណ្ដាលខាងឆ្វេងគឺជាព្រះ វិស្ណុ។ ប្រទេសកម្ពុជាគោរព ព្រះហរិហរៈនេះតាំងពីសម័យនគរភ្នំមកម្ល៉េះ។ សិវលិង្គ ៖ ជាធម្មតា ព្រះសិវៈ ត្រូវបានគេគោរពបូជានៅក្នុងទម្រង់ជា លិង្គ ដែលឱ្យ ឈ្មោះថា សិវៈលិង្គ។ សិវៈលិង្គ(Lingam-/Linga) គឺជាអង្គជាតិរបស់ ព្រះសិវៈ ដែលមានបដិមាជាលិង្គតំណាងឱ្យព្រះអង្គ និង អំណាចបង្កើតលោករបស់ព្រះអង្គ។ លឹង្គ គេឆ្លាក់មានរាងជា៤ជ្រុងនៅគល់ មានរាង៨ជ្រុងនៅកណ្ដាល និងមានរាងមូលនៅខាងចុង។ នៅសម័យអាណាចក្រខ្មែរ លិង្គ ត្រូវបានគេសាងឡើងធ្វើជានិមិត្តរូបព្រះមហា ក្សត្រតម្កល់នៅក្នុងប្រាសាទ។ លិង្គដែលបន្សល់មកពីសម័យអង្គរ ជាទូទៅគេធ្វើពីថ្មដុស។ លិង្គ សម័យអង្គរមានប្រភេទមិនដូចគ្នាទេ លិង្គមួយចំនួនគេដាក់នៅកន្លែងផ្ទៃរាបរាងការេគេឱ្យឈ្មោះថា យោនី (yoni) ជានិមិត្តរូប នៃអវៈយវៈភេទស្ត្រី។ លិង្គមួយចំនួនគេឆ្លាក់មុខព្រះសិវៈនៅលើនោះ។ ដូចជាលិង្គដែលគេហៅថា មុខលិង្គ(mu-khalingas)។ លិង្គមួយចំនួនទៀតត្រូវបានគេចែកជាបីផ្នែក៖ ផ្នែករាងការេជានិមិត្តរូបព្រហ្ម ផ្នែកកណ្ដាលជានិមិត្តរូបព្រះវិស្ណុ, និងផ្នែកចុងរាងមូលជានិមិត្តរូបនៃព្រះសិវៈ[១៥]។

[១៥] https://en.wikipedia.org/wiki/Khmer_architecture, Linga

លិង្គ ជាគូនឹងយោនី ។ សម្ព័ន្ធភាពនៃភេទទាំងពីរនេះ គឺតំណាងឱ្យ ដំណើរអមតៈនៃការ បង្កើតលោក ហើយនិងការដុះ ដាល[១៦] ។ គំនិតបង្រួបបង្រួមរវាងគ្រុឌនិងនាគ ៖ គ្រុឌ និងនាគ គឺជាយានជំនិះរបស់ព្រះវិស្ណុ[១៧]។នៅក្នុងស្ពា ដែស្ថាបត្យកម្មខ្មែរ គេតែងតែឆ្លាក់រូបគ្រុឌជិះលើក្បាលនាគ នេះបង្ហាញឱ្យឃើញពីគំនិតបង្រួបបង្រួមរវាង សត្វនាគនិងគ្រុឌ ព្រោះថា ជាធម្មជាតិ សត្វទាំងពីរនេះមិនដូចគ្នា ហើយមានលំនៅក៏មិនដូចគ្នាដែរ។ គ្រុឌគឺជាសត្វបក្សីដែលតែងតែហោះហើរនៅលើមេឃ ហើយនិងចុះមករកចំណីនៅលើដី។ ឯនាគវិញគឺជាសត្វ ដែលមានលំនៅនិងរកចំណីនៅក្នុងទឹក ហើយតែងតែផុសមកលេងនៅលើឆ្នេរខ្សាច់។ សត្វទាំងពីរនេះមាន ចរិកកាចមិនដែលត្រូវគ្នាទេ។ នៅពេលជួបគ្នាម្តងៗពួកវាតែងតែប្រយុទ្ធគ្នាស្លាប់រស់ ដែលជាហេតុនាំឱ្យគ្រុឌ មិនអាចចុះមករកស៊ីនៅលើដីបាន ឯនាគក៏មិនអាចឡើងមកលើគោកបានដែរ។ ហេតុនេះ សត្វទាំងពីរនេះ ត្រូវប្រឈមមុខនឹងសេចក្តីស្លាប់ទាំងអស់គ្នា។ ដោយហេតុនេះ ហើយបានជាសិល្បៈករខ្មែរឆ្លាក់រូបសត្វទាំងពីរ នេះឱ្យនៅជាមួយគ្នាដោយជិះគ្នា ដែលចង់បង្ហាញប្រាប់ន័យថា ការបង្រួបបង្រួមគ្នាគឺរស់ បែកបាក់គ្នាគឺស្លាប់។ គំនិតបង្រួបបង្រួមនៅក្នុងប្រាសាទបាយ័ន ៖ ប្រាសាទ បាយ័ន ជាប្រាសាទភ្នំកសាងនៅចុងរជ្ជ កាលព្រះបាទជ័យវរ្ម័នទី៧។ នៅក្នុងប្រាសាទនេះមិនតម្កល់សិវលិង្គដូចមុនទេ ប៉ុន្តែតម្កល់ ព្រះពុទ្ធបដិមាដែលមានកំពស់ជិត៤ម។ នេះជាទេពកោសល្យរបស់ព្រះបាទ ជ័យវរ្ម័នទី៧ ក្នុងការសម្របសម្រួល អ្វីដែល ជារបស់សាសនាពីមុន (ប្រា-សាទភ្នំ) និងអ្វីដែលជារបស់សាសនាថ្មី (ពុទ្ធរាជ) ដើម្បីបំពេញចិត្តទាំងពួក ព្រាហ្មណ៍ និងប្រជារាស្ត្រ។ នៅលើជញ្ជាំងប្រាសាទនេះ ទាំងក្នុងថែវខាងក្នុងនិងខាងក្រៅ សុទ្ធតែមានចម្លាក់ និយាយពី ជីវភាពរបស់ប្រជារាស្ត្រដែលអ្នកស្រាវជ្រាវចាត់ទុកថាជា ឯកសារសំខាន់មួយសម្រាប់ឆ្លុះមើល សង្គមខ្មែរក្នុងសម័យនោះ។ នេះជាលើកទីមួយហើយដែលនៅលើជញ្ជាំងប្រាសាទមានចម្លាក់និយាយពីជីវ ភាព របស់ប្រជារាស្ត្រ។ ប្រាសាទបាយ័នមានប្រាង្គមុខ៤ សរុបទាំងអស់ចំនួន៥៤ប្រាង្គ

[១៦] Ibit., Yoni

[១៧] https://km.wikipedia.org/wiki/ព្រះវិស្ណុ

ដែលអ្នកស្រាវជ្រាវ ខ្លះយល់ថា ជារូបភាពនៃអាណាខេត្តទាំងមូលដែលគេបង្រួញ។ ប្រាង្គនិមួយៗជានិមិត្តរូបនៃខេត្តខណ្ឌមួយ។ ចំណែកឯ មុខ៤ គឺជាព្រះភក្ត្រព្រះព្រហ្ម ឬព្រហ្មមុខ៤ ឬមុខព្រហ្ម (បើតាមអ្នកកាន់ លទ្ធិព្រាហ្មណ៍ត្រូវចិត្ត ពួកព្រាហ្មណ៍); ព្រះភក្ត្រព្រះពោធិសត្វអវលោកិតេស្វរៈ (បើតាមអ្នកកាន់ពុទ្ធលទ្ធិ ត្រូវចិត្តពួកពុទ្ធបរិស័ទ) ដែលគេគិតថាជាតំណាងឱ្យ ព្រះភក្ត្រព្រះរាជា ឬ មហិទ្ធិឫទ្ធិ របស់ព្រះអង្គដែលផ្សព្វផ្សាយទៅគ្រប់ទិសទី។ នៅក្នុងបំពេញចិត្តក៏ដូចជាទឹកព្រះទ័យរបស់ព្រះ បាទជយវរ្ម័នទី៧ ព្រះអង្គបានចារទុកនូវព្រះរាជទស្សនៈថា "ទុក្ខរបស់រាស្ត្រគឺជាទុក្ខរបស់អ្នកដឹកនាំ" បង្ហាញឱ្យឃើញពីគំនិតយកចិត្តទុកដាក់បង្រួបបង្រួមធ្វើឱ្យជាតិមាន ការឯកភាពគ្នា។ សិលាចារឹកព្រះខាន់បានឱ្យដឹងថា ក្រៅពីប្រាសាទនៅមានសាលាសំណាក់ (ធម៌សាលា) ចំនួន ១២១ នៅតាមបណ្តោយផ្លូវធំៗនៃអាណាចក្រចម្ងាយ ១៥គ.ម. ពីមួយទៅមួយ។ សិលាចារឹកតាព្រហ្ម ណ៍បានឱ្យដឹងថា ទ្រង់កសាងមន្ទីរពេទ្យ ចំនួន ១០២ ដែលមនុស្សវណ្ណៈទាំង៤ អាចចូលទៅព្យាបាលបាន ដូចគ្នាដោយសេរី[១៨]។ សម័យមហាអង្គរជាសម័យកាលដ៏រុងរឿងបំផុត។ ភាពរុងរឿងនេះមិនមែនបានមកដោយ ចៃដន្យទេ។ គឺបានមកដោយភាពវៃឆ្លាតរបស់ព្រះរាជា ដែលចេះផ្សំរវាង កត្តាមនុស្ស និង កត្តាសាសនា។ កត្តាទាំងពីររួម ផ្សំគ្នាបង្កើតទៅជាកម្លាំងនយោបាយដ៏ខ្លាំងក្លាមួយដែលអាចព្យាបាល អាណាចក្រចេនឡាដែលបានបែកបាក់ឱ្យ មកជាសះស្បើយ និងរួបរួមគ្នាបង្កើតទៅជាសម័យអង្គរមួយដ៏អស្ចារ្យ។ និយាយពីកត្តាមនុស្សគឺនិយាយពីកត្តា នៃ អ្នកដឹកនាំដែលជាព្រះរាជា និង កត្តានៃអ្នកដែលត្រូវគេដឹកនាំគឺប្រជារាស្ត្រ។ ប៉ុន្តែបើនិយាយពីកត្តាសាសនា វិញ គឺនិយាយពី បញ្ហាជំនឿ និងបញ្ហាចិត្តសាស្ត្រ។ កត្តាទាំងនេះមិនអាចកាត់ផ្តាច់ចេញពីគ្នាបានទេ។ ព្រះរា ជាដឹកនាំដោយជោគជ័យទៅបាន គឺអាស្រ័យលើ មានការជឿទុកចិត្ត ពីប្រជារាស្ត្រ។ ប្រជារាស្ត្រអាចជឿទុក ចិត្តបានគឺទាក់ទងទៅនឹង ភាពអស្ចារ្យរបស់ព្រះរាជា។ ភាពអស្ចារ្យនៅត្រង់ចំណុចនេះ ព្រះបាទ ជយវរ្ម័នទី២ ទ្រង់យល់ច្បាស់ពីសារសំខាន់នៃកត្តាចិត្តសាស្ត្រ។ លទ្ធិទេវរាជ

---

[១៨] ត្រឹង ងា, ជ.ឯ.ម., ទំព័រ ១៤០-១៤២

មានលក្ខណៈជាសាសនាផង, ជាអំណាច, ជាបារមីឬជាឫទ្ធចេស្តារផង, និងជាចិត្តសាស្ត្រនោះផងដែរ។ ការរៀបចំធ្វើពិធីទេវរាជនៅលើភ្នំគូលែនគឺ ដើម្បីអភិ សេកព្រះអង្គឱ្យមានឋានៈជា អាទិទេព នេះជាភាពអស្ចារ្យ (បើត្រឹមតែស្តេច ឬអ្នកដឹកនាំសាមញ្ញ មិនងាយនឹងបង្រួបបង្រួមជាតិបានទេ ព្រោះគេមិនកោតខ្លាច)។ បញ្ញារបស់ព្រះរាជា គឺជាបញ្ញារបស់អាទិទេព។ ដីធ្លី ច្បាប់ (អំណាចទាំងបីរបស់រដ្ឋស្ថិត នៅលើដៃព្រះអង្គតែមួយអង្គ) កងទ័ពសាសនា និង ស្តេរភាពសង្គម រួមទាំង ជីវិតនិង ជោគវាសនា ផងគឺព្រះរាជាជាអ្នកសម្រេច (នេះជាអំណាចដែលមានប្រភពមកពីអាទិ ទេព ដែលលទ្ធិទេវរាជបាននាំមក)។ កត្តាអស្ចារ្យធ្វើឱ្យព្រះបាទជយវរ្ម័នទី២ក្លាយទៅជាព្រះរាជាដ៏មានអំណាច និងបារមី។ ទ្រឹស្តីនយោបាយនៅសម័យនោះចែងថា "អ្នកដែលគោរពប្រតិបត្តិតាមបញ្ញាព្រះអាទិទេពនឹងនាំ មកនូវកុសលផលបុណ្យដល់អ្នកដែលបានប្រព្រឹត្តិអំពើនោះ"[១៩]។ ហេតុនេះ ប្រជារាស្ត្រមិនហ៊ានប្រឆាំង ឬធ្វើ អ្វីទាស់ខុសនយោបាយដឹកនាំរបស់ព្រះរាជាទេ។ នេះជាចិត្តសាស្ត្រនយោបាយយ៉ាងជ្រាលជ្រៅនៃលទ្ធិទេវរាជ។ ក្នុងន័យចិត្តសាស្ត្រនេះដែរ នៅពេលយាងទៅណាមកណា ព្រះបាទជយវរ្ម័នទី២ទ្រង់ឱ្យគេយកទេវរូប ដង្ហែរតាម ដើម្បីឱ្យរាស្ត្រជឿនិងគោរពថា ទ្រង់ជាទេវរាជមួយអង្គ។ ជាងនេះទៀត ព្រះរាជាដែលជាតំណាងអា ទិទេពខិតខំប្រឹងសម្តែងឫទ្ធានុភាពឱ្យអស្ចារ្យសក្តិសមជាអាទិទេពពិតៗនៅលើផែនដីនេះ។ ពីរជ្ជកាលមួយ ទៅរជ្ជកាលមួយ ព្រះរាជាដែលដើរតាមលទ្ធិទេវរាជខិតខំកសាងប្រាសាទកាន់តែធំ កាន់តែច្រើន កាន់តែ ល្អទៅៗជាងរជ្ជកាលមុនៗជាដរាប។ ព្រះរាជាថ្វីត្បិតតែព្រះអង្គជា អគ្គបញ្ជាការកងទ័ព ប៉ុន្តែព្រះរាជាជា មេ ទ័ពដឹកនាំទ័ពចេញប្រយុទ្ធសត្រូវនៅសមរភូមិតែម្តង។ អត្ថបទសិលាចារិកជាច្រើនបានកោតសរសើរចំពោះ គុណសម្បត្តិយោធារបស់ព្រះរាជា សុទ្ធសឹងតែមានតេជដៃខ្លាំងពូកែ មានជ័យជំនះ លើសត្រូវជានិច្ច។ នេះជា គំរូចិត្តសាស្ត្រដ៏ល្អមួយសម្រាប់បំផុសទឹកចិត្តក្លាហានរបស់ទាហានក្នុងការប្រយុទ្ធការពារទឹកដី ពង្រីកអំណាច ពង្រីកទឹកដីតាមលទ្ធិទេវរាជ។ ទាហានដែលមាន

---

[១៩] ត្រឹង ង៉ា, ជ.ឯ.ម., ទំព័រ ១១០

គុណ បំណាច់ចំពោះជាតិ ត្រូវបានលើកតម្កើងជាអតិបរមា ដោយមានការកសាងរូបបដិមានិងប្រាសាទ សម្រាប់រំលឹកគុណ[20]។ គួរកត់សម្គាល់លើកត្តាចិត្តសាស្ត្រសំខាន់មួយទៀតថា ព្រះរាជា ថ្វីត្បិតតែព្រះអង្គមានអំណាចដែលមានប្រភពមកពី អាទិទេព មានលក្ខណៈទូលំទូលាយក៏ពិតមែន ប៉ុន្តែ មិនមានន័យថា ព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេ ព្រះអង្គត្រូវ គោរពវិន័យវណ្ណៈ ក្សត្រិយៈ គោរពសិក្ខាបទសាសនា ពោលគឺ ទ្រង់ត្រូវប្រកបដោយទសពិធរាជធម៌។ សិលាចារិកព្រះគោ ស្លោកទី៣ បាននិយាយពីព្រះបាទឥន្ទ្រវរ្ម័នទី១ថា "ស្រីឥន្ទ្រវរ្ម័នធ្វើឱ្យប្រជារាស្ត្រសប្បុរសប្បាយ ដោយការប្រត្តិបត្តិនូវវិន័យទាំង៣ប្រការ" [21]។ សព្វថ្ងៃ កត្តាសាសនានៅតែមានសក្តានុពល។ ទាំងគណៈបក្សប្រជាជនក៏ដូចជា  គណៈបក្សដទៃទៀត ដែរសុទ្ធតែយកចិត្តទុកដាក់នឹងបញ្ហាសាសនានេះ ជាពិសេសព្រះពុទ្ធសាសនា ដូចជា ចូលរួមកាន់បិណ្ឌ ហែរកឋិនទាន កសាងវត្តជាមួយប្រជាពលរដ្ឋជាដើម។ ធ្វើបែបនេះដើម្បីឱ្យ ប្រជាជនកោតស្ញប់ស្ញែង ជឿទុកចិត្ត និងស្និទ្ធស្នាល។ ការដែលប្រជាជនកោតស្ញប់ស្ញែង ជឿទុកចិត្ត និងស្និទ្ធស្នាលនាំឱ្យការដឹកនាំប្រព្រឹត្តទៅ ដោយរលូនប្រកបដោយសេចក្តីសុខ និងសេចក្តីចម្រើន។ ដូច្នេះយុទ្ធសាស្ត្រនយោបាយកំឡាយខ្លួនព្រះរាជាទៅជាអាទិទេព គឺជាយុទ្ធសាស្ត្រដ៏វៃឆ្លាត មួយរបស់ព្រះ បាទជយវរ្ម័នទី២ ក៏ដូចជាព្រះបាទជយវរ្ម័នទី៧ដែរ ហើយក៏ជាគំរូល្អដល់ព្រះរាជា ឬអ្នកដឹកនាំជំនាន់ក្រោយៗ រហូតមកដល់សព្វថ្ងៃនេះ។

## ៥- សេចក្តីសន្និដ្ឋាន

សិល្បៈដឹកនាំរបស់ស្តេចសម័យអង្គរ មានលក្ខណៈសីលធម៌ទន់ភ្លន់ បត់បែន និងប្រកបដោយ បញ្ញា។ ស្តេចយល់និងស្គាល់ពីព្រះអង្គឯង យល់និងស្គាល់ពី ចរិកឬធម្មជាតិរបស់រាស្ត្រ ដែលព្រះអង្គត្រូវប្រាស្រ័យទាក់ទងជាមួយច្បាស់លាស់ យល់និងស្គាល់ពីពេលវេលា និងទីកន្លែង ជាស្តេចមានសុច្ចរិតភាព យុត្តិធម៌ និងព្រហ្មវិហារធម៌។ គុណសម្បត្តិនិងគុណធម៌ទាំង នេះគឺជាកម្លាំងនិង

---

[20] -ដ- ទំព័រ ៧៩

[21]-ដ- ទំព័រ ១១០

ការស្អិតជំមានប្រសិទ្ធិភាពក្នុងការបង្រួប បង្រួមឱ្យមានការឯកភាពគ្នាជាតិ និងឈាន ទៅដឹកនាំជាតិឱ្យមានសេចក្ដីសុខសេចក្ដីចម្រើន។ ជំនឿបង្កើត ឱ្យមានទំនុកចិត្ត និងការដើរតាម (ជឿជាក់ + គោរព + ប្រតិបត្តតាម) និងឈានទៅរកការបង្រួបបង្រួម ជាតិឱ្យមាន ការឯកភាពគ្នាបានយ៉ាងមានប្រសិទ្ធិភាព។ ដោយហេតុនេះ សិល្បៈនៅក្នុងការបង្រួបបង្រួមជាតិ គឺជាប្រភពនៃសម័យដ៏រុងរឿងរបស់ខ្មែរ ដែលអ្នកដឹកនាំខ្មែរមិនត្រូវបំភ្លេចចោលនៅក្នុងកម្មវិធីដឹកនាំរបស់ខ្លួន ទេ។ អតីតកាលជាបទពិសោធន៍និងជាមេរៀន បច្ចុប្បន្នជាការសិក្សារៀនសូត្រពីបទពិសោធន៍និងមេរៀន ទាំងនោះ អនាគតគឺជាផលដែលទទួលបានពីការសិក្សារៀនសូត្រពីបទ ពិសោធន៍និងមេរៀនទាំងនោះ។ លោក ចហ្គ សានតាយាណា (George Santayana) លើកឡើងថា "អ្នកដែលបំភ្លេចអតីតកាល នឹងត្រូវប្រ ឈមមុខនឹងធ្វើរឿងដដែលៗ (He who forgets the past is doomed to repeat it)"។ ដូច្នេះ វាដូច គ្នានឹងការនិយាយថា យើងត្រូវតែគិតពិចារណាឱ្យបានម៉ត់ចត់ចំពោះរឿងរ៉ាវនានាពី អតីតកាល (the things of the past) ពីព្រោះពួកវាពិតជាមានឥទ្ធិពលលើ បច្ចុប្បន្ន (the present) និងអនាគត (the future) យ៉ាងពិតប្រាកដ។ លើសពីនេះទៀត យើងត្រូវតែចងចាំថា អ្វីដែលយើងកំពុងធ្វើនៅថ្ងៃនេះ គឺជាផលិតផល មួយអំពីអ្វីដែលគេបានធ្វើវាកាលពីមុនៗ អ្វីដែលពួកវានឹងក្លាយជាថ្ងៃស្អែក វាអាស្រ័យទៅលើអ្វីដែលយើងធ្វើ នៅថ្ងៃនេះ។

## គន្ថនិទ្ទេស


១- ព្រឹត្តិប័ត្រ, ទស្សនាវដ្ដី, សារពត៌មាន និង Internet

-https://en.wikipedia.org/wiki/Khmer_architecture

-https://km.wikipedia.org/wiki/ព្រះវិស្ណុ

២- ស្នាដៃនិពន្ធជាភាសាខ្មែរ

-ត្រឹង ង៉ា, «ប្រវត្តិសាស្ត្រខ្មែរ (ភាគ១និងភាគ២)», ភ្នំពេញ, គ.ស.១៩៧៣/ព.ស.២៥១៧

-ឆយ យីហ៊ាង, "ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤

៣- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

- Cambridge Advanced Learner's Dictionary, 3rd Ed. Cambridge University Press, 2008
- Daniel Chandler and Rod Munday, Oxford Dictionary of Media and Communication (3 ed.), 2020
- Simon Blackburn, The Oxford Dictionary of Philosophy, (2 rev. Ed.), Oxford University Press 2008
- Venancio B. Ardales, "*An Introductory Text to Philosophy*" Philippines, 1987

# សីលធម៌ក្នុងដំណាក់កាលរាតត្បាតជំងឺកូវីដ១៩ ( Covid-19 )

ដោយៈ លោកស្រីបណ្ឌិត ជា វណ្ណី ប្រធានផ្នែកធម្មសាស្ត្រនិងចរិយាសាស្ត្រ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
Email: vannykhim2003@yahoo.co.uk

សីលធម៌ (សីលធម្ម) សីលដែលជាធម៌ ឬ សីលនិងធម៌ សំដៅលើកិរិយាមារយាទ សណ្ដាប់ធ្នាប់ ដំបូន្មានដែលនាំឱ្យចៀសវាង អំពើអាក្រក់ ហើយឱ្យប្រព្រឹត្តតែអំពើល្អ។ ការប្រកាន់ខ្ជាប់នូវសីលធម៌និងគុណធម៌ក្នុងការរស់នៅ ដូចជាការគោរពចាស់ទុំ និងគោរពច្បាប់សង្គមជាតិ គឺជាអ្វីដែលយើងទាំងអស់គ្នាត្រូវធ្វើ ជាពិសេសការអប់រំដល់មនុស្សជំនាន់ក្រោយដែលជាទំពាំងស្នងឫស្សី។ ការខ្វះសីលធម៌ និងគុណធម៌ ក៏ដូចជាការខ្វះការគោរពច្បាប់សង្គមនោះ វានឹងបង្កនូវការមិនគោរពគ្នា ការមិនឱ្យតម្លៃគ្នា ការមិនស្រឡាញ់គ្នា ការមើលងាយគ្នា ការប្រកួតប្រជែងគ្នា ការអាងបុណ្យសក្តិធំ ជាដើម។ ឧទាហរណ៍ បញ្ហាខ្វះសីលធម៌ក្នុងការបើកបរបង្កនូវការកកស្ទះចរាចរណ៍និងគ្រោះថ្នាក់ចរាចរណ៍ជាដើម។

នៅពេលថ្មីៗនេះ ជំងឺរលាកសួតដោយវីរុសកូរូណាឬកូវីដ១៩កំពុងរាតត្បាត និងសម្លាប់មនុស្សអស់រាប់ម៉ឺននាក់នៅទូទាំងពិភពលោក។ ប្រទេសកម្ពុជាក៏កំពុងទទួលរងការរាតត្បាតពីមេរោគមួយនេះដែរ ដែលរហូតមកដល់ថ្ងៃនេះ មានមនុស្សឆ្លងមេរោគកូវីដ-១៩ ចំនួន១២២ ក៏ប៉ុន្តែមិនមានអ្នកស្លាប់ទេ។ មនុស្សខ្លះ នៅពេលឆ្លងមេរោគកូវីដ មានអារម្មណ៍ថាខ្មាចគេរើសអើង។ ស្របគ្នានេះដែរ មានមនុស្សខ្លះគិតថា មានទង្វើអសីលធម៌ ឬសីលធម៌ធ្លាក់ចុះក្នុងមានដែលមានជម្ងឺកូវីដ-១៩កើតចំពោះបុគ្គលណាម្នាក់។ ប្រសិនបើយើងគិតឱ្យបានស៊ីជម្រៅ យើងក៏មិនអាចនិយាយថា ដោយសារជំងឺនេះបានធ្វើឱ្យបញ្ហាសីលធម៌របស់មនុស្សធ្លាក់ចុះនោះទេ ព្រោះយើងដឹងហើយថា ជំងឺរលាកសួតបណ្ដាលពីវីរុសកូរ៉ូណាមេរោគថ្មីនេះ ជាទូទៅអាចឆ្លងចូលទៅក្នុងខ្លួនមនុស្សផ្សេងៗទៀតតាមរយៈ ការក្អក ការកណ្ដាស់ ការប៉ះពាល់គ្នា ការខ្វះអនាម័យ ការបរិភោគសាច់ឆៅ សាច់សត្វមានពិសជាដើម ដ្បិតជំងឺនេះជាជំងឺសាហាវដែលអាច

ធក់យកអាយុជីវិតរបស់មនុស្សក្នុងពេលដ៏ខ្លី។ ជំងឺនេះមានរោគសញ្ញា គ្រុនក្តៅ ហៀរសំបោរ ក្អក ឈឺបំពង់ក ដកដង្ហើមញាប់ ដកដង្ហើមមិនពេញលេញ និងមានដង្ហើមដង្ហក់ដែលធ្វើឱ្យមានការពិបាកក្នុងការដកដង្ហើមជាដើម។ បុគ្គលណាបានកើតនិងឆ្លងជំងឺនេះនឹងប្រឈមនឹងការមិនហ៊ាននៅក្បែរ ឬ ការរត់គេចចេញរបស់បុគ្គលផ្សេងៗទៀត ដែលគេយល់ថាជាការរើសអើង។ ពីព្រោះគេខ្លាចបុគ្គលដែលមានមេរោគ ចម្លងមេរោគទៅខ្លួនរបស់គេ ដែលទង្វើនេះ គឺជាការការពារខ្លួនតែប៉ុណ្ណោះ មិនមែនជាការរើសអើង ហើយក៏មិនមែនជាការធ្លាក់ចុះនៃសីលធម៌របស់មនុស្សនោះដែរ។ តួយ៉ាងដូចជាជាតិជនជាតិចិនដែលជាជនជាតិមួយត្រូវបានទទួលការមិនសូវពេញចិត្តពីសាសន៍ដទៃមុនគេ ដ្បិតថាពួកគាត់បានកើតជំងឺកូរ៉ូណានេះដំបូងគេ។ គ្រាន់តែត្រឹមដំណាច់ខែមករា ដើមឆ្នាំ២០២០ កន្លងទៅ ប្រទេសចិនដែលមានប្រជាជន១៣៨៦លាននាក់ និងជារដ្ឋអធិបតេយ្យមួយក្នុងចំណោមរដ្ឋអធិបតេយ្យ១៩៣ប្រទេស បានបាត់បង់អាយុជីវិតប្រជាពលរដ្ឋខ្លួនអស់ជាង២០០នាក់ ខណៈជិត១០០០០នាក់ទៀតស្ថិតក្នុងដំណាក់កាលតាមដាន ដោយសារតែវិជ្ជមាននូវវីរុសកូរ៉ូណា ឬកូវីដដ៏កំណាចនេះនៅក្នុងខ្លួនរបស់ពួកគេ ហើយដោយសារតែវីរុសនេះ ទើបបានបង្កឱ្យប្រទេសស្ទើរតែទូទាំងពិភពលោកមានការឆ្លងរាលដាលនូវជំងឺនេះរហូតមកដល់សព្វថ្ងៃ។

សព្វថ្ងៃដោយសារតែជំងឺនេះ បានធ្វើឱ្យពិភពលោកចាប់ផ្តើមមានទុក្ខព្រួយជាខ្លាំងព្រោះស្ថានភាពកើតមាននៅចិនបានសាយភាយមកកាន់ប្រទេសនានាក្នុងនិងក្រៅតំបន់អាស៊ី។ មជ្ឈដ្ឋានខ្លះយល់ថា ដូចជាយឺតពេលណាស់ដែលចិនបិទទីក្រុង បិទជើងហោះហើរពលរដ្ឋខ្លួនទៅបរទេស ក្រោយពីមេរោគកូរ៉ូណាបានវាយលុកចេញពីក្រុងអ៊ូហាន។ ការបិទទីក្រុងធ្វើឱ្យក្រុងអ៊ូអរមួយនេះ ប្រែទៅជាស្ងាត់ជ្រងំ គ្មានចរាចរណ៍ បិទទីផ្សារ គឺប្រៀបបានជាទីក្រុងដែលគេទុកចោល។ អ៊ូហានជាទីក្រុងធំមួយ ស្ថិតនៅភាគកណ្តាលប្រទេសចិនត្រូវបានវាយលុកដោយមេរោគម្យ៉ាងដែលជាពពួកមេរោគផ្តាសាយធំមានឈ្មោះថា ***វីរុសកូរ៉ូណាប្រភេទថ្មី ឬកូវីដ១៩*** ហើយវាបានបង្កឱ្យមនុស្សក្នុងក្រុងរាប់សិបនាក់ធ្លាក់ខ្លួនឈឺផ្ទួនៗនៅក្នុងខែធ្នូ ឆ្នាំ២០១៩ កន្លងទៅ។ អ្នកជំងឺទាំងនោះត្រូវបានគេរកឃើញថា ជាអ្នករស់នៅតំបន់ផ្សារលក់គ្រឿងសមុទ្រអ៊ូណាន ហើយជាអាជីវករសាច់ត្រី និងគ្រឿងសមុទ្រ។ មកដល់សប្តាហ៍ទី២ នៃខែមករា ឆ្នាំ២០២០ វីរុសនេះបានអង្រួនពិភពលោក ព្រោះក្រោយពីធ្លាក់ខ្លួនឈឺ អ្នកជំងឺទាំងនោះបានស្លាប់ជាបន្ត

បន្ទាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ វីរុសដែលសាហាវធ្វើឱ្យគេខ្លាចរអា មិនទាន់មានអ្នកវិទ្យាសាស្ត្រជំនាញសុខាភិបាលណាម្នាក់រកឃើញថាវាមានប្រភពមកពីអ្វីឱ្យពិតប្រាកដនោះនៅឡើយទេ? គឺវាប្រៀបបាននឹងវីរុសដ៏អាថ៌កំបាំង។ អ្នកដែលមានប្រព័ន្ធស៊ាំខ្សោយត្រូវបានគេចាត់ទុកថា ជាជនងាយរងគ្រោះបំផុត ព្រោះមេរោគនឹងឆ្លងតាមប្រព័ន្ធផ្លូវដង្ហើម ដែលបញ្ចេញដោយម៉ូលេគុលទឹកមាត់ ដោយការក្អក និងកណ្ដាស់ ហើយអាចធ្វើឱ្យអ្នកជិតខាងឆ្លងបានជាបន្តបន្ទាប់។ ដើម្បីសុខុមាលភាពនៃមនុស្សជាតិ មុននឹងប្រកាសពីភាពអាសន្ន អង្គការសុខភាពពិភពលោក(WHO) ក៏បានប្រកាសពីវិធីការពារខ្លួនជាបន្តបន្ទាប់ពីជំងឺនេះដោយផងដែរ ដោយមិនឱ្យភ្លេចពីការលាងដៃជាមួយសាប៊ូ អាល់កុល ឬជែលអាល់កុល និងត្រូវខ្ទប់មាត់និងច្រមុះ នៅពេលក្អក និងកណ្ដាស់ដោយយកកន្សែង ក្រម៉ា ក្រដាស ឬដោយកែងដៃ ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកដែលគ្រុនក្ដៅ និងក្អក ឬផ្ដាសាយ និងត្រូវចម្អិនសាច់និងស៊ុតឱ្យបានឆ្អិនល្អ ជៀសវាងប៉ះពាល់ជាមួយសត្វព្រៃរស់ ឬកន្ទេលចិញ្ចឹមសត្វដោយគ្មានពាក់សម្ភារការពារខ្លួន ដ្បិតជំងឺផ្លូវដង្ហើមបង្កឡើងដោយវីរុសនេះ អាចចូលមកពិឃាតជីវិតមនុស្សយ៉ាងសម្ងាត់ និងលឿនបំផុតដែលធ្វើឱ្យគេមិនហ៊ាននៅក្បែរអ្នកជំងឺ ជាពិសេសគឺអ្នកជំងឺមានប្រភពមកពីអ៊ូហាន ឬជាជនជាតិចិន។ នាឱកាសនោះ វិធានការចំនួន៤ ត្រូវបានសហគមន៍អន្តរជាតិបានធ្វើទៅលើចិន គឺធ្វើទៅលើប្រជាជនខ្លួនឯងដែលរស់នៅប្រទេសចិន និងជនជាតិចិនដែលរស់នៅក្នុងប្រទេសរបស់ពួកគេ។ វិធានការចំនួនបួននោះរួមមាន ការជម្លៀសពលរដ្ឋរបស់ប្រទេសពួកគេចេញពីចិន ខេត្តហឺប៉ី និងខេត្តនានា ការបិទជើងហោះហើរនៃក្រុមហ៊ុនអាកាសចរណ៍ធំៗ ការបិទទិដ្ឋាការសម្រាប់ជនជាតិចិន និងប្រទេសជុំវិញចិនក៏បានចាប់ផ្ដើមបិទព្រំដែន។ បើតាមគេហទំព័រសារព័ត៌មាន Newsweek ស្ទើរតែគ្រប់ប្រទេសទាំងអស់ដែលមានព្រំដែននឹងចិន បានសម្រេចចិត្តបិទព្រំដែនតាមរយៈកិច្ចព្រមព្រៀងពីចម្ងាយជាបន្តបន្ទាប់ ដូចជា ហ្កានីស្ថាន ប៊ូតាន ឥណ្ឌា កាសាស្ថាន គីហ្គីស្ថាន ឡាវ ម៉ុងហ្គោលី មីយ៉ាន់ម៉ា ណេប៉ាល់ កូរ៉េខាងជើង ប៉ាគីស្ថាន តាជីគីស្ថាន វៀតណាម និងរុស្ស៊ីចុងក្រោយគេ។ បន្ទាប់មកនៅយប់ថ្ងៃទី២៩ មករា យន្តហោះអាមេរិកនិងជប៉ុនបានចូលដឹកពលរដ្ឋរបស់ខ្លួនសរុបគឺជិត៥០០នាក់ពីទីក្រុងអ៊ូហាន ព្រមទាំងព្រមានពលរដ្ឋខ្លួនថា បើមិនមានការចាំបាច់មិនត្រូវទៅចិនទេ។ ចំពោះអង់គ្លេសវិញ នាយប់ថ្ងៃទី៣០មករា គឺបានស្នើចិនអនុញ្ញាតឱ្យបើកក្រុងបន្តិច ដើម្បីជម្លៀស

ពលរដ្ឋខ្លួនមកកាន់មាតុភូមិវិញ ដោយ អង់គ្លេសបានយកយោធាទៅសង្គ្រោះទៅជាមួយផងដែរ។ បើតាមសារព័ត៌មានញ៉ូវយ៉កថាម បានរាយការណ៍ថា ក្នុងនោះប្រទេសបារាំង កូរ៉េខាងត្បូង ម៉ារ៉ុក អាល្លឺម៉ង់ កាហ្សាក់ស្ថាន អង់គ្លេស កាណាដា រុស្ស៊ី ហូល្លង់ ភូមា និងអូស្ត្រាលី ក៏គ្រោងនឹងជម្លៀសពលរដ្ឋខ្លួនពីអ៊ូហានដែរ។ ក្នុងចំណោមប្រទេសដែលបិទព្រំដែននោះ ក៏មានប្រទេសបិទទិដ្ឋាការផងដែរ តែជម្រើសមួយនេះ ត្រូវបានគេមើលឃើញជាពិសេស គឺនៅតំបន់អាស៊ីអាគ្នេយ៍ដែលដំបូងគេ គឺហ្វីលីពីន មេដឹកនាំកំពូល**ឌូឌឺតេ** បានប្រកាសស្នើរជារៀងរាល់ថ្ងៃពីវិធានការទប់ស្កាត់ការបិទទិដ្ឋាការអ្នកដំណើរចិន តែទីបំផុតប្រទេសនេះក៏បានឆ្លងមួយករណី។ បន្ទាប់មកវិធានការដដែលនេះបាននាំឱ្យម៉ាឡេស៊ី វៀតណាម ធ្វើតាម ហើយសិង្ហបុរី និងថៃកំពុងស្ថិតក្នុងការពិចារណា។ ជាមួយគ្នានេះ ក្រុមហ៊ុនអាកាសចរណ៍ធំៗ ក៏បានផ្អាក និងកាត់បន្ថយ សេវាកម្មដល់ប្រទេសចិនរួមមាន ក្រុមហ៊ុនអាកាសចរណ៍អង់គ្លេសអ៊ែរវ៉េ EU Airline ក្រុមហ៊ុនអាកាស ចរណ៍អាល្លឺម៉ង់ Lufthansa ក្រុមហ៊ុនអាកាសចរណ៍អាមេរិក KLM និង United។ ចំណែកក្រុមហ៊ុន Toyota Volkswagen IKEA Starbucks Tesla ក្រុមហ៊ុន McDonald's និងក្រុមហ៊ុនបច្ចេកវិទ្យាយក្ស Foxconn បានបិទហាងជាបណ្ដោះអាសន្ននៅចិនព្រមទាំងព្រមានដើរចេញពីប្រទេសចិន។ ដើម្បីជាការឆ្លើយតបវិញ រដ្ឋាភិបាលនៃទីក្រុងប៉េកាំងបានសម្រេចថា នឹងបញ្ជូនយន្តហោះទៅដឹកប្រជាជនដែលមានស្រុកនៅកំណើតនៅខេត្តហ៊ូប៉ី (Hubei) ពីបណ្ដាប្រទេសនានាត្រឡប់មកវិញឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ព្រោះប្រទេសមួយចំនួន បានសម្រេចផ្អាកជើងហោះហើរជាមួយចិន ដែលជាហេតុធ្វើឱ្យប្រជាជនចិនទាំងនោះ មិនអាចត្រឡប់មកប្រទេសកំណើតវិញបាន។ អាកាសចរណ៍ស៊ីវិលចិនបានរាយការណ៍ឱ្យដឹងថា មុនបិទទីក្រុងប្រជាជនក្រុងអ៊ូហានបានហោះហើរទៅកាន់គោលដៅជាច្រើន គឺស្ទើរតែកន្លះលាននាក់ក្នុងចំណោមប្រជាជនអ៊ូហានសរុប ១១លាននាក់។ ក្នុងនោះគឺមានទៅសិង្ហបុរី និងថៃជិត១ម៉ឺននាក់ ដែលចំនួននេះគឺច្រើនជាងប្រទេសណាៗទាំងអស់។ នៅថ្ងៃទី៣១មករា ជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ចិន Xiamen នឹងទៅដឹកជនជាតិចិនពីទីក្រុង Kota Kinabalu ក្នុងប្រទេសម៉ាឡេស៊ី និងទីក្រុងបាងកក ប្រទេសថៃ។ នៅក្នុងទីក្រុងបាងកក គឺមានជនជាតិចិនមកពីខេត្តហ៊ូប៉ី ចំនួន១១៧នាក់ កំពុងជាប់គាំងនៅទីនោះ ហើយ១០០នាក់ទៀតក្នុងទីក្រុង Kota Kinabalu ដែល

បង្ហាញឆន្ទៈចង់ជិះយន្តហោះនេះត្រឡប់មកក្រុងអ៊ូហានវិញឆាប់ៗតាមដែលអាចធ្វើបាន។[1]

រាល់ នីតិបុគ្គល ក្រុមហ៊ុន និងរដ្ឋទាំងអស់ដែលធ្វើរបៀបនេះដូចបានរៀបរាប់ខាងលើ គឺដើម្បីបង្ការហានិភ័យអាយុជីវិតពលរដ្ឋសញ្ជាតិពួកគេដែលត្រូវបានចាត់ទុកថា ជាការធ្វើឡើងដើម្បីការពារប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេជាមួយចិន ខណៈចិនកំពុងមានបញ្ហា ហើយទង្វើទាំងនេះ ក៏យើងមិនអាចចាត់ទុកថា ជាការធ្លាក់ចុះលើផ្នែកសលីធម៌ដែរ។

នៅបណ្តាប្រទេសអាស៊ី អង្គការសុខភាពពិភពលោកបានយកថ្ងៃចុងខែមករា ប្រកាសអាសន្នកម្រិតពិភពលោក ព្រោះតួលេខអ្នកស្លាប់ដោយជំងឺកូវីដ១៩ បានកើនឡើងជាង២០០នាក់ តែព្យាបាលជាសះស្បើយបានចំនួន១៨៧នាក់ក្នុងចំណោមអ្នកមានផ្ទុកមេរោគជិត១០០០០នាក់។ អង្គការសុខភាពពិភពលោក បានអំពាវនាវឱ្យប្រទេសទាំងអស់ការពារខ្លួន តែមិនត្រូវបោះបង់ចោលការសហប្រតិបត្តិការជាមួយអន្តរជាតិនោះទេ គឺត្រូវរួមគ្នាវាយបង្ក្រាបជំងឺកំណាចនេះជាមួយចិន។ យ៉ាងណាចិនខ្លួនឯង បានប្តេជ្ញាថានឹងបង្ក្រាបជំងឺកំណាចដែលឆក់យកជីវិតពលរដ្ឋរបស់គេជាបន្តបន្ទាប់ តែក៏មិនចោលការស្វាគមន៍កិច្ចសហប្រតិបត្តិការផងដែរ។ ការសហប្រតិបត្តិការនេះ ចិនបានស្វាគមន៍ជាពិសេសនឹងអង្គការសុខភាពពិភពលោក និងបណ្តាអង្គការអន្តរជាតិដទៃទៀត ខណៈអាមេរិកព្យាយាមទៅត្រួតពិនិត្យស្ថានការណ៍ជំងឺនៅអ៊ូហាន។ ចំណែកអូស្ត្រាលី ជប៉ុន ហុងកុង កំពុងស្វែងរកវ៉ាក់សាំងការពារដែលត្រូវបានវាយតម្លៃថា នឹងចំណាយពេលដល់ទៅមួយត្រីមាស។ ក្នុងពេលជាមួយគ្នានោះដែរ ក៏មានអតីតអ្នកចារកម្មអ៊ីស្រាអែលម្នាក់បានយល់ថា មេរោគនេះបានធ្លាយចេញពីវិទ្យាស្ថានជីវសាស្ត្រដែលមានចម្ងាយប្រមាណ៣០គីឡូម៉ែត្រពីតំបន់ផ្ទុះមេរោគ គឺលោកសង្ស័យថា មេរោគនេះ ចិននឹងយកទៅបង្កើតដើម្បីសង្គ្រាមជីវសាស្ត្រក៏ថាបាន។ តែយ៉ាងណា ចិនបានច្រានចោលព័ត៌មានដែលចុះផ្សាយដោយសារពត៌មានអន្តរជាតិមួយចំនួនពីរឿងរ៉ាវនេះ។ ចំពោះការចោទប្រកាន់ និងការបដិសេធនេះ បើយើងយកបញ្ហាសីលធម៌មកនិយាយវិញ គឺមនុស្សជាតិនៃពិភពលោកយើងនៅមានសីលធម៌ និងគុណធម៌ខ្ពស់ណាស់ចំពោះសុខុមាលភាពមនុស្សជាតិ ដ្បិតមិនត្រឹមតែអង្គការសុខភាព

[1] តាមការចុះផ្សាយរបស់ CAN នាថ្ងៃសុក្រ ទី៣១ ខែមករា

ពិភពលោកមិនទុកឱ្យចិនឯកោដូចជាការរើសអើងនោះទេ។ នៅមានមេដឹកនាំបណ្តាប្រទេសមួយចំនួនបង្ហាញពីសាមគ្គីភាពនឹងចិន ក្នុងការឈរទប់ទល់នឹងជំងឺកូវីដ១៩ នេះដែរ។ លោក **មូនចេអ៊ីន** ប្រធានាធិបតីកូរ៉េខាងត្បូង បានថ្លែងសង្កត់ន័យធ្ងន់ៗក្នុងសន្និសីទចំពោះមុខទូរទស្សន៍ប្រព័ន្ធឃោសនានានាថា *អាវុធដើម្បីការពារខ្លួនយើងពីកូរ៉ូណាវីរុសប្រភេទថ្មីនេះ ពុំមែនជាភាពភ័យខ្លាច និងការស្អប់ខ្ពើមទេ ក៏ប៉ុន្តែគឺកិច្ចសហប្រតិបត្តិ និងជំនឿចិត្ត។* លោកបានចេញមុខមកធ្វើសន្និសីទសារព័ត៌មាននេះ គឺដើម្បីបង្ហាញពីចំណាត់ការក្តៅប្រឆាំងនឹងព័ត៌មានក្លែងក្លាយ (Fake News) ពាក់ព័ន្ធរឿងកូរ៉ូណាវីរុស ដែលបង្កភាពភិតភ័យដល់ពលរដ្ឋ។ ចំណែកមេដឹកនាំថៃលោក **ប្រាយុទ្ធចាន់អូចា** ក៏បានកោតសរសើរដល់ប្រព័ន្ធសុខាភិបាលរបស់ខ្លួន ដែលបានព្យាបាលជនជាតិចិន៥នាក់ជាសះស្បើយពីជំងឺនេះ។ រដ្ឋាភិបាលថៃថា មិនត្រឹមតែត្រួតពិនិត្យមើលអ្នកដំណើរមកពីអ៊ូហានទេ ប៉ុន្តែត្រូវតាមដានរាល់បណ្តាអ្នកមកពីគ្រប់ប្រទេសដែលមានហានិភ័យ ដោយវាស់កម្តៅពេលដើរ តាមរយៈកាមេរ៉ា។ ប្រសិនបើជនសង្ស័យត្រូវបានគេរកឃើញថា មានផ្ទុកមេរោគនោះ គេនឹងត្រូវបញ្ជូនទៅសង្កេតមើលរោគសញ្ញា និងព្យាបាលដោយមិនគិតពីអ្នក ដែលមកពីប្រទេសណាក៏ដោយ គឺត្រូវតែទទួលបានការស្វាគមន៍ ពីព្រោះពួកគេត្រូវបានចាត់ទុកជាភ្ញៀវរបស់ប្រទេស។ លោក **ប្រាយុទ្ធ**បានបន្តថា *គ្មានសុខទុក្ខអ្វីសំខាន់ជាងសុខទុក្ខរាស្ត្រនោះទេ។* យ៉ាងណាមិញ ចំពោះមេដឹកនាំកម្ពុជា នៅពេលដែលរកឃើញមានវីរុសកូរ៉ូណាមួយករណីនៅក្រុងព្រះសីហនុនោះ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានសម្រេចចិត្តដោយមិនជម្លៀសប្រជាជនខ្លួនពីទីក្រុងអ៊ូហាន ឬ ចិននោះទេ គឺសម្តេចបានឱ្យពេទ្យព្យាបាលជនជាតិនោះដោយយកចិត្តទុកដាក់បំផុតរហូតទទួលបានជោគជ័យក្នុងការព្យាបាលផងដែរ។ ស្ថិតក្នុងកាលៈទេសៈដ៏គួរឱ្យព្រួយបារម្ភនេះ មេដឹកនាំជាច្រើនក្នុងពិភពលោកបានចេញមកអូសទាញស្មារតីប្រជាជាតិខ្លួន កុំឱ្យមានចរិតរើសអើងចិនដោយសារជំងឺកូវីដ១៩នេះ ដោយលើកឡើងថា ជំងឺមិនកំណាចដល់ជំងឺភ័យខ្លាចជ្រុល និងបុរេស្អប់ខ្ពើមដែលមានក្នុងខ្លួនមនុស្សជាតិនោះទេ។

តាមរយៈហេតុការណ៍ខ្វះ មានមនុស្សមួយចំនួនបានលើកឡើងថា ពិភពលោកហាក់បានធ្លាក់ចុះផ្នែកសីលធម៌និងចរិតមនុស្សធម៌ ខ្វះការទទួលខុសត្រូវចំពោះបញ្ហាសិទ្ធិមនុស្ស និងសិទ្ធិរស់រានមានជីវិត។ ជាក់ស្តែងមានបណ្តាប្រទេសមួយចំនួនមិនបាន

អនុញ្ញាតឱ្យនាវា Westherdam ដែលផ្ទុកមនុស្សជិត ២០០០ នាក់ចូលចតនៅក្នុងប្រទេសរបស់ខ្លួន ដោយសារការភ័យខ្លាចការឆ្លងជំងឺកូវីដ១៩នេះ។ ប្រការនេះយើងក៏មិនអាចនិយាយថាប្រទេសទាំងនោះធ្លាក់ចុះនូវសីលធម៌ដែរ ដ្បិតគេខ្លាចអ្នកនៅកប៉ាល់នោះចម្លងមេរោគដ៏កាចសាហាវនេះដល់ប្រជាជនរបស់ពួកគេ គ្រាន់តែថាប្រទេសទាំងនោះខ្វះវិធានការក្នុងការចាត់ចែងទទួល។ ប៉ុន្តែសម្រាប់កម្ពុជា គឺសម្តេច **ហ៊ុន សែន** ដែលជាមេដឹកនាំកម្ពុជា បានអនុញ្ញាតឱ្យកប៉ាល់នោះចូលចត ដោយយល់ពីតម្លៃមនុស្សធម៌និងសិទ្ធិក្នុងការរស់រៀនមានជីវិត។ ទង្វើនេះបានបង្ហាញពិភពលោកថា កម្ពុជាកំពុងឈរលើមូលដ្ឋានសីលធម៌និងគុណធម៌ខ្ពស់ ដែលយើងសឹងតែអាចនិយាយថា មិនមានបណ្តាអារ្យប្រទេសមួយចំនួនធ្វើបាន។

ក្រៅពីការមានសីលធម៌ក្នុងការយល់ពីតម្លៃមនុស្សធម៌ និងសិទ្ធិក្នុងការរស់រៀនមានជីវិត សីលធម៌នៃការទទួលខុសត្រូវក្នុងតួនាទីការងាររបស់ខ្លួនក៏ដូចជាការលើកទឹកចិត្ត ក៏មានព្រមជាមួយគ្នាផងដែរ។ សម្តេចតេជោនាយករដ្ឋមន្ត្រីនៃកម្ពុជា បានថ្លែងកោតសរសើរថ្នាក់ដឹកនាំ មន្ត្រីរាជការ ជាពិសេសបុគ្គលិកសុខាភិបាលនៅទូទាំងប្រទេស ដែលបានខិតខំអនុវត្តគោលនយោបាយសុខាភិបាលនិងកម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ។ ការផ្តល់សេវាអប់រំសុខភាព ការបង្ការជំងឺ ការពិនិត្យព្យាបាល និងការថែទាំសុខភាពជូនប្រជាជន គឺជាការងារអាទិភាពរបស់យើងក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលនៃជំងឺកូវីដ១៩។ ការការពារការឆ្លងមេរោគ មានដូចជាការកុំឱ្យចាប់ដៃស្វាគមន៍ពេលជួបគ្នា គឺត្រូវប្រើវប្បធម៌ដ៏ល្អរបស់ខ្មែរដែលពេលជួបគ្នា ត្រូវលើកដៃជម្រាបសួរគ្នា ដើម្បីបង្កាជំងឺកូវីដ១៩ក៏ដូចជាឱ្យមានការពិចារណាការឧបត្ថម្ភផ្សេងៗក្នុងករណីមានអ្នកកើតជំងឺកូវីដ។[២]

ចំពោះមុខនៃវិបត្តិសុខភាពពិភពលោក ដោយសារតែការរាតត្បាតជំងឺកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** បានចាត់វិធានការជាកញ្ចប់ដើម្បីទប់ទល់នឹងផលប៉ះពាល់ពីជំងឺនេះ ទាំងវិធានការការពារសុខុមាលភាពប្រជាពលរដ្ឋ និងវិធានការសេដ្ឋកិច្ច។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាល

[២] សម្តេចបានថ្លែងនៅពេលដែលសម្តេចអញ្ជើញជាអធិបតីបិទសន្និបាតបូកសរុបការងារឆ្នាំចាស់ឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំថ្មីឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ដែលប្រារព្ធធ្វើឡើងនៅសណ្ឋាគារសុខា កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០។

បានរៀបចំវិធានការដើម្បីជួយដល់កម្មករ កម្មការិនី ដែលប្រឈមនឹងការបាត់បង់ការងារ ដោយសារតែពេងចក្រសុំព្យួរសកម្មភាព ជួិតកង្វះវត្ថុធាតុដើម។ ខណៈពិភពលោកទាំងមូលកំពុងប្រឈមនឹងការរាតត្បាតនៃជំងឺកូវីដ១៩ នាយករដ្ឋមន្ត្រីកម្ពុជា បានពុះពារយ៉ាងខ្លាំង ទាំងផ្តល់ការលើកទឹកចិត្ត និងការសម្រេចអនុញ្ញាតឱ្យនាវាទេសចរណ៍ Westerdam ចូលចតនៅក្នុងកំពង់ផែអន្តរជាតិព្រះសីហនុ ខណៈប្រទេស៤ កោះចំនួន២ បានបដិសេធមិនឱ្យនាវាយក្សនេះចូលចត ដោយសារតែភ័យខ្លាចជំងឺកូវីដ១៩។ ពាក់ព័ន្ធនឹងបញ្ហានេះ ប្រជាជនចិនបានប្រសិទ្ធនាមចំពោះកាយវិការមនុស្សធម៌ និងការយកចិត្តទុកដាក់ចំពោះប្រទេសជាមិត្តរបស់ខ្លួនក្នុងគ្រាលំបាកនេះថា «**បុរសសង្ហាដើរបញ្ច្រាសទិស**» ខណៈមេដឹកនាំនៃប្រទេសផ្សេងៗ មិនហ៊ានទៅកាន់ប្រទេសចិន ហើយពិភពលោកក្នុងសតវត្សរ៍ទី២១នេះ។ សម្តេចតេជោបានមានប្រសាសន៍ថា *ជំងឺកូវីដ១៩ គ្មានអ្វីគួរឱ្យភ័យខ្លាចឡើយ ប៉ុន្តែជំងឺភ័យខ្លាចបានជារឿងដែលគួរឱ្យភ័យខ្លាច*។ ការភ័យខ្លាចនៃជំងឺនេះបានរុញច្រានឱ្យមានការរើសអើងជាតិសាសន៍ រើសអើងមនុស្សនៅក្នុងសង្គម។ ការភ័យខ្លាចបានធ្វើឱ្យមនុស្សមួយចំនួនបាត់បង់នូវភាពម្ចាស់ការ បាត់បង់ជំនឿចិត្តលើខ្លួនឯង។

តើយើងអាចនិយាយបានទេថា ការប្រឈមនឹងជំងឺកូវីដ១៩នេះ ធ្វើឱ្យមនុស្សធ្លាក់ចុះនូវសីលធម៌? ស្របគ្នានឹងសកម្មភាពមនុស្សធម៌ដែលបានបង្ហាញតាមរយៈការសាមគ្គីភាពដ៏រឹងមាំជាធ្លុងមួយជួយគ្នាគ្រប់ពេលវេលារបស់ប្រជាជនកម្ពុជាដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងគាំទ្រដោយសម្តេចតេជោ **ហ៊ុន សែន** ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩នេះ? តាមរយៈកាយវិការនេះ យើងអាចនឹងធ្វើឱ្យជំងឺនេះជៀសផុតពីការឆ្លងកម្រិតអាសន្ននៅកម្ពុជា ហើយប្រជាពលរដ្ឋនឹងចាកផុតពីជំងឺរាតត្បាតនេះតាម រយៈការអនុវត្តបទដ្ឋាន អនាម័យជាប្រចាំ និងគ្មានការភ័យខ្លាចចំពោះជំងឺដែលអាចបង្ការបាននេះឡើយ ដោយយើងរួមគ្នាកម្ចាត់ជំងឺកូវីដ១៩ទាំងអស់គ្នា និងចូលរួមអនុវត្តវិធានការដែលដាក់ចុះដោយក្រសួងសុខាភិបាល ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រឆាំងនឹងវិបត្តិជំងឺកូវីដ១៩។ ចំពោះមុខនឹងការប្រឈមមុខការរាតត្បាតនៃមហន្តរាយដែលកំពុងតែវាយលុកពិភពលោកបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចុះនូវកញ្ចប់វិធានការលើផ្នែកសុខុមាលភាព សាធារណៈនិងសេដ្ឋកិច្ចសង្គម ដើម្បីបង្ការនិងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលបង្កឡើងដោយជំងឺកូវីដ១៩។ ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ដែលស

ម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានប្រកាសឱ្យក្រសួងស្ថាប័នទាំងរដ្ឋនិងឯកជន ព្រមទាំងពលរដ្ឋម្នាក់ៗត្រូវចាត់ទុកថា ***ជាការងារអាទិភាពទី១ និងចាំបាច់បំផុត។***

វិធានការដែលបានត្រៀមរៀបចំមុនពេលបុរសជនជាតិខ្មែរម្នាក់ត្រូវបានរកឃើញថាបានឆ្លងវីរុសកូវីដ១៩ ពីបុរសជនជាតិជប៉ុនម្នាក់ដែលធ្វើការនៅកន្លែងជាមួយគ្នា នៅទីរួមខេត្តសៀមរាប កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០២០ គឺអ្នកជំងឺត្រូវបានព្យាបាល និងថែទាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់ក្រុមគ្រូពេទ្យជំនាញៗ ជាមួយគ្នានេះ ក្រុមគ្រួសារ៣នាក់ផ្សេងទៀតរបស់គាត់រួមជាមួយអ្នកមានទំនាក់ទំនងនឹងអ្នកជំងឺជនជាតិខ្មែរ និងជប៉ុនសរុបជិត៣០នាក់នោះ ត្រូវបានធ្វើតេស្តស្វែងរកពោគសញ្ញាដោយវិទ្យាស្ថានប៉ាស្ទ័រ នៅល្ងាចថ្ងៃទី៨ និងទី៩ ខែមីនា និងបានបង្ហាញលទ្ធផលថា មានអវិជ្ជមានមេរោគកូវីដ១៩។ ទោះជាស្ថានភាពនៃការរាតត្បាតនៃវីរុសនេះលឿនរហ័ស និងមានភាពគួរឱ្យព្រួយបារម្ភ ជាពិសេសសម្រាប់មនុស្សវ័យចំណាស់ដែលមានភាពស៊ាំនៃសព៌ាង្គកាយខ្សោយ ប៉ុន្តែភាពភ័យខ្លាចរបស់មនុស្សចំពោះវីរុសកូវីដ១៩ មានសភាពធ្ងន់ធ្ងរខ្លាំងជាងលើសពីហានិភ័យពិតរបស់វា។ ចាប់តាំងពីការផ្ទុះឡើងនៃការរាតត្បាតចម្លងវីរុសកូវីដ១៩ ពីទីក្រុងអ៊ូហានប្រទេសចិន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ **ហ៊ុន សែន** បានដើរតួនាទីសំខាន់ក្នុងសកម្មភាពមនុស្សធម៌អន្តរជាតិ ទាំងការលើកទឹកចិត្ត និងការសហការជាលក្ខណៈអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺថ្មីនេះ។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងបញ្ជាក់ថា *ចាប់តាំងពីផ្ទុះជំងឺកូវីដ១៩រហូតមកដល់ពេលនេះ និងរហូតទៅដល់ការបញ្ចប់នៃជំងឺកូវីដ១៩នេះ ការងារអាទិភាពខ្ពស់បំផុតរបស់កម្ពុជា គឺប្រយុទ្ធប្រឆាំងនឹងការរាលដាលនៃកូវីដ១៩ ដែលនេះគឺជាការងារដែលយើងត្រូវធ្វើទាំងអស់គ្នា*។ សម្តេចបានបន្តថា *កម្ពុជាត្រូវតែរៀបចំផែនការ និងវិធានការនានាដែលត្រូវប្រកាន់យកក្នុងករណីកូវីដ១៩បានឆ្លងមកដល់កម្ពុជា និងបានឆ្លងរាលដាលពីពលរដ្ឋម្នាក់ទៅពលរដ្ឋម្នាក់ដែលមានល្បឿនលឿន និងទ្រង់ទ្រាយធំ។ រដ្ឋបានត្រៀមថវិកាសម្រាប់ជួយពលរដ្ឋក្នុងករណីចាំបាច់នៃការឆ្លងរាលដាលកូវីដ១៩ តាមរយៈការសម្រេចកាត់បន្ថយការចំណាយរបស់ក្រសួងស្ថាប័នទាំងអស់ចំនួន៥០ភាគរយ លើកលែងតែ ក្រសួងការបរទេស ក្រសួងពាណិជ្ជកម្ម និងទីស្តីការគណៈរដ្ឋមន្ត្រី ដែលត្រូវកាត់បន្ថយ២៥ភាគរយ ដើម្បីសន្សំប្រាក់ទាំងនោះ។ ការចំណាយរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ក៏ត្រូវកាត់បន្ថយដែរ ដើម្បីសន្សំប្រាក់ទាំងនោះទុកសម្រាប់បង្វែរ*

ការចំណាយចាំបាច់ទៅលើវិស័យសុខាភិបាល។ ជាវិធានការដាក់ស្តែង ក្រោយពីបុរសម្នាក់នៅខេត្តសៀមរាបត្រូវបានរកឃើញថាមានភាពវិជ្ជមានវីរ៉ុសកូវីដ១៩ វិធានការបន្ទាន់គឺសម្តេចតេជោ **ហ៊ុន សែន** បានបញ្ជាឱ្យក្រសួងអប់រំបិទសាលារៀនទាំងអស់ក្នុងក្រុងសៀមរាបជាបណ្តោះអាសន្ន ដើម្បីជៀសវាងកុំឱ្យមានការឆ្លងវីរ៉ុសកូវីដ១៩ជាយថាហេតុរហូតដល់មានការជូនដំណឹងជាថ្មី។ គម្រោងរៀបចំប្រារព្ធសង្ក្រាន្តសៀមរាបក៏ត្រូវបានប្រមុខរាជរដ្ឋាភិបាលបញ្ជាឱ្យលុបចោលផងដែរ។ នៅថ្ងៃទី៩ ខែមីនា សាលារៀនទាំងរដ្ឋនិងឯកជនសរុបចំនួ១១០ រាប់តាំងពីសាលាមត្តេយ្យរហូតដល់សាកលវិទ្យាល័យ និងសាលាបណ្តុះវិជ្ជាជីវៈក៏ត្រូវបានបិទជាបណ្តោះអាសន្ន។ នេះគឺជាវិធានការដើម្បីបង្ការការរីករាលដាលនៃការឆ្លងជំងឺកូវីដប្រកបទៅដោយសីលធម៌ និងការយកចិត្តទុកដាក់ខ្ពស់ក្នុងភាពជាអ្នកដឹកនាំ។ ជាមួយគ្នានេះដែរ ប្រជាពលរដ្ឋអាចចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩នេះ ដោយបញ្ឈប់ការភ័យខ្លាចហួសហេតុដែលនាំឱ្យមានការបង្កចលាចល តែត្រូវងាកមកអនុវត្តការសម្អាតអនាម័យ(សម្អាតផ្ទះសម្បែង ឧស្សាហ៍លាងដៃនឹងសាប៊ូ ឬទឹកអាកុល និងដែលផ្សេងៗ ប្រើម៉ាស់ ឬក្រម៉ានៅកន្លែងចាំបាច់មួយចំនួនៗ ក្នុងករណីមានការសង្ស័យក្រោយពីមានរោគសញ្ញាសង្ស័យមួយចំនួន គួរប្រញាប់ទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពដែលនៅជិតលោកអ្នកដើម្បីធ្វើតេស្តរកមើលជំងឺកូវីដ១៩) និង ស្នើសុំអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសអយ្យការអមតុលាការរាជធានីខេត្តទាំងអស់នៅទូទាំងប្រទេសកម្ពុជា ចាត់វិធានការផ្លូវច្បាប់ដ៏តឹងរឹងចំពោះជនណាដែលបំពុលព័ត៌មាន ផ្សព្វផ្សាយព័ត៌មានមិនពិតទាក់ទងនឹងជំងឺកូវីដ១៩ និងប្តេជ្ញាចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដដោយរួមសាមគ្គីជាធ្លុងមួយទប់ស្កាត់ការរាតត្បាតនៃជំងឺនេះ ប្រឆាំងដាច់ខាតការបំពុលសង្គម និងការបំភ័យដោយក្រុមជនទុច្ចរិត ជាដើម។

ទន្ទឹមនឹងនេះ អង្គការសុខភាពពិភពលោក បានចេញសេចក្តីប្រកាសព័ត៌មានមួយកាលពីថ្ងៃទី១៩ ខែកុម្ភៈ ស្នើឱ្យកម្ពុជាត្រៀមលក្ខណៈឱ្យបានល្អ ដើម្បីឆ្លើយតបរហ័សនិងទាន់ពេលវេលា ចំពោះលទ្ធភាពនៃការរីករាលដាលជំងឺកូវីដ១៩ ដែលអាចកើតមាននៅកម្ពុជា។ ដើម្បីត្រៀមបង្ការការឆ្លងរាលដាលនេះ អង្គការសុខភាពសុភាពពិភពលោក កំពុងធ្វើការជាមួយក្រសួងសុខាភិបាល និងដៃគូដទៃទៀត ដើម្បីឱ្យប្រទេសកម្ពុជាធ្វើបច្ចុប្បន្នភាពអំពីផែនការត្រៀមលក្ខណៈ និងការឆ្លើយតប

កម្រិតថ្នាក់ជាតិ ហើយនិងកំណត់ចំណុចខ្វះខាតចំពោះសកម្មភាពត្រៀមជាអាទិភាព។ ចំណុចអាទិភាពដែលត្រូវត្រៀមទុក រួមមាន ការគ្រប់គ្រងឧប្បត្តិហេតុ ការធ្វើផែនការ ការសម្របសម្រួលផ្នែកពហុវិស័យ ការវាយតម្លៃតាមដានហានិភ័យ មន្ទីរពិសោធន៍ ការគ្រប់គ្រងគ្លីនិក និងសេវាកម្មថែទាំសុខភាព ការត្រួតពិនិត្យនិងបង្ការការឆ្លង វិធានការសុខភាពសាធារណៈមិនមែនឱសថ និងសម្ភារៈសម្រាប់ធ្វើប្រតិបត្តិការជាដើម។

បន្ទាប់មកទៀត ក្នុងសប្តាហ៍ទី២នៃខែមីនា ក្រសួងអប់រំបានចេញសេចក្តីណែនាំសារជាថ្មី ឱ្យផ្អាកគ្រឹះស្ថានសិក្សាគ្រប់ប្រភេទចាប់ពីថ្ងៃចន្ទ ទី១៦ ខែមីនា ឆ្នាំ២០២០ ក្រោយពីមានការផ្ទុះឡើងនូវជំងឺកូវីដ១៩នៅក្នុងប្រទេសកម្ពុជាកាលពីពេលថ្មីៗនេះ ដោយក្រសួងអប់រំ យុវជន និងកីឡា បានចេញនូវសេចក្តីណែនាំលើកទី២ ស្តីពីការចាប់ផ្តើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈ និងឯកជន នៅទូទាំងប្រទេស។ យោងទៅតាមសេចក្តីប្រកាសលេខ១៣ អយក.សណន ចុះនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២០នេះ មានសេចក្តីថា ផ្អែកទៅតាមរបាយការណ៍ស្ថានភាពរាតត្បាតនៃវីរុសកូវីដ១៩ របស់អង្គការសុខភាពពិភពលោក ព្រមទាំងការរកឃើញជាបន្តបន្ទាប់នូវវិជ្ជមានវីរុសកូវីដ១៩ លើជនជាតិខ្មែរ និងជនជាតិបរទេសដែលបានធ្វើដំណើរចូលមកកម្ពុជា តម្រូវឱ្យមានវិធានការបង្ការ និងទប់ស្កាត់ជាបន្ទាន់ និងតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងអប់រំយុវជន និងកីឡាបានធ្វើការណែនាំដល់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈ និងឯកជននៅទូទាំងប្រទេសដែលក្នុងនោះរួមមាន គ្រឹះស្ថានសិក្សាចំណេះដឹងទូទៅ តាំងពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ និងមត្តេយ្យសិក្សាគ្រប់កម្រិតគ្រប់ប្រភេទ ទាំងសាធារណៈ និងឯកជនត្រូវចាប់អនុវត្តវិស្សមកាលតូចមុនកាលកំណត់ ចាប់ពីថ្ងៃនេះរហូតដល់មានការជូនដំណឹងពីក្រសួង ហើយសម្រាប់សាលាដែលមិនទាន់បានបញ្ចប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងឆមាសទី១ ត្រូវយកលទ្ធផលសិក្សាជាមធ្យមភាគនៃពិន្ទុប្រចាំខែ ចាប់ពីខែធ្នូ ឆ្នាំ២០១៩ រហូតដល់ខែកុម្ភៈ ឆ្នាំ២០២០ ជាមធ្យមភាគពិន្ទុប្រចាំឆមាស ចំណែកឯគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈ និងឯកជន ត្រូវអនុញ្ញាតឱ្យគរុសិស្សបានឈប់សម្រាកមួយរយៈ។ ក្រៅពីនេះ មន្ទីរអប់រំយុវជន និងកីឡារាជធានីខេត្ត ត្រូវលើកទឹកចិត្តឱ្យអាណាព្យាបាលសិស្ស ជំរុញទឹកចិត្តឱ្យបុត្រធីតារបស់

ខ្លួនស្វ័យសិក្សានៅផ្ទះដោយខ្លួនឯងក្នុងរយៈពេលថ្ងៃវិស្សមកាលតូចមុនថ្ងៃកំណត់នេះ។ ក្រសួងអប់រំបានសុំឱ្យមន្ទីរអប់រំយុវជន និងកីឡារាជធានីខេត្ត ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះឱ្យបានទូលាយដល់គ្រប់ការិយាល័យ។ ដោយឡែក គណៈគ្រប់គ្រងសាលារៀនគ្រប់កម្រិត គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប គួរសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងតាមដានជាប់ជាប្រចាំនូវការផ្សព្វផ្សាយរបស់ក្រសួងអប់រំ និងក្រសួងសុខាភិបាល ដែលនេះជាការទទួលខុសត្រូវខ្ពស់ប្រកបដោយសីលធម៌ក្នុងភាពជាអ្នកដឹកនាំ។

បច្ចុប្បន្ន អង្គការសុខភាពពិភពលោកបានអំពាវនាវឱ្យមានវិធានការខ្លាំងក្លាបំផុតនៅអាស៊ីអាគ្នេយ៍ ដើម្បីប្រយុទ្ធប្រឆាំងកូរ៉ូណា[៣] ដែលករណីនេះ គេមើលឃើញថា ដោយសារការឆ្លងរីករាលដាលបានកើនឡើងនៅទូទាំងតំបន់នៅក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះ ជាហេតុជំរុញឱ្យប្រទេសមួយចំនួនណែនាំឱ្យចាត់វិធានការសំខាន់ៗជាបន្តបន្ទាប់ មានជាអាទិ៍ការបិទព្រំដែនរបស់ប្រទេសសមាជិកអាស៊ាន ដោយមិនអនុញ្ញាតឱ្យក្រុមអ្នកដំណើរបរទេសចូលក្នុងប្រទេស និងការដាក់បម្រាមគោចរនៅពេលយប់រហូតដល់ការបិទសាលារៀន និងការលុបចោលព្រឹត្តិការណ៍ ការប្រកួតកីឡាធំៗជាដើម។ យើងសង្កេតនៅពេលដែលមានការផ្ទុះជំងឺកូវីដ១៩ នៅប្រទេសម៉ាឡេស៊ីនាសប្តាហ៍កន្លងមក រដ្ឋាភិបាលម៉ាឡេស៊ីបាននិយាយថា នឹងបិទព្រំដែនបណ្តោះអាសន្នពីថ្ងៃទី១៧ ដល់ថ្ងៃ៣១ ខែមីនា។ កត្តានេះបានជះឥទ្ធិពលដល់ពលរដ្ឋម៉ាឡេស៊ីឱ្យភៀសខ្លួនទៅកាន់ប្រទេសសិង្ហបុរី ហើយរដ្ឋាភិបាលសិង្ហបុរីក៏បានបិទព្រំដែនមុនចំណាត់ការរបស់ម៉ាឡេស៊ីបានមកដល់ទៅទៀត។[៤] ដោយឡែក នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ កន្លងទៅ ប្រទេសវៀតណាមក៏បានបិទព្រំដែនជាឯកតោភាគី និងមានវិធានការតឹងរឹងដោយតម្រូវឱ្យអ្នកដំណើរចេញពីកម្ពុជាមានលិខិតបញ្ជាក់សុខភាព ព្រមទាំងឃុំខ្លួនអ្នកទាំងនោះក្នុងកំឡុងពេល១៤ថ្ងៃ ហើយដើម្បីជាការឆ្លើយតបវិញ រដ្ឋាភិបាលកម្ពុជាបានប្រកាសបិទព្រំដែនទាំងអស់វិញ លុះត្រាមានការចរាចរទ្វេភាគីឡើងវិញ។

[៣] ការចុះផ្សាយរបស់កាសែតភ្នំពេញប៉ុស្តិ៍នាថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២០។

[៤] ការចុះផ្សាយរបស់សារព័ត៌មាន រ៉យទ័រ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

លើសពីនេះទៅទៀត ប្រទេសឡាវនិងថៃក៏មានវិធានការតឹងរឹងចំពោះជនបរទេសដែលចូលទៅប្រទេសរបស់គេរៀងៗខ្លួនដែរ ដែលក្នុងនោះ ប្រទេសថៃបានបិទព្រំដែនគោកមួយចំនួនជាមួយកម្ពុជាផងដែរ គឺដើម្បីឆ្លើយតបនឹងវិធានការទប់ស្កាត់ការរីករាលដាលកូវីដ១៩ មិនមែនជាការធ្លាក់ចុះលើផ្នែកសីលធម៌នោះទេ។ ម្យ៉ាងវិញទៀតយើងត្រូវបែងចែកឱ្យបានច្បាស់នូវសីលធម៌ និងការការពារខ្លួនពីវីរុសដ៏កំណាចនេះ តួយ៉ាងដូចជា កាលពីក្នុងខែកុម្ភៈនិងខែមីនា កន្លងទៅថ្មីៗនេះ មានបងប្អូនជនជាតិខ្មែរឥស្លាម ចំនួន៧៩នាក់ ដែលបានធ្វើដំណើរទៅចូលរួមពិធីសាសនាតាមប្រពៃណីរបស់ពួកមូស្លីមនៅប្រទេសម៉ាឡេស៊ី ហើយនៅពេលដែលពួកគាត់ត្រឡប់មកវិញក៏មានបុគ្គលមួយចំនួនបានឆ្លងមេរោគកូវីដ១៩ មកជាមួយ និងបានចម្លងជាបន្តបន្ទាប់ដោយមិនដឹងខ្លួនដល់ប្រជាជននៅក្នុងសហគមន៍របស់គាត់ ហើយនៅពេលនោះមានអ្នកលេងបណ្តាញសង្គម(ហ្វេសប៊ុក)មួយចំនួនបានបញ្ចេញមតិធ្វើឱ្យប៉ះពាល់អារម្មណ៍របស់ពួកគាត់ ទើបពួកគាត់ប្រតិកម្មថា សហគមន៍ខ្មែររើសអើងពួកគាត់។ យ៉ាងណាមិញ នៅពេលដែលក្រសួងសុខាភិបាលប្រកាសថា «អ្នកធ្វើតេស្តកូវីដ១៩វិជ្ជមាន គឺជាខ្មែរឥស្លាម» នោះ ក៏ពួកគាត់យល់ថា ជាពាក្យដែលធ្វើឱ្យមានការរើសអើងពួកគាត់ដែរ គួរថាត្រឹមតែខ្មែរបានហើយ ព្រោះពួកគាត់ក៏ជាខ្មែរដែរ។ តែការហៅបងប្អូនជនជាតិភាគតិចចាមថាជា «ខ្មែរឥស្លាម» ឬការប្រកាសរបស់ក្រសួងសុខាភិបាលថា បងប្អូនខ្មែរឥស្លាមដែលវិលត្រឡប់មកពីការចូលរួមពិធីសាសនាមួយនៅម៉ាឡេស៊ី «បានធ្វើតេស្តកូវីដ១៩ វិជ្ជមាន» មិនមែនជាឥរិយាបថ ឬភាសារើសអើងទេ វាជាភាសាដែលគេប្រើជាធម្មតាសម្រាប់ការកំណត់អត្តសញ្ញាណជនជាតិនីមួយៗតែប៉ុណ្ណោះ។ ឧទាហរណ៍ ខ្មែរឥស្លាម១០នាក់បានធ្វើតេស្តកូវីដ១៩ វិជ្ជមាន ជនជាតិម៉ាឡេស៊ី៦នាក់បានធ្វើតេស្តកូវីដ១៩ វិជ្ជមាន ជនជាតិបារាំង២នាក់បានធ្វើតេស្តកូវីដ១៩ វិជ្ជមាន ជាដើម។ លើសពីនេះទៀត សូមយើងគួរកុំយល់ច្រឡំថា ជាការរើសអើងចំពោះការដាក់មនុស្សណាម្នាក់ ឬក្រុមណាមួយដែលគេសង្ស័យថាអាចមានការឆ្លងជំងឺកូវីដ១៩ឱ្យនៅដាច់ដោយឡែក។ ក៏ដូចជាការព្យាបាលអ្នកជំងឺកូវីដ១៩ក្នុងបន្ទប់ដោយឡែក ព្រោះដើម្បីបង្ការការពារការឆ្លង ទើបគ្រូពេទ្យត្រូវពាក់ម៉ាស ពាក់ស្រោមដៃ និងត្រូវស្លៀកសម្លៀកបំពាក់សុវត្ថិភាពក្នុងពេលពិនិត្យនិងព្យាបាលអ្នកជំងឺកូវីដ១៩។ ក៏ដូចជាប្រជាពលរដ្ឋទូទៅដែរត្រូវតែពាក់ម៉ាសក្នុងពេលបំពេញការងារ ពេលចូលទៅក្នុងទីប្រជុំជន មិនសូវហ៊ានស្និទ្ធស្នាលជាមួយអ្នកដែល

ធ្លាប់ធ្វើការជាមួយគ្នាដោយហេតុតែគេសង្ស័យថា មានជាប់ពាក់ព័ន្ធនឹងជំងឺកូវីដ១៩នោះ។ តាមពិត គោលការណ៍នេះ គឺជាបច្ចេកទេសសុខាភិបាល ដែលតម្រូវឱ្យគ្រូពេទ្យ និងមហាជនទូទាំងពិភពលោកប្រើប្រាស់ជាទូទៅ តាំងពីយូរណាស់មកហើយសម្រាប់ករណីមានជំងឺឆ្លងគ្រប់ប្រភេទ កុំថាឡើយជំងឺកូវីដ១៩នេះ។

បើនិយាយពីការជួយគ្នា និងការចែករំលែកគ្នាក៏ឃើញថា ក្នុងអំឡុងនៃការរាតត្បាតនៃជំងឺនេះមានបងប្អូនខ្មែរយើងមួយចំនួនដែលមានលទ្ធភាពក៏បានបរិច្ចាគនូវគ្រឿងឧបភោគបរិភោគដល់អ្នកខ្វះខាតផងដែរ។ ទន្ទឹមនឹងនោះ តាមការអំពាវនាវរបស់រាជរដ្ឋាភិបាលដែលមានសម្ដេច **ហ៊ុន សែន** ជាប្រមុខដឹកនាំនោះ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ដែលមានលទ្ធភាពបានបរិច្ចាគប្រាក់បៀវត្សរបស់ខ្លួនប្រចាំខែ ឬក៏ក្នុងចំណែកណាមួយ ចាប់ពី៣ខែឡើងទៅដើម្បីជាការចូលរួមចំណែកក្នុងការឧបត្ថម្ភការព្យាបាល ការការពារ និងការទប់ស្កាត់ជំងឺកូវីដ១៩ ដ៏កាចសាហាវនេះផងដែរ។

ជាការសន្និដ្ឋាន នៅពេលដែលមនុស្សបានឆ្លងកាត់ដំណាក់កាលនេះរួច មនុស្សនឹងរឹតតែមានសីលធម៌ល្អប្រសើរឡើង ដ្បិតវីរុសដែលជាគ្រោះកំណាចនេះ បានជួយបង្រៀនមនុស្សនិងផ្ដល់មេរៀន ព្រមទាំងបទពិសោធន៍ឱ្យចេះកែប្រែនូវកំហុសឆ្គង និងអ្វីដែលបានគិតមិនសូវត្រឹមត្រូវពីពេលមុនមក។ ហើយអ្វីដែលកម្ពុជាបានធ្វើកន្លងមកតាមរយៈមេដឹកនាំនោះ គឺការយកចិត្តទុកដាក់ដល់ជីវិតមនុស្សជាតិនិងសិទ្ធិរស់រៀនមានជីវិតដែលនេះជាតម្លៃសីលធម៌ដ៏ខ្ពស់មួយ ដែលមិនអាចកាត់ថ្លៃបាន។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងសង្កេតឃើញថា អាចមានបុគ្គលមួយចំនួនតូចបានប្រើពាក្យពេចន៍អសុរោះ និងធ្វើការអត្ថាធិប្បាយមួយចំនួនដែលធ្វើឱ្យមានការប៉ះពាល់ដល់អារម្មណ៍និងសេចក្ដីថ្លៃថ្នូររបស់បុគ្គលដែលផ្ទុកមេរោគកូវីដ១៩នោះ។ ការបំភ័យឱ្យខ្លាចជ្រុលដែលធ្វើឱ្យបុគ្គលមួយចំនួនបាត់ម្ចាស់ការ ភ័យស្ទន់ស្ទោរ និងងាយនឹងជឿតាមការបំពុលព័ត៌មានរបស់ក្រុមជនមួយចំនួន ដែលបានឆ្លៀតប្រើប្រាស់ការភ័យខ្លាចជ្រុលហួសហេតុរបស់ប្រជាពលរដ្ឋមួយចំនួនទៅបម្រើប្រយោជន៍ផ្ទាល់ខ្លួនដូចជា ការលក់ម៉ាស់ការពារ និងទឹកអាកុលលាងដៃក្នុងតម្លៃថ្លៃ ការបំផុសបំផុល បំភិតបំភ័យពលរដ្ឋឱ្យទិញអង្ករ ត្រីសាច់ និងគ្រឿងឧបភោគដើម្បីរក្សាស្តុកទុកជាដើម។ ដូចករណីឈ្មួញមួយចំនួនបានឆ្លៀតឱកាសដំឡើងថ្លៃទំនិញខុសពីធម្មតា គឺគ្រាន់តែជាកម្រិតបុគ្គលនិងភាគតិច

ប៉ុណ្ណោះ ហើយគួរកុំយកករណីនៃការធ្លាក់ចុះសីលធម៌របស់បុគ្គលមួយចំនួនតូចមកវាយតម្លៃសីលធម៌មនុស្សក្នុងសង្គមទាំងមូល។ ជាក់ស្តែង សូម្បីតែក្នុងវិស័យវិស័យព្រះពុទ្ធសាសនា គ្រាន់តែបុគ្គលសង្ឃមួយឬពីរអង្គដែលអបត្តិនឹងវិន័យព្រះពុទ្ធសាសនា ក៏តាំងស្រែកជៀល ឬថ្កោលទោសទូទៅដែលធ្វើឱ្យប៉ះពាល់ដល់ព្រះសង្ឃភាគច្រើនដែលប្រកាន់ខ្ជាប់នូវវិន័យព្រះពុទ្ធសាសនា បានល្អនោះ។ យ៉ាងណាមិញនៅពេលកម្ពុជាទទួលរងនូវការរាតត្បាតដោយជំងឺកូវីត១៩នេះ ក៏មានបុគ្គលមួយចំនួនបាននិយាយថា សង្គមខ្មែរកំពុងធ្លាក់ចុះនូវសីលធម៌ ដោយសារតែឃើញបុគ្គលមួយចំនួនតូចដែលឆ្លៀតយកឱកាសនេះ កេងចំណេញដោយតម្លើងថ្លៃម៉ាស់ ថ្លៃអាល់កុល ឬដែលអាល់កុលសម្រាប់លាងដៃជាដើម។ ទន្ទឹមនឹងនោះយើងឃើញមានសប្បុរសជនជាច្រើនដែលបានលះបង់សម្ភារ និងថវិការបស់ខ្លួនដើម្បីទប់ស្កាត់និងប្រឆាំងនូវជងឺនេះ ដោយចែកជាម៉ាស់ ជាអាល់កុល គ្រឿងឧបភោគបរិភោគដល់បងប្អូនប្រជាពលរដ្ឋដែលខ្វះខាត ក៏ដូចជាការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រឆាំងនឹងជំងឺដ៏កាចសាហាវនេះផងដែរ។

ហេតុនេះដើម្បីបន្តសាមគ្គីភាព ការសហការ ការចែករំលែក រួមសុខរួមទុក្ខដោយចែកគ្នារស់ មិនដណ្តើមគ្នារស់ និងសុខដុមនីយកម្មក្នុងសង្គមខ្មែរទាំងមូល សូមពលរដ្ឋខ្មែរទាំងអស់បន្តប្រកាន់ខ្ជាប់នូវសីលធម៌ល្អនេះជាដរាប។ យើងមានគំរូតាមរយៈទង្វើដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំ គឺសម្តេចតេជោ **ហ៊ុន សែន** ដែលពិភពលោកកំពុងសរសើរនូវទឹកចិត្តប្រកបដោយសីលធម៌និងគុណធម៌ ដូចជាការអនុញ្ញាតឱ្យនាវា Westerdam ចូលចត ព្រមទាំងបានសង្គ្រោះមនុស្សជាង២០០០នាក់ ការព្យាបាលជនបរទេសដែលមានជំងឺកូវីដ១៩នៅក្នុងប្រទេសកម្ពុជាដោយមិនបង់ប្រាក់ ការគ្រប់គ្រងប្រទេសនិងចាត់វិធានការទប់ស្កាត់បានយ៉ាងល្អ ប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការចូលរួមបរិច្ចាគប្រាក់ខែ ហើយមានមន្ត្រីរាប់ពាន់នាក់ និងសប្បុរសជននានាចូលរួមយ៉ាងសស្រាក់សស្រាំទៅតាមលទ្ធភាពដែលខ្លួនមាន។

សូមសំណូមពរដល់បុគ្គលមួយចំនួនតូចដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន កេងចំណេញលើប្រជាជនដែលកំពុងរងវិបត្តិជំងឺធ្ងន់ធ្ងរ ក៏ដូចជាសំណូមពរដល់អ្នកដែលជាអ្នកលេងបណ្តាញសង្គម ជៀសវាងឱ្យបានការប្រើពាក្យពេចន៍អុជអាល អសុរោះ រោហាសាស្ត្រ និងអត្ថាធិប្បាយណាមួយ ដែលនាំឱ្យប៉ះពាល់អារម្មណ៍ មានជម្លោះ អំពើហិង្សា និង

*ការរើសអើងកើតឡើងនៅក្នុងសង្គម។ សូមកុំយកករណីនៃការខ្វះសីលធម៌របស់បុគ្គលមួយចំនួនតូច មកធ្វើការវាយតម្លៃចំពោះមនុស្សទូទាំងសង្គមបន្តទៀត ដ្បិតសង្គមបច្ចុប្បន្នជាសង្គមកំពុងឈានឆ្ពោះទៅភាពសុខដុមរមនាដោយរួមសហការគ្នាប្រយុទ្ធប្រឆាំងកំចាត់ជំងឺកូវីដ១៩នេះឱ្យបានក្នុងពេលឆាប់ៗខាងមុខតាមរយៈការស្តាប់និងធ្វើតាមការអំពាវនាវរបស់ក្រសួងសុខាភិបាលក៏ដូចជារាជរដ្ឋាភិបាល ដើម្បីនាំសង្គមជាតិឆ្ពោះទៅរកវឌ្ឍនភាពពិតៗ និងជាសង្គមដែលពោរពេញទៅដោយសីលធម៌និងគុណធម៌នៅក្នុងជីវិតរស់នៅលើភពផែនដីដ៏ស្រស់ស្អាតនេះ៕*

**គន្ថនិទ្ទេស**

- *ការចុះផ្សាយរបស់* CAN *នាថ្ងៃសុក្រ ទី៣១ ខែមករា ឆ្នាំ២០២០*
- *កាសែតភ្នំពេញប៉ុស្តិ៍នាថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០*
- *សារព័ត៌មាន រ៉ាយទ័រ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។*

# ស្ថាប័ននីតិប្បញ្ញត្តិ (១៩៩៣-២០១៨)

ដោយៈ បណ្ឌិត **ហែម ឡាច**
មន្ត្រីស្រាវជ្រាវ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា
Email: hemlach1971@gmail.com

## ១- រដ្ឋសភា

រដ្ឋសភាជាអង្គការកំពូលតំណាងប្រជាពលរដ្ឋដែលមានអំណាចនីតិប្បញ្ញត្តិ។ តំណាងរាស្ត្រក្នុងរដ្ឋសភាជាតំណាង ប្រជាជាតិខ្មែរទាំងមូលដែលកើតចេញពីការបោះឆ្នោតជាសកល ដោយសេរីនិងសម្ងាត់ពីប្រជាពលរដ្ឋខ្មែរ។ នីតិកាលរបស់រដ្ឋសភាមានកំណត់៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។

### ១.១- តួនាទីរបស់រដ្ឋសភា

រដ្ឋសភាបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ជាធរមាន។ រដ្ឋសភាមានតួនាទីសំខាន់ៗដូចជាៈ

#### ១.១.១- ការអនុម័ត

- សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។ តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់។

- រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចីការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែ ឬលុបចោលពន្ធដារ។

- រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល។

- រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ។ រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម។ ការអនុម័តខាងលើនេះប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

#### ១.១.២-ទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

- រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកសភាទាំងមូល។

- តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយមកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស។

- រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង

ដោយអនុម័តញត្តិបន្ទោសតាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិកទាំងមូល។ ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួន៣០នាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន។

- តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។ ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូបឬច្រើនរូបអាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូបឬច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។ ចម្លើយរបស់មន្ត្រីឬរបស់នាយកមន្ត្រីអាចធ្វើដោយផ្ទាល់មាត់ឬសរសេរ ជាលាយលក្ខណ៍អក្សរ។

- រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់ការឆ្លើយសំណួរ។

### ១.១.៣-ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ

តំណាងរាស្ត្រធ្វើការងារក្នុងរដ្ឋសភាបីខែ មានវិស្សមកាលបីខែ។ តំណាងរាស្ត្រត្រូវចុះសួរសុខទុក ជួយដោះស្រាយបញ្ហាសំណូម ពររបស់ប្រជាពលរដ្ឋតាមមណ្ឌលរៀងខ្លួន ឬតាមខេត្តទាំងឡាយទូទាំងប្រទេសឱ្យអស់លទ្ធភាព និងត្រូវទាក់ទងជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

## ១.២-អំពីវិសមិតភាពនិងអភ័យឯកសិទ្ធិ

សភាតំណាងរាស្ត្រមិនអាចបំពេញមុខងារជាសមាជិករដ្ឋសភាផងជាសមាជិកព្រឹទ្ធ សភាផងស្របពេលតែមួយបានឡើយ។សមាជិកសភាមានវិសមតិភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលបានចែងក្នុងរដ្ឋធម្មនុញ្ញរៀរលែងតែបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាល។ ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះ មានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុង គណៈកម្មាធិការអចិន្ត្រៃយ៍និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា។ ដើម្បីឱ្យសមាជិកសភាបំពេញតួនាទីជាតំណាងប្រជាពលរដ្ឋ និងប្រជាជាតិបានល្អ រដ្ឋធម្មនុញ្ញបានផ្តល់អភ័យឯកសិទ្ធិសភាជូនសមាជិកសភា តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។អភ័យឯកសិទ្ធិនេះធានាឯករាជ្យភាពរបស់សមាជិកសភា។ តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុ

ពីបានសំដែងយោបល់ឬ បញ្ចេញ មតិក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។

**១.៣- គណៈកម្មាធិការអចិន្ត្រៃយ៍**

គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាត្រូវបានបង្កើតឡើង ដើម្បីជានាដំណើរការរដ្ឋសភាក្នុងចន្លោះសម័យប្រជុំ និងសម្រេចពីរបៀបវរៈប្រជុំពេញអង្គ និងកិច្ចការធំៗរបស់រដ្ឋសភា។ សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍មានដូចតទៅៈ

-ប្រធានរដ្ឋសភា

-អនុប្រធានទាំងពីរ

-ប្រធានគណៈកម្មការនានានៃរដ្ឋសភា។

រដ្ឋសភាបង្កើតគណៈកម្មការជំនាញនានាចំនួន១០ ដើម្បីទទួលពិនិត្យសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នានានិងជាពិសេសទទួលបន្ទុកទៅតាមមុខជំនាញរបស់ខ្លួនក្នុងការត្រួតមើលកិច្ចការរបស់រាជរដ្ឋាភិបាល។

សមា សភាពនៃគណៈកម្មការជំនាញនីមួយៗមានចំនួន៧រូបយ៉ាងតិច។ **គណៈកម្មការជំនាញទាំង១០នោះគឺៈ**

១-គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនង រដ្ឋសភា ព្រឹទ្ធសភា

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣-គណៈកម្មការផែនការ វិនិយោគកសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

៥-គណៈកម្មការកិច្ចការបរទេសសហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន

៦-គណៈកម្មការនីតិកម្ម និងយុត្តិធម៌

៧-គណៈ កម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ចអតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៩-គណៈកម្មការសាធារណៈការដឹកជញ្ជូនទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគររូបនីយកម្ម និងសំណង់

១០-គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ។ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៩៣ដល់បច្ចុប្បន្ននីតិកាលទី១(១៩៩៣១៩៩៨)រៀបចំដោយអ៊ុនតាក់(UNTAC) ២៣-២៨ ឧសភា ១៩៩៣

- គណបក្សចូលរួមប្រកួតប្រជែងមានចំនួន ២០

- ចំនួនអាសនៈ ១២០

- គណបក្សឈ្នះអាសនៈមាន៤ គឺៈ

+គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៥៨អាសនៈ

+គណបក្សប្រជាជនកម្ពុជា ទទួលបាន ៥១អាសនៈ

+គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាទទួលបាន ១០អាសនៈ

+គណបក្សម៉ូលីណាកានិង អ្នកតស៊ូខ្មែរដើម្បីសេរីភាពទទួលបាន ១អាសនៈ។

នីតិកាលទី២(១៩៩៨-២០០៣)

រៀបចំដោយគ.ជ.ប. **២៦-កក្កដា ១៩៩៨**

- គណបក្សចូលរួមប្រកួតប្រជែងមាន ចំនួន ៣៩

- ចំនួនអាសនៈ ១២២

- គណបក្សឈ្នះអាសនៈមាន៣ គឺៈ

+គណបក្សប្រជាជនកម្ពុជាទទួលបាន ៦៤អាសនៈ

+គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ៤៣អាសនៈ

+គណបក្សសម រង្ស៊ីទទួលបាន១៥ អាសនៈ។

នីតិកាលទី៣(២០០៣-២០០៨)

រៀបចំដោយគ.ជ.ប. **២៧-កក្កដា ២០០៣**

-គណបក្សចូលរួមប្រកួតប្រជែងមាន ចំនួន ២៣

- ចំនួនអាសនៈ ១២៣

- គណបក្សឈ្នះអាសនៈមាន៣ គឺៈ

+គណបក្សប្រជាជនកម្ពុជា ទទួលបាន ៧៣អាសនៈ

+គណបក្សហ៊្វុនស៊ិនប៉ិចទទួល បាន ២៦អាសនៈ

+គណបក្សសម រង្ស៊ីទទួល បាន ២៤អាសនៈ។

នីតិកាលទី៤(២០០៨-២០១៣)

រៀបចំដោយគ.ជ.ប. **២៧-កក្កដា ២០០៨**

- គណបក្សចូលរួមប្រកួតប្រជែងមាន ចំនួន ១១

- ចំនួនអាសនៈ ១២៣

- គណបក្សឈ្នះអាសនៈមាន៥ គឺៈ

+គណបក្សប្រជាជនកម្ពុជាទទួលបាន ៩០អាសនៈ

+គណបក្សសម រង្ស៊ីទទួលបាន ២៦ អាសនៈ

+គណបក្សសិទ្ធិមនុស្សទទួលបាន ៣ អាសនៈ

+គណបក្សនរោត្តមរណឫទ្ធិទទួល បាន ២អាសនៈ

+ គណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន ២ អាសនៈ។

នីតិកាលទី៥ (២០១៣-២០១៨)

រៀបចំដោយគ.ជ.ប. **២៨-កក្កដា ២០១៣**

- គណបក្សចូលរួមប្រកួតប្រជែងមានចំនួន ៨

- ចំនួនអាសនៈ ១២៣

- ចំនួនគណបក្សឈ្នះអាសនៈមាន២ គឺ៖

+គណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៨អាសនៈ

+គណបក្សសង្គ្រោះជាតិទទួលបាន ៥៥អាសនៈ។

នីតិកាលទី៦(២០១៨-២០២៣)

រៀបចំដោយគ.ជ.ប. **២៩-កក្កដា ២០១៨**

- គណបក្សចូលរួមប្រកួតប្រជែងមានចំនួន ២០

- ចំនួនអាសនៈ ១២៥

-ចំនួនគណបក្សឈ្នះអាសនៈមាន១ គឺ

+គណបក្សប្រជាជនកម្ពុជាទទួលបាន ១២៥អាសនៈ។

២- ព្រឹទ្ធសភា

ក្រោយការបោះឆ្នោតជាសកល ជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ វិបត្តិនយោបាយផ្ទៃក្នុងមួយបានកើតឡើង។ ដើម្បីដោះស្រាយវិបត្តិនេះកិច្ចប្រជុំកំពូលរវាងថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សនយោបាយទាំងពីរ គឺ គណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិចបានប្រារព្ធឡើងពីថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ នាប្រាសាទខេមរិន្ទ ព្រះបរមរាជវាំង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ដែលនៅពេលនោះព្រះអង្គទ្រង់ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

តាមរយៈលទ្ធផលនៃកិច្ចប្រជុំកំពូលនេះ ស្ថាប័នព្រឹទ្ធសភា ត្រូវបានបង្កើតឡើងនិងក្លាយជាចំណែកមួយនៃស្ថាប័ននីតិប្បញ្ញត្តិជាតិ ដែលមានពីរថ្នាក់ បន្ទាប់ពីរដ្ឋធម្មនុញ្ញនីតិកាលទី២បានធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយការតែងតាំងនិងមានអាណត្តិ៥ឆ្នាំ។ សមាជិកចំនួន៦១រូប ត្រូវបានជ្រើសរើសពីក្នុងចំណោមឥស្សរជនជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២។ ព្រឹទ្ធសភា**នីតិកាលទី១** បានបើកសម័យប្រជុំលើកទី១នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩។ ព្រឹទ្ធសភា**នីតិកាលទី២** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យទី២២ ខែ

មករា ឆ្នាំ២០០៦ ដោយមានអាណត្តិ៦ឆ្នាំ។ ព្រឹទ្ធសភា**នីតិកាលទី៣** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។ ព្រឹទ្ធសភា**នីតិកាលទី៤** កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។ ក្នុងចំណោមសមាជិក៦២រូប មាន៥៨រូបត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាអសកល០២រូបជ្រើសតាំងដោយរដ្ឋសភា និង០២តែងតាំងដោយព្រះមហាក្សត្រ។

## ២.១- ការរៀបចំព្រឹទ្ធសភា

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើនស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ។ សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និងជ្រើសរើសសារជាថ្មីបាន។ នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់៦ឆ្នាំ។ ប៉ុន្តែនីតិកាលទី១មានកំណត់ត្រឹម៥ឆ្នាំ។

- សមាជិកព្រឹទ្ធសភាចំនួន២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ
- សមាជិកព្រឹទ្ធសភាចំនួន២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប។
- សមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភាគឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច៤០ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត។
- ព្រឹទ្ធសភាមានថវិការស្វ័យតសម្រាប់ដំណើរការ។ សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់ចំណាច់។ ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ។ សម័យប្រជុំនីមួយៗមានថិរវេលាយ៉ាងតិចបីខែ។

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា។ សមាជិកព្រឹទ្ធសភារូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។

## ២.២- មុខងារសំខាន់ៗរបស់ព្រឹទ្ធសភា

### ២.២.១- មុខងារនីតិកម្ម

ពិនិត្យឱ្យយោបល់លើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភា និងផ្តួចផ្តើមធ្វើសេចក្តីស្នើច្បាប់។ តួនាទីសំខាន់របស់ព្រឹទ្ធ

*សភាគឺការពិនិត្យឡើងវិញរាល់អត្ថបទច្បាប់ទាំងឡាយដែលរដ្ឋសភាបានអនុម័តរួចហើយ។ រដ្ឋសភាមិនអាចបញ្ជូនច្បាប់ដែលខ្លួនបានអនុម័តរួចហើយឱ្យព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើប្រាសជាផ្លូវការមុនពេលដាក់ជូនឱ្យព្រឹទ្ធសភាពិនិត្យបានឡើយ។រដ្ឋធម្មនុញ្ញមិនបានផ្តល់ឱ្យព្រឹទ្ធសភានូវអំណាចអនុម័តច្បាប់ឬអំណាចជំទាស់អត្ថបទច្បាប់ឡើយ ប៉ុន្តែផ្តល់នូវតួនាទីប្រឹក្សា ឬអំណាចធ្វើអនុសាសន៍ដែលរដ្ឋសភាបានអនុម័ត។ ទោះបីជាព្រឹទ្ធសភាអាចធ្វើការបដិសេធ ឬស្នើធ្វើវិសោធនកម្មទៅលើអត្ថបទច្បាប់ ព្រឹទ្ធសភាពុំមានអំណាចចាប់បង្ខំឱ្យរដ្ឋសភាទួលយកអនុសាសន៍របស់ខ្លួនឡើយ។*

*ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើកបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ។*

### ២.២.២- មុខងារត្រួតពិនិត្យ

*ព្រឹទ្ធសភាអាចតាមដានត្រួតពិនិត្យការងារ និងការអនុវត្តគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាលជាពិសេសត្រួតពិនិត្យការប្រើប្រាស់ថវិកាជាតិរបស់រាជរដ្ឋាភិបាល។*

***-ត្រួតពិនិត្យការអនុវត្តច្បាប់*** *ព្រឹទ្ធសភាមានតួនាទីសំខាន់ក្នុងកាតាមដានដំណើរការងាររបស់ស្ថាប័នរដ្ឋ និងត្រួតពិនិត្យយ៉ាងទៀតទាត់អំពីការអនុវត្តច្បាប់របស់ស្ថាប័ននីតិប្រតិបត្តិ។*

***-ត្រួតពិនិត្យការអនុវត្តកម្មវិធី និងផែនការរបស់រដ្ឋាភិបាល*** *ព្រឹទ្ធសភាក៏ដើរតួនាទីសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តកម្មវិធីនិងផែនការរបស់រាជរដ្ឋាភិបាលលើការងារប្រជាធិបតេយ្យ នីតិរដ្ឋ ការងារកែទម្រង់រដ្ឋការងារកាត់បន្ថយភាពក្រីក្រ ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច។*

### ២.២.៣- មុខងារជាតំណាង

***-តំណាងសមូហភាពដែនដី****(ក្រុមប្រឹក្សាឃុំ-សង្កាត់)ព្រឹទ្ធសភាតំណាងភូមិភាគ និងសមូហភាពដែនដី(ក្រុមប្រឹក្សាឃុំ-សង្កាត់)។មាត្រា៩ និងមាត្រា១១នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបានបង្ហាញច្បាស់អំពីអត្តសញ្ញាណរបស់សមាជិកព្រឹទ្ធសភា។ សមាជិកព្រឹទ្ធសភាត្រូវចុះសួរសុខទុក្ខជួយដោះស្រាយបញ្ហា សំណូមពរ របស់ប្រជាពលរដ្ឋតាម មណ្ឌលរៀងខ្លួន ឬតាម*

រាជធានី ខេត្តទាំងឡាយទូទាំងប្រទេសឱ្យអស់លទ្ធភាពនិងត្រូវទាក់ទងជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

**-តំណាងស្ថាប័នជាតិ**

សមាជិក០២រូប តែងតាំងដោយព្រះមហាក្សត្រ និង០២រូបទៀត ជ្រើសតាំងដោយរដ្ឋសភា។ព្រឹទ្ធសភាក៏តំណាងព្រះមហាក្សត្រ និងរដ្ឋសភា ហើយក៏ជាអ្នកសម្របសម្រួលការងាររដ្ឋសភា និងរាជរដ្ឋាភិបាល។ មាត្រា១១២ បញ្ជាក់ថាព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល។

## ២.៣- គណៈកម្មាធិការអចិន្ត្រៃយ៍

គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភាត្រូវបានបង្កើតឡើង ដើម្បីជានាដំណើរការព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំ និងសម្រេចពីរបៀបវារៈប្រជុំពេញអង្គ និងកិច្ចការធំៗរបស់ព្រឹទ្ធសភា។ សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍មានដូចតទៅះ

-ប្រធានព្រឹទ្ធសភា

-អនុប្រធានទាំងពីរ

-ប្រធានគណៈកម្មការនានានៃព្រឹទ្ធសភា។

ព្រឹទ្ធសភាបង្កើតគណៈកម្មការជំនាញនានាចំនួន១០ ដើម្បីទទួលពិនិត្យសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់នានានិងជាពិសេសទទួលបន្ទុកទៅតាមមុខជំនាញរបស់ខ្លួនក្នុងការត្រួតមើលកិច្ចការរបស់រាជរដ្ឋាភិបាល។ សមាសភាពនៃគណៈកម្មការជំនាញនីមួយៗមានចំនួន៧រូបយ៉ាងតិច។

**គណៈកម្មការជំនាញទាំង១០នោះគឺះ**

១-គណៈកម្មការការពារសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា

២-គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម

៣-គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក

៤-គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ

៥-គណៈកម្មការកិច្ចការបរទេសហប្រតិបត្តិការអន្តរជាតិឃោសនាការ និងព័ត៌មាន

៦-គណៈកម្មការនីតិកម្ម និងយុត្តិធម៌

៧-គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

៨-គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៩-គណៈកម្មការសាធារណៈការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហ

*កម្មវិធីថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគររូបនីយកម្ម និងសំណង់*

*១០-គណៈកម្មការអង្កេតបោសសម្អាត និងប្រឆាំងអំពើពុករលួយ។ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៩៩ដល់បច្ចុប្បន្ន*

*នីតិកាលទី១(១៩៩៩-២០០៦)*

*ព្រឹទ្ធសភានីតិកាលទី១កើតឡើងដោយការតែងតាំងទាំងអស់។ ព្រឹទ្ធសភានីតិកាលទី១ មានសមាជិកចំនួន ៦១រូប ក្នុងនោះគណបក្សប្រជាជនកម្ពុជាមានចំនួន៣១រូប គណបក្សហ៊្វុនស៊ិនប៉ិច ២១រូប គណបក្សសម រង្ស៊ី ៧រូប និង០២រូបទៀតចាត់តាំងដោយព្រះមហាក្សត្រ សម្រាប់រយៈពេល៥ឆ្នាំ។ ព្រឹទ្ធសភានីតិកាលទី១ បានបន្តនីតិកាលរបស់ខ្លួនចំនួន ២ដង (ម្តង១ឆ្នាំ)។*

***នីតិកាលទី២** (២០០៦-២០១២)*

*ព្រឹទ្ធសភានីតិកាលទី២កើតចេញពីការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ សម្រាប់រយៈពេល៦ឆ្នាំ។ នៅក្នុងនីតិកាលទី២នេះ សមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូចនីតិកាលទី១ដែរក្នុងនោះ៤៥រូបមកពីគណបក្សប្រជាជនកម្ពុជា ១០រូបមកពីគណបក្សហ៊្វុនស៊ិនប៉ិច ០២រូបមកពីគណបក្សសម រង្ស៊ី ០២រូបចាត់តាំងដោយព្រះមហាក្សត្រនិង ០២រូបទៀតជ្រើសតាំងដោយរដ្ឋសភា។*

***នីតិកាលទី៣**(២០១២-២០១៨)*

*ការបោះឆ្នោតអសកលជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ បានប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២។ សម្រាប់នីតិកាលទី៣នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន៦១រូប ដូចនីតិកាលទី១ និងនីតិកាលទី២ដែរ ក្នុងនោះមកពីគណបក្សប្រជាជនកម្ពុជា៤៦រូប សម រង្ស៊ី១១រូប ០២រូបចាត់តាំងដោយព្រះមហាក្សត្រ និងជ្រើសតាំងដោយរដ្ឋសភា០២រូប។*

***នីតិកាលទី៤**(២០១៨-២០២៤)*

*ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ បានប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។ សម្រាប់នីតិកាលទី៤ នេះ ចំនួនសមាជិកព្រឹទ្ធសភាមាន៦២រូប ក្នុងនោះមកពីគណបក្សប្រជាជនកម្ពុជាចំនួន៥៨ រូប តែងតាំងដោយព្រះមហាក្សត្រ០២រូប និងជ្រើសតាំងដោយរដ្ឋសភា០២រូប។*

# ផលិតកម្មបន្លែចងក្រងដោយសហគមន៍
# អភិវឌ្ឍន៍កសិកម្មបន្លែចម្រុះជាយក្រុងកំពង់ស្ពឺ

*ដោយ៖ លោក* **យិន ពោ**
*មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រ*
*សង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា*
Email: yinpo9999@gmail.com

*សមាគមន៍អភិវឌ្ឍន៍កសិកម្មបន្លែចម្រុះជាយក្រុងកំពង់ស្ពឺផងដែរ*(Peri Urban Agriculture Cooperative) *ដើម្បីសិក្សាស្វែងយល់ពីចង្វាក់ផលិតកម្ម និងទីផ្សារលក់បន្លែរបស់សហគមន៍ ព្រមទាំងចុះសិក្សាស្វែងយល់ផ្ទាល់ពីការដាំរបស់ប្រជាកសិករនៅភូមិទំពូង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និង ទីតាំងពិសោធន៍ ដាំបន្លែដោយប្រើប្រាស់បាយអូធាជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវ ដែលស្ថិតនៅភូមិប្រកខ្ពង់ ឃុំទ័ពមាន ស្រុកថ្ពង់ ខេត្តកំពង់ស្ពឺ។ លោក* **ចណ្ណា៖ សម្បត្តិ** *ជាលេខាធិការនៃសហគមន៍ បានរៀបរាប់ពីស្ថានភាពទូទៅរបស់សហគមន៍ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៩ គោលបំណងដើម្បីជួយលើកកម្ពស់ជីវភាពក្រីក្រនៅខេត្តកំពង់ស្ពឺ ហើយបច្ចុប្បន្នមានបុគ្គលិកកំពុងបំពេញការងារចំនួន៦នាក់។ សហគមន៍អាចដំណើរការទៅបានដោយទទួលបានប្រាក់ចំណូលមកពីប្រភពបី គឺ៖*

*១. ទិញស្រូវ ដើម្បីផលិតជាអង្ករលក់*

*២. បង្កើតឥណទានខ្នាតតូច ដោយយកការប្រាក់ទាប*

*៣. ចងក្រងសហគមន៍ដាំបន្លែ បានចំនួន៨០គ្រួសារ លើផ្ទៃដីដាំដុះចំនួន៨ ហិកតា។*

` *ទាក់ទងចង្វាក់ផលិតកម្មទិញនិងលក់បន្លែវិញ សមាគមន៍មានទីផ្សារជំមួយ គឺ* Japan Farm Products (Cambodia) Co.,Ltd. (SEA-TS) *ដែលអាចទទួលទិញបន្លែចាប់ពី៧០០ទៅ៨០០គីឡូក្រាមក្នុងមួយថ្ងៃ។ បច្ចុប្បន្នសហគមន៍មានដំណើរការល្អ ពោលគឺអាចលក់បានក្នុង១ថ្ងៃចាប់ពី៣០០ទៅ៤០០គីឡូ*

ក្រោម ដោយក្នុងមួយគីឡូក្រាមតម្លៃ៤០០០ រៀល ក្នុងនោះ មានសាឡាត់ ត្រកួន សាឡាត់ ឡាត់ពណ៌។ល។ ចំពោះតម្លៃវិញ មានការប្រែប្រួលទៅតាមប្រភេទបន្លែ។

លោកស្រីមានប្រសាសន៍បន្តទៀតថា ដោយសារសហគមន៍ធ្វើការបានល្អ ទើបនៅឆ្នាំ២០១៨ សហគមន៍ទទួលបានចំណាត់ថ្នាក់ ព្រមទាំងទទួលបានការលើកទឹកចិត្តទាំងស្មារតី និងសម្ភារៈមួយចំនួនពីរាជរដ្ឋាភិបាល ដើម្បីពង្រីកផលិតកម្មបន្លែមទៀតនូវថវិកាចំនួន១០ ០០០ ០០០ រៀល(ដប់លានរៀល) និងម៉ាស៊ីនបូមទឹកចំនួន១០គ្រឿងផងដែរ។ ទន្ទឹមនឹងការជួយជ្រោមជ្រោងពីសំណាក់រាជរដ្ឋាភិបាល សមាគមន៍តែងតែជួបបញ្ហាមួយចំនួន និងសូមសំណូមពរៈ

- ជួយសង់រោងបន្លែដល់ប្រជាកសិករម្នាក់១ រោងបន្លែមដែលមានទំហំ១០ម៉ែត្រ គុណនឹង ២៥ម៉ែត្រ ឬទំហំ១០ម៉ែត្រ គុណនឹង៥០ម៉ែត្រ។
- ជួយជីកប្រព័ន្ធស្រោចស្រព អណ្តូងឬស្រះជាដើម។

បន្ទាប់ពីសិក្សាស្វែងយល់ពីចរន្តទីផ្សារ ក៏ដូចជាដំណើរការទូទៅរបស់សហគមន៍កន្ទងមក។ លោក **វណ្ណៈ សម្បត្តិ** បានដឹកនាំក្រុមការងារគម្រោងបន្លែ និង ក្រុមការងារគម្រោងបាយអូឌា ចុះទៅសិក្សាស្វែងយល់ផ្ទាល់ពីការដាំរបស់ប្រជាកសិករនៅភូមិទំពូង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ កសិករដាំបន្លែដែលជាសមាជិកនៃសមាគមន៍អភិវឌ្ឍកសិកម្ម បន្លែចម្រុះដាយក្រុងកំពង់ស្ពឺ បានបង្ហាញច្បាស់ថា សហគមន៍បានធ្វើការងារដោយភាពស្មោះត្រង់ជាមួយកសិករ ពិសេសគឺតម្លៃទិញពីកសិករ និងតម្លៃលក់ចេញឱ្យក្រុមហ៊ុនជប៉ុន ឬ លក់ឱ្យឈ្មួញកណ្តាលផ្សេងទៀតដោយមានតម្លាភាព។ ដូច្នេះ កសិករមានជំនឿលើសហគមន៍ ទើបមិនងាកបែររកកន្លែងលក់ថ្មី ទោះបីមានការឈ្មួញកណ្តាលថ្មីៗមកសុំចរចារទិញបន្លែពីពួកគាត់ក៏ដោយ។

សមាគមន៍អភិវឌ្ឍន៍កសិកម្ម បន្លែចម្រុះដាយក្រុងកំពង់ស្ពឺនៅរក្សានិរន្តភាពក្នុងដំណើរការរបស់ខ្លួនបាន ដោយសារតម្លាភាពជាមួយកសិករ ពិសេសគឺភាពស្មោះត្រង់។



ទីតាំងសហគមន៍អភិវឌ្ឍន៍កសិកម្ម បន្លែចម្រុះជាយក្រុងកំពង់ស្ពឺ




សហគមន៍អភិវឌ្ឍន៍កសិកម្ម បន្លែចម្រុះជាយក្រុងកំពង់ស្ពឺ



កសិករកាត់សម្អាតបន្លែមុននឹងថ្លឹងលក់ទៅឱ្យសហគមន៍



កសិករកាត់សម្អាតបន្លែមុននឹងថ្លឹងលក់ទៅឱ្យសហគមន៍

# ប្រវត្តិកីឡាអាស៊ីអាគ្នេយ៍

ដោយៈ បណ្ឌិត **សុខ ស៊ីណា** មន្ត្រីស្រាវជ្រាវនាយកដ្ឋានប្រវត្តិវិទ្យា
និងវិទ្យាសាស្ត្រនយោបាយនៃវិទ្យាស្ថានមនុស្សសាស្ត្រ និង
វិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា
Email: songsyna888@gmail.com

## សេចក្តីផ្តើម

*ក្រៅពីធ្វើឱ្យរាងកាយរឹងមាំ និងមានសុខភាពល្អ កីឡាក៏ជាប្រទេសកម្ពុជាស្ថិតនៅក្នុងភូមិសាស្ត្រអាស៊ីអាគ្នេយ៍ក៏តែងតែបានចូលរួមប្រកួតកីឡានេះជាបន្តបន្ទាប់ផងដែរ។ ដោយសារតែការប្រកួតកីឡាបាននាំមកនូវសារប្រយោជន៍ជាច្រើននោះ ទើបមានការចាប់អារម្មណ៍លើកយកប្រធានបទនេះមកសិក្សាស្រាវជ្រាវ ដើម្បីបង្ហាញនូវប្រវត្តិនៃកីឡាអាស៊ីអាគ្នេយ៍ថា តើការបង្កើតកីឡាក្នុងតំបន់អាស៊ីអាគ្នេយ៍មានប្រវត្តិ និង ការវិវត្តយ៉ាងដូចម្តេចខ្លះ? ហើយការប្រកួតកីឡានេះបានផ្តល់នូវអត្ថប្រយោជន៍អ្វីខ្លះសម្រាប់តំបន់នេះ?*

## ១-ប្រវត្តិកីឡាអាស៊ីអាគ្នេយ៍

*កីឡាអាស៊ីអាគ្នេយ៍មានប្រភពដើមរបស់ខ្លួន ជាប់ទាក់ទងទៅនឹងកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍* (SEAP Games : the South East Asian Peninsula Games)*។ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៥៨ គណៈប្រតិភូមកពីបណ្តាប្រទេសនៅឧបទ្វីបអាស៊ីអាគ្នេយ៍បានទៅចូលរួមក្នុងព្រឹត្តិការណ៍កីឡាអាស៊ី* (Asian Games) *នៅទីក្រុងតូក្យូប្រទេសជប៉ុន ក្នុងឱកាសនោះហើយដែលពួកគេបានជួបប្រជុំគ្នាដើម្បីផ្តួចផ្តើមបង្កើតកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍នេះឡើង។*

*ហេតុផលដែលបានស្នើ គឺថាព្រឹត្តិការណ៍កីឡាក្នុងតំបន់នឹងជួយជំរុញឱ្យមានកិច្ចសហប្រតិបត្តិការ ការយល់ដឹងនិងទំនាក់ទំនងរវាងបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសចំនួន៦ គឺប្រទេសភូមា កម្ពុជា ឡាវ ម៉ាឡេស៊ី ថៃ និងវៀតណាមខាងត្បូង គឺជាសមាជិកស្ថាបនិកនៃកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍។ ប្រទេសទាំងនេះបានព្រមព្រៀងគ្នាដើម្បីរៀបចំការប្រកួតកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍ជារៀងរាល់ឆ្នាំ គឺតាំងពីខែមិថុនា ឆ្នាំ១៩៥៩ រៀងមកហើយគណៈកម្មាធិការសហព័ន្ធកីឡា*

ឧបទ្វីបអាស៊ី អាគ្នេយ៍ក៏ត្រូវបានបង្កើតឡើងផងដែរ។

ការប្រកួតកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍លើកទី១ ត្រូវបានប្រារព្ធឡើងនៅទីក្រុងបាងកក ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៥៩ ដែលមានអត្តពលិក និង មន្ត្រីជាង៥២៧ នាក់មកពីប្រទេសថៃ ភូមា ម៉ាឡេស៊ី សិង្ហបុរី វៀតណាមខាងត្បូង និង ឡាវ ចូលរួមប្រកួតកីឡាចំនួន១២ប្រភេទ។ ក្នុងចំណោមបណ្តាប្រទេសស្ថាបនិកទាំង៦មានតែប្រទេសកម្ពុជាប៉ុណ្ណោះដែលមិនបានចូលរួម។ បណ្តាប្រទេសសមាជិកនៃសហព័ន្ធកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍បានចូលរួមរាល់ពីរឆ្នាំម្តងនៅក្នុងការប្រកួតរហូតដល់ឆ្នាំ១៩៧៥។ ក្នុងនោះមានករណីលើកលែងតែមួយគត់គឺការលុបចោលព្រឹត្តិការណ៍កីឡានេះនៅឆ្នាំ១៩៦៣ (ឆ្នាំដែលត្រូវចំវេននៃប្រទេសកម្ពុជា ព្រឹត្តិការណ៍នេះកម្ពុជាមិនអាចរៀបចំឡើងបានក្រោមហេតុផលបញ្ហានយោបាយ)។

នៅឆ្នាំ១៩៧៥ ក្នុងអំឡុងពេលនៃការប្រកួតលើកទី៨ សហព័ន្ធបានសិក្សាពីជាតុរបស់ប្រទេសហ្វីលីពីន និង ឥណ្ឌូណេស៊ី។ ប្រទេសទាំងពីរនេះត្រូវបានគេទទួលស្គាល់ជាផ្លូវការនៅឆ្នាំ១៩៧៧ ក៏ដូចជាប្រទេសព្រុយណេ ដែលក្រោយមកទៀតនៅតែជាអាណានិគមអង់គ្លេស។ នៅឆ្នាំ១៩៧៧ គឺជាឆ្នាំដែលសហព័ន្ធកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍បានប្តូរឈ្មោះទៅជាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ហើយកីឡានេះបានក្លាយទៅជាកីឡាអាស៊ីអាគ្នេយ៍។ បញ្ជីនៃបណ្តាប្រទេសដែលចូលរួមប្រកួតកីឡាអាស៊ីអាគ្នេយ៍បានពង្រីកបន្ថែមទៀត គឺឆ្នាំ២០០៣ ក្នុងព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី២២ នៅប្រទេសវៀតណាម ដែលពេលនោះគេបានដាក់បញ្ចូលប្រទេសទីម័រខាងកើត បន្ទាប់ពីប្រទេសនេះទទួលបានឯករាជ្យនៅឆ្នាំ២០០២។ កីឡាអាស៊ីអាគ្នេយ៍ គឺជាការប្រកួតពហុកីឡា ប្រព្រឹត្តទៅរៀងរាល់ពីរឆ្នាំម្តង ដែលពាក់ព័ន្ធនឹងប្រទេសចំនួន១១។ ការប្រកួតនេះត្រូវបានរៀបចំដោយសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍និងត្រួតពិនិត្យដោយគណៈ កម្មាធិការអូឡាំពិកអន្តរជាតិ និង ក្រុមប្រឹក្សាអូឡាំពិកអាស៊ី។

## ២-ការប្រកួតកីឡាបាល់ទាត់អាស៊ីអាគ្នេយ៍

ការប្រកួតប្រជែងនេះត្រូវបានរៀបចំឡើងដោយសមាគមបាល់ទាត់អាស៊ាន ដែល

ត្រូវបានទទួលស្គាល់ដោយ FIFA : "Fédération Internationale de Football Association" in French. In English, it is known as International Federation of Association Football។ ការប្រកួតកីឡាបាល់ទាត់អាស៊ានគឺជាការប្រកួតដណ្ដើមជើងឯកបាល់ទាត់នៃប្រជាជាតិអាស៊ាន។ ការប្រកួតនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៦ ក្រោមឈ្មោះថា Tiger Cup។ ការយកឈ្មោះពានរង្វាន់ Tiger Cup នេះគឺដោយផ្អែកលើឈ្មោះស្រាបៀរ Tiger (Tiger Beer) របស់ប្រទេសសិង្ហបុរី ដែលជាអ្នកឧបត្ថម្ភធំនៃការប្រកួតកីឡានេះ។ ចាប់ពីឆ្នាំ២០០៨ មកគេបានប្តូរឈ្មោះទៅជាពានរង្វាន់ Suzuki Cup គឺយកឈ្មោះតាមក្រុមហ៊ុនផលិតម៉ូតូ Suzuki ដែលជាអ្នកឧបត្ថម្ភធំនៃការប្រកួតកីឡានេះ។

## ការប្រកួតកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍ និង ការប្រកួតកីឡាអាស៊ីអាគ្នេយ៍

| ល.រ | កាលបរិច្ឆេទប្រកួត | ប្រទេស | ទីក្រុង | ប្រទេសជ័យលាភី |
|---|---|---|---|---|
| ការប្រកួតកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍ | | | | |
| ១ | ១២-១៧ ខែធ្នូ ឆ្នាំ១៩៥៩ | ថៃ | បាងកក | ថៃ |
| ២ | ១១-១៦ ខែធ្នូ ឆ្នាំ១៩៦១ | ភូមា | យ៉ាងហ្គោន | ភូមា |
| | នៅឆ្នាំ១៩៦៣ (ឆ្នាំដែលត្រូវចំវេននៃប្រទេសកម្ពុជា ព្រឹត្តិការណ៍នេះកម្ពុជាមិនអាចរៀបចំឡើងបានក្រោមហេតុផលបញ្ហានយោបាយ) | | | |
| ៣ | ១៤-២១ ខែធ្នូ ឆ្នាំ១៩៦៥ | ម៉ាឡេស៊ី | គូឡាឡាំពួ | ថៃ |
| ៤ | ៩-១៦ ខែធ្នូ ឆ្នាំ១៩៦៧ | ថៃ | បាងកក | ថៃ |
| ៥ | ៦-១៣ ខែធ្នូ ឆ្នាំ១៩៦៩ | ភូមា | យ៉ាងហ្គោន | ភូមា |
| ៦ | ៦-១៣ ខែធ្នូ ឆ្នាំ១៩៧១ | ម៉ាឡេស៊ី | គូឡាឡាំពួ | ថៃ |
| ៧ | ១-៨ ខែកញ្ញា ឆ្នាំ១៩៧៣ | សិង្ហបុរី | សិង្ហបុរី | ថៃ |
| ៨ | ៩-១៦ ខែធ្នូ ឆ្នាំ១៩៧៥ | ថៃ | បាងកក | ថៃ |

| ការប្រកួតកីឡាអាស៊ីអាគ្នេយ៍ | | | | |
|---|---|---|---|---|
| ៩ | ១៩-២១ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ | ម៉ាឡេស៊ី | គូឡាឡាំពួ | ឥណ្ឌូណេស៊ី |
| ១០ | ២១-៣០ ខែកញ្ញា ឆ្នាំ ១៩៧៩ | ឥណ្ឌូណេស៊ី | ហ្សាការតា | ឥណ្ឌូណេស៊ី |
| ១១ | ៦-១៥ ខែធ្នូ ឆ្នាំ១៩៨១ | ហ្វីលីពីន | ម៉ានីល | ឥណ្ឌូណេស៊ី |
| ១២ | ២៨ ខែឧសភា-៦ ខែមិថុនា ឆ្នាំ១៩៨៣ | សិង្ហបុរី | សិង្ហបុរី | ឥណ្ឌូណេស៊ី |
| ១៣ | ៨-១៧ ខែធ្នូ ឆ្នាំ១៩៨៥ | ថៃ | បាង៍កក | ថៃ |
| ១៤ | ៩-២០ ខែកញ្ញា ឆ្នាំ១៩៨៧ | ឥណ្ឌូណេស៊ី | ហ្សាការតា | ឥណ្ឌូណេស៊ី |
| ១៥ | ២០-៣១ ខែសីហា ឆ្នាំ ១៩៨៩ | ម៉ាឡេស៊ី | គូឡាឡាំពួ | ឥណ្ឌូណេស៊ី |
| ១៦ | ២៤ ខែវិច្ឆិកា-៣ ខែធ្នូ ឆ្នាំ ១៩៩១ | ហ្វីលីពីន | ម៉ានីល | ឥណ្ឌូណេស៊ី |
| ១៧ | ១២-២០ ខែមិថុនា ឆ្នាំ ១៩៩៣ | សិង្ហបុរី | សិង្ហបុរី | ឥណ្ឌូណេស៊ី |
| ១៨ | ៩-១៧ ខែធ្នូ ឆ្នាំ១៩៩៥ | ថៃ | ឈៀងម៉ៃ | ថៃ |
| ១៩ | ១១-១៩ ខែតុលា ឆ្នាំ ១៩៩៧ | ឥណ្ឌូណេស៊ី | ហ្សាការតា | ឥណ្ឌូណេស៊ី |
| ២០ | ៧-១៥ ខែសីហា ឆ្នាំ១៩៩៩ | ព្រុយណេ | បានដាសេរីបេហ្កាវ៉ាន់ | ថៃ |
| ២១ | ៨-១៧ ខែកញ្ញា ឆ្នាំ២០០១ | ម៉ាឡេស៊ី | គូឡាឡាំពួ | ម៉ាឡេស៊ី |
| ២២ | ៥-១៣ ខែធ្នូ ឆ្នាំ២០០៣ | វៀតណាម | ហាណូយ-ហូជីមីញ | វៀតណាម |

| | | | | |
|---|---|---|---|---|
| ២៣ | ២៧ ខែវិច្ឆិកា-៥ ខែធ្នូ ឆ្នាំ ២០០៥ | ហ្វីលីពីន | ម៉ានីល | ហ្វីលីពីន |
| ២៤ | ៦-១៥ ខែធ្នូ ឆ្នាំ២០០៧ | ថៃ | នគររាជសីមា | ថៃ |
| ២៥ | ៩-១៨ ខែធ្នូ ឆ្នាំ២០០៩ | ឡាវ | វៀងចន្ទន៍ | ថៃ |
| ២៦ | ១១-២២ ខែវិច្ឆិកា ឆ្នាំ២០១១ | ឥណ្ឌូណេស៊ី | ហ្សាការតា និង Palembang | ឥណ្ឌូណេស៊ី |
| ២៧ | ១១-២២ ខែវិច្ឆិកា ឆ្នាំ ២០១៣ | មីយ៉ាន់ម៉ា | ណៃពិដោ | ថៃ |
| ២៨ | ៥-១៦ ខែមិថុនា ឆ្នាំ២០១៥ | សិង្ហបុរី | សិង្ហបុរី | ថៃ |
| ២៩ | ១៩-៣០ ខែសីហា ឆ្នាំ ២០១៧ | ម៉ាឡេស៊ី | គូឡាឡាំពួ | ម៉ាឡេស៊ី |
| ៣០ | ៣០ ខែវិច្ឆិកា-១១ ខែធ្នូ ឆ្នាំ ២០១៩ | ហ្វីលីពីន | Various | ហ្វីលីពីន |
| ៣១ | ២១ ខែវិច្ឆិកា-២ ខែធ្នូ ឆ្នាំ ២០២១ | វៀតណាម | ហាណូយ | |
| ៣២ | ៥-១៦ ខែឧសភា ឆ្នាំ ២០២៣ | កម្ពុជា | ភ្នំពេញ | |
| ៣៣ | ៧-១៩ ខែធ្នូ ឆ្នាំ២០២៥ | ថៃ | ចន្ទបុរី | |
| ៣៤ | ២៤ ខែមករា-២៤ ខែកុម្ភៈឆ្នាំ ២០២៧ | ព្រុយណេ | ? | |
| ៣៥ | ២០២៩ | ឡាវ | ? | |

## ៣-រូបសញ្ញាកីឡាអាស៊ីអាគ្នេយ៍

រូបសញ្ញាកីឡាអាស៊ីអាគ្នេយ៍ត្រូវបានដាក់បង្ហាញក្នុងអំឡុងការប្រកួតកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍លើកទី១ ឆ្នាំ១៩៥៩ នៅទីក្រុងបាងកក។ រូបសញ្ញានោះមានរាងជារង្វង់៦ ដែលតំណាងឱ្យសមាជិកស្ថាបនិកចំនួន៦ ហើយរូបសញ្ញានោះត្រូវបានប្រើរហូតដល់ឆ្នាំ១៩៩៧។ នៅឆ្នាំ១៩៩៩ រូបសញ្ញាជារង្វង់៦ បានកើនឡើងដល់ចំនួន១០។ នៅឆ្នាំ២០១១ គេបានដាក់បញ្ចូលប្រទេសទីម័រខាងកើត ហេតុនេះបច្ចុប្បន្នរូបសញ្ញារង្វង់នេះបានឡើងដល់ចំនួន១១។




រូបសញ្ញាកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍ប្រើក្នុង ការប្រកួតលើកទី១ នៅប្រទេសថៃ ឆ្នាំ១៩៥៩ក្លួតលើកទី១



រូបសញ្ញាកីឡាអាស៊ីអាគ្នេយ៍ដែលប្រើបច្ចុប្បន្ន

## ៤-ការប្រកួតកីឡាអាស៊ីអាគ្នេយ៍នៅឆ្នាំ២០១៩

ការប្រកួតកីឡាអាស៊ីអាគ្នេយ៍បានប្រព្រឹត្តទៅពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ នៅប្រទេសហ្វីលីពីន។ ការប្រកួតកីឡាអាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០១៩ គឺជាការប្រកួតលើទី៣០ ដែលមានប្រទេសចំនួន ១១ ស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍បានចូលរួម គឺ ប្រទេសព្រុយណេ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ទីម័រខាងកើត ថៃ និង វៀតណាម។ លទ្ធផលនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍ប្រចាំឆ្នាំ២០១៩ នៅប្រទេសហ្វីលីពីនមានដូចខាងក្រោម ៖

តារាងលទ្ធផលនៃការប្រកួតតាមប្រទេសនីមួយៗ

| ល.រ | ឈ្មោះប្រទេស | មេដាយមាស | មេដាយប្រាក់ | មេដាយសំរិទ្ធ | សរុប |
|---|---|---|---|---|---|
| ១ | ហ្វីលីពីន | ១៤៩ | ១១៧ | ១២១ | ៣៨៧ |
| ២ | វៀតណាម | ៩៨ | ៨៥ | ១០៥ | ២៨៨ |
| ៣ | ថៃ | ៩២ | ១០៣ | ១២៣ | ៣១៨ |
| ៤ | ឥណ្ឌូណេស៊ី | ៧២ | ៨៤ | ១១១ | ២៦៧ |
| ៥ | ម៉ាឡេស៊ី | ៥៦ | ៥៧ | ៧១ | ១៨៤ |
| ៦ | សិង្ហបុរី | ៥៣ | ៤៦ | ៦៨ | ១៦៧ |
| ៧ | មីយ៉ាន់ម៉ា | ៤ | ១៨ | ៥១ | ៧៣ |
| ៨ | កម្ពុជា | ៤ | ៦ | ៣៦ | ៤៦ |
| ៩ | ព្រុយណេ | ២ | ៥ | ៦ | ១៣ |
| ១០ | ឡាវ | ១ | ៥ | ២៩ | ៣៥ |
| ១១ | ទីម័រខាងកើត | ០ | ១ | ៥ | ៦ |
| | សរុប១១ ប្រទេស | ៥៣១ | ៥២៧ | ៧២៦ | ១ ៧៨៤ |

រូបសញ្ញាការប្រកួតកីឡា
អាស៊ីអាគ្នេយ៍លើកទី៣០
នៅប្រទេសហ្វីលីពីន ឆ្នាំ២០១៩

## សន្និដ្ឋាន

*សរុបមកតាមការស្រាវជ្រាវខាងលើ បានបង្ហាញឱ្យឃើញថា កីឡាអាស៊ីអាគ្នេយ៍ មានដើមកំណើតតាំងពីឆ្នាំ១៩៥៨ ហើយព្រឹត្តិការណ៍នៃការប្រកួតជាលើកដំបូងត្រូវបានធ្វើឡើងនៅប្រទេសថៃក្នុងឆ្នាំ១៩៥៩។ កីឡានេះបានវិវត្តជាបន្តបន្ទាប់ ដោយបានពង្រីកនូវសមាជិករបស់ខ្លួនតាំងពីចំនួន៦រហូតដល់បច្ចុប្បន្នមានសមាជិកចំនួន១១ប្រទេស។ ពីឆ្នាំ១៩៥៨ ដល់ឆ្នាំ១៩៧៥គេហៅថាកីឡាឧបទ្វីបអាស៊ីអាគ្នេយ៍ ហើយចាប់ពីឆ្នាំ១៩៧៧ មកកីឡាឧបទ្វីអាស៊ីអាគ្នេយ៍បានប្តូរឈ្មោះទៅជាកីឡាអាស៊ីអាគ្នេយ៍។ ការប្រកួតត្រូវបានធ្វើឡើងរៀងរាល់ពីរឆ្នាំម្តងតាមអក្ខរក្រមនៃឈ្មោះរបស់ប្រទេសជាសមាជិកអាស៊ាន។ តាមរយៈការប្រកួតកីឡាអាស៊ីអាគ្នេយ៍នេះគឺជាការជួយជំរុញនូវកិច្ចសហប្រតិបត្តិការ ការយល់ដឹង។*

## គន្ថនិទ្ទេស


១-អគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ***សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍*** (អាស៊ាន) ភ្នំពេញ ឆ្នាំ១៩៩៨។

២-*The ASEAN CHARTER*, ASEAN Secretariat 2009.

៣-*Jeux d'Asie du Sud-Est,* Wikipédia

៤-*Association des nations de l'Asie du Sud-Est,* Wikipédia.

៥-*Association of Southeast Asian Nations,* Wikipedia.

# ឧស្សាហកម្មសណ្ឋាគារនិងភោជនីយដ្ឋាន
# កម្ពុជាក្នុងដំណាក់កាលកូវីដ-១៩

ដោយ: លោក **ហៃ សុគន្ធា**
មន្ត្រីស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិង
វិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា
Email: haysokunthea@yahoo.com

កូវីដ១៩(COVID-១៩) គឺជាជំងឺឆ្លងថ្មីមួយបង្កឡើងដោយវីរុសកូរ៉ូណាប្រភេទថ្មីដែលបណ្តាលឱ្យមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ។ ប្រភពដំបូងនៃជំងឺនេះត្រូវបានគេកំណត់នាខែធ្នូ ឆ្នាំ២០១៩ នៅទីក្រុងអ៊ូហាន ខេត្តហ៊ឺប៉ី ប្រទេសចិន ហើយចាប់តាំងពីពេលនោះមកវាបានរាលដាលយ៉ាងខ្លាំងពាសពេញសកលលោក។ បើគិតត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ប្រទេសនិងដែនដីចំនួន២១២ នៅក្នុងសកលលោក ត្រូវបានរាយការណ៍ថា មានករណីឆ្លងជំងឺកូវីដ១៩ ទៅលើមនុស្សចំនួនប្រមាណ ៤ ៥៤០ ១៣៦ នាក់ ដែលក្នុងនោះមនុស្សចំនួនប្រមាណ ៣០៣ ៥៨៤ នាក់ បានស្លាប់ និងមនុស្សចំនួនប្រមាណជាង ១ ៧១១ ៤២៨ នាក់ ត្រូវបានព្យាបាលសះស្បើយឡើងវិញ[១]។ រោគរាតត្បាតដោយវីរុសឆ្លងកូរ៉ូណា(COVID-១៩) ដែលបានសាយភាយពាសពេញពិភពលោកក្នុងរយៈពេលតែប៉ុន្មានសប្តាហ៍កន្លងមកនេះ គឺមិនត្រឹមតែមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ដល់សុខភាពសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផ្នែកមួយនៃសេដ្ឋកិច្ចពិភពលោក ក៏ដូចជាឧស្សាហកម្មទេសចរណ៍ផងដែរ។ ជាក់ស្តែង គិតត្រឹមដើមខែឧសភា ឆ្នាំ២០២០ ប្រទេសជាច្រើនទូទាំងសកលលោក បានណែនាំបម្រាមគោចរ និងការរឹតត្បិតការធ្វើដំណើររបស់ប្រជាជនស្ទើរតែទាំងស្រុង ដើម្បីទប់ស្កាត់ការរីករាលដាលនៃវីរុសនេះ។

[១] https://www.worldometers.info/ - coronavirus

តាមលទ្ធផលនៃការស្រាវជ្រាវរបស់អង្គការទេសចរណ៍ពិភពលោក អង្គការសហប្រជាជាតិ(UNWTO) ស្តីអំពីការវាយតម្លៃផលប៉ះពាល់នៃកូវីដ១៩ លើវិស័យទេសចរណ៍អន្តរជាតិ ចេញផ្សាយខែឧសភា ឆ្នាំ២០២០ បានបង្ហាញថា[២]៖ ជំងឺកូវីដ១៩ដែលមិនធ្លាប់មានពីមុនបានប៉ះទង្គិចធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ ពោលគឺចំនួនភ្ញៀវទេសចរអន្តរជាតិបានធ្លាក់ចុះប្រមាណជា២២% នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០ និងអាចបន្តធ្លាក់ចុះប្រមាណពី៦០% ទៅ៨០% ក្នុងឆ្នាំ២០២០ បើធៀបទៅនឹងចំនួនភ្ញៀវទេសចរអន្តរជាតិក្នុងឆ្នាំ២០១៩។ សម្រាប់ ការមកដល់របស់ភ្ញៀវទេសចរអន្តរជាតិនៅក្នុងខែមីនា ឆ្នាំ២០២០ បានធ្លាក់ចុះរហូតដល់៥៧% បន្ទាប់ពីប្រទេសជាច្រើនបានធ្វើការបិទប្រទេស (Lockdown) ការដាក់ពង្រាយការរឹតបន្តឹងការធ្វើដំណើរ ការបិទព្រលានយន្តហោះ និងការបិទព្រំដែនអន្តរជាតិជាដើម ដែលធ្វើឱ្យបាត់បង់ចំនួនអ្នកទេសចរអន្តរជាតិប្រមាណ៦៧លាននាក់ និងខាតចំណូលដែលអាចទទួលបានពីវិស័យនេះប្រមាណជា៨០ពាន់លានដុល្លារអាម៉េរិក។

តាមការស្រាវជ្រាវនិងតាមដានរបស់អង្គការសុខភាពពិភពលោក បានឱ្យដឹងថា កូវីដ ១៩ ប៉ះពាល់យ៉ាងខ្លាំងដល់ឧស្សាហកម្មសេវាកម្ម ក្រោយពីមានមនុស្សជាច្រើន បានឆ្លងកូវីដ ១៩ ពីអ្នកជំងឺម្នាក់ ដែលពួកគេបានអង្គុយញ៉ាំអាហារជិតគ្នានៅក្នុងភោជនីយដ្ឋានបិទជិតមួយកន្លែង។ ការចម្លងនេះបណ្តាលមកពីសំណើមខ្យល់នៃម៉ាស៊ីនត្រជាក់នៅក្នុងភោជនីយដ្ឋាននោះផ្ទាល់តែម្តង ដែលបានចម្លងវីរុសកូរ៉ូណាពីអ្នកមានជំងឺម្នាក់ទៅកាន់មនុស្សច្រើននាក់ផ្សេងទៀតនៅជុំវិញ។ យើងពិតជាបានដឹងគ្រប់គ្នាហើយថា វីរុសចម្លងកូរ៉ូណាឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ដោយតំណក់តូចៗចេញពីសំណើមទឹកមាត់ ហើយក៏មិនងាយនឹងអណ្តែតសាយភាយក្នុងបរិយាកាសឆ្ងាយជាងមួយម៉ែត្រនោះទេ ប៉ុន្តែការចម្លងខ្លះអាចបណ្តាលមកពីម៉ាស៊ីនត្រជាក់នៅក្នុងសណ្ឋាគារ អគារទំនើប ហាងទំនិញ និងភោជនីយដ្ឋានជាដើម ដែលបានបក់ឱ្យតំណក់ទឹកមាត់តូចៗនោះអណ្តែតទៅក្នុងបរិយាកាសបានកាន់តែឆ្ងាយជាង

[២] https://www.unwto.org/news/covid-19-international-tourist-could-fall-60-80-in-2020

ចម្ងាយមួយម៉ែត្រ[៣]។ ការស្រាវជ្រាវបានវាយតម្លៃផងដែរពីផលប៉ះពាល់យ៉ាងធំដល់វិស័យឧស្សាហកម្មសេវាកម្ម ដូចជាសេវាកម្មសណ្ឋាគារ និងសេវាកម្មអាហារនិងភេសជ្ជៈជាដើម ហើយការប៉ះពាល់នេះបានធ្វើឱ្យកម្មករនិយោជិតបាត់បង់ការងារធ្វើ និងបាត់បង់ប្រាក់ចំណូលយ៉ាងច្រើន។ បើតាមការគូសបញ្ជាក់របស់សមាគមន៍ភោជនីយដ្ឋានជាតិ (National Restaurant Association) កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ បានឱ្យដឹងថា គ្រាន់តែឧស្សាហកម្មភោជនីយដ្ឋានតែមួយប៉ុណ្ណោះនៅក្នុងសហរដ្ឋអាម៉េរិក បានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារវិបត្តិកូវីដ១៩ ពោលគឺបុគ្គលិកសេវាកម្មអាហារនិងភេសជ្ជៈប្រមាណជា៨លាននាក់គ្មានការងារធ្វើ និងខាតបង់ទឹកប្រាក់ប្រមាណ៨០ពាន់លានដុល្លាអាម៉េរិក[៤]។

ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាប្រទេសនានាក្នុងសកលលោកដែរ កំពុងរងផលប៉ះពាល់លើវិស័យទេសចរណ៍ ដោយសារតែវិបត្តិនៃការរីករាលដាលនៃជំងឺ Covid-19។ តាមរយៈរបាយការណ៍របស់ក្រសួងទេសចរណ៍បានឱ្យដឹងថា នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០នេះ ប្រទេសកម្ពុជា ទទួលបានភ្ញៀវទេសចរបរទេសបានត្រឹមប្រមាណ ១.១ លាននាក់ប៉ុណ្ណោះ ខណៈភ្ញៀវទេសចរជនជាតិចិននៅតែឈរលំដាប់ទី១ មានជាង២៥ម៉ឺននាក់ ប៉ុន្តែបានធ្លាក់ចុះ៦២% បើធៀបនឹងរយៈពេលដូចគ្នាទៅនឹងឆ្នាំ២០១៩។ ដូចគ្នានេះដែរ វិស័យសណ្ឋាគារ និងផ្ទះសំណាក់ទូទាំងប្រទេសកម្ពុជា បានបន្តបិទទ្វារជាបន្តបន្ទាប់(បណ្តោះអាសន្ន) ដោយសារឥទ្ធិពលនៃជំងឺកូវីដ១៩ ហើយថ្មីៗនេះរាជរដ្ឋាភិបាលបានបញ្ជាឱ្យបិទកាស៊ីណូ បៀរហ្គាជិន ខារ៉ាអូខេ និងរោងភាពយន្តនៅទូទាំងប្រទេសកម្ពុជា ខណៈដែលភោជនីយដ្ឋានមួយចំនួនបានបិទទ្វារដោយខ្លួនឯងដោយសារតែគ្មានភ្ញៀវចូលមករកសេវាកម្មនេះ។ ជាក់ស្តែង គិតត្រឹម ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ មានសណ្ឋាគារចំនួន១៥២ និងផ្ទះសំណាក់ចំនួន២៣៥ បានបិទទ្វារផ្អាកដំណើរការសេវាកម្ម ហើយក្នុងនោះខេត្ត

---

[៣] https://www.construction-property.com/km/chinese-researchers-service-industry

[៤] https://www.nrn.com/operations/national-restaurant-association-releases-coronavirus-reopening-guide-industry

សៀមរាបមានការបិទទ្វារច្រើនជាងគេ ព្រមទាំងបណ្ដាលឱ្យកម្មករនិយោជិត ដែលកំពុងបម្រើការនៅក្នុងវិស័យនេះ ប្រមាណជាង៧ពាន់នាក់ ត្រូវបានបាត់បង់ការងារ ហើយចំនួនតួលេខទាំងនេះ គឺមិនទាន់រាប់បញ្ចូលសេវាកម្មផ្សេងទៀតផង ដូចជា ភោជនីយដ្ឋាន ខារ៉ាអូខេ និងក្លឹបកំសាន្តជាដើម[៥]។

ទោះបីជាមានការធ្លាក់ចុះយ៉ាងគំហុកនូវចំនួនភ្ញៀវទេសចរជាតិ និងបរទេសក៏ដោយ ក៏ឧស្សាហកម្មសណ្ឋាគារ និងភោជនីយដ្ឋានមួយចំនួននៅក្នុងប្រទេសកម្ពុជានៅតែបើកបម្រើសេវាកម្ម ប៉ុន្តែបានកម្រិតសេវាកម្មរបស់ខ្លួនជាអប្បរមាអាស្រ័យទៅនឹងស្ថានភាពជាក់ស្តែង របស់វិស័យទេសចរណ៍ និងអនុវត្តខ្ជាប់ខ្ជួនទៅតាមការណែនាំរបស់ស្ថាប័នជំនាញ ពាក់ព័ន្ធជាមួយនឹងវិធានការការពារជំងឺឆ្លងកូវីដ១៩។ ជាការពិត កាតព្វកិច្ចនៃការថែរក្សាសេវាកម្មជូនអតិថិជនសណ្ឋាគារ និងភោជនីយដ្ឋាននាកំឡុងពេលនៃការរាតត្បាតរបស់មេរោគកូវីដ១៩ គឺជាសកម្មភាពចាំបាច់របស់កម្មករនិយោជិតដើម្បីធានាសុវត្ថិភាពឬសុខុមាលភាពរបស់ភ្ញៀវ ហើយក៏ជាទិដ្ឋភាពដ៏សំខាន់នៃដំណើរប្រតិបត្តិការសណ្ឋាគារ និងភោជនីយដ្ឋានផងដែរ។ ចំណែកឯសណ្ឋាគារជាច្រើនដែលបានបិទដំណើរការ ដោយសារតែការរីករាលដាលនៃជំងឺ កូវីដ១៩ ក៏នៅតែមានការព្រួយបារម្ភអំពីរបៀបដែលនឹងត្រូវអនុវត្តកាតព្វកិច្ចនៃការថែទាំ នៅពេលដែលសណ្ឋាគារ និងភោជនីយដ្ឋានត្រូវបើកដំណើរការឡើងវិញ។ មិនត្រឹមតែស្តង់ដារ អនាម័យដែលតម្រូវដោយរដ្ឋាភិបាលស្តីអំពីការការពាររោគរាតត្បាត និងការកំណត់នូវតម្រូវការថ្មីៗពីអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែការរំពឹងទុករបស់សាធារណជនចំពោះសុខភាព និងសុវត្ថិភាពក៏អាចនឹងមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផងដែរ។

ការថែរក្សាតម្លៃនិងគុណភាពនៃសេវាកម្មនៅក្នុងសណ្ឋាគារ និងភោជនីយដ្ឋាននៅក្នុង សកលលោកក៏ដូចជាប្រទេសកម្ពុជាដែរ គឺនៅតែរក្សាការផ្តល់សេវាកម្មប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ប៉ុន្តែស្ថិតនៅក្នុងដំណាក់កាលនៃវិបត្តិកូវីដ១៩នេះ វិធានការជាច្រើនដែលបានណែនាំពីស្ថាប័ន

[៥] លោក តុប សុកក្រ័ អ្នកនាំពាក្យក្រសួងទេសចរណ៍ ថ្លែងប្រាប់វិទ្យុបារាំង RFI, ២៦ មីនា ២០២០



**រូបភាពទី១៖ ការបាញ់ថ្នាំសម្លាប់មេរោគក្នុងបន្ទប់ស្នាក់នៅសណ្ឋាគារ**
*ប្រភព៖ បណ្ដាញអ្នកបម្រើសេវាកម្មសណ្ឋាគារ*

ជំនាញសុខាភិបាល ត្រូវបានយកអនុវត្តន៍បន្ថែមលើសេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាន។ ដោយសារតែភាពខុសគ្នានៃវិធីសាស្ត្រក្នុងការទាក់ទាញភ្ញៀវរបស់សណ្ឋាគារ ការបង្កើតវិធីច្នៃប្រឌិតជាច្រើន ដើម្បីធ្វើឱ្យសេវាកម្មកាន់តែមានភាពងាយស្រួល ដូចជាការបង្ហោះរូបភាពនៃសកម្មភាពបុគ្គលិកនៅទូទាំងសណ្ឋាគារ តាមបណ្ដាញ សង្គម ឬផ្ញើសារឌីជីថលផ្ទាល់មុនពេលឬកំឡុងពេលចូលស្នាក់នៅ។ បន្ថែមលើសនេះទៀត គឺសណ្ឋាគារបានចែករំលែកប្រវត្តិរបស់កម្មករនិយោជិតនៅលើគេហទំព័រសណ្ឋាគារ ដើម្បីជាការបញ្ជាក់បន្ថែមដល់ភ្ញៀវថា កម្មករនិយោជិតនៅក្នុងសណ្ឋាគារបានត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីផ្ដល់សេវាកម្មកម្រិតខ្ពស់ជាមួយនឹងការធានាសុវត្ថិភាពដល់មនុស្សគ្រប់គ្នានៅក្នុង សណ្ឋាគារ។

ដើម្បីធានាបាននូវដំណើរការដែលមានប្រសិទ្ធភាព និងដោយរលូន

សម្រាប់វិស័យ សណ្ឋាគារ និងភោជនីយដ្ឋាន ការសិក្សាស្រាវជ្រាវនិងចងក្រងគំនិតសំខាន់ៗមួយចំនួននៅពេលធ្វើការផ្លាស់ប្ដូរគោលនយោបាយផ្ទៃក្នុង គឺជាកាតព្វកិច្ចរបស់អ្នកគ្រប់គ្រងនៅតាមសណ្ឋាគារ និងភោជនីយដ្ឋាននីមួយៗ ដើម្បីបំពេញតាមគោលការណ៍សុខភាពសាធារណៈថ្មី ដូចជា ស្ដង់ដារអនាម័យ ការរក្សាគម្លាតសង្គម ការត្រួតពិនិត្យសីតុណ្ហភាព និងការធ្វើចត្តាឡីស័កក្នុងករណីតម្រូវជាដើម។

តាមអង្គការសុខភាពពិភពលោក(WHO) បង្ហាញថាវីរុសកូរ៉ូណាអាចរស់បានរហូតដល់ប្រាំបួនថ្ងៃនៅលើផ្ទៃលោហៈ កញ្ចក់ និងប្លាស្ទិក ដរាបណាពួកវាមិនត្រូវបានសម្អាត[៦]។ ដូច្នេះ

---

[៦] https://www.who.int/emergencies/diseases/novel-coronavirus-2019/question-and-

ការបង្កើនការសម្អាតញឹកញាប់ទីកន្លែងផ្សេងៗរបស់សណ្ឋាគារដូចជា បន្ទប់រង់ចាំ កន្លែងបរិភោគអាហារ បន្ទប់ប្រជុំ ប៊ូតុងជណ្តើរប្រអប់ បង្កាន់ដៃជណ្តើរ ដៃទ្វារ និងកន្លែងជាច្រើនទៀតជាដើម គឺជារឿងអទិភាព។ វីរុសនេះ ក៏អាចរស់បានក្នុងដំណក់ទឹកជាច្រើនម៉ោងនៅក្នុងបរិយាកាសនៃអគារសណ្ឋាគារ ដូច្នេះត្រូវធានាថាបុគ្គលិកទាំងអស់ធ្វើការសម្អាតដោយមានបំពាក់ឧបករណ៍ការពារសមស្រប រួមទាំងស្រោមដៃនិងរបាំងមុខផង។ សណ្ឋាគារ គឺមិនអនុញ្ញាតឱ្យភ្ញៀវថ្មីចូលបន្ទប់ស្នាក់នៅទេ ប្រសិនបើមិនទាន់បានផ្លាស់ប្តូរសម្ភារៈ និងធ្វើការត្រួតពិនិត្យអនាម័យឱ្យល្អិតល្អន់ជាមុនសិន បន្ទាប់ពីភ្ញៀវចាស់បានចាកចេញ។ បន្ថែមពីលើនេះទៀត បុគ្គលិកត្រូវបានផ្តល់ឱ្យនូវឧបករណ៍ការពារ ជាមួយនឹងការបណ្តុះបណ្តាលអំពីរបៀបពាក់និងដោះរបាំងឱ្យបានត្រឹមត្រូវដើម្បីកុំឱ្យកខ្វក់ខ្លួនឯង។

យោងទៅលើសំទុះនៃការរីករាលដាលជំងឺកូវីដ១៩ នាពេលថ្មីៗនេះ បានបណ្តាលឱ្យមនុស្សមានការអនុវត្តអនាម័យផ្ទាល់ខ្លួនខ្ពស់ ពោលគឺភាពស្អាតបានឈានដល់ទីតាំងតែម្តង បើគិតអំពីភាពប្រកួតប្រជែងសម្រាប់សេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាននានា។ ជាការពិត ប្រទេសអភិវឌ្ឍជាច្រើន បានដើរតួនាទីជាប្រទេសឈានមុខគេ ក្នុងការទប់ទល់នឹងរោគរាតត្បាតនេះ ដោយបានដាក់ចេញនូវកម្មវិធីអនាម័យដែលមានប្រសិទ្ធភាពខ្ពស់សម្រាប់វិស័យសណ្ឋាគារ ភោជនីយដ្ឋាន និងគ្រឹះស្ថានទេសចរណ៍ដទៃទៀត។ វិញ្ញាបណ្ណបត្រមានការទទួលស្គាល់ដោយស្ថាប័នជាន់ខ្ពស់ផ្នែកសុខភាព ត្រូវបានដាក់នៅតាមគ្រឹះស្ថាននានា គឺមានគោលបំណងផ្តល់ឱ្យប្រជាជននិងភ្ញៀវទេសចរនូវ "សន្តិភាពផ្លូវចិត្ត" ដែលនឹងទទួលសេវាកម្មសុវត្ថិភាពពីស្ថាប័ននោះ។ ម្យ៉ាងទៀត សណ្ឋាគារទូទាំងសកលលោក បានធ្វើសវនកម្មផ្នែកក្នុងទៅលើដំណើរការសម្អាតដោយផ្ទាល់ ពោលគឺអនុវត្តទៅតាមការណែនាំរបស់ស្ថាប័នសុខាភិបាល ដើម្បីឱ្យដំណើរការសេវាកម្មកាន់តែប្រសើរឡើងស្របតាមស្តង់ដារអន្តរជាតិ ដូចជាប្រទេសដែលផ្តល់ការត្រួតពិនិត្យដោយមជ្ឈមណ្ឌលត្រួតពិនិត្យនិងការពារជំងឺសហរដ្ឋអាមេរិក(CDC) ឬអង្គការសុខភាពពិភពលោក(WHO)។ ការ

---

answers-hub/q-a-detail/q-a-on-infection-prevention-and-control-for-health-care-workers-caring-for-patients-with-suspected-or-confirmed-2019-ncov

ណែនាំ និងអនុសាសន៍មួយចំនួន ដើម្បីការពារឱ្យមានប្រសិទ្ធភាពខ្ពស់លើវិស័យសេវាកម្ម រួមមាន៖

- លាងនិងជូតសម្អាតផ្ទៃរឹងនៃសម្ភារៈទាំងអស់ ដូចជា តុ កៅអី គ្រឿងសង្ហារឹម... ជាមួយនឹងទឹកថ្នាំលាងសម្អាតស្តង់ដារសូលុយស្យុង ឬល្បាយដែលមានកម្រិតជាតិអាល់កុលយ៉ាងតិច ៧០%

- លាងនិងជូតសម្អាតផ្ទៃទន់នៃសម្ភារៈទាំងអស់ ដូចជា កំរាលព្រំ ក្រណាត់... ជាមួយផលិតផលសម្អាតដែលសមស្រប។

- ជូតនិងសម្អាតជាប្រចាំនូវកន្លែងដែលត្រូវបានប៉ះពាល់ញឹកញាប់ ដូចជាដៃទ្វារ កុងតាក់បិទបើកភ្លើង ឧបករណ៍បញ្ជាមេក្នុងបន្ទប់ ប្រអប់សុវត្ថិភាព ម៉ាស៊ីនកាហ្វេ មីនីបារ ឧបករណ៍បញ្ជាទូរទស្សន៍ជាដើម។

- បោកសម្អាតកម្រាលពូក ស្រោមខ្នើយ និងកន្សែងប្រើប្រាស់ជាដើម ជាមួយសាប៊ូដែលមានការទទួលស្គាល់ពីស្ថានប័នជំនាញសុខាភិបាល។ ជូតសម្អាតប្រភេទក្រណាត់ និងសម្ភារៈសម្រាប់តុបតែងលម្អនៅក្នុងបន្ទប់ ដែលមិនងាយនឹងធ្វើការផ្លាស់ប្តូរជាមួយនឹងថ្នាំសម្លាប់មេរោគ និងឧបករណ៍សម្អាតដែលមានការណែនាំដោយស្ថាប័នជំនាញ បន្ទាប់ពីភ្ញៀវចាកចេញពីការស្នាក់នៅ ពោលគឺជានាសុវត្ថិភាពដោយមិនមានការចម្លងតាមរយៈសម្ភារៈប្រើប្រាស់ទាំងនោះទៅកាន់ភ្ញៀវដែលចូលមកស្នាក់នៅពេលបន្ទាប់ឡើយ។




***រូបភាពទី២៖ ការជូតសម្អាតសម្ភារៈភោជនីយដ្ឋានជាមួយនឹងទឹកអាល់កុល***

*ប្រភព៖ សណ្ឋាគារនៅក្នុងរាជធានីភ្នំពេញ*

ដរាបណា ថ្នាំព្យាបាល ឬវ៉ាក់សាំងសម្រាប់ការពារវីរុសប្រភេទនេះ មិនទាន់ត្រូវបានគេរកឃើញ វិធានការការពារសុខភាពសាធារណៈ ដូចជាការរក្សាគម្លាតនៅក្នុងសង្គមរវាងមនុស្សនៅតែសកម្មភាពអទិភាពមួយ និងបានក្លាយទៅជាបទដ្ឋានចាំបាច់ក្នុងសណ្ឋាគារ និងភោជនីយដ្ឋាន។ អាស្រ័យលើប្រទេសនិងរដ្ឋបាលនៅក្នុងតំបន់ សណ្ឋាគារ និងភោជនីយដ្ឋានប្រហែលជាត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិជាក់លាក់សម្រាប់សុខភាពសាធារណៈ ដែលមានវិធានការការពារដូចខាងក្រោម ៖

- ផ្តល់នូវការចែកចាយទឹកស្អាតដែលមានជាតិអាល់កុលដល់ដៃអតិថិជនទូទៅ និងកម្មករនិយោជិតសណ្ឋាគារ ជាពិសេសនៅតំបន់ដែលមានចរាចរណ៍មមាញឹកខ្ពស់ ដូចជាភោជនីយដ្ឋានឬបន្ទប់ប្រជុំជាដើម។

- បង្កើតសញ្ញាសម្គាល់នៃការរក្សាគម្លាតសង្គម ការលាងដៃ ការក្អក និងការកណ្តាស់ជាដើម នៅតាមទីកន្លែងប្រមូលផ្តុំសំខាន់ៗ ដូចជាកន្លែងចុះឈ្មោះនិងចាកចេញពីការស្នាក់នៅ កន្លែងទទួលភ្ញៀវនិងកន្លែងគិតលុយក្នុងភោជនីយដ្ឋានជាដើម។

- រៀបឱ្យមានគម្លាតនៅក្នុងភោជនីយដ្ឋាន ដូចជាកន្លែងរង់ចាំនិងកន្លែងអង្គុយរបស់អតិថិជនត្រូវរក្សាចម្ងាយសមរម្យ(១,៥ម៉ែត្រយ៉ាងតិច) រវាងភ្ញៀវដែលអង្គុយទទួលទាន។

- សម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងភោជនីយដ្ឋាន ត្រូវធ្វើការសម្អាតជាមួយនឹងទឹកថ្នាំក្នុងរយៈពេល២ទៅ៣ម៉ោងម្តងទោះបីជាមិនមានការប្រើប្រាស់ក៏ដោយ ឬអាចមិនបាច់រៀបចំនៅលើតុអាហារភ្ញៀវ ប៉ុន្តែត្រូវផ្តល់ឱ្យភ្ញៀវជាបន្ទាន់នៅពេលមានតម្រូវការ ពោលគឺសម្ភារៈទាំងនោះត្រូវរក្សាទុកកន្លែងសុវត្ថិភាពនៃភោជនីយដ្ឋានតែម្តង។

- កាត់បន្ថយការប្រាស្រ័យទាក់ទងទល់មុខគ្នារវាងបុគ្គលិក និងភ្ញៀវគ្រប់ទីកន្លែងតាមតែអាចធ្វើទៅបាន។

- បុគ្គលិកដែលកំពុងផ្តល់សេវាកម្ម គឺតម្រូវឱ្យពាក់ម៉ាសបិទមុខឬតំឡើងក្បាំងការពារមុខ ក៏ដូចជាអតិថិជនដែរ គឺតម្រូវដោយបទប្បញ្ញត្តិមួយដើម្បីពាក់ម៉ាស់មុខនៅពេលដែលចូលមកទទួលសេវាកម្មផ្សេងៗក្នុងសណ្ឋាគារ និងដើម្បីធានាថា ការប្រាស្រ័យទាក់ទងគ្នាគឺមានសុវត្ថិភាពអំឡុងពេលស្នាក់នៅ។

អ្វីដែលសំខាន់ជាងនេះទៀត គឺភោជនីយដ្ឋាននៅក្នុងព្រះរាជាណាចក្រ

កម្ពុជាទាំងឡាយណាដែលមិនអនុវត្តន៍តាមវិធានអនាម័យក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ឬទប់ស្កាត់មិនឱ្យជំងឺនោះរីករាលដាល ត្រូវផ្អាកជាបណ្ដោះអាសន្ន[៧]។

ភ័យដល់អតិថិជន។ ទោះជាយ៉ាងណាក៏ដោយ ក៏សេវាកម្មអាហារនិងភេសជ្ជៈត្រូវបានកែសម្រួលឡើងវិញដើម្បីឆ្លើយទៅនឹងវិធានការការពារនៃការចម្លងកូវីដ១៩ ដូចជា ការផ្ដល់សេវាកម្មអាហារប៊ូហ្វេឡើងវិញគ្រប់ប្រភេទ រួមបញ្ចូល



**រូបភាពទី៣៖ ការបាញ់អាល់កុលនិងការរៀបចំគម្លាតសង្គមក្នុងភោជនីយដ្ឋាន**

ប្រភព៖ ភោជនីយដ្ឋាននៃសណ្ឋាគារមួយនៅក្នុងរាជធានីភ្នំពេញ

ទោះបីជាមិនមានភស្តុតាងណាមួយបង្ហាញថា អាហារឬការវេចខ្ចប់អាហារ ជាប្រភពនៃការចម្លងCOVID-១៩ក៏ដោយ ក៏សណ្ឋាគារដែលមានកម្មវិធីអាហារនិងភេសជ្ជៈ នៅតែត្រូវការការប្រុងប្រយ័ត្នបន្ថែមជាមួយសេវាកម្មបរិភោគអាហារ ដើម្បីកាត់បន្ថយហានិ

ទាំងអាហារពេលព្រឹក ពេលថ្ងៃត្រង់ និងពេលល្ងាច ជាដើម តែតម្រូវឱ្យមានបុគ្គលិកផ្ដល់សេវាកម្មឈរចាំបម្រើចេញពីតុអាហារប៊ូហ្វេជំនួសឱ្យការបម្រើខ្លួនឯងរបស់អតិថិជន។ ចំពោះអាហារសម្រន់បម្រើដោយខ្លួនឯងវិញត្រូវបានរៀបចំជូនអតិថិជនជាលក្ខណៈបុគ្គល ហើយស្នើសុំឱ្យភ្ញៀវប្រើស្រោមដៃដែលអាចចោលបានបន្ទាប់ពីពេលបម្រើខ្លួនឯង។ ម្យ៉ាងទៀត ការបង្កើតជម្រើសបរិភោគអាហារឱ្យបានច្រើននៅតាមបន្ទប់ស្នាក់នៅ គឺអាចជួយកាត់បន្ថយជម្រើសរបស់អតិថិជនដែលចង់

[៧] បទបញ្ជារបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី ថ្លែងឡើងនៅក្នុងពេលកំពុងដឹកនាំប្រជុំគណៈរដ្ឋមន្ត្រី នាព្រឹកថ្ងៃសុក្រ ទី ១៥ ខែឧសភា ឆ្នាំ២០២០ នៅវិមានសន្តិភាព

ទទួលទានអាហារនៅតាមភោជនីយដ្ឋានសាធារណៈនានា។ ទោះបីជាជម្រើសនៃការផ្តល់សេវាកម្មអាហារនៅតាមបន្ទប់របស់សណ្ឋាគារមួយចំនួនមានកម្រិតក៏ដោយ ក៏ការពង្រីកសេវាកម្មអាហារនិងភេសជ្ជៈនៅតែផ្តល់ជម្រើសច្រើនដល់អតិថិជន តាមរយៈការចាប់ដៃគូជាមួយភោជនីយដ្ឋាននានានៅក្នុងតំបន់ ដើម្បីផ្តល់សេវាកម្មដឹកជញ្ជូនដល់ទីកន្លែង(Home delivery)។

ចំណែកឯការត្រួតពិនិត្យសីតុណ្ហភាពបានក្លាយជារឿងថ្មីនិងធម្មតាមួយ នៅក្នុងតំបន់ ដូចជានៅតាមព្រលានយន្តហោះ តាមការិយាល័យ តាមសណ្ឋាគារ និងតាមភោជនីយដ្ឋានជាដើម។ ការអនុវត្តការត្រួតពិនិត្យសីតុណ្ហភាពនៅតាមសណ្ឋាគារ គឺត្រូវប្រាកដថាត្រូវធ្វើតាមបទបញ្ជានិងការណែនាំនៃវិធានការក្នុងតំបន់ទាំងអស់ ពោលគឺអនុវត្តតាមការណែនាំដោយធ្វើការត្រួតពិនិត្យសីតុណ្ហភាពកម្មករនិយោជិតទាំងអស់ ដូច្នេះបុគ្គលិកដែលមិនមានសុខភាពល្អអាចត្រូវបានបញ្ជូនទៅផ្ទះវិញ។ ដូចគ្នានេះដែរ ការត្រួតពិនិត្យសីតុណ្ហភាពភ្ញៀវ គឺត្រូវប្រាកដថាមាននីតិវិធីដែលមានឯកសារច្បាស់លាស់មានន័យថាបើអ្នកណាម្នាក់ត្រូវបានរកឃើញថាមានសីតុណ្ហភាពខ្ពស់ គឺត្រូវការការពិនិត្យបន្ថែម ឬពិគ្រោះជាមួយវេជ្ជបណ្ឌិតជំនាញភ្លាម។ បន្ថែមលើនេះទៀត នីតិវិធីទាំងនេះត្រូវបានទាក់ទងយ៉ាងច្បាស់លាស់ជាមួយភ្ញៀវមុនពេលពួកគាត់មកដល់ ជាពិសេសភ្ញៀវទេសចរអន្តរជាតិដែលមិនបានទទួលការត្រួតពិនិត្យសីតុណ្ហភាពសាធារណៈ។

ទោះបីជាប្រទេសមួយចំនួន បានចាប់ផ្តើមបន្ធូរបន្ថយការរឹតត្បិតការធ្វើដំណើររបស់ពួកគេក៏ដោយ ក៏ពួកគេនៅតែអាចសម្រេចចិត្តដាក់លក្ខខណ្ឌសម្រាប់អ្នកធ្វើដំណើរចូលក្នុងប្រទេសទាំងអស់ ដូចជា ការដាក់ដាច់ដោយបង្ខំ ឬភាពឯកោដោយខ្លួនឯងជាដើម។ ដោយ អនុវត្តន៍ទៅតាមការរឹតត្បិតការចូលប្រទេសនៃប្រទេសនីមួយៗ សណ្ឋាគារ អាចជូនដំណឹងដល់ភ្ញៀវមុនពេលមកដល់ និងអាចប្រាប់អំពីអ្វីៗដែលនឹងអាចផ្លាស់ប្តូរបានយ៉ាងឆាប់រហ័ស ដើម្បីជានាអំពីផែនការច្បាស់លាស់សម្រាប់ទំនាក់ទំនងដល់អតិថិជនទាំងអស់ ដែលបានកក់រួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់សណ្ឋាគារ និងជូនដំណឹងដល់ដៃគូចែកចាយ។ សណ្ឋាគារ បានរៀបចំនីតិវិធី

និងចងក្រងឯកសារច្បាស់លាស់សម្រាប់គ្រប់គ្រងករណីសង្ស័យនៃកូវីដ១៩ រួមបញ្ចូលទាំងដំណើរការដែលត្រូវកំណត់ និងគ្រប់គ្រងបុគ្គលិកឈឺ អ្នកជួល អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ និងភ្ញៀវសណ្ឋាគារជាដើម ដូចជាៈ

- ការរៀបចំតំបន់ដាច់ពីគ្នាសម្រាប់ករណីសង្ស័យ
- ការរៀបចំការដឹកជញ្ជូនទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលបានកំណត់
- ផែនការជម្លៀសបុគ្គលដែលនៅសេសសល់ក្នុងសណ្ឋាគារ
- ការរៀបចំនីតិវិធីសម្រាប់សម្អាត និងការសម្លាប់មេរោគក្នុងបរិវេណដែលកំពុងប្រឈម ឬអាចជាករណីសង្ស័យ។

ឧស្សាហកម្មសណ្ឋាគារនិងភោជនីយដ្ឋានជាច្រើន បានកាត់បន្ថយចំនួនបុគ្គលិកដែលតម្រូវឱ្យផ្តល់សេវាកម្មនៅក្នុងដំណាក់កាលនេះ ហើយកម្មករនិយោជិតជាច្រើនអាចនឹងមិនមានការងារធ្វើ ប៉ុន្តែគណៈគ្រប់គ្រងនៃសណ្ឋាគារនិងភោជនីយដ្ឋានមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា បានសម្រេចចិត្តឱ្យមានការបម្រើការងារផ្ទាស់គ្នា អាស្រ័យលើបរិមាណនៃតម្រូវការរបស់អតិថិជន។ ឆ្លើយតបនឹងបញ្ហានៃវិបត្តិកូវីដ១៩នេះ អ្នកវិទ្យាសាស្ត្របានផ្តល់ អនុសាសន៍ជាវិធានការមួយចំនួនដើម្បីឱ្យវិស័យសេវាកម្មនេះដើរទៅមុខទៀតបាន ក្នុងកំឡុងពេលនិងក្រោយពេលនៃវិបត្តិនេះ ដែលវិធានការទាំងនេះ មានដូចជា ស្តង់ដារអនាម័យ ការឱ្យមនុស្សអង្គុយបរិភោគអាហារឆ្ងាយពីគ្នាជាពិសេសការញ៉ាំអាហារនៅខាងក្រៅ បុគ្គលិកទាំងអស់ត្រូវពាក់ម៉ាសនិងស្រោមដៃ បង់លុយថ្លៃអាហារតាមប្រព័ន្ធអេឡិចត្រូនិចជំនួសឱ្យការបង់ជាសាច់ប្រាក់ ប្រើបញ្ជីមុខម្ហូបសម្រាប់ភ្ញៀវដែលអាចបោះចោលបានក្រោយពីប្រើរួច ការកែលម្អគុណភាពប្រព័ន្ធចំពោះខ្យល់ និងការកំណត់ចំនួនមនុស្សអតិបរមាក្នុងបន្ទប់ទទួលភ្ញៀវជាដើម។ ប្រសិនបើអាច និយោជកក្រុមហ៊ុននានាគួរធ្វើការចាត់តាំងអ្នកគ្រប់គ្រងសណ្ឋាគារ ឬភោជនីយដ្ឋាន ដែលមានបទពិសោធន៍ចាត់ចែងការត្រួតពិនិត្យការអនុវត្តវិធានការថ្មី និងធានាឱ្យមានការអនុលោមតាមច្បាប់។ ទោះបីជាសណ្ឋាគារ និងភោជនីយដ្ឋានមួយចំនួនត្រូវបានបិទបណ្តោះអាសន្នក៏ដោយ ក៏និយោជកគួររៀបចំនីតិវិធីប្រតិបត្តិតាមស្តង់ដារ ដើម្បីបង្កើតផែនការបណ្តុះបណ្តាលសម្រាប់

កម្មករនិយោជិតពេលដែលសណ្ឋាគារ និងភោជនីយដ្ឋានបើកដំណើរការវិញ។

ជាមួយគ្នានេះដែរ ក្រសួងទេសចរណ៍កម្ពុជាមានចក្ខុវិស័យសុទិដ្ឋិនិយមថា វិស័យទេសចរណ៍កម្ពុជានឹងវិលត្រឡប់ទៅរកភាពប្រសើរឡើងវិញ ក្រោយវិបត្តិនៃការរីករាលដាលជាសកលនៃជំងឺកូវីដ១៩ ស្របតាមយុទ្ធនាការ«Stay Home Today, Travel Tomorrow»។ ក្នុងបរិបទនេះ ភ្ញៀវទេសចរជាតិនិងអន្តរជាតិនឹងមានតម្រូវការកាន់តែខ្ពស់អំពីគុណភាពនៃសេវាកម្ម ជាពិសេសការយកចិត្តទុកដាក់ចំពោះអនាម័យ សុវត្ថិភាព សេវាកម្ម និងផលិតផលទេសចរណ៍។ ក្នុងដំណាក់កាលអន្តរកាលនៃការរង់ចាំស្ថានភាពថយចុះនៃការរីករាលដាលជាសកលនៃវីរុសកូវីដ១៩ ក្រសួងទេសចរណ៍ បានអំពាវនាវដល់ម្ចាស់សណ្ឋាគារ និងសេវាកម្មទេសចរណ៍ទាំងអស់ត្រៀមលក្ខណៈសម្បត្តិ ដោយពង្រឹងគុណភាពសេវាកម្មរបស់ខ្លួនឱ្យបានកាន់តែប្រសើរជាងមុន។ ក្រសួងក៏បានលើកទឹកចិត្តដល់ម្ចាស់អាជីវកម្មទាំងអស់ដែលបានធ្វើអាជីវកម្មច្រើនឆ្នាំកន្លងទៅ គួរឆ្លៀតក្នុងឱកាសនៃវិបត្តិជំងឺឆ្លងនេះ កែលម្អនិងជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីបង្កើនគុណភាពនិងលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងអាចបង្កើនលទ្ធភាពដើម្បីទទួលបានការវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ក្នុងកម្រិតប្រសើរជាងមុនទៀតផង។

**គន្ថនិទ្ទេស**


- បណ្ឌិត ព្រុំ ទេវី *កូវីដ-១៩និងការលក់ចំណីអាហារតាមផ្លូវក្នុងរាជធានីភ្នំពេញ* អត្ថបទស្រាវជ្រាវ ចំនួន១០ ទំព័រ
- ហេង សុភី *សេដ្ឋកិច្ចនិងទេសចរណ៍កម្ពុជាដំណាក់កាលកូវីដ-១៩* អត្ថបទស្រាវជ្រាវ ចំនួន១០ ទំព័រ
- សេចក្តីអំពាវនាវរបស់ក្រសួងទេសចរណ៍លេខ ០០១ សអពន ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០ ***ស្តីអំពីការត្រៀមលក្ខណៈសម្បត្តិសេវាកម្មសណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍ក្នុងការងើបឡើងវិញ (Recovery) ក្រោយជំងឺឆ្លងនៃ វីរុសរលាកផ្លូវដង្ហើមប្រភេទថ្មី(Post Covid 19)***
- សេចក្តីជូនដំណឹងលេខ ០៣២សអ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ របស់ក្រុមហ៊ុនសុខា អូតែល ***ស្តីពីការចាត់ចែងឱ្យបុគ្គលិកឈប់សម្រាកពីការងារដោយឥតប្រាក់ខែ*** ចំនួន០២ខែ គិតចាប់ពីថ្ងៃទី០១ ខែមេសា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។
- https://www.worldometers.info/coronavirus
- https://www.unwto.org/news/covid-19-international-tourist-could-fall-60-80-in-2020
- https://www.construction-property.com/km/chinese-researchers-service-industry-hugely-affected-after-9-people-found-covid19-infected-by-air-conditioning
- https://edition.cnn.com/2020/02/29/health/coronavirus-mask-hysteria-us-trnd/index.html
- https://www.who.int/emergencies/diseases/novel-coronavirus-2019/question-and-answers-hub/q-a-detail/q-a-on-infection-prevention-and-control-for-health-care-workers-caring-for-patients-with-suspected-or-confirmed-2019-ncov
- http://www.rfi.fr/km/កម្ពុជា/20200309
- https://www.unicef.org/cambodia/km
- https://www.khmertimeskh.com/711328/coronavirus-bites-deep-into-the-hospitality-industry
- https://www.nrn.com/operations/national-restaurant-association-releases-coronavirus-reopening-guide-industry

# សេដ្ឋកិច្ចនិងទេសចរណ៍កម្ពុជា
# ក្នុងដំណាក់កាលជំងឺកូវីត១៩

ដោយៈ លោក **ហេង សុភី**
មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា
Email: sophyheng168@yahoo.com

កូវីត១៩ ជំងឺរាតត្បាតសាកលបាននឹងកំពុងរីករាលដាលលើ២១០ប្រទេសនិងដែនដី។ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០នេះ មានអ្នកឆ្លងរហូតដល់៣,៩៣០,៤៨៥នាក់ អ្នកស្លាប់ចំនួន២៧០,៨៧៩នាក់ និងអ្នកព្យាបាលជាសះស្បើយចំនួន ១,៣៤៧,៩៧០ នាក់។ វាជាពេលវេលាដែលមិនប្រាកដប្រជា ហើយបញ្ហាប្រឈមនាពេលនេះ គឺយើងមិនអាចដឹងអំពីជម្រៅនិងរយៈពេលនៃវិបត្តិនេះនៅឡើយទេ។ ដូច្នេះ ទំហំនៃភាពស្មុគស្មាញនៃវិបត្តិជំងឺកូវីត១៩ក៏នៅមិនទាន់ប្រាកដប្រជាដូចគ្នា។ កាន់តែធ្ងន់ធ្ងរជាងនេះទៅទៀត ផលប៉ះពាល់សេដ្ឋកិច្ចសង្គម និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបង្កមកពីជំងឺរាតត្បាតកូវីត១៩ កាន់តែអាក្រក់ទៅៗ។ ក្នុងរបាយការណ៍របស់មូលនិធិរូបិយវត្ថុពិភពលោកដែលចេញផ្សាយនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០ បានឱ្យដឹងថា សេដ្ឋកិច្ចអាស៊ីទំនងជាមិនមានកំណើនឡើយនៅឆ្នាំ២០២០។ លោក Changyong Rhee ប្រធាននាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិបានថ្លែងថា អ្នកធ្វើគោលនយោបាយគួរកំណត់គោលដៅ គាំទ្រដល់ក្រុមហ៊ុននិងក្រុមគ្រួសារទាំងឡាយណាដែលរងគ្រោះខ្លាំងដោយបម្រាមធ្វើដំណើរ គោលនយោបាយគម្លាតសុវត្ថិភាព និងវិធានការទាំងឡាយណាដែលរាំងខ្ទប់ការឆ្លងរបស់ជំងឺកូវីត១៩។ លោកបន្ថែមទៀតថា «សេដ្ឋកិច្ចពិភពលោកនៅពេលនេះមានបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជាខ្ពស់។ ចំណែកតំបន់អាស៊ីប៉ាស៊ីហ្វិកក៏នឹងមិនអាចចៀសផុតបានដែរ។ ផលប៉ះ

ពាល់នៃជំងឺកូវីតនឹងមានលក្ខណៈធ្ងន់ធ្ងរប៉ះពាល់ដល់មនុស្សគ្រប់រូប និងមិនដែលធ្លាប់មានពីមុនមក»។

បើទោះបីជាសេដ្ឋកិច្ចអាស៊ីទទួលផលប៉ះពាល់តិចជាងតំបន់ដទៃទៀត តែការព្យាករណ៍នេះមានសភាព ធ្ងន់ធ្ងរជាងពេលមុន។ ជាក់ស្តែង បើធៀបទៅនឹងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុពិភពលោក សេដ្ឋកិច្ចអាស៊ីមានកំណើន៤,៧ភាគរយ និង ក្នុងពេលមានវិបត្តិហិរញ្ញវត្ថុអាស៊ីនៅចុងឆ្នាំ១៩៩០ សេដ្ឋកិច្ចអាស៊ីមានកំណើន១,៣ ភាគរយ។

ទោះជាយ៉ាងណាក្តី មូលនិធិរូបិយវត្ថុអន្តរជាតិព្យាករថានៅឆ្នាំក្រោយកំណើនសេដ្ឋកិច្ចនៅអាស៊ីអាចនឹងកើនឡើង៧,៦ភាគរយវិញ ដោយរំពឹងថាគោលនយោបាយទប់ស្កាត់ការឆ្លងជំងឺទទួលបានជោគជ័យ ប៉ុន្តែបន្ថែមថាការព្យាករណ៍នេះមានភាពមិនប្រាកដប្រជាខ្ពស់។ ខុសពីវិបត្តិហិរញ្ញវត្ថុសាកលនៅឆ្នាំ២០០៨ ដែលបណ្តាលមកពីការរលំរបស់បណ្តាញហិរញ្ញវត្ថុសាកល Lehman Brothers ជំងឺរាតត្បាតនេះប៉ះពាល់ដោយផ្ទាល់ដល់វិស័យសេវាកម្ម ដោយបង្ខំឲ្យមនុស្សនៅផ្ទះនិងបិទអាជីវកម្ម[១]។

តាមរបាយការណ៍ពីអង្គការទេសចរណ៍ពិភពលោកបានឱ្យដឹងថា នាអំឡុងឆ្នាំ២០២០នេះភ្ញៀវទេសចរទូទាំងពិភព លោកនឹងមានការធ្លាក់ចុះពី២០% ទៅ៣០% ពោលគឺធ្លាក់ចុះពីកំណើនដែលបានប៉ាន់ស្មានពី ៣% ទៅ៤% នាដើមខែមករាឆ្នាំ២០២០។ នេះអាចបណ្តាលឱ្យខាតបង់ពី៣០ ទៅ ៥០ ពាន់លានដុល្លារអាម៉េរិក ក្នុងការ ចំណាយរបស់ភ្ញៀវទេសចរអន្តរជាតិ[២]។ បើធៀបនឹងផលប៉ះពាល់នៃការវាយប្រហារអគារពាណិជ្ជកម្មសហរដ្ឋ អាម៉េរិកក្នុងឆ្នាំ២០០១ ការផ្ទុះឡើងនៃជំងឺសារកាលពីឆ្នាំ២០០៣ និងវិបត្តិសេដ្ឋកិច្ចសាកលឆ្នាំ២០០៩ វិបត្តិលើក នេះគឺធំជាងព្រមទាំងមិនទាន់អាចប៉ាន់ស្មាននៅពេលណាដែលនឹងត្រូវបញ្ចប់។

[១] www.thmeythmey.com/ ចុះផ្សាយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

[២] World Tourism Organization, Impact Assessment of the COVID-19 Outbreak on International Tourism, 24 March 2020.

តារាងទី១៖ ការប៉ាន់ស្មាននៃការធ្លាក់ចុះនៃភ្ញៀវទេសចរពិភពលោកក្នុងឆ្នាំ២០២០




ប្រភព៖ **UNWTO**

កំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានក្នុងអត្រា៧ភាគរយនៅឆ្នាំ២០១៨ និង ២០១៩ ប៉ុន្តែចាប់តាំងពីការ រាតត្បាតជំងឺកូវីត១៩នៅប្រទេសចិនកាលពីដើមខែធ្នូ ឆ្នាំ២០១៩ និងបន្តរាលដាលនៅជុំវិញពិភពលោក បានបង្កឲ្យសេដ្ឋកិច្ចពិភពលោកជាប់គាំងស្ទើរគ្រប់វិស័យ ដោយរួមទាំងសេដ្ឋកិច្ចកម្ពុជាក៏រងផលប៉ះពាល់ដែរ។

«តាមការព្យាកររបស់យើងអត្រាកំណើន GDPកម្ពុជានឹងធ្លាក់ចុះដល់១,៩ ភាគ រយក្នុងឆ្នាំ ២០២០» នេះបើតាមលោក Changyong Rhee ប្រធាននាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដោយ បន្ថែមថាកំណើនសេដ្ឋកិច្ចអាស៊ីនៅឆ្នាំ២០២០ នឹងមិនមានកំណើនជាលើកដំបូងក្នុងរយៈពេល ៦០ឆ្នាំចុងក្រោយ។ ការរងគ្រោះមិនធ្លាប់មានពីមុនមកនេះបណ្ដាលមកពីវិបត្តិជំងឺកូវីត១៩

ដែលប៉ះពាល់ដល់វិស័យសេវាកម្ម និងការនាំចេញទៅកាន់ទីផ្សារចម្បង[៣]។

វិធានការមួយចំនួនដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីត១៩ មានដូចជាការបិទសាលារៀន ក្លឹបកំសាន្ត ឌីស្កូថេក ការ៉ាអូខេ ក្លឹបហាត់ប្រាណ និងការជួបជុំសាសនាជាដើម។ រដ្ឋាភិបាលក៏បានហាមទិដ្ឋាការពីបណ្ដាប្រទេសមួយចំនួនក្នុងការចូលមកប្រទេសកម្ពុជា ក្នុងនោះរួមមានបារាំង អាល្លឺម៉ង់ អ៊ីរ៉ង់ អ៊ីតាលី អេស្ប៉ាញ និងសហរដ្ឋអាម៉េរិក ក្នុងន័យតែមួយគត់គឺទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីត១៩ចូលក្នុងសហគមន៍។ វិធានការនេះត្រូវបានសាទរពីមហាជននិងប្រជាពលរដ្ឋទូទៅ។ ជាលទ្ធផលនៅកម្ពុជា មានករណីឆ្លងតែ១២២នាក់ប៉ុណ្ណោះ ព្យាបាលជាសះស្បើយមានចំនួន១២០នាក់និងមិនមានអ្នកស្លាប់ទេ។ អាត្រានេះ បានធ្វើឱ្យកម្ពុជាមានការព្យាបាលជាសះស្បើយច្រើនជាងគេ បើធៀបក្នុងប្រទេសដែលជាសមាជិកក្នុងសហគមន៍អាស៊ាន។

តាមរបាយការណ៍របស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលបានឱ្យដឹងថា តួលេខនៅខែកុម្ភៈ ឆ្នាំ ២០២០ អ្នកដំណើរតាមជើងយន្តហោះថយចុះ២០ភាគរយ នៅខែមីនាថយចុះជាង៥០ភាគរយ ហើយឈានចូលដល់ខែមេសាឆ្នាំ២០២០ ថយចុះយ៉ាងគំហុករហូតដល់ទៅ៩០ភាគរយ។ នៅសល់៨ទៅ៩ភាគរយនៃដំណើរមក ដល់ពេលនេះភាគច្រើនគឺមកពីកូរ៉េ ជប៉ុន និងចិន។ ក្រុមហ៊ុនហោះហើរបរទេសនៅកម្ពុជាទាំងអស់ចំនួន៣៩ក្រុមហ៊ុន ភាគច្រើនគឺបានផ្អាកការហោះហើរ នៅសល់ចន្លោះតែ៨ទៅ១០ភាគរយតែប៉ុណ្ណោះ ដែលនៅបន្តការហោះហើរ។ មិនមែនតែកម្ពុជាទេ ពិភពលោកទាំងមូលតែម្តងដែលរងផលប៉ះពាល់លើការបាត់បង់អ្នកធ្វើដំណើរតាមជើងហោះហើរដោយសារកូវីត១៩។ មានមូលហេតុធំៗ២យ៉ាងក្នុងបញ្ហានេះគឺ ទី១៖ អ្នកដំណើរមិនហ៊ានធ្វើដំណើរដោយខ្លួនឯង ទី២៖ ប្រទេសខ្លះបានបិទប្រទេសរបស់ខ្លួនមិនឱ្យមានការធ្វើដំណើរចេញចូល[៤]។

[៣] https://thmeythmey.com/ចុះផ្សាយថ្ងៃទី១៧ ខែ មេសា ឆ្នាំ២០២០

[៤] https://thmeythmey.com/ចុះផ្សាយថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០

តាមរបាយការណ៍ស្ថិតិទេសចរណ៍កម្ពុជា នា៣ខែដើមឆ្នាំ២០២០ បានឱ្យដឹងថា ភ្ញៀវទេសចរដែលបានចូលមកប្រទេសកម្ពុជា ១,១៥៥,២២៦នាក់ ថយចុះ-៣៨.១% បើធៀបនឹង៣ខែដើមឆ្នាំ២០១៩មានចំនួន១,៨៧៧,៨៥៣នាក់។ ភ្ញៀវទេសចរអន្តរជាតិចូលតាមផ្លូវអាកាសមានចំនួន៦៦៣,៦៤១នាក់ ក្នុងរយៈពេល៣ខែដើមឆ្នាំ២០២០ ធ្លាក់ចុះ-៤៨.៩%បើធៀបនឹង៣ខែដើមឆ្នាំ២០១៩មានចំនួន១,២៩៩,១២២នាក់។ ភ្ញៀវទេសចរអន្តរជាតិចូលតាមផ្លូវគោកនិងផ្លូវទឹកក្នុងអំឡុង៣ខែដើមឆ្នាំ២០២០មានចំនួន៤៩១,៥៨៥នាក់ ធ្លាក់ចុះ-១៥.១% បើធៀបនឹង៣ខែដើមឆ្នាំ ២០១៩ មានចំនួនភ្ញៀវទេសចរ៥៧៨,៧៣១នាក់[៥]។

ភ្ញៀវទេសចរអន្តរជាតិនឹងបន្តធ្លាក់ចុះទៀតក្នុងអំឡុងខែមេសានិងឧសភាឆ្នាំ២០២០នេះបើតាមការលើកឡើងពីមន្ត្រីអាកាសចរស៊ីវិល ព្រមទាំងទិន្នន័យភ្ញៀវចូលទស្សនាតំបន់អង្គរចេញដោយអាជ្ញាធរអប្សរា។

តារាងទី២៖ ស្ថិតិភ្ញៀវទេសចរបរទេសមកកម្ពុជាក្នុងខែមករានិងកុម្ភៈ

**CAMBODIA: TOURISM STATISTICS REPORT IN THE FIRST QUARTER 2020**

**I. INBOUND TOURISM**

1. International tourist arrivals in January - March 2020

| | Inbound tourism | | | Share (%) | Change (%) | |
|---|---|---|---|---|---|---|
| | 2018 | 2019 | 2020 | 2020* | 19/18 | 2020*/19 |
| **Air** | **1,157,632** | **1,299,122** | **663,641** | **57.4** | **12.2** | **-48.9** |
| Phnom Penh Int'l Airport (PNH) | 495,215 | 581,709 | 365,315 | 31.6 | 17.5 | -37.2 |
| Siem Reap Int'l Airport (REP) | 631,444 | 583,879 | 240,785 | 20.8 | -7.5 | -58.8 |
| Kong Keng (KOS) | 30,973 | 133,534 | 57,541 | 5.0 | 331.1 | -56.9 |
| **Land and Waterways** | **553,621** | **578,731** | **491,585** | **42.6** | **4.5** | **-15.1** |
| Land | 498,016 | 512,309 | 440,096 | 38.1 | 2.9 | -14.1 |
| Waterways | 55,605 | 66,422 | 51,489 | 4.5 | 19.5 | -22.5 |
| **Total** | **1,711,253** | **1,877,853** | **1,155,226** | **100.0** | **9.7** | **-38.5** |

ប្រភព៖ ក្រសួងទេសចរណ៍

[៥] Ministry of Tourism, Tourism Statistics Report in March 2020

*វិបត្តិនៃជំងឺកូវីត១៩ បានធ្វើឱ្យអាជីវកម្មទេសចរណ៍ទាំងឡាយនៅទូទាំងប្រទេសត្រូវបានផ្អាកដំណើរការ និង បិទបញ្ចប់អាជីវកម្មមានចំនួនសរុប២,៨៦៥ទីតាំង ដោយបានធ្វើឱ្យប៉ះពាល់ការងាររបស់បុគ្គលិកចំនួន ៤៦,៣៦៩នាក់ ចំណែកឯមគ្គុទ្ទេសក៍ទេសចរណ៍ដែលបានព្យួរអាជ្ញាបណ្ណទេសចរណ៍មានចំនួនសរុប ៩៦នាក់។*

*បើតាមឯកឧត្តម* **ថោង ខុន** *រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដែលបានថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាននាថ្ងៃទី ២៩ខែមេសាកន្លងទៅនេះ បានឱ្យដឹងថា «គិតត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ អាជីវកម្មទេសចរណ៍ដែលត្រូវបានបិទ (បិទដោយការផ្អាកដំណើរការនិងបិទបញ្ចប់អាជីវកម្ម) នៅទូទាំងប្រទេសមានចំនួនសរុប២,៨៦៥ ទីតាំងស្មើនឹង២៩.៥៧%ធៀបនឹងទីតាំងអាជីវកម្មទេសចរណ៍សរុបដែលមាន៩,៦៨៩ទីតាំង (សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ម៉ាស្សា ស្ប៉ា ទីភ្នាក់ងារទេសចរណ៍ ខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន និងកីឡាទេសចរណ៍) និងប៉ះពាល់ដល់បុគ្គលិកចំនួន៤៦,៣៦៩នាក់ស្មើនឹង ៤២.៦%ធៀបនឹងបុគ្គលិកសរុប ១០៨,៨៤៧ នាក់ និងមគ្គុទ្ទេសក៍ទេសចរណ៍ព្យួរអាជ្ញាបណ្ណទេសចរណ៍សរុបចំនួន៩៦នាក់ស្មើនឹង១.៥% ធៀបនឹង ចំនួនមគ្គុទ្ទេសក៍ទេសចរណ៍សរុប ៦,៤១៦ នាក់»។*

**ចំពោះសេវាកម្មស្នាក់នៅផ្នែកសណ្ឋាគារត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន២៨២ សណ្ឋាគារ (១៥,៤៨៨ បន្ទប់) ស្មើនឹង២៧% ធៀបនឹងចំនួនសណ្ឋាគារសរុបដែលមាន ១,០៤៤ ទីតាំង (៤៨,៧៩១ បន្ទប់) និងប៉ះពាល់បុគ្គលិក១៦,២០៣នាក់ ស្មើនឹង៤១% ធៀបនឹងបុគ្គលិកសរុប៣៩,១៥១នាក់។*

** ចំពោះផ្ទះភ្ញៀវ (ផ្ទះសំណាក់) ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន៤០៥ ទីតាំង (៥,៦៤៤ បន្ទប់) ស្មើនឹង១៥% ធៀបនឹងចំនួនផ្ទះភ្ញៀវសរុបដែលមាន២,៦៤៣ទីតាំង (៣៤,៩៥៧បន្ទប់) និងប៉ះពាល់បុគ្គលិក២,០៨៧នាក់ស្មើនឹង១៩.៥% ធៀបនឹងបុគ្គលិកសរុប១០,៦៦៩ នាក់។*

** ចំពោះភោជនីយដ្ឋាន ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន៣៧១ទីតាំង (១៧,០២៧ កៅអី) ស្មើនឹង១០.៨%ធៀបនឹងចំនួនភោជនីយដ្ឋានសរុបដែលមាន៣,៤១៥ ទីតាំង (១៦៧,៦៣៨កៅអី) ប៉ះពាល់បុគ្គលិក*

៣,២០១នាក់ ស្មើនឹង១១.១១% ធៀបនឹងបុគ្គលិកសរុប២៨,៧៣៨ នាក់។

* ចំពោះទីភ្នាក់ងារទេសចរណ៍ ត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន៤៧ទីតាំងស្មើនឹង៦.៤៧% ធៀបនឹងចំនួនអាជីវកម្មទីភ្នាក់ងារទេសចរណ៍សរុប៧២៦ទីតាំង ប៉ះពាល់បុគ្គលិក២០៨នាក់ស្មើនឹង៦%ធៀបនឹងបុគ្គលិកសរុប៣,៤៤៤ នាក់។

* ចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ បានព្យួរអាជ្ញាបណ្ណទេសចរណ៍នៅទូទាំងប្រទេសមានចំនួន៩៦នាក់ ស្មើនឹង១.៥%ធៀបនឹងចំនួនមគ្គុទ្ទេសក៍ទេសចរណ៍សរុប៦,៤១៦នាក់។

*ចំពោះសេវាកម្មភ្នាក់ទេសចរណ៍មនុស្សពេញវ័យ (ខារ៉ាអូខេ រង្គសាលឌីស្កូតែក បៀហ្គាឌិន) ត្រូវបានបិទអាជីវកម្មទាំងស្រុងនៅទូទាំងប្រទេសមានចំនួន១,១៤៧ទីតាំង ប៉ះពាល់បុគ្គលិកសរុប១៨,២០៤នាក់។ ប្រភេទសេវាកម្មខារ៉ាអូខេត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន៨៨០ទីតាំង(ស្មើនឹង១០០%) និងប៉ះពាល់ បុគ្គលិកសរុប១៤,១៦១នាក់ប្រភេទសេវាកម្មរង្គសាលឌីស្កូតែកត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន២០០ ទីតាំង(ស្មើនឹង១០០%)និងប៉ះពាល់បុគ្គលិកសរុប៣,០៧៨នាក់ ប្រភេទសេវាកម្មបៀហ្គាឌិនត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន៦៧ទីតាំង(ស្មើនឹង១០០%) និងប៉ះពាល់បុគ្គលិកសរុប៩៦៥ នាក់។

* ចំពោះសេវាកម្មស្ប៉ានិងម៉ាស្សាត្រូវបានបិទនៅទូទាំងប្រទេសមានចំនួន៥៩០ទីតាំង(៤,៦៤៤គ្រែ)ស្មើនឹង៨៨%ធៀបនឹងចំនួនអាជីវកម្មស្ប៉ានិងម៉ាស្សាសរុបដែលមាន៦៦៨ទីតាំង(៥,២៩៣គ្រែ) ប៉ះពាល់បុគ្គលិក៥,៩៤៨នាក់ ស្មើនឹង៩៥% ធៀបនឹងបុគ្គលិកសរុប៦,២៤៧ នាក់។

* ចំពោះអាជីវកម្មកីឡាទេសចរណ៍ (កីឡាប៊ូលីង អាងហែលទឹក ទូកកែយ៉ាក់ បាឡុងបង្ហោះ ស្នូកឃ័រ ម៉ាស៊ីនហ្គេម) ត្រូវបានផ្អាកបណ្តោះអាសន្ននៅទូទាំងប្រទេសមានចំនួន២៣ទីតាំងស្មើនឹង៥០%ធៀបនឹងចំនួនអាជីវកម្មកីឡាទេសចរណ៍សរុប៤៦ទីតាំង និង

ប៉ះពាល់បុគ្គលិក៥១៨នាក់ស្មើនឹង២២%ធៀបនឹងបុគ្គលិកសរុប ២,៣២២នាក់[៦]។

បន្ថែមលើនេះទៀត ប្រជាពលរដ្ឋដែលកំពុងមានមុខរបរក្នុងលក្ខណៈជាសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចជា អ្នករត់ ម៉ូតូកង់បី នឹងអ្នកលក់ដូរកំប៉ិកកំប៉ុក រទេះរុញ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុក៏កំពុងប្រឈម នឹងបញ្ហាវិបត្តិនេះខ្លាំងដែរ។ នៅខេត្តសៀមរាបនិងខេត្តព្រះសីហនុ ពួកគេរកចំណូលបានម្នាក់ក្នុងមួយថ្ងៃជាមធ្យម ១ម៉ឺនរៀលប៉ុណ្ណោះ ខណៈលើកមុនចំណូលពួកគាត់ ម្នាក់ក្នុង១ថ្ងៃយ៉ាងតិចបំផុតចំនួន៦ម៉ឺនរៀលគឺស្មើនឹង១៥ ដុល្លារ។ ដោយឡែកនៅភ្នំពេញវិញ ក្នុងមួយថ្ងៃពួកគេរកបានប្រមាណ២០ដុល្លារ តែពេលនេះបានធ្លាក់មកនៅត្រឹម៣ម៉ឺនរៀលជាមធ្យម[៧]។ នេះមិនទាន់គិតពីអ្នកលក់វត្ថុអនុស្សាវរីយ៍ផ្សេងៗ ក៏ដូចជាកម្មកររោងចក្រដែលត្រូវបានព្យួរការងារឬក៏បានបិតជាបន្តបន្ទាប់កន្លងមក។

ផលប៉ះពាល់ដែលបណ្តាលមកពីកូវីត ១៩ មានលក្ខណៈធំធេងទៅលើសេដ្ឋកិច្ចសង្គមជាច្រើនទៀត។ សាលាត្រូវបានបិទដោយក្រសួងអប់រំតម្រូវឱ្យសាលាទាំងនោះបង្រៀនតាមលក្ខណៈបច្ចេកវិទ្យាអនឡាញ (ELearning)។ មាតាបិតាសិស្សមួយចំនួនត្រូវជួបបញ្ហាសេដ្ឋកិច្ចមួយផ្នែក រីឯមួយផ្នែកទៀតត្រូវឆ្លៀតដើម្បីបង្ហាត់បង្ហាញ កូនតូចរបស់ខ្លួនក្នុងការរៀនតាមអនឡាញនេះ។ ពួកគេនៅតូចមិនទាន់អាចធ្លាប់ទៅនឹងវិធីបង្រៀនតាមលក្ខណៈបច្ចេកវិទ្យានេះទេ ដែលជាផលលំបាកមួយសម្រាប់មាតាបិតាគ្រប់រូប។ ប្រសិនបើឪពុកម្តាយទាំងនោះមានចំណេះ សមល្មមដើម្បីបង្ហាត់បង្ហាញកូនទាំងនោះមិនថ្វីទេ ប៉ុន្តែបើពួកគាត់ពុំសូវយល់ពីការប្រើប្រាស់បច្ចេកវិទ្យានោះនឹងជួប ការលំបាកកាន់តែខ្លាំងឡើងថែមទៀត។

ក្នុងកាលៈទេសៈដ៏លំបាកនេះ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការទប់ស្កាត់ការរីករាល ដាលនៃជំងឺកូវីត១៩។ ជំហានដំបូងគឺការចាត់វិធានការទប់ស្កាត់ការរីករាលដាលនៅក្នុងសហគមន៍។ បន្ទាប់មក គឺការគិតគូរដោះស្រាយពីផលប៉ះពាល់ផ្សេងៗមកលើសេដ្ឋកិច្ច និងសង្គម។ រាជរដ្ឋាភិបាល

[៦] http://freshnewsasia.com ចេញផ្សាយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

[៧] http://www.rfi.fr/km ផ្សាយថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០២០

បានត្រៀមកញ្ចប់ថវិកា ៣០០លានដុល្លារសហរដ្ឋអាម៉េរិកសម្រាប់បម្រុងជួយគាំពារសង្គម និងសន្តិសុខស្បៀងក្នុងអំឡុងពេលវិបត្តិកូវីត ១៩។ ក្រសួងសេដ្ឋកិច្ចបានបញ្ចេញ "កញ្ចប់ជំនួយសហគ្រិនខ្មែរ" ជួយសម្រួលដល់សហគ្រាសធុនតូចនិងមធ្យម និងធុរកិច្ចបង្កើតថ្មី។ រាជរដ្ឋាភិបាលបានបង្កើតឲ្យមានធនាគារសហគ្រាសធុនតូចនិងមធ្យម (SMEs Bank) ដើម្បីសម្រាប់ផ្តល់ប្រាក់កម្ចីដល់ម្ចាស់សហគ្រាសធនតូចនិងមធ្យមដែលមានអត្រាការទាប ផ្តល់ជូនដល់អ្នកវិនិយោគលើវិស័យ SMEsត្រឹមតែ៧ភាគរយក្នុង១ឆ្នាំ ខណៈដែលមានដើមទុនដំបូងរបស់ធនាគារមានចំនួន ១០០លានដុល្លារសហរដ្ឋអាម៉េរិក។ រហូតមកដល់ពេលនេះ មានសេចក្តីរាយការណ៍ថាមានធនាគារចំនួន៣៣ទៀតបានបរិច្ចាគជួយដល់ធនាគារ SMEs។ ដូច្នេះធនាគារSMEsមានទុនចូលដល់១៥០លានដុល្លារសហរដ្ឋអាម៉េរិកដែលផ្តល់ឲ្យកម្ចីក្នុងអត្រាការប្រាក់៧ភាគរយ។ ចំពោះឥណទាននេះផ្តល់ឱកាសឲ្យម្ចាស់សហគ្រាសធុនតូច និងមធ្យមទទួលឥណទានទុនបង្វិល២០ម៉ឺនដុល្លារ ហើយចំពោះការវិនិយោគទៅលើគ្រឿងម៉ាស៊ីន បានរហូតដល់៣០ម៉ឺនដុល្លារ ក្នុងមួយក្រុមហ៊ុន[៨]។ រាជរដ្ឋាភិបាលក៏បានគិតគូរទៅដល់អ្នកដែលធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធផងដែរតាមរយៈមូលនិធិជួយសង្គមទៅលើពលរដ្ឋ ដែលមានបណ្ណ័ក្រីក្រនិងជនដែលងាយរងគ្រោះ។

រីឯវិស័យទេសចរណ៍ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវវិធានការជាអទិភាពជាបន្តបន្ទាប់ ដើម្បីសម្រាលការ លំបាកនិងជួយដល់វិស័យឯកជន កម្មករនិយោជិតដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិជំងឺកូវីត១៩ ម្ចាស់អាជីវកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និង ទីភ្នាក់ងារទេសចរណ៍ដែលបានព្យួរ ឬនឹងត្រូវព្យួរដាក់ពាក្យ ស្នើសុំព្យួរកិច្ចសន្យាការងារនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមរយៈមន្ទីរការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈរាជធានី-ខេត្តដើម្បីទទួលបានប្រាក់ឧបត្ថម្ភ៤០ដុល្លារអាម៉េរិកក្នុងមួយខែ សម្រាប់រយៈពេលពីរខែពីរាជ រដ្ឋាភិបាលដោយមិនភ្ជាប់លក្ខខណ្ឌតម្រូវឱ្យកម្មករ

[៨] http://freshnewsasia.com/ផ្សាយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០

និយោជិតចូលរួមវគ្គបណ្តុះបណ្តាលជំនាញទន់ (Soft Skills) រយៈពេលខ្លីដែលមានក្នុងវិធានការអន្តរាគមន៍ជុំទី១និងជុំទី២នោះទេ។ ចំពោះមុខអនុវត្តតែរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត និងចំពោះតែអាជីវកម្មដែលបានដាក់ពាក្យព្យួរកិច្ចសន្យា ការងារស្របតាមការណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈតែប៉ុណ្ណោះ។

ស្របពេលនឹងស្ថានភាពនៅទំនេររបស់កម្មករនិយោជិត និងដើម្បីប្រែក្លាយស្ថានភាពប្រឈមបច្ចុប្បន្ន ជាឱកាសក្នុងការពង្រឹងនិងអភិវឌ្ឍសមត្ថភាពអ្នកជំនាញទេសចរណ៍ និងសិស្សនិស្សិត ក្រសួងទេសចរណ៍បាននិងកំពុងជំរុញរៀបចំកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍តាមអនឡាញ សម្រាប់អ្នកបម្រើការនៅក្នុងវិស័យទេសចរណ៍ក៏ដូចជាសម្រាប់សិស្សនិស្សិតដែលសិក្សានៅតាមគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចនិងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍អាចសិក្សាបាននៅគ្រប់ទីកន្លែងនិងគ្រប់ពេលវេលាបាន។

ក្នុងស្ថានភាពពិភពលោក ក៏ដូចជាកម្ពុជាកំពុងប្រឈមនឹងការរីករាលដាលនៃជំងឺកូវីត ១៩ ធនាគារជាតិ នៃកម្ពុជាស្នើសុំឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងអស់ផ្តល់ការអនុគ្រោះបន្ថែមដល់អតិថិជនដើម្បីជួយសម្រាលបន្ទុករបស់ពួកគាត់ ជាពិសេសបន្ធូរបន្ថយកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងឥណទាន ឬលើកលែងការផាកពិន័យផ្សេងៗ ចំពោះអតិថិជនរបស់ខ្លួនរហូតដល់ខែធ្នូ ឆ្នាំ២០២០ខាងមុខនេះ[៩]។

ទោះបីជាមានការយកទុកដាក់ពីរាជរដ្ឋាភិបាល ក្នុងការទប់ទល់និងវិបត្តិផ្សេងៗកើតឡើងដោយជំងឺកូវីត ១៩យ៉ាងណាក្តី ក៏ក្រុមហ៊ុនធុរកិច្ចជាច្រើនកំពុងប្រឈមមុខនឹងការជិតដួលរលំទាំងស្រុង បន្ទាប់ពីពួកគាត់បានព្យាយាមបន្តដំណើរការអាជីវកម្ម ចាប់តាំងពីមានការធ្លាក់ចុះប្រាក់ចំណូលយ៉ាងធំធេង ចាប់តាំងពីដើមឆ្នាំ២០២០ កន្លងទៅ នេះបើតាម (លិខិតរបស់ក្រុមហ៊ុនធុរកិច្ចផ្ញើជូនទៅ

[៩] សេចក្តីប្រកាសរបស់ធនាគារជាតិកម្ពុជា ចេញផ្សាយថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០

ប្រធានសភាពាណិជ្ជកម្មកម្ពុជាកាលពីថ្ងៃទី ២៤ ខែមេសាឆ្នាំ២០២០)។ លិខិតនេះបន្តទៀតថា ទោះបីជារាជរដ្ឋាភិបាល និង ធនាគារជាតិកម្ពុជាបានជំរុញឱ្យម្ចាស់ជួលអចលនទ្រព្យ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្តល់ការគាំទ្រ និងភាពបត់បែនកាន់តែច្រើនដល់ផ្នែកឯកជនយ៉ាងណាក្តី ប៉ុន្តែម្ចាស់ជួលអចលនទ្រព្យ និងស្ថាប័នទាំងនោះភាគច្រើនបដិសេធមិនអនុវត្តតាមការអំពាវនាវនេះឡើយ ដោយសារតែការរំពឹងទុកមានលក្ខណៈមិនស្របតាមភាពជាក់ស្តែង។ ជាសំណូមពរក្រុមហ៊ុនធុរកិច្ច ទាំងនោះបានស្នើដល់រាជ រដ្ឋាភិបាលមេត្តាផ្តល់មូលនិធិចាំបាច់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ និង ធានាឥណទានអនុគ្រោះដើម្បី ទប់ទល់នឹងហានិភ័យនេះ[១០]។ វិធានការពិសេសទាំងនេះរួមមាន (ឥណទានដែលធានាដោយរាជរដ្ឋាភិបាល និង ការលើកលែងសារពើពន្ធ) គឺជាមធ្យោបាយតែមួយគត់ដើម្បីសង្គ្រោះសេដ្ឋកិច្ចរបស់កម្ពុជាដែលកំពុងតែលិចលង់ តាមរយៈកិច្ចខិតខំប្រឹងប្រែងរួមរបស់ភាគីពាក់ព័ន្ធទាំងអស់។ រាជរដ្ឋាភិបាលត្រូវជួយតាមរយៈការផ្តល់ការធានា ចាំបាច់សម្រាប់ឥណទាននិងលើកលែងចោលនូវចំណូលសារពើពន្ធ រីឯវិស័យឯកជនត្រូវជួយតាមរយៈការ ធ្វើកិច្ចសន្យាបំណុលនិងប្តេជ្ញារក្សាចំនួនបុគ្គលិករបស់ខ្លួន ហើយជាការឆ្លើយតបបុគ្គលិកត្រូវជួយតាមរយៈការ ធ្វើការងារមិនពេញម៉ោង។

សរុបសេចក្តីមក ផលប៉ះពាល់ដែលកើតឡើងដោយវិបត្តិជំងឺកូវីត១៩ ពិតជាបានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចសង្គម ទេសចរណ៍ និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលពុំទាន់អាចប៉ាន់ស្មានថាពេលណាដែលត្រូវបញ្ចប់។ កិច្ចខំប្រឹងប្រែងចំពោះមុខរបស់រាជរដ្ឋាភិបាលគឺការរក្សាបាននូវសេចក្តីសុខ សុវត្ថិភាពសុខភាព ទប់ស្កាត់ការរីករាលដាលនៃកូវីត១៩ទៅក្នុងសហគមន៍។ ជំហានជាបន្តបន្ទាប់គឺត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវវិធានការផ្សេងៗដែល បានចេញដោយអង្គការសុខភាពពិភពលោក និង ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដូចជាការលាង ដៃឱ្យបានញឹកញាប់ខ្ជាប់ខ្ជួន ការរក្សាគម្លាតសុវត្ថិភាព

[១០] លិខិតសមាគមន៍ក្រុមហ៊ុនធុរកិច្ចជាតិនិងអន្តរជាតិផ្ញើជូនប្រធានសភាពាណិជ្ជកម្មកម្ពុជា ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២០

សង្គម ការពាក់ម៉ាសនៅពេលទៅកន្លែងដែលមានមនុស្សច្រើននិងវិធានការចាំបាច់មួយចំនួនផ្សេងទៀត។

មិនថាវិស័យទេសចរណ៍ពិភពលោក ឬទេសចរណ៍កម្ពុជា ក្នុងដំណាក់កាលនេះគឺឆ្លងកាត់នៅភាពលំបាកដូចគ្នា។ ដើម្បីចូលរួមទប់ស្កាត់និងដោះស្រាយបញ្ហាប្រឈមទាំងនេះ ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជាបានខិតខំប្រឹងប្រែងបង្កើតស្តង់ដាថ្មីៗបន្ថែមទៀត ដូចជា ស្តង់ដាសេវាកម្មស្នាក់ នៅ សេវាកម្មម្ហូបអាហារ និងសេវាកម្មទេសចរណ៍សហគមន៍-រមណីយដ្ឋានទេសចរណ៍ ដើម្បីបង្កើបឱ្យមានសកម្មភាពទេសចរណ៍ឬចលនាទេសចរក្នុងប្រទេសឡើងវិញ ដែលធានាបាននូវសុវត្ថិភាពសុខភាពរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរទាំងអស់គ្នាជាដាច់ខាត។ ស្តង់ដាអាជីវកម្មទេសចរណ៍ថ្មីនេះនឹងមានការចេញប្រកាសឱ្យអនុវត្តជាផ្លូវការយ៉ាងយូរត្រឹមចុងខែឧសភា ឆ្នាំ២០២០។ បន្ថែមទៀត ក្រសួងក៏បាននឹងកំពុងបង្កើតកម្មវិធីសិក្សាបង្រៀនជាលក្ខណៈអនឡាញ ដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សដែលកំពុងបម្រើក្នុងវិស័យទេសចរណ៍ឱ្យកាន់តែមានសមត្ថភាពប្រសើរជាងមុន ដើម្បីត្រៀមទទួលការត្រឡប់មកវិញនៃភ្ញៀវទេសចរគ្រប់ជាតិសាសន៍ បន្ទាប់ពីវិបត្តិកូវីត១៩។ ការពង្រឹងបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា ភាពស្អាតនៃផ្លូវធ្វើដំណើរ ភាពស្អាតនៃចំណីអាហារ ភាពស្អាតកន្លែងស្នាក់នៅ ភាពស្អាតនៃស្នាមញញឹមរួសរាយរាក់ទាក់របស់ប្រជាពលរដ្ឋខ្មែរ ភាពស្អាតនៃតម្លៃសេវាកម្មផ្សេងៗ និងភាពស្អាតនៃតំបន់រមណីយដ្ឋានទេសចរណ៍ប្រកបដោយភាពទាក់ទាញ និងដោយភាពច្នៃប្រឌិត ដែលទាំងនេះកើតឡើងពីស្ថាប័នរដ្ឋ ឯកជន សហគមន៍ ព្រមទាំងប្រជាពលរដ្ឋទូទៅ ត្រូវតែចូលរួមទាំងអស់គ្នា ព្រមទាំងមានផែនការច្បាស់លាស់ផងដែរ។ ក្រសួងទេសចរណ៍គួរតែត្រៀមកញ្ចប់ថវិកាដើម្បីត្រៀមផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ពិភពលោកនៅពេលដែលវិបត្តិកូវីត១៩បានបញ្ចប់។ ប្រសិនបើ ស្ថានភាពវិបត្តិនេះនៅបន្តរយៈពេលយូរទៀត ក្រសួងទេសចរណ៍កម្ពុជា គួរតែស្នើទៅអង្គការទេសចរណ៍ពិភពលោក ដើម្បីរកចំណុចរួមមួយក្នុងការសម្រាល និងស្រោចស្រង់ដល់វិស័យនេះ ដូចជាការចេញបណ្ណធ្វើដំណើរដល់ពលរដ្ឋណាដែលគ្មានជំងឺកូវីត១៩អាចធ្វើដំណើរទូទាំងពិភពលោកបាន។

វិបត្តិកូវីត១៩បានផ្តល់ឱកាសដល់វិស័យកសិកម្មកម្ពុជាឱ្យមានភាពប្រសើរជាងមុន ដោយរាជរដ្ឋាភិបាលបានបញ្ចេញកញ្ចប់ថវិកាដើម្បីជួយទ្រទ្រង់ដល់វិស័យនេះឱ្យមានដំណើរការកាន់តែប្រសើរដើម្បីផ្គត់ផ្គង់ស្បៀងសម្រាប់ ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រាន់។ បន្ថែមលើនេះក៏មានវិធានការផ្សេងៗក្នុងការទប់ស្កាត់ផលិតផលកសិកម្មដែលនាំចូលពីបណ្តាប្រទេសជិតខាងផងដែរ។ វិស័យកសិកម្មនឹងកាន់តែខ្លាំងជាងមុននៅពេលដែលវិបត្តិកូវីតត្រូវបានបញ្ចប់ ហើយក៏បានផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋដែលកំពុងតែប្រឈមនឹងបញ្ហាកូវីដ១៩នេះដែរ ប៉ុន្តែទាមទារឱ្យស្ថាប័នពាក់ព័ន្ធត្រូវមានយន្តការ និង ផែនការច្បាស់លាស់ ចុះជួយប្រជាពលរដ្ឋដល់មូលដ្ឋានទើបអាចជំនះនៅភាពលំបាកក្នុងដំណាក់កាលនេះទាំងអស់គ្នាបាន។ ភាពធ្លាក់ចុះធ្លាយសេដ្ឋកិច្ច ដែលកើតឡើងពីការនាំចូលផលិតផលកសិកម្មផ្សេងៗ សម្រាប់បម្រើដល់វិស័យទេសចរណ៍នឹងត្រូវកាត់បន្ថយនៅពេលដែលដំណើរការទេសចរណ៍ជាតិនិងអន្តរជាតិចាប់ផ្តើមឡើងវិញ។

បទពិសោធន៍មួយទៀតដែលបង្រៀនប្រជាពលរដ្ឋកម្ពុជានាអំឡុងពេលវិបត្តិកូវីត ១៩ គឺការជំរុញឱ្យពលរដ្ឋគ្រប់រូបដើរឱ្យទាន់បច្ចេកវិទ្យា៤.០ រាប់ទាំងការធ្វើការពីចម្ងាយ ការរៀនតាមអនឡាញ និង ការប្រើប្រាស់បច្ចេកវិទ្យាចាំបាច់ផ្សេងៗជាច្រើនទៀត។

**ឯកសារពិគ្រោះ**


១. www.worldometers.info

២. www.thmeythmey.com/ ចុះផ្សាយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

៣. World Tourism Organization, Impact Assessment of the COVID-19 Outbreak on International Tourism, 24 March 2020.

៤. https://thmeythmey.com/ចុះផ្សាយថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០

៥.https://thmeythmey.com/ចុះផ្សាយថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០

៦. Ministry of Tourism, Tourism Statistics Report in March 2020

៧. http://freshnewsasia.com ចេញផ្សាយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

៨. http://www.rfi.fr/km ផ្សាយថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

៩. http://freshnewsasia.com/ផ្សាយថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០នេះ

ទ្រឹស្ដីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ដោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ